Smart Book

# គណិតវិទ្យា

## កម្រងវិញ្ញាសា និងចម្លើយ

### ប្រឡងជ្រើសរើសគ្រូបង្រៀន

### គ្រូមត្តេយ្យ គ្រូបឋម គ្រូមធ្យម

### ពីឆ្នាំ ២០០២ ដល់ឆ្នាំ ២០១៩

ស្រាវជ្រាវ រៀបរៀង និងចែករំលែកដោយ : ប្រើស ដាក់

២០ មីនា ២០២០

នេះជាវិញ្ញាសា និងចម្លើយ នៃការប្រឡងជ្រើសរើសគ្រូបង្រៀន

# សូមចុចលើវិញ្ញាសាតាមឆ្នាំនីមួយៗ ដែលអ្នកចង់អាន

## វិញ្ញាសា ប្រឡងគ្រូមត្តេយ្យ-បឋម

| | |
|---|---|
| 2019 | 2018 |
| 2017 | 2016 |
| 2015 | 2014 |
| 2013 | 2012 |
| 2011 | 2010 |
| 2009 | 2008 |
| 2007 | 2006 |
| 2005 | 2004 |
| 2003 | 2002 |

## វិញ្ញាសា ប្រឡងគ្រូមធ្យម

| | |
|---|---|
| 2019 | 2018 |
| 2017 | 2016 |
| 2015 | 2014 |
| 2013 | 2012 |
| 2011 | 2010 |
| 2009 | 2008 |
| 2007 | 2006 |
| 2005 | 2004 |
| 2003 | 2002 |

Smart Book

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ...............................

បន្ទប់លេខ : ...............................

តុលេខ : ...............................

ហត្ថលេខា : ...............................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា**

**សម័យប្រឡង : ២១ វិច្ឆិកា ២០១៩**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**1.** គណនាលីមីតខាងក្រោម ៖ (**0.៥ ពិន្ទុ**)

ក. $\lim_{x\to\infty}\frac{(3x^3+2x^2-x-3)}{(x^3+3x+1)}$ ខ. $\lim_{x\to\infty}\sqrt{(4x^2+3x-2)}-\sqrt{(x^2-2x+3)}$ ។

**2.** ដោះស្រាយសមីការខាងក្រោម ៖ (**0.៥ ពិន្ទុ**)

ក. $\log_3(3x+1)-\log_3(2x-1)=3$ ខ. $4(2^{2x})-2^x=1-4(2^x)$ ។

**3.** គណនាអាំងតេក្រាលខាងក្រោម ៖ (**0.៥ ពិន្ទុ**)

ក. $I=\int(2e^x+3)^2e^xdx$ ខ. $J=\int_1^2\frac{x^2-1}{x-1}dx$ ។

**4.** ក្នុងប្រអប់មួយមានក្រដាសពណ៌លឿង 8 សន្លឹក និងក្រដាសពណ៌បៃតង 6 សន្លឹក ។ អ្នកគ្រូបុប្ផាចាប់យកក្រដាសពណ៌ 6 សន្លឹក ចេញពីប្រអប់ដោយចៃដន្យ មកធ្វើកាំជ្រួច ។ រកប្រូបាបនៃព្រឹត្តិការណ៍ ៖

ក. គាត់ចាប់បានក្រដាសពណ៌ 6 សន្លឹកសុទ្ធតែពណ៌លឿង ។ (**0.៥ ពិន្ទុ**)

ខ. គាត់ចាប់បានក្រដាសពណ៌ 3 សន្លឹកពណ៌បៃតង ។ (**0.៥ ពិន្ទុ**)

គ. គាត់ចាប់បានយ៉ាងហោចណាស់ក្រដាសពណ៌បៃតង 1 សន្លឹក ។ (**0.៥ ពិន្ទុ**)

**5.** គេមានអនុគមន៍ $f(x)=x^3-3x+2$ ។

ក. សិក្សាអថេរភាព និងគូសខ្សែកោង $(C)$ នៃអនុគមន៍ $f(x)$ ។ (**២ពិន្ទុ**)

ខ. កំណត់តម្លៃប៉ារ៉ាម៉ែត្រ $m$ ដើម្បីឱ្យសមីការ ៖ $x^3-3x+2-m=0$ មានឫសបីផ្សេងគ្នា ។ (**១ពិន្ទុ**)

**6.** ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានបីចំណុច $A(3,-1,2)$, $B(0,-4,2)$ និង $C(-3,2,1)$ ។

ក. រកវ៉ិចទ័រ $\overrightarrow{AB}$, $\overrightarrow{AC}$ និង $\overrightarrow{BC}$ ។ (**១.៥0 ពិន្ទុ**)

ខ. ចូរសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(d)$ កាត់តាមចំណុច $A$ និង $B$ ។ (**១ពិន្ទុ**)

គ. រកប្រភេទនៃត្រីកោណ $ABC$ ។ (**១ពិន្ទុ**)

ឃ. ចូរគណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ។ (**0.៥ ពិន្ទុ**)

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០១៩

**1. គណនាលីមីត**

**ក.** $\lim_{x\to\infty}\frac{3x^3+2x^2-x-3}{x^3+3x+1}$ (មានរាងមិនកំណត់ $\frac{\infty}{\infty}$)

$$=\lim_{x\to\infty}\frac{\cancel{x^3}\left(3+\frac{2}{x}-\frac{1}{x^2}-\frac{3}{x^3}\right)}{\cancel{x^3}\left(1+\frac{3}{x^2}+\frac{1}{x^3}\right)}=\frac{3+0-0-0}{1+0+0}=\boxed{3}$$

(ព្រោះ $x\to\infty$ នោះ $\frac{n}{x}\to 0$ ដែល $n$ ជាចំនួនថេរ)

**ខ.** $\lim_{x\to\infty}\sqrt{(4x^2+3x-2)}-\sqrt{(x^2-2x+3)}$

(មានរាងមិនកំណត់ $+\infty-\infty$ ឬ $-\infty+\infty$)

$$=\lim_{x\to\infty}\frac{\sqrt{(4x^2+3x-2)}^2-\sqrt{(x^2-2x+3)}^2}{\sqrt{(4x^2+3x-2)}+\sqrt{(x^2-2x+3)}}$$

$$=\lim_{x\to\infty}\frac{3x^2+5x-5}{\sqrt{x^2\left(4+\frac{3}{x}-\frac{2}{x^2}\right)}+\sqrt{x^2\left(1-\frac{2}{x}+\frac{3}{x^2}\right)}}$$

$$=\lim_{x\to\infty}\frac{x^2\left(3+\frac{5}{x}-\frac{5}{x^2}\right)}{|x|\left(\sqrt{\left(4+\frac{3}{x}-\frac{2}{x^2}\right)}+\sqrt{\left(1-\frac{2}{x}+\frac{3}{x^2}\right)}\right)}$$

• បើ $x\to+\infty$ នោះ $|x|=x$ និង $\frac{n}{x}\to 0$ ដែល $n$ ថេរ

$$=\frac{(+\infty)(3+0-0)}{\sqrt{(4+0-0)}+\sqrt{(1-0+0)}}=\frac{+\infty}{3}=+\infty$$

• បើ $x\to-\infty$ នោះ $|x|=-x$ និង $\frac{n}{x}\to 0$ ដែល $n$ ថេរ

$$=\frac{(-\infty)(3+0-0)}{-\left(\sqrt{(4+0-0)}+\sqrt{(1-0+0)}\right)}=\frac{-\infty}{-3}=+\infty$$

ដូចនេះ $\boxed{\lim_{x\to\infty}\sqrt{(4x^2+3x-2)}-\sqrt{(x^2-2x+3)}=+\infty}$

**2. ដោះស្រាយសមីការ**

**ក.** $\log_3(3x+1)-\log_3(2x-1)=3$

សមីការលោការីតនេះមានន័យ កាលណា

$$\begin{cases}3x+1>0\\2x-1>0\end{cases}\Leftrightarrow\begin{cases}x>-1/3\\x>1/2\end{cases}\Rightarrow x>\frac{1}{2}$$

គេបាន៖

$$\log_3\frac{(3x+1)}{(2x-1)}=3\log_3 3$$

$$\frac{(3x+1)}{(2x-1)}=27$$

$$3x+1=54x-27$$

$$28=51x$$

$x=\frac{28}{51}$ (ជាតម្លៃដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $x>\frac{1}{2}$)

ដូចនេះ $\boxed{x=\frac{28}{51}}$ ជាឫសនៃសមីការ ។

**ខ.** $4(2^{2x})-2^x=1-4(2^x)$

គេតាង $t=2^x$ នោះគេបាន $t>0$, $\forall x\in\mathbb{R}$

គេបាន $4t^2-t=1-4t$

$4t^2+3t-1=0$

ឃើញថា $a-b+c=4-3+(-1)=0$

នាំឱ្យ $t=-1$ (មិនយកព្រោះ លក្ខខណ្ឌ $t>0$, $\forall x\in\mathbb{R}$)

$t=-\frac{c}{a}=-\frac{-1}{4}=\frac{1}{4}=2^{-2}$

ចំពោះ $t=2^{-2}\Leftrightarrow 2^x=2^{-2}$ ទាញបាន $x=-2$

ដូចនេះ សមីការមានឫសតែមួយគត់គឺ $\boxed{\mathbf{x=-2}}$ ។

**3. គណនាអាំងតេក្រាល**

**ក.** $I=\int(2e^x+3)^2e^xdx$

គេតាង $t=2e^x+3$ នោះ $dt=2e^xdx$

គេបាន $I=\frac{1}{2}\int(2e^x+3)^2\cdot 2e^xdx$

$$=\frac{1}{2}\int t^2dt=\frac{1}{2}\left(\frac{t^3}{3}+c_1\right)$$

$$=\frac{1}{6}t^3+\frac{1}{2}c_1=\frac{1}{6}(2e^x+3)^3+c$$

ដែល $c_1$ និង $c$ ជាចំនួនថេរ ហើយ $\frac{1}{2}c_1=c$

ដូចនេះ គណនាបាន $\boxed{I=\frac{1}{6}(2e^x+3)^3+c}$ ។

ខ. $J=\int_1^2 \frac{x^2-1}{x-1}dx$

$$=\int_1^2 \frac{(x-1)(x+1)}{x-1}dx$$

$$=\int_1^2 (x+1)dx$$

$$=\left[\frac{x^2}{2}+x\right]_1^2=(2+2)-\left(\frac{1}{2}+1\right)$$

$$=4-\frac{3}{2}=\boxed{\frac{5}{2}}$$

**4. រកប្រូបាបនៃព្រឹត្តិការណ៍ ៖**

ក្នុងប្រអប់មួយមានក្រដាសពណ៌លឿង 8 សន្លឹក និងបៃតង 6 សន្លឹក ។ អ្នកគ្រូចាប់យកក្រដាសពណ៌ 6 សន្លឹក ដោយចៃដន្យ នាំឱ្យ ចំនួនករណីអាច គឺ $n(S)=C(14,\,6)$

$$n(S)=\frac{14!}{(14-6)!\cdot 6!}=\frac{14\cdot 13\cdot 12\cdot 11\cdot 10\cdot 9\cdot \not{8}!}{\not{8}!\cdot 6\cdot 5\cdot 4\cdot 3\cdot 2\cdot 1}=3003$$

**ក. គាត់ចាប់បានក្រដាសពណ៌ 6 សន្លឹកសុទ្ធតែពណ៌លឿង**

តាង $A$ «ជាព្រឹត្តិការណ៍ចាប់បានក្រដាសពណ៌ 6 សន្លឹកសុទ្ធតែពណ៌លឿង» នោះចំនួនករណីស្របគឺ $n(A)=C(8\,,\,6)$

គេបាន $n(A)=\frac{8!}{(8-6)!\cdot 6!}=\frac{8\cdot 7\cdot 6!}{2\cdot 1\cdot 6!}=28$

នាំឱ្យ $P(A)=\frac{n(A)}{n(S)}=\frac{28}{3003}=\frac{4}{429}\approx 0.009$

ដូចនេះ $\boxed{P(A)=\frac{4}{429}\approx 0.009}$ ។

**ខ. គាត់ចាប់បានក្រដាសពណ៌ 3 សន្លឹកពណ៌បៃតង**

គាត់ចាប់បានក្រដាសពណ៌ 3 សន្លឹកពណ៌បៃតង មានន័យថា ក្រដាស 3សន្លឹកទៀតមានពណ៌លឿង ព្រោះគាត់ចាប់ 6 សន្លឹក តាង $B$ «ជាព្រឹត្តិការណ៍ចាប់បានក្រដាសពណ៌បៃតង 3 សន្លឹក និងពណ៌លឿង 3 សន្លឹក» នោះចំនួនករណីស្របគឺ

$$n(B)=C(6\,,\,3)\times C(8\,,\,3)$$

$$=\frac{6!}{3!\cdot 3!}\times\frac{8!}{5!\cdot 3!}=20\times 56=1120$$

នាំឱ្យ $P(B)=\frac{n(B)}{n(S)}=\frac{1120}{3003}=\frac{160}{429}\approx 0.373$

ដូចនេះ $\boxed{P(B)=\frac{160}{429}\approx 0.373}$ ។

**គ. គាត់ចាប់បានយ៉ាងហោចណាស់ក្រដាសពណ៌បៃតង 1 សន្លឹក**

តាង $\overline{A}$ «ជាព្រឹត្តិការណ៍ចាប់បានយ៉ាងហោចណាស់ក្រដាសពណ៌បៃតង 1 សន្លឹក» វាជាព្រឹត្តិការណ៍បំពេញនឹងព្រឹត្តិការណ៍ $A$ «ចាប់បានក្រដាសពណ៌ 6 សន្លឹកសុទ្ធ តែពណ៌លឿង»

គេបាន $P(\overline{A})+P(A)=1$

$$P(\overline{A})=1-P(A)=1-\frac{4}{429}=\frac{425}{429}\approx 0.991$$

ដូចនេះ $\boxed{P(\overline{A})=\frac{425}{429}\approx 0.991}$ ។

5. **ក. សិក្សាអថេរភាព និងសង់ក្រាប $(C)$ នៃអនុគមន៍ $f(x)$**

គេមាន $f(x)=x^3-3x+2$

(យោបល់អ្នករៀបរៀង ប្រើស ដារ៉ា : ក្នុងនាមខ្ញុំជាអ្នកតាមដានការប្រឡងគ្រូអនុ. និងគ្រូបឋម ម្នាក់យ៉ាងយកចិត្តទុកដាក់ និងបានធ្វើចម្លើយគ្រប់ឆ្នាំចាប់ពីឆ្នាំ២០០២ ខ្ញុំចាប់អារម្មណ៍ឃើញថា លំហាត់អនុគមន៍ ចេញស្រដៀងគ្នា ឬពេលខ្លះដូចគ្នាទាំងស្រុង ជាក់ស្ដែងដូចជា លំហាត់នេះ $f(x)=x^3-3x+2$ ស្រដៀងនឹងការប្រឡងគ្រូបឋមឆ្នាំ២០១៦ $f(x)=x^3-3x+1$ ប៉ុន្តែដូចគ្នាទាំងស្រុងប្រឡងគ្រូអនុ.២០១៣ $f(x)=x^3-3x+2$ ហេតុនេះ **អ្នកប្រឡងជាប់គ្រូ មិនប្រាកដថាជាអ្នកខ្លាំង ប៉ុន្តែជាអ្នកធ្វើបានចម្លើយត្រូវល្អជាងគេ**)

• ដែនកំណត់ : អនុគមន៍ $f$ មានន័យគ្រប់ $x\in\mathbb{R}$

ដូចនេះ ដែនកំណត់ $\boxed{D=\mathbb{R}=(-\infty\,,+\infty)}$ ។

• ទិសដៅអថេរភាព

គេមាន $f(x)=x^3-3x+2$

ដេរីវេ : $f'(x)=3x^2-3=3(x-1)(x+1)$

គេឱ្យ $f'(x)=0$

$3(x-1)(x+1)=0$ នោះ $x=1\,,\,x=-1$

គេបាន $f(1)=1^3-3\cdot 1+2=0$

$f(-1)=(-1)^3-3(-1)+2=4$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |

•បរមា

-ត្រង់ $x=-1$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$

បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើ $f(-1)=4$ ។

-ត្រង់ $x=1$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើ $f(1)=0$ ។

•លីមីត $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\left(x^3-3x+2\right)=-\infty$

$\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\left(x^3-3x+2\right)=+\infty$

•តារាងអថេរភាព

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $4$ | $\searrow$ | $0$ | $\nearrow$ | $+\infty$ |

•ភាពប៉ោងផត និងចំណុចរបត់

ដេរីវេទី២ $f''(x)=\left(3x^2-3\right)'=6x$

គេឱ្យ $f''(x)=0 \Leftrightarrow 6x=0$ នោះ $x=0$

- បើ $x>0$ នោះ $f''(x)>0$

  នាំឱ្យ ខ្សែកោងបែរភាពផតទៅខាងលើ

- បើ $x<0$ នោះ $f''(x)<0$

  នាំឱ្យ ខ្សែកោងបែរភាពផតទៅខាងក្រោម

- បើ $x=0$ , $f''(x)=0$ និងប្តូរសញ្ញា

  នាំឱ្យ $f$ មានចំណុចរបត់ $I(0, f(0))=I(0,2)$

•ផ្ចិតឆ្លុះ

គេនឹង បង្ហាញថា ចំណុចរបត់ $I(0\,,\,2)$ ជាផ្ចិតឆ្លុះនៃខ្សែកោង

បើ $I(a\,,\,b)$ ជាផ្ចិតឆ្លុះលុះត្រាតែ $f(2a-x)+f(x)=2b$

គេបាន $f(-x)+f(x)=4$

ដោយ $f(-x)+f(x)$

$=(-x)^3-3(-x)+2+x^3-3x+2$

$=-x^3+3x+2+x^3-3x+2=4$ ពិត

ដូចនេះ $I(0\,,\,2)$ ជាផ្ចិតឆ្លុះនៃខ្សែកោងតាងអនុគមន៍ $f$ ។

•សង់ក្រាប

តារាងតម្លៃលេខ

| $x$ | $-2$ | $-1$ | $0$ | $1$ | $2$ |
|---|---|---|---|---|---|
| $y$ | $0$ | $4$ | $2$ | $0$ | $4$ |




**ខ. កំណត់តម្លៃប៉ារ៉ាម៉ែត្រ $m$ ដើម្បីឱ្យសមីការ**

**$x^3-3x+2-m=0$ មានឫសបីផ្សេងគ្នា**

គេមាន សមីការ $x^3-3x+2-m=0$

គេបាន $m=x^3-3x+2$

ឫសនៃសមីការនេះបានពីប្រសព្វរវាង បន្ទាត់ដេក $y=m$ និង ក្រាប $C$ ។ តាមក្រាបដើម្បីឱ្យសមីការ $x^3-3x+2-m=0$ មានឫសបីផ្សេងគ្នា កាលណា $m\in(0\,,\,4)$

ដូចនេះ តម្លៃនៃប៉ារ៉ាម៉ែត្រ $m$ កំណត់បានគឺ $\boxed{m\in(0\,,\,4)}$ ។

6. **ក. រកវ៉ិចទ័រ $\overrightarrow{AB}$ , $\overrightarrow{AC}$ និង $\overrightarrow{BC}$**

គេមាន $A(3,\,-1,\,2)$ , $B(0,\,-4,\,2)$ និង $C(-3\,,\,2\,,\,1)$

$\overrightarrow{AB}=\left(x_B-x_A\,,\,y_B-y_A\,,\,z_B-z_A\right)$

$=(0-3\,,\,-4+1\,,\,2-2)$

$=\boxed{\mathbf{(-3\,,\,-3\,,\,0)}}$

$\overrightarrow{AC}=\left(x_C-x_A\,,\,y_C-y_A\,,\,z_C-z_A\right)$

$=(-3-3\,,\,2+1\,,\,1-2)$

$=\boxed{\mathbf{(-6\,,\,3\,,\,-1)}}$

$\overrightarrow{BC}=\left(x_C-x_B\,,\,y_C-y_B\,,\,z_C-z_B\right)$

$=(-3-0\,,\,2+4\,,\,1-2)$

$=\boxed{\mathbf{(-3\,,\,6\,,\,-1)}}$

**ខ. សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(d)$ កាត់ $A$ និង $B$**

សមីការការប៉ារ៉ាម៉ែតមានរាង $(\mathrm{d}):\begin{cases} x = x_0 + at \\ y = y_0 + bt\ ,\ t \in \mathbb{R} \\ z = z_0 + ct \end{cases}$

ដោយ $(\mathrm{d})$ កាត់តាមចំណុច $A$ និង $B$ នោះបន្ទាត់ $(\mathrm{d})$

មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{AB} = (-3\ ,\ -3\ ,\ 0)$

នោះទាញបាន $a = -3\ ,\ b = -3\ ,\ c = 0$

ហើយ $(\mathrm{d})$ កាត់តាមចំណុច $A(3,\ -1,\ 2)$

នោះទាញបាន $x_0 = 3,\ y_0 = -1,\ z_0 = 2$

នាំឱ្យ $(\mathrm{d}):\begin{cases} x = 3 - 3t \\ y = -1 - 3t\ ,\ t \in \mathbb{R} \\ z = 2 - 0t \end{cases}$

ដូចនេះ $\boxed{(\mathrm{d}):\begin{cases} x = 3 - 3t \\ y = -1 - 3t\ ,\ t \in \mathbb{R} \\ z = 2 \end{cases}}$ ។

**គ. រកប្រភេទនៃត្រីកោណ $ABC$**

គេនឹងគណនាប្រវែងជ្រុងនីមួយៗនៃត្រីកោណ $ABC$

$\overrightarrow{AB} = (-3\ ,\ -3\ ,\ 0)$

$AB = \left|\overrightarrow{AB}\right| = \left|(-3,\ -3,\ 0)\right| = \sqrt{9+9+0} = 3\sqrt{2}$

$\overrightarrow{AC} = (-6\ ,\ 3\ ,\ -1)$

$AC = \left|\overrightarrow{AC}\right| = \left|(-6\ ,\ 3\ ,\ -1)\right| = \sqrt{36+9+1} = \sqrt{46}$

$\overrightarrow{BC} = (-3\ ,\ 6\ ,\ -1)$

$BC = \left|\overrightarrow{BC}\right| = \left|(-3\ ,\ 6\ ,\ -1)\right| = \sqrt{9+36+1} = \sqrt{46}$

ឃើញថាត្រីកោណ $ABC$ មានប្រវែងជ្រុង $AC = BC = \sqrt{46}$

នាំឱ្យ $ABC$ ជាត្រីកោណសមបាតកំពូល $C$

ដូចនេះ $\boxed{ABC \text{ ជាត្រីកោណសមបាតកំពូល } C}$ ។

**ឃ. គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$**

**របៀបទី១** $S_{ABC} = \dfrac{1}{2}bh$




$$h = \sqrt{\sqrt{46^2} - \left(\frac{3\sqrt{2}}{2}\right)^2} = \sqrt{\frac{83}{2}}$$

$$S_{ABC} = \frac{1}{2} \times 3\sqrt{2} \times \frac{\sqrt{83}}{\sqrt{2}} = \frac{3\sqrt{83}}{2}$$

ដូចនេះ $\boxed{S_{ABC} = \dfrac{3\sqrt{83}}{2}}$ ឯកត្តាផ្ទៃក្រឡា ។

**របៀបទី២**

គេមាន $\overrightarrow{AB} = (-3\ ,\ -3\ ,\ 0)$ និង $\overrightarrow{AC} = (-6\ ,\ 3\ ,\ -1)$

$$\overrightarrow{AB} \times \overrightarrow{AC} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ -3 & -3 & 0 \\ -6 & 3 & -1 \end{vmatrix} = 3\vec{i} - 3\vec{j} - 27\vec{k}$$

$$S_{ABC} = \frac{1}{2}\left|\overrightarrow{AB} \times \overrightarrow{AC}\right| = \frac{1}{2}\left|3\vec{i} - 3\vec{j} - 27\vec{k}\right|$$

$$= \frac{1}{2}\sqrt{3^2 + (-3)^2 + (-27)^2}$$

$$= \frac{3}{2}\sqrt{1+1+9^2}$$

$$= \frac{3\sqrt{83}}{2}$$

ដូចនេះ $\boxed{S_{ABC} = \dfrac{3\sqrt{83}}{2}}$ ឯកត្តាផ្ទៃក្រឡា ។

**របៀបទី៣** តាមរូបមន្តហេរ៉ុង

$$S_{ABC} = \sqrt{p(p-a)(p-b)(p-c)}\ \ ,\ \ p = \frac{a+b+c}{2}$$

ដោយ $a = 3\sqrt{2}\ ,\ b = c = \sqrt{46}$

គេបាន $p = \dfrac{3\sqrt{2} + 2\sqrt{46}}{2} = \dfrac{3\sqrt{2}}{2} + \sqrt{46}$

នាំឱ្យ $p - a = \dfrac{3\sqrt{2}}{2} + \sqrt{46} - 3\sqrt{2} = \sqrt{46} - \dfrac{3\sqrt{2}}{2}$

$p - b = \dfrac{3\sqrt{2}}{2} + \sqrt{46} - \sqrt{46} = \dfrac{3\sqrt{2}}{2}$

$p - c = \dfrac{3\sqrt{2}}{2} + \sqrt{46} - \sqrt{46} = \dfrac{3\sqrt{2}}{2}$

$$S_{ABC} = \sqrt{\left(\frac{3\sqrt{2}}{2} + \sqrt{46}\right)\left(\sqrt{46} - \frac{3\sqrt{2}}{2}\right)\left(\frac{3\sqrt{2}}{2}\right)\left(\frac{3\sqrt{2}}{2}\right)}$$

$$= \sqrt{\left(\sqrt{46^2} - \left(\frac{3\sqrt{2}}{2}\right)^2\right)\left(\frac{3\sqrt{2}}{2}\right)^2}$$

$$= \frac{3\sqrt{2}}{2}\sqrt{46 - \frac{9}{2}} = \frac{3\sqrt{2}}{2}\sqrt{\frac{83}{2}} = \frac{3}{2}\sqrt{83}$$

ដូចនេះ $\boxed{S_{ABC} = \dfrac{3\sqrt{83}}{2}}$ ឯកត្តាផ្ទៃក្រឡា ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

បន្ទប់លេខ : ..................................

តុលេខ : ..................................

ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា**

**សម័យប្រឡង : ៣០ វិច្ឆិកា ២០១៨**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

## I. ផ្នែកពីជគណិត

1. គណនាលីមីត ៖ ក. $\lim_{x\to 1}\frac{x^3-x^2+x-1}{x^2-1}$ ខ. $\lim_{x\to 0}\frac{(\sin 5x)(\sin 4x)}{-2x^2}$ ។ (**១ពិន្ទុ**)

2. ចូរដោះស្រាយនៅក្នុងសំណុំ $\mathbb{C}$ នៃចំនួនកុំផ្លិចសមីការ ៖ (**១ពិន្ទុកន្លះ**)

ក. $-9Z^2+18Z-36=0$ ។ យើងតាង $Z_1$ ជាឫសសមីការដែលមានផ្នែកនិមិត្តវិជ្ជមាន និង $Z_2$ ជាឫសមួយទៀត ។

ខ. ចូររកម៉ូឌុល និងអាគុយម៉ង់នៃចំនួនកុំផ្លិច $\left(\frac{Z_1}{Z_2}\right)^2$ ។

3. គណនាអាំងតេក្រាល ៖ ក. $I=\int_1^2\left[(x-1)(x^2+2x-3)\right]dx$ ខ. $J=\int_{-1}^0\left(\frac{1}{(x-1)^2}-\frac{1}{(x-1)}\right)dx$ ។ (**១ពិន្ទុ**)

4. អ្នកចិញ្ចឹមសត្វម្នាក់គាត់ទិញ កូនមាន់ កូនទា និងកូនជ្រូកមកចិញ្ចឹម ។ (**១ពិន្ទុកន្លះ**)

បើគាត់ទិញកូនមាន់ $3000$ ក្បាល កូនទា $2000$ ក្បាល និងកូនជ្រូក $100$ ក្បាល គាត់ត្រូវចំណាយអស់ប្រាក់ $12\,000\,000$ រៀល។

បើគាត់ទិញកូនមាន់ $2000$ ក្បាល កូនទា $1000$ ក្បាល និងកូនជ្រូក $110$ ក្បាល គាត់ត្រូវចំណាយអស់ប្រាក់ $8\,800\,000$ រៀល ។

បើគាត់ទិញកូនមាន់ $1100$ ក្បាល កូនទា $500$ ក្បាល និងកូនជ្រូក $52$ ក្បាល គាត់ត្រូវចំណាយអស់ប្រាក់ $4\,510\,000$ រៀល ។

ចូររកតម្លៃ កូនមាន់មួយក្បាល កូនទាមួយក្បាល និងកូនជ្រូកមួយក្បាល ។

5. គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=\frac{x^2-5x+7}{2-x}$ ។

ក. រកដែនកំណត់នៃអនុគមន៍ $f(x)$ និងបង្ហាញថា $f(x)=-x+3-\frac{1}{(x-2)}$ ។ (**១ពិន្ទុ**)

ខ. រកសមីការនៃអាស៊ីមតូតទ្រេត និងអាស៊ីមតូតឈរនៃក្រាប $C$ របស់ $f$ ។ (**១ពិន្ទុ**)

គ. សិក្សាអថេរភាព និងសង់ក្រាប $C$ នៃអនុគមន៍ $f(x)$ ។ (**១ពិន្ទុ**)

## II. ផ្នែកធរណីមាត្រ

1. ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $M(-4,2,0)$, $N(0,2,2)$, $P(2,4,4)$ និង $Q(0,6,-8)$ ។

ក. រកវ៉ិចទ័រ $\overrightarrow{MN}$, $\overrightarrow{MP}$, $\overrightarrow{MQ}$, $\overrightarrow{NP}$, $\overrightarrow{NQ}$, $\overrightarrow{PQ}$ ។ (**១ពិន្ទុ**)

ខ. គណនាប្រវែង $MN$, $MP$, $MQ$, $NQ$, $PQ$ ។ បង្ហាញថាត្រីកោណ $MNQ$ និង $MPQ$ កែងត្រង់ $M$ ។ (**១ពិន្ទុ**)

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០១៨

## I. ចម្លើយផ្នែកពីជគណិត

**1. គណនាលីមីត**

ក. $\lim\limits_{x\to 1}\dfrac{x^3-x^2+x-1}{x^2-1}$ (មានរាងមិនកំណត់ $\dfrac{0}{0}$)

$=\lim\limits_{x\to 1}\dfrac{x^2(x-1)+(x-1)}{(x-1)(x+1)}$

$=\lim\limits_{x\to 1}\dfrac{\cancel{(x-1)}(x^2+1)}{\cancel{(x-1)}(x+1)}$

$=\dfrac{1^2+1}{1+1}=\boxed{1}$

ខ. $\lim\limits_{x\to 0}\dfrac{(\sin 5x)(\sin 4x)}{-2x^2}$ (មានរាងមិនកំណត់ $\dfrac{0}{0}$)

$=\lim\limits_{x\to 0}\left(\dfrac{(\sin 5x)}{5x}\times\dfrac{(\sin 4x)}{4x}\times\dfrac{20}{-2}\right)$

$=1\times 1\times(-10)=\boxed{-10}$

**2.** ក. ដោះស្រាយនៅក្នុងសំណុំ $\mathbb{C}$ នៃចំនួនកុំផ្លិច

គេមាន $-9Z^2+18Z-36=0$

$Z^2-2Z+4=0$ (មាន $b$ គូ , តាម $\Delta'$)

គេបាន $\Delta'=(-1)^2-4=-3$

នាំឱ្យ $Z_1=\dfrac{-(-1)+\sqrt{-3}}{1}=1+i\sqrt{3}$

$Z_2=\dfrac{-(-1)-\sqrt{-3}}{1}=1-i\sqrt{3}$

ដូចនេះ: $\boxed{Z_1=1+i\sqrt{3}\ ,\ Z_2=1-i\sqrt{3}}$ ។

ខ. រកម៉ូឌុល និងអាគុយម៉ង់នៃចំនួនកុំផ្លិច $\left(\dfrac{Z_1}{Z_2}\right)^2$

ដោយ $\dfrac{Z_1}{Z_2}=\dfrac{1+i\sqrt{3}}{1-i\sqrt{3}}=\dfrac{(1+i\sqrt{3})^2}{(1-i\sqrt{3})(1+i\sqrt{3})}$

$=\dfrac{-2+2i\sqrt{3}}{4}=-\dfrac{1}{2}+i\dfrac{\sqrt{3}}{2}=\cos\dfrac{2\pi}{3}+i\sin\dfrac{2\pi}{3}$

$\left(\dfrac{Z_1}{Z_2}\right)^2=\left(\cos\dfrac{2\pi}{3}+i\sin\dfrac{2\pi}{3}\right)^2=\cos\dfrac{4\pi}{3}+i\sin\dfrac{4\pi}{3}$

ដូចនេះ: **ម៉ូឌុល $r=1$ អាគុយម៉ង់ $\theta=\dfrac{4\pi}{3}+2k\pi\ ,\ k\in\mathbb{Z}$**

**3. គណនាអាំងតេក្រាល**

ក. $I=\int_1^2\left[(x-1)(x^2+2x-3)\right]dx$

$=\int_1^2(x^3+2x^2-3x-x^2-2x+3)dx$

$=\int_1^2(x^3+x^2-5x+3)dx$

$=\left[\dfrac{x^4}{4}+\dfrac{x^3}{3}-\dfrac{5x^2}{2}+3x\right]_1^2$

$=\left(4+\dfrac{8}{3}-10+6\right)-\left(\dfrac{1}{4}+\dfrac{1}{3}-\dfrac{5}{2}+3\right)$

$=\dfrac{7}{3}+\dfrac{9}{4}-3=\dfrac{28+27-36}{12}=\boxed{\dfrac{19}{12}}$

ខ. $J=\int_{-1}^0\left(\dfrac{1}{(x-1)^2}-\dfrac{1}{(x-1)}\right)dx$

$=\int_{-1}^0\left(\dfrac{(x-1)'}{(x-1)^2}-\dfrac{(x-1)'}{(x-1)}\right)dx$

$=\left[-\dfrac{1}{x-1}-\ln|x-1|\right]_{-1}^0$

$=(1-\ln 1)-\left(\dfrac{1}{2}-\ln 2\right)=\boxed{\dfrac{1}{2}+\ln 2}$

**4. គណនាតម្លៃឯកត្តានៃ កូនមាន់ កូនទា កូនជ្រូក**

គេតាង $x$ , $y$ , $z$ ជាតម្លៃឯកត្តា កូនមាន់ កូនទា កូនជ្រូក រៀងគ្នា គិតជារៀល មានតម្លៃវិជ្ជមាន

បម្រាប់ គេអាចសរសេរបានប្រព័ន្ធសមីការ

$$\begin{cases}3000x+2000y+100z=12\,000\,000 & (1)\\ 2000x+1000y+110z=8\,800\,000 & (2)\\ 1100x+500y+52z=4\,510\,000 & (3)\end{cases}$$

$$\begin{array}{l}2(2)-(1)\to\\ 2(3)-(2)\to\end{array}\begin{cases}1000x+120z=5\,600\,000 & (i)\\ 200x-6z=220\,000 & (ii)\end{cases}$$

គេយក $(i)\div 20+(ii)\to 250x=500000$ នោះ $x=2000$

ទាញរកបានតម្លៃ $z=30000$ រួចទាញរក $y=1500$

ក្រោយពីផ្ទៀងផ្ទាត់ (សូមផ្ទៀងផ្ទាត់ដោយខ្លួនឯង) ពិត

ដូចនេះ: តម្លៃមួយក្បាលៗនៃកូនមាន់ កូនទា កូនជ្រូករៀងគ្នាគឺ $x=2000$ , $y=1500$ , $z=30000$ (គិតជារៀល)

5. **ក. រកដែនកំណត់នៃអនុគមន៍ $f(x)$**

គេមាន $f(x)=\dfrac{x^2-5x+7}{2-x}$

ដោយ $f(x)$ មានន័យកាលណា $2-x\neq 0$ ឬ $x\neq 2$

ដូចនេះ $\boxed{D=\mathbb{R}\setminus\{2\}=(-\infty\,,2)\cup(2\,,+\infty)}$ ។

**បង្ហាញថា** $f(x)=-x+3-\dfrac{1}{(x-2)}$

ដោយ $f(x)=\dfrac{x^2-5x+7}{2-x}=\dfrac{-x^2+5x-7}{x-2}$

$=\dfrac{-x^2+2x+3x-6-1}{x-2}$

$=\dfrac{-x(x-2)+3(x-2)-1}{x-2}$

$=-x+3-\dfrac{1}{x-2}$

ដូចនេះ $\boxed{f(x)=-x+3-\dfrac{1}{(x-2)}}$ ត្រូវបានបង្ហាញ ។

**ខ. រកសមីការនៃអាស៊ីមតូតទ្រេត និងអាស៊ីមតូតឈរនៃក្រាប $C$**

គេមាន $f(x)=-x+3-\dfrac{1}{x-2}$ និង $\lim\limits_{x\to\pm\infty}\left(-\dfrac{1}{x-2}\right)=0$

ដូចនេះ $\boxed{y=-x+3 \text{ ជាសមីការអាស៊ីមតូតទ្រេត}}$ ។

ដោយ $\lim\limits_{x\to 2}f(x)=\lim\limits_{x\to 2}\left(-x+3-\dfrac{1}{(x-2)}\right)$

$x<2:\ \lim\limits_{x\to 2^-}\left(-x+3-\dfrac{1}{(x-2)}\right)=-2+3-\dfrac{1}{0^-}=+\infty$

$x>2:\ \lim\limits_{x\to 2^+}\left(-x+3-\dfrac{1}{(x-2)}\right)=-2+3-\dfrac{1}{0^+}=-\infty$

ដោយ $\lim\limits_{x\to 2}f(x)=\pm\infty$ នោះ $\boxed{x=2 \text{ ជាអាស៊ីមតូតឈរ}}$

**គ. សិក្សាអថេរភាព និងសង់ក្រាប $C$ នៃអនុគមន៍ $f(x)$**

• ដែនកំណត់ : $D=(-\infty\,,2)\cup(2\,,+\infty)$ រករួចខាងលើ

• ទិសដៅអថេរភាព

គេមាន $f(x)=-x+3-\dfrac{1}{x-2}$

ដេរីវេ : $f'(x)=-1+\dfrac{1}{(x-2)^2}=\dfrac{-x^2+4x-3}{(x-2)^2}$

គេឱ្យ $f'(x)=0$ សមមូល $-x^2+4x-3=0$

ករណីពិសេស នោះ $x=1\,,\ x=3$

គេបាន $f(1)=-1+3-\dfrac{1}{(1-2)}=3$

$f(3)=-3+3-\dfrac{1}{(3-2)}=-1$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | $1$ | | $2$ | | $3$ | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | $-$ | $0$ | $+$ | ‖ | $+$ | $0$ | $-$ |

• បរមា

-ត្រង់ $x=1$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើ $f(1)=3$ ។

-ត្រង់ $x=3$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ$(-)$

បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើ $f(3)=-1$ ។

• លីមីត $\lim\limits_{x\to 2^-}f(x)=+\infty$ , $\lim\limits_{x\to 2^+}f(x)=-\infty$ (រករួច)

$\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to+\infty}\left(-x+3-\dfrac{1}{x-2}\right)=-\infty$

$\lim\limits_{x\to-\infty}f(x)=\lim\limits_{x\to-\infty}\left(-x+3-\dfrac{1}{x-2}\right)=+\infty$

• តារាងអថេរភាព

| $x$ | $-\infty$ | $1$ | | $2$ | | $3$ | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | $-$ | | $+$ | ‖ | $+$ | | $-$ |
| $f(x)$ | $+\infty$ ↘ | $3$ | ↗ $-\infty$ | ‖ | $-\infty$ ↗ | $-1$ | ↘ $-\infty$ |

• សង់ក្រាប (សូមឱ្យតារាងតម្លៃលេខដោយខ្លួនឯង)



## II. ចម្លើយផ្នែកធរណីមាត្រ

គេមាន ចំណុច $M(-4, 2, 0)$ , $N(0, 2, 2)$ ,

$P(2, 4, 4)$ និង $Q(0, 6, -8)$

**ក. រកវ៉ិចទ័រ** $\overrightarrow{MN}$ , $\overrightarrow{MP}$ , $\overrightarrow{MQ}$ , $\overrightarrow{NP}$ , $\overrightarrow{NQ}$ , $\overrightarrow{PQ}$

$$\overrightarrow{MN}=(0+4,\ 2-2,\ 2-0)=\boxed{(4,\ 0,\ 2)}$$

$$\overrightarrow{MP}=(2+4,\ 4-2,\ 4-0)=\boxed{(6,\ 2,\ 4)}$$

$$\overrightarrow{MQ}=(0+4,\ 6-2,\ -8-0)=\boxed{(4,\ 4,\ -8)}$$

$$\overrightarrow{NP}=(2-0,\ 4-2,\ 4-2)=\boxed{(2,\ 2,\ 2)}$$

$$\overrightarrow{NQ}=(0-0,\ 6-2,\ -8-2)=\boxed{(0,\ 4,\ -10)}$$

$$\overrightarrow{PQ}=(0-2,\ 6-4,\ -8-4)=\boxed{(-2,\ 2,\ -12)}$$

**ខ. គណនាប្រវែង** $MN$ , $MP$ , $MQ$ , $NQ$ , $PQ$

ប្រវែងជ្រុងខាងក្រោម គិតជាឯកត្តាប្រវែង

$$MN=\left|\overrightarrow{MN}\right|=\left|(4,\ 0,\ 2)\right|=\sqrt{16+0+4}=\boxed{2\sqrt{5}}$$

$$MP=\left|\overrightarrow{MP}\right|=\left|(6,\ 2,\ 4)\right|=\sqrt{36+4+16}=\boxed{2\sqrt{14}}$$

$$MQ=\left|\overrightarrow{MQ}\right|=\left|(4,\ 4,\ -8)\right|=\sqrt{16+16+64}=\boxed{4\sqrt{6}}$$

$$NQ=\left|\overrightarrow{NQ}\right|=\left|(0,\ 4,\ -10)\right|=\sqrt{0+16+100}=\boxed{2\sqrt{29}}$$

$$PQ=\left|\overrightarrow{PQ}\right|=\left|(-2,\ 2,\ -12)\right|=\sqrt{4+4+144}=\boxed{2\sqrt{38}}$$

**បង្ហាញថាត្រីកោណ $MNQ$ និង $MPQ$ កែងត្រង់ $M$**

ដោយ ត្រីកោណ $MNQ$ មានប្រវែងជ្រុងទាំងបីគឺ

$MN=2\sqrt{5}$ , $MQ=4\sqrt{6}$ , $NQ=2\sqrt{26}$

ដែល $MN^2+MQ^2=20+96=116$

ហើយ $NQ^2=\left(2\sqrt{29}\right)^2=116$

គេបាន $MN^2+MQ^2=NQ^2$ តាមទ្រឹស្តីបទពីតាគ័រ

$MNQ$ ជាត្រីកោណកែងត្រង់ $M$

ដូចនេះ: $\boxed{MNQ \text{ ជាត្រីកោណកែងត្រង់ } M}$ ។

ដោយ $MP=2\sqrt{14}$ , $MQ=4\sqrt{6}$ , $PQ=2\sqrt{38}$

ដែល $\left(2\sqrt{14}\right)^2+\left(4\sqrt{6}\right)^2=\left(2\sqrt{38}\right)^2$ ពិត

នាំឱ្យ $MP^2+MQ^2=PQ^2$ ផ្ទៀងផ្ទាត់ទ្រឹស្តីបទពីតាគ័រ

ដូចនេះ: $\boxed{MPQ \text{ ជាត្រីកោណកែងត្រង់ } M}$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................
បន្ទប់លេខ : ..................................
តុលេខ : ..................................
ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "**
**សម័យប្រឡង : ២៥ វិច្ឆិកា ២០១៧**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

## I. ផ្នែកពីជគណិត

1. គេឱ្យអនុគមន៍ $f(x)=\sqrt{\dfrac{|x|-1}{2-|x|}}$ ។ រកដែនកំណត់នៃអនុគមន៍ $f(x)$ ។ (**១ពិន្ទុ**)

2. គណនាលីមីតខាងក្រោម ៖ (**0.៥0ពិន្ទុ**)

ក. $\lim\limits_{x\to1}\dfrac{2x^2-3x+1}{x^3-x}$ ខ. $\lim\limits_{x\to\infty}\dfrac{3x^2+x+6}{2x^2-3}$ ។

3. គណនាអាំងតេក្រាលខាងក្រោម ៖ (**១ពិន្ទុ**)

ក. $\int_0^1\left(\dfrac{x}{x+2}\right)dx$ ខ. $\int_0^2\left(\dfrac{x^2-3}{x+1}\right)dx$ ។

4. គេមានសមីការ $z^2-6z+12=0$ ។

ក. រកឫសកុំផ្លិច $z_1$ និង $z_2$ នៃសមីការនេះ ដោយដឹងថាឫស $z_1$ មានផ្នែកនិមិត្តវិជ្ជមាន ។ (**0.៥0ពិន្ទុ**)

ខ. សរសេរឫស $z_1$ និង $z_2$ ជាទម្រង់ត្រីកោណមាត្រ ។ (**0.៥0ពិន្ទុ**)

5. គេឱ្យអនុគមន៍ $f(x)=x^3+3x^2-2$ ។

ក. សិក្សាអថេរភាព និងគូសក្រាប $C$ នៃអនុគមន៍ $f(x)$ ។ (**១.៥0ពិន្ទុ**)

ខ. សរសេរសមីការបន្ទាត់ប៉ះនឹងក្រាប $C$ នៃអនុគមន៍ $f(x)$ ត្រង់ចំណុចរបត់ $I$ ។ (**0.៥0ពិន្ទុ**)

គ. ប្រើប្រាស់ក្រាប $C$ នៃអនុគមន៍ $f(x)$ ។ ចូរពិភាក្សាចំនួនឫសរបស់សមីការ $x^3+3x^2-2=m$ ទៅតាមតម្លៃនៃប៉ារ៉ាម៉ែត្រ m ។ (**0.៥0ពិន្ទុ**)

## II. ផ្នែកធរណីមាត្រ

1. នៅក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានបីចំណុច $A(3,-1,2)$, $B(0,-4,2)$ និង $C(-3,2,1)$ ។

ក. រកកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}$, $\overrightarrow{AC}$, $\overrightarrow{BC}$ និងគណនាបរិមាត្រនៃត្រីកោណ $ABC$ ។ (**១ពិន្ទុ**)

ខ. កំណត់ប្រភេទនៃត្រីកោណ $ABC$ និងគណនាផ្ទៃក្រឡានៃត្រីកោណនេះ ។ (**១ពិន្ទុ**)

2. គេមានប៉ារ៉ាបូល $(P)$ មួយដែលមានកំពូលនៅត្រង់ចំណុច $O(0,0)$ និងមានអ័ក្សឆ្លុះជាអ័ក្សអាប់ស៊ីស ។

ក. រកកូអរដោនេកំណុំ $F$ និងសរសេរសមីការស្តង់ដានៃប៉ារ៉ាបូលនេះ ដោយដឹងថាក្រាភិចវាកាត់តាម $A(2,4)$ ។ (**១ពិន្ទុ**)

ខ. រកតម្លៃ $x_1$ និងកំណត់ចំណុច $B$ ដោយដឹងថាចំណុច $B(x_1,8)$ ស្ថិតនៅលើប៉ារ៉ាបូល $(P)$ ។ (**0.៥0ពិន្ទុ**)

គ. ចូរសរសេរសមីការនៃបន្ទាត់ $(d)$ ប៉ះនឹងប៉ារ៉ាបូលនៅត្រង់ចំណុច $A$ ខាងលើ ។ (**0.៥0ពិន្ទុ**)

# ចម្លើយ វិញ្ញាសាគណិតវិទ្យា

## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០១៧

## I. ចម្លើយផ្នែកពីជគណិត

**1. រកដែនកំណត់នៃអនុគមន៍ $f(x)$**

គេមាន $f(x)=\sqrt{\dfrac{|x|-1}{2-|x|}}$ មានន័យលុះត្រា $\begin{cases} 2-|x|\neq 0 & (1) \\ \dfrac{|x|-1}{2-|x|}\geq 0 & (2) \end{cases}$

តាម $(1): 2-|x|\neq 0$ នោះ $x\neq \pm 2$

តាម $(2): \dfrac{|x|-1}{2-|x|}\geq 0$ គេនឹងសិក្សាសញ្ញារបស់វា

•ឫសនៃភាគយក $|x|-1=0$ នោះ $x=\pm 1$

•ឫសនៃភាគបែង $2-|x|=0$ នោះ $x=\pm 2$

តារាងសញ្ញា

| $x$ | $-\infty$ | $-2$ | | $-1$ | | $1$ | | $2$ | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $\lvert x\rvert-1$ | $+$ | | $+$ | $0$ | $-$ | $0$ | $+$ | | $+$ |
| $2-\lvert x\rvert$ | $-$ | $0$ | $+$ | | $+$ | | $+$ | $0$ | $-$ |
| $\dfrac{\lvert x\rvert-1}{2-\lvert x\rvert}\geq 0$ | $-$ | | $+$ | $0$ | $-$ | $0$ | $+$ | | $-$ |

ដូចនេះ ដែនកំណត់គឺ $\boxed{D=(-2,-1]\cup[1\,,2)}$ ។

**2. គណនាលីមីតខាងក្រោម ៖**

ក. $\lim\limits_{x\to 1}\dfrac{2x^2-3x+1}{x^3-x}$ (មានរាងមិនកំណត់ $\dfrac{0}{0}$)

$$=\lim_{x\to 1}\frac{(x-1)(2x-1)}{x(x-1)(x+1)}$$

$$=\lim_{x\to 1}\frac{(2x-1)}{x(x+1)}$$

$$=\frac{2\cdot 1-1}{1(1+1)}=\frac{1}{2}$$

ដូចនេះ $\boxed{\lim\limits_{x\to 1}\dfrac{x^2-3x+1}{x^3-x}=\dfrac{1}{2}}$ ។

ខ. $\lim\limits_{x\to\infty}\dfrac{3x^2+x+6}{2x^2-3}$ (មានរាងមិនកំណត់ $\dfrac{\infty}{\infty}$)

$$=\lim_{x\to\infty}\frac{\cancel{x^2}\left(3+\frac{1}{x}+\frac{6}{x^2}\right)}{\cancel{x^2}\left(2-\frac{3}{x^2}\right)}=\frac{3+0+0}{2-0}=\boxed{\frac{3}{2}}$$ ។

**3. គណនាអាំងតេក្រាលខាងក្រោម ៖**

ក. $\displaystyle\int_0^1\frac{x}{x+2}dx=\int_0^1\frac{x+2-2}{x+2}dx=\int_0^1\left(1-2\cdot\frac{1}{x+2}\right)dx$

$$=\int_0^1\left(1-2\cdot\frac{(x+2)'}{x+2}\right)dx$$

$$=\Big[x-2\ln|x+2|\Big]_0^1$$

$$=(1-2\ln 3)-(0-2\ln 2)=\boxed{1-2\ln\frac{3}{2}}$$

ខ. $\displaystyle\int_0^2\frac{x^2-3}{x+1}dx=\int_0^2\frac{x^2-1-2}{x+1}dx$

$$=\int_0^2\left(\frac{x^2-1}{x+1}-2\cdot\frac{1}{x+1}\right)dx$$

$$=\int_0^2\left(x-1-2\cdot\frac{(x+1)'}{x+1}\right)dx$$

$$=\left[\frac{x^2}{2}-x-2\ln|x+1|\right]_0^2$$

$$=(2-2-2\ln 3)-2\ln 1=\boxed{-2\ln 3}$$

**4. ក. រកឫសកុំផ្លិច $z_1$ និង $z_2$ ដែល $z_1$ មានផ្នែកនិមិត្តវិជ្ជមាន៖**

គេមាន $z^2-6z+12=0$ , $\Delta'=9-12=-3$

នាំឱ្យ $z_1=\dfrac{-(-3)+\sqrt{-3}}{1}=3+i\sqrt{3}$

$z_2=\dfrac{-(-3)-\sqrt{-3}}{1}=3-i\sqrt{3}$

ដូចនេះ សមីការមានឫស $\boxed{z_1=3+i\sqrt{3}\ \ ,\ z_2=3-i\sqrt{3}}$ ។

ខ. សរសេរឫស $z_1$ និង $z_2$ ជាទម្រង់ត្រីកោណមាត្រ

$$z_1=3+i\sqrt{3}=2\sqrt{3}\left(\frac{\sqrt{3}}{2}+\frac{1}{2}i\right)$$

$$=\boxed{2\sqrt{3}\left(\cos\frac{\pi}{6}+i\sin\frac{\pi}{6}\right)}$$

$$z_2=3-i\sqrt{3}=2\sqrt{3}\left(\frac{\sqrt{3}}{2}-\frac{1}{2}i\right)$$

$$=\boxed{2\sqrt{3}\left(\cos\frac{11\pi}{6}+i\sin\frac{11\pi}{6}\right)}$$

5. **ក. សិក្សាអថេរភាព និងគូសក្រាប $C$ នៃអនុគមន៍ $f(x)$**

គេមាន $f(x)=x^3+3x^2-2$ **(ប្រហែលគ្រូអនុ.២០១៧)**

•ដែនកំណត់ : អនុគមន៍ $f$ មានន័យគ្រប់ $x\in\mathbb{R}$

ដូចនេះ ដែនកំណត់ $\boxed{D=\mathbb{R}=(-\infty\,,+\infty)}$ ។

•ទិសដៅអថេរភាព

គេមាន $f(x)=x^3+3x^2-2$

ដេរីវេ : $f'(x)=3x^2+6x=3x(x+2)$

គេឱ្យ $f'(x)=0$

$3x(x+2)=0$ នោះ $x=0\,,\,x=-2$

គេបាន $f(0)=0^3+3\cdot 0^2-2=-2$

$f(-2)=(-2)^3+3(-2)^2-2=2$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $-2$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |

•បរមា

-ត្រង់ $x=-2$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$

បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើ $f(-2)=2$ ។

-ត្រង់ $x=0$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ$(+)$

បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើ $f(0)=-2$ ។

•លីមីត $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\left(x^3+3x^2-2\right)=-\infty$

$\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\left(x^3+3x^2-2\right)=+\infty$

•តារាងអថេរភាព

| $x$ | $-\infty$ | | $-2$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $2$ | $\searrow$ | $-2$ | $\nearrow$ | $+\infty$ |

•ភាពប៉ោង និងភាពផត

ដេរីវេទី២ $f''(x)=\left(3x^2+6x\right)'=6x+6$

គេឱ្យ $f''(x)=0 \Leftrightarrow 6x+6=0$ នោះ $x=-1$ ជាឫស

- បើ $x>-1$ នោះ $f''(x)>0$

នាំឱ្យ ខ្សែកោងបែរភាពផតទៅខាងលើ

- បើ $x<-1$ នោះ $f''(x)<0$

នាំឱ្យ ខ្សែកោងបែរភាពផត ចុះខាងក្រោម

- បើ $x=-1$ , $f''(x)=0$ និងប្តូរសញ្ញា

នាំឱ្យ $f$ មានចំណុចរបត់មួយតាងដោយ $I$ ដែល

$I(-1,f(-1))$ ឬ $I(-1,0)$

•សង់ក្រាប




**ខ. សរសេរសមីការបន្ទាត់ប៉ះនឹងក្រាប $C$ ត្រង់ចំណុចរបត់ $I$**

សមីការបន្ទាត់ប៉ះមានរាង $T: y=f'(x_0)(x-x_0)+f(x_0)$

ដោយ $T$ ប៉ះក្រាប $C$ ត្រង់ចំណុចរបត់ $I(-1,0)$

នាំឱ្យ $x_0=-1$ , $y_0=0$

នោះ $f'(x_0)=f'(-1)=3(-1)^2+6(-1)=-3$

$f(x_0)=f(-1)=(-1)^3+3(-1)^2-2=0$

គេបាន $T: y=-3(x+1)+0=-3x-3$

ដូចនេះ សមីការបន្ទាត់ប៉ះគឺ $\boxed{T: y=-3x-3}$ ។

**គ. ប្រើប្រាស់ក្រាប $C$ នៃអនុគមន៍ $f(x)$ ពិភាក្សាចំនួនឫស របស់សមីការ $x^3+3x^2-2=m$ តាមតម្លៃប៉ារ៉ាម៉ែត្រ** m

គេមាន សមីការ $x^3+3x^2-2=m$

ឫសនៃសមីការនេះបានពីប្រសព្វរវាង បន្ទាត់ដេក $y=m$ និង ក្រាប $C$ ។ តាមក្រាបគេបានអត្ថិភាពនៃឫសដូចខាងក្រោម ៖

•$m\in(-\infty,-2)$ : សមីការមានឫសតែមួយគត់ $x_1<0$

•$m=-2$ : សមីការមានឫសបី $x_1=-3\,,x_2=x_3=0$

•$m\in(-2\,,\,2)$ : មានឫសបីផ្សេងគ្នា $x_1<x_2<0<x_3$

•$m=2$ : សមីការមានឫសបី $x_1=x_2=-2\,,\,x_3=1$

•$m\in(2\,,+\infty)$ : សមីការមានឫសវិជ្ជមានតែមួយគត់ $0<x_1$

## II. ចម្លើយផ្នែកធរណីមាត្រ

**1. ក. រកកូអរដោនេនៃវ៉ិចទ័រ** $\overrightarrow{AB}\,,\,\overrightarrow{AC}\,,\,\overrightarrow{BC}$

គេមាន $A(3\,,-1\,,2)\,,\,B(0\,,-4\,,2)\,,\,C(-3\,,2\,,1)$

គេបាន $\overrightarrow{AB}=(x_B-x_A\,,\,y_B-y_A\,,\,z_B-z_A)$

$=(0-3\,,-4+1\,,2-2)$

$=\boxed{(-3\,,-3\,,0)}$

$\overrightarrow{AC}=(x_C-x_A\,,\,y_C-y_A\,,\,z_C-z_A)$

$=(-3-3\,,2+1\,,1-2)$

$=\boxed{(-6\,,3\,,-1)}$

$\overrightarrow{BC}=(x_C-x_B\,,\,y_C-y_B\,,\,z_C-z_B)$

$=(-3-0\,,2+4\,,1-2)$

$=\boxed{(-3\,,6\,,-1)}$

**គណនាបរិមាត្រនៃត្រីកោណ** $ABC$

គេមាន $\overrightarrow{AB}=(-3\,,-3\,,0)$

$AB=\left|\overrightarrow{AB}\right|=\sqrt{(-3)^2+(-3)^2+0^2}=3\sqrt{2}$

$\overrightarrow{AC}=(-6\,,3\,,-1)$

$AC=\left|\overrightarrow{AC}\right|=\sqrt{(-6)^2+3^2+(-1)^2}=\sqrt{46}$

$\overrightarrow{BC}=(-3\,,6\,,-1)$

$BC=\left|\overrightarrow{BC}\right|=\sqrt{(-3)^2+6^2+(-1)^2}=\sqrt{46}$

នាំឱ្យ បរិមាត្រនៃត្រីកោណ $ABC$

$P=AB+AC+BC=3\sqrt{2}+\sqrt{46}+\sqrt{46}$

ដូចនេះ $\boxed{P=3\sqrt{2}+2\sqrt{46}}$ ឯកតាប្រវែង ។

**ខ. កំណត់ប្រភេទនៃត្រីកោណ** $ABC$

ដោយ ត្រីកោណ $ABC$ មានប្រវែងជ្រុង $AC=BC=\sqrt{46}$

ដូចនេះ $\boxed{ABC \text{ ជាត្រីកោណសមបាទកំពូល } C}$ ។

**គណនាផ្ទៃក្រឡានៃត្រីកោណនេះ (របៀបទី១)**

$h=\sqrt{\sqrt{46^2}-\left(\dfrac{3\sqrt{2}}{2}\right)^2}=\dfrac{\sqrt{166}}{2}$

$S_{ABC}=\dfrac{1}{2}\left(3\sqrt{2}\times\dfrac{\sqrt{166}}{2}\right)$

$=\dfrac{3\sqrt{83}}{2}$




ដូចនេះ $\boxed{S_{ABC}=\dfrac{3\sqrt{83}}{2}}$ ឯកតាផ្ទៃ ។

**គណនាផ្ទៃក្រឡានៃត្រីកោណនេះ (របៀបទី២)**

រូបមន្ត $S=\dfrac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AB}\right|$

$\overrightarrow{AB}\times\overrightarrow{AB}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ -3 & -3 & 0\\ -6 & 3 & -1\end{vmatrix}=3\vec{i}-3\vec{j}-27\vec{k}$

$S=\dfrac{1}{2}\sqrt{3^2+(-3)^2+(-27)^2}$

$=\dfrac{3}{2}\sqrt{1+1+9^2}=\dfrac{3\sqrt{83}}{2}$

ដូចនេះ $\boxed{S_{ABC}=\dfrac{3\sqrt{83}}{2}}$ ឯកតាផ្ទៃ ។

**2. ក. រកកូអរដោនេកំណុំ** $F$

ដោយ ប៉ារ៉ាបូល $(P)$ មានកំពូល $O(0\,,0)$ និងមានអ័ក្ស ឆ្លុះជាអ័ក្សអាប់ស៊ីស

គេបាន សមីការស្តង់ដាមានរាង $y^2=4px$

បម្រាប់ ក្រាភិចប៉ារ៉ាបូល $(P)$ កាត់តាម $A(2\,,4)$

គេបាន $4^2=4p\cdot 2$ នោះ $p=2$

ដូចនេះ កូអរដោនេកំណុំ $\boxed{F(p\,,0)=F(2\,,0)}$ ។

**សរសេរសមីការស្តង់ដានៃប៉ារ៉ាបូលនេះ៖**

ដោយ សមីការស្តង់ដាមានរាង $y^2=4px$ ដែលមាន $p=2$

ដូចនេះ សមីការស្តង់ដាសរសេរបាន $\boxed{(P):\,y^2=8x}$ ។

**ខ. រកតម្លៃ** $x_1$ **និងកំណត់ចំណុច** $B$

ដោយដឹងថាចំណុច $B(x_1\,,8)$ ស្ថិតនៅលើប៉ារ៉ាបូល $(P)$

គេបាន $y^2=8x$ ទៅជា $8^2=8x_1$ នោះ $x_1=8$

ដូចនេះ $\boxed{x_1=8\,,\,B(8\,,8)}$ ។

**គ. សរសេរសមីការបន្ទាត់** $(d)$ **ប៉ះនឹងប៉ារ៉ាបូលត្រង់ចំណុច** $A$

សមីការបន្ទាត់ប៉ះរាង $(d):\,y=y'(x_0)(x-x_0)+y(x_0)$

ដោយ$(d)$ប៉ះ $(P)$ ត្រង់ $A(2,4)$ នោះ $x_0=2,\,y(x_0)=4$

ហើយ $y^2=8x$ នោះ $2yy'=8$ នោះ $y'=\dfrac{4}{y}$

នាំឱ្យ $y'(x_0)=\dfrac{4}{y(x_0)}=\dfrac{4}{4}=1$

គេបាន $(d):\,y=1(x-2)+4$ ឬ $y=x+2$

ដូចនេះ សមីការបន្ទាត់ប៉ះសរសេរបាន $\boxed{(d):\,y=x+2}$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

បន្ទប់លេខ : ..................................

តុលេខ : ..................................

ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា "១២ + ២"**

**សម័យប្រឡង : ២៦ វិច្ឆិកា ២០១៦**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

## I. ផ្នែកពីជគណិត

1. គណនាលីមីតខាងក្រោម ៖ (**១ពិន្ទុ**)

ក. $\lim_{x\to 2}\frac{(x^2-3x+2)}{(x^2-x-2)}$ ខ. $\lim_{x\to 0}\frac{\sin 2x}{\sin 3x}$

2. គណនាអាំងតេក្រាលខាងក្រោម ៖ (**១ពិន្ទុ**)

ក. $\int\frac{1}{(x^2+x-6)}dx$ ខ. $\int x\sin(4-x^2)dx$

3. ចូរដោះស្រាយសមីការខាងក្រោមក្នុងសំណុំនៃចំនួនកុំផ្លិច ៖ (**១ពិន្ទុ**)

ក. $-3x^2+2x-1=0$ ខ. $x^4-2x^2-15=0$

4. អ្នកគ្រូបុប្ផាធ្វើប័ណ្ណលេខចំនួន 9 សន្លឹក ដែលសន្លឹកនីមួយៗសរសេរតែមួយលេខខុសៗគ្នា ក្នុងចំណោមពីលេខ 1 ដល់លេខ 9 ។ ក្នុងការពង្រឹងវិធីគុណ ដែលមានតួគុណនីមួយៗជាលេខ 1 ខ្ទង់ គាត់បានឱ្យក្រុមសិស្សនីមួយៗ ចាប់យកប័ណ្ណលេខចំនួន 2 សន្លឹក រួចគណនាផលគុណនៃលេខក្នុងប័ណ្ណទាំងពីរនោះ ។ រកប្រូបាបនៃការចាប់បានប័ណ្ណលេខ 2 សន្លឹក ដែលផលគុណនៃលេខរបស់វាជាចំនួនគូ ។ (**១ពិន្ទុ**)

5. គេមានអនុគមន៍ $f(x): y=x^3-3x+1$ ។

ក. សិក្សាអថេរភាព និងគូសខ្សែកោងនៃអនុគមន៍ $f(x)$ ។ (**១ពិន្ទុ**)

ខ. ប្រើប្រាស់ខ្សែកោងនៃអនុគមន៍ $f(x)$ ចូរពិភាក្សាតាមតម្លៃ m នូវចំនួនឫសរបស់សមីការ $x^3-3x+1-m=0$ ។ (**១ពិន្ទុ**)

## II. ផ្នែកធរណីមាត្រ

1. គេមានអេលីប (E) ដែលមានចំណុចកំណុំ $F_1(1,-3)$, $F_2(1,1)$ និងកាត់តាមចំណុច $A(-\sqrt{2}+1,1)$ ។

ក. ចូររកចម្ងាយពីផ្ចិតអេលីប (E) ទៅចំណុចកំណុំរបស់អេលីបនោះ ។ (**១ពិន្ទុ**)

ខ. គណនាប្រវែងអ័ក្សធំ និងអ័ក្សតូចរបស់អេលីប (E) រួចសរសេរសមីការស្តង់ដានៃអេលីបនោះ ។ (**១ពិន្ទុ**)

2. នៅក្នុងតម្រុយអរតូណរម៉ាល់ មានទិសដៅអវិជ្ជមាន គេមាន 4 ចំណុច $I(3,-1,5)$, $M(4,2,-1)$, $N(1,-2,3)$ និង $A(1,1,3)$ ។

ក. ចូរសរសេរសមីការទូទៅនៃប្លង់ (P) កាត់តាម 3 ចំណុច $I$, $M$ និង $N$ ។ (**១ពិន្ទុ**)

ខ. គណនាផ្ទៃក្រឡានៃត្រីកោណ $IMN$ និងសរសេរសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ (d) កាត់តាមចំណុច $A$ និងកាត់ប្លង់ (P) ត្រង់ចំណុច $M$ ។ (**១ពិន្ទុ**)

## ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០១៦

### I. ចម្លើយផ្នែកពីជគណិត

**1. គណនាលីមីតខាងក្រោម ៖**

ក. $\lim\limits_{x\to 2}\dfrac{(x^2-3x+2)}{(x^2-x-2)}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$=\lim\limits_{x\to 2}\dfrac{(x-2)(x-1)}{(x-2)(x+1)}$

$=\lim\limits_{x\to 2}\dfrac{x-1}{x+1}=\dfrac{2-1}{2+1}=\boxed{\dfrac{1}{3}}$

ខ. $\lim\limits_{x\to 0}\dfrac{\sin 2x}{\sin 3x}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$=\lim\limits_{x\to 0}\left(\dfrac{\sin 2x}{2x}\times\dfrac{3x}{\sin 3x}\times\dfrac{2}{3}\right)$

$=1\times 1\times\dfrac{2}{3}=\boxed{\dfrac{2}{3}}$

**2. គណនាអាំងតេក្រាលខាងក្រោម ៖**

ក. $\displaystyle\int\frac{1}{(x^2+x-6)}dx$

$=\displaystyle\int\frac{1}{(x-2)(x+3)}dx$

$=\displaystyle\int\frac{1}{5}\left[\frac{1}{(x-2)}-\frac{1}{(x+3)}\right]dx$

$=\dfrac{1}{5}\left[\ln|x-2|-\ln|x+3|\right]+c$ , $c$ ថេរ

$=\boxed{\dfrac{1}{5}\ln\left|\dfrac{x-2}{x+3}\right|+c}$

ខ. $\displaystyle\int x\sin(4-x^2)dx$

គេតាង $t=4-x^2$ នោះ $dt=-2xdx$ គេបាន ៖

$\displaystyle\int x\sin(4-x^2)dx=-\frac{1}{2}\int\sin(4-x^2)\cdot(-2xdx)$

$=-\dfrac{1}{2}\displaystyle\int\sin(4-x^2)\cdot(-2xdx)$

$=-\dfrac{1}{2}\displaystyle\int\sin t dt=-\frac{1}{2}(-\cos t)+c$ , $c$ ថេរ

$=\boxed{\dfrac{1}{2}\cos(4-x^2)+c}$

**3. ដោះស្រាយសមីការខាងក្រោមក្នុងសំណុំនៃចំនួនកុំផ្លិច ៖**

ក. $-3x^2+2x-1=0$ មាន $a=-3$ , $b=2$ , $c=-1$

ដោយ $\Delta'=1-3=-2$

នាំឱ្យ $x=\dfrac{-1\pm\sqrt{-2}}{-3}=\dfrac{1}{3}\mp i\dfrac{\sqrt{2}}{3}$

ដូចនេះ: $\boxed{x=\dfrac{1}{3}-i\dfrac{\sqrt{2}}{3}\ ,\ x=\dfrac{1}{3}+i\dfrac{\sqrt{2}}{3}}$ ជាឫស ។

ខ. $x^4-2x^2-15=0$

គេតាង $t=x^2$ គេបាន ៖ $t^2-2t-15=0$

ដោយ $\Delta'=(-1)^2+15=16$

នាំឱ្យ $t=\dfrac{1\pm\sqrt{16}}{1}=\left[\begin{array}{l}5\\-3\end{array}\right.$

ចំពោះ: $t=5$ សមមូល $x^2=5\Rightarrow x=\pm\sqrt{5}$

ចំពោះ: $t=-3$ សមមូល $x^2=-3\Rightarrow x=\pm\sqrt{-3}=\pm i\sqrt{3}$

ដូចនេះ: $\boxed{x=\pm\sqrt{5}\ ,\ x=\pm i\sqrt{3}}$ ជាឫសនៃសមីការ ។

**4. រកប្រូបាបចាប់បានប័ណ្ណ មានផលគុណនៃលេខរបស់វាជាចំនួនគូ**

គេមាន ប័ណ្ណ 9 មានចុះលេខពីលេខ 1 ដល់លេខ 9

ដើម្បីឱ្យផលគុណនៃប័ណ្ណទាំងពីរជាចំនួនគូលុះត្រាតែ គេចាប់បានប័ណ្ណមានលេខគូមួយយ៉ាងតិច មានន័យថា គូមួយ ឬគូពីរ

តាង $A$ ជាព្រឹត្តិការណ៍ចាប់បានប័ណ្ណមានផលគុណជាលេខគូ

គេបាន $P(A)=P(\text{គូ សេស})+P(\text{គូ គូ})+P(\text{សេស គូ})$

$=\left(\dfrac{4}{9}\cdot\dfrac{5}{8}\right)+\left(\dfrac{4}{9}\cdot\dfrac{3}{8}\right)+\left(\dfrac{5}{9}\cdot\dfrac{4}{8}\right)$

$=\dfrac{20}{72}+\dfrac{12}{72}+\dfrac{20}{72}=\dfrac{52}{72}=\dfrac{13}{18}$

ដូចនេះ: $\boxed{P(A)=\dfrac{13}{18}=0.72}$ ។

**5. ក. សិក្សាអថេរភាព និងគូសខ្សែកោងនៃអនុគមន៍ $f(x)$**

គេមាន $y=f(x)=x^3-3x+1$ (ដូចគ្រូអនុ. 2013)

• ដែនកំណត់

ដោយ អនុគមន៍ $f$ ជាអនុគមន៍ពហុធា មានន័យគ្រប់ $x\in\mathbb{R}$

ដូចនេះ: $\boxed{D=\mathbb{R}=(-\infty\ ,+\infty)}$ ។

• ទិសដៅអថេរភាព

គេមាន $f(x)=x^3-3x+1$

ដេរីវេ : $f'(x)=3x^2-3=3(x-1)(x+1)$

គេឱ្យ $f'(x)=0$

$3(x-1)(x+1)=0$ នោះ $x=1\,,\,x=-1$

គេបាន $f(1)=1^3-3\cdot1+1=-1$

$f(-1)=(-1)^3-3(-1)+1=3$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |

• បរមា

-ត្រង់ $x=-1$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$ បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើ $f(-1)=3$ ។

-ត្រង់ $x=1$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$ បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើ $f(1)=-1$ ។

• លីមីតត្រង់ចុងដែនកំណត់

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\left(x^3-3x+1\right)=-\infty$$

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\left(x^3-3x+1\right)=+\infty$$

• តារាងអថេរភាព

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $3$ | $\searrow$ | $-1$ | $\nearrow$ | $+\infty$ |

• ភាពប៉ោងផត និងចំណុចរបត់

ដេរីវេទី២ $f''(x)=\left(3x^2-3\right)'=6x$

គេឱ្យ $f''(x)=0 \Leftrightarrow 6x=0$ នោះ $x=0$

- បើ $x>0$ នោះ $f''(x)>0$

នាំឱ្យ ខ្សែកោងបែរភាពផតទៅខាងលើ

- បើ $x<0$ នោះ $f''(x)<0$

នាំឱ្យ ខ្សែកោងបែរភាពផតទៅខាងក្រោម

- បើ $x=0$ , $f''(x)=0$ និងប្តូរសញ្ញា

នាំឱ្យ $f$ មានចំណុចរបត់ $I(0,f(0))=I(0,1)$

• ផ្ចិតឆ្លុះ:

គេនឹង បង្ហាញថា ចំណុចរបត់ $I(0\,,1)$ ជាផ្ចិតឆ្លុះនៃខ្សែកោង បើ $I(a\,,b)$ ជាផ្ចិតឆ្លុះលុះត្រាតែ $f(2a-x)+f(x)=2b$

គេបាន $f(-x)+f(x)=2$

ដោយ $f(-x)+f(x)$

$=(-x)^3-3(-x)+1+x^3-3x+1$

$=-x^3+3x+1+x^3-3x+1=2$ ពិត

ដូចនេះ $I(0\,,1)$ ជាផ្ចិតឆ្លុះនៃខ្សែកោង $C$ តាងអនុគមន៍ $f$

• សង់ក្រាប




## ខ. ពិភាក្សាតាមតម្លៃ m នូវចំនួនឫសរបស់សមីការ

គេមាន សមីការ $x^3-3x+1-m=0$

គេបាន $m=x^3-3x+1$

ឫសនៃសមីការនេះបានពីប្រសព្វរវាង បន្ទាត់ដេក $y=m$ និងក្រាប $C$ ។ តាមក្រាបគេបានអត្ថិភាពនៃឫសដូចខាងក្រោម ៖

• $m\in(-\infty,-1)$ : សមីការមានឫសតែមួយគត់ $x_1<0$

• $m=-1$ : សមីការមានឫសបី $x_1=-2\,,\,x_2=x_3=1$

• $m\in(-1\,,3)$ : សមីការមានឫសបីផ្សេងគ្នា

• $m=3$ : សមីការមានឫសបី $x_1=x_2=-1\,,\,x_3=2$

• $m\in(3\,,+\infty)$ : សមីការមានឫសតែមួយគត់ $0<x_1$

## II. ចម្លើយផ្នែកធរណីមាត្រ

**1.** ក. រកចម្ងាយពីផ្ចិតអេលីប(E) ទៅចំណុចកំណុំរបស់អេលីបនោះ:

ដោយ ផ្ចិតជាចំណុចកណ្តាលនៃ កំណុំទាំងពីរ

គេបាន $2c = F_1F_2$ ឬ $c = \dfrac{F_1F_2}{2}$

ដោយ $F_1(1,-3)$ , $F_2(1,1)$

នោះ $F_1F_2 = \sqrt{(1-1)^2+(1+3)^2} = \sqrt{0+4^2} = 4$

នាំឱ្យ $c = \dfrac{F_1F_2}{2} = \dfrac{4}{2} = 2$

ដូចនេះ ចម្ងាយពីផ្ចិតទៅកំណុំគឺ $\boxed{c=2}$ ឯកតាប្រវែង ។

**ខ. គណនាប្រវែងអ័ក្សធំ និងអ័ក្សតូចរបស់អេលីប (E)**

ដោយ អេលីប (E) កាត់តាមចំណុច $A\left(-\sqrt{2}+1\,,1\right)$

តាមនិយមន័យអេលីប ដែលមាន $2a$ ជាប្រវែងអ័ក្សធំ

គេបាន $AF_1 + AF_2 = 2a$

ដោយ $AF_1 = \sqrt{\left(1+\sqrt{2}-1\right)^2+(-3-1)^2} = \sqrt{18} = 3\sqrt{2}$

$AF_2 = \sqrt{\left(1+\sqrt{2}-1\right)^2+(1-1)^2} = \sqrt{2}$

នាំឱ្យ $2a = 3\sqrt{2}+\sqrt{2} = 4\sqrt{2}$

ដូចនេះ ប្រវែងអ័ក្សធំ $\boxed{2a=4\sqrt{2}}$ ឯកតាប្រវែង ។

ដោយ $b = \sqrt{a^2-c^2} = \sqrt{\left(2\sqrt{2}\right)^2-2^2} = 2$

ដូចនេះ ប្រវែងអ័ក្សតូច $\boxed{2b=4}$ ឯកតាប្រវែង ។

**➤សរសេរសមីការស្តង់ដានៃអេលីបនោះ:**

ដោយ $F_1(1,-3)$ , $F_2(1,1)$ មានអាប់ស៊ីសដូចគ្នា

នោះ (E) ជាអេលីបមានអ័ក្សធំស្របអ័ក្សអាប់ស៊ីស

សមីការ ស្តង់ដា $(\mathrm{E}): \dfrac{(x-h)^2}{a^2}+\dfrac{(y-k)^2}{b^2} = 1$

ដោយ ផ្ចិត $I$ ជាចំណុចកណ្តាលនៃ កំណុំទាំងពីរ

$$I(h\,,k) = I\left(\frac{1+1}{2}\,,\frac{-3+1}{2}\right) = I(1\,,-1)$$

គេបាន $h=1\,, k=-1$

នាំឱ្យ សមីការស្តង់ដានៃអេលីបអាចសរសេរបានគឺ៖

$$(\mathrm{E}): \frac{(x-1)^2}{\left(2\sqrt{2}\right)^2}+\frac{(y+1)^2}{2^2} = 1$$

ដូចនេះ $\boxed{(\mathrm{E}): \dfrac{(x-1)^2}{\left(2\sqrt{2}\right)^2}+\dfrac{(y+1)^2}{2^2} = 1}$ ។

**2.** **ក. សរសេរសមីការទូទៅនៃប្លង់ (P) កាត់ $I$ , $M$ និង $N$**

ប្លង់រាង $(P): a(x-x_0)+b(y-y_0)+c(z-z_0) = 0$

ដោយ ប្លង់ (P) កាត់តាមបីចំណុច $I$ , $M$ និង $N$

នោះប្លង់ $(P)$ កាត់តាមចំណុច $I(3,-1,5)$ និង

មានវ៉ិចទ័រណរម៉ាល់ $\vec{n} = \overrightarrow{IM}\times\overrightarrow{IN}$

គេមាន $I(3,-1,5)$ , $M(4,2,-1)$ , $N(1,-2,3)$

នាំឱ្យ $\overrightarrow{IM} = (1\,,3\,,-6)$ , $\overrightarrow{IN} = (-2\,,-1\,,-2)$

នោះ $\vec{n} = \overrightarrow{IM}\times\overrightarrow{IN} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 1 & 3 & -6 \\ -2 & -1 & -2 \end{vmatrix} = -12\vec{i}+14\vec{j}+5\vec{k}$

គេបាន $(P): -12(x-3)+14(y+1)+5(z-5) = 0$

$$-12x+14y+5z+36+14-25 = 0$$

$$-12x+14y+5z+25 = 0$$

ដូចនេះ $\boxed{(\mathrm{P}): -12x+14y+5z+25 = 0}$ ។

**ខ. គណនាផ្ទៃក្រឡានៃត្រីកោណ $IMN$**

រូបមន្ត $S_{IMN} = \dfrac{1}{2}\left|\overrightarrow{IM}\times\overrightarrow{IN}\right| = \dfrac{1}{2}\sqrt{(-12)^2+14^2+5^2}$

$$= \frac{1}{2}\sqrt{365} = \frac{\sqrt{365}}{2}$$

ដូចនេះ គណនាបាន $\boxed{S_{IMN} = \dfrac{\sqrt{356}}{2}}$ ឯកតាផ្ទៃក្រឡា ។

**➤សរសេរសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ (d)**

សមីការការប៉ារ៉ាម៉ែតមានរាង $(\mathrm{d}): \begin{cases} x = x_0+at \\ y = y_0+bt\ ,\ t\in\mathbb{R} \\ z = z_0+ct \end{cases}$

ដោយ (d) កាត់តាមចំណុច $A(1\,,1\,,3)$ និងកាត់តាម

ចំណុច $M(4\,,2\,,-1)$ នោះបន្ទាត់ (d) មាន

វ៉ិចទ័រប្រាប់ទិស $\overrightarrow{AM} = (3\,,1\,,-4)$

នាំឱ្យ $(\mathrm{d}): \begin{cases} x = 1+3t \\ y = 1+t\quad ,\ t\in\mathbb{R} \\ z = 3-4t \end{cases}$

ដូចនេះ $\boxed{(\mathrm{d}): \begin{cases} x = 1+3t \\ y = 1+t\quad ,\ t\in\mathbb{R} \\ z = 3-4t \end{cases}}$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ...............................

លេខបន្ទប់ : ...............................

លេខតុ : ...............................

ហត្ថលេខា : ...............................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "**

**សម័យប្រឡង : ០៦ ធ្នូ ២០១៥**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

## I. ផ្នែកពីជគណិត

1. គណនាលីមីតខាងក្រោម ៖

$$A=\lim_{x\to+\infty}\frac{(2x^2-2x-1)}{(x^2+1)} \qquad B=\lim_{x\to-1}\frac{(x+1)(x^2-x+1)}{(x+1)(2x+1)}$$ (១ពិន្ទុ)

2. គណនាអាំងតេក្រាលខាងក្រោម ៖

$$A=\int(x^2-2x+1)dx \qquad B=\int_0^1\left(3x^3-\frac{1}{4}x\right)dx$$ (១ពិន្ទុ)

3. គេមានចំនួនកុំផ្លិច $Z=\frac{\sqrt{3}}{2}+\frac{1}{2}i$

ក. សរសេរចំនួនកុំផ្លិច $Z$ ជាទម្រង់ត្រីកោណមាត្រ ។ (កន្លះពិន្ទុ)

ខ. ចូរគណនា $Z^2$ រួចសរសេរជាទម្រង់ត្រីកោណមាត្រ ។ (កន្លះពិន្ទុ)

4. គេមានអនុគមន៍ $f(x)=\frac{(kx^2-5x+7)}{(kx-2)}$ ។

ក. ចូរសិក្សាអថេរភាព និងគូសខ្សែកោង $(C)$ នៃអនុគមន៍ $f(x)$ ចំពោះ $k=1$ ។ (២ពិន្ទុ)

ខ. ចូរកំណត់តម្លៃ $k$ ដើម្បីឱ្យខ្សែកោង $(C)$ នៃអនុគមន៍ $f(x)$ ប៉ះបន្ទាត់ $y=1$ ។ (១ពិន្ទុ)

## II. ផ្នែកធរណីមាត្រ

1. នៅក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(O,\vec{i},\vec{j},\vec{k})$ នៃលំហ គេមានបីចំណុច $A(1,2,1)$ , $B(2,0,3)$ និង $C(-1,2,0)$ ។

ក. ចូរគណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចបង្ហាញថា ចំណុច $A$ , $B$ និង $C$ មិននៅលើបន្ទាត់តែមួយ ។ (១ពិន្ទុ)

ខ. គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ។ (១ពិន្ទុ)

2. ប៉ារ៉ាបូលមួយមានកំពូលនៅត្រង់ចំណុច $(0,0)$ និងកំណុំស្ថិតនៅលើអ័ក្សអាប់ស៊ីស $(x'x)$ ។

ក. រកសមីការស្តង់ដានៃប៉ារ៉ាបូល ដោយដឹងថាវាកាត់តាមចំណុច $A(4,8)$ ។ (១ពិន្ទុ)

ខ. គេមានចំណុច $B(x_1,4)$ ស្ថិតនៅលើប៉ារ៉ាបូលនោះ ។ ចូរគណនាតម្លៃ $x_1$ ។ (១ពិន្ទុ)

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
# ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ២០១៥

## I. ចម្លើយផ្នែកពីជគណិត

**1. គណនាលីមីតខាងក្រោម ៖**

$$A=\lim_{x\to+\infty}\frac{\left(2x^2-2x-1\right)}{\left(x^2+1\right)}\quad \text{(រាងមិនកំណត់ } \tfrac{\infty}{\infty}\text{)}$$

$$=\lim_{x\to+\infty}\frac{x^2\left(2-\frac{2}{x}-\frac{1}{x^2}\right)}{x^2\left(1+\frac{1}{x^2}\right)}=\frac{2-0-0}{1+0}=\boxed{2}$$

$$B=\lim_{x\to-1}\frac{(x+1)\left(x^2-x+1\right)}{(x+1)(2x+1)}\quad \text{(រាងមិនកំណត់ } \tfrac{0}{0}\text{)}$$

$$=\lim_{x\to-1}\frac{x^2-x+1}{2x+1}=\frac{3}{-1}=\boxed{-3}$$

**2. គណនាអាំងតេក្រាលខាងក្រោម ៖**

$$A=\int\left(x^2-2x+1\right)dx=\boxed{\frac{x^3}{3}-x^2+x+c}$$ ដែល $c$ ថេរ

$$B=\int_0^1\left(3x^3-\frac{1}{4}x\right)dx=\left[\frac{3x^4}{4}-\frac{x^2}{8}\right]_0^1$$

$$=\left(\frac{3}{4}-\frac{1}{8}\right)-(0-0)=\boxed{\frac{5}{8}}$$

**3. ក. សរសេរចំនួនកុំផ្លិច $Z$ ជាទម្រង់ត្រីកោណមាត្រ**

គេមាន $Z=\frac{\sqrt{3}}{2}+\frac{1}{2}i=\cos\frac{\pi}{6}+i\sin\frac{\pi}{6}$

ដូចនេះ $\boxed{Z=\cos\frac{\pi}{6}+i\sin\frac{\pi}{6}}$ ។

**ខ. គណនា $Z^2$ រួចសរសេរជាទម្រង់ត្រីកោណមាត្រ**

គេមាន $Z=\cos\frac{\pi}{6}+i\sin\frac{\pi}{6}$

តាមដឺម៉ូ $\left(\cos\theta+i\sin\theta\right)^n=\cos n\theta+i\sin n\theta$

នាំឱ្យ $Z^2=\left(\cos\frac{\pi}{6}+i\sin\frac{\pi}{6}\right)^2$

$$=\cos\frac{\pi}{3}+i\sin\frac{\pi}{3}$$

ដូចនេះ $\boxed{Z^2=\cos\frac{\pi}{3}+i\sin\frac{\pi}{3}}$ ។

**4. ក. សិក្សាអថេរភាព និងគូសខ្សែកោង $(C)$**

គេមាន $f(x)=\frac{\left(kx^2-5x+7\right)}{(kx-2)}$

ចំពោះ $k=1$ គេបាន $f(x)=\frac{x^2-5x+7}{x-2}$

•ដែនកំណត់

អនុគមន៍ $f$ មានន័យលុះត្រាតែ $x-2\neq 0\Rightarrow x\neq 2$

ដូចនេះ ដែនកំណត់ $\boxed{D=(-\infty\,,\,2)\cup(2\,,\,+\infty)}$ ។

•ទិសដៅអថេរភាព

$$f'(x)=\frac{\left(x^2-5x+7\right)'(x-2)-(x-2)'\left(x^2-5x+7\right)}{(x-2)^2}$$

$$=\frac{(2x-5)(x-2)-\left(x^2-5x+7\right)}{(x-2)^2}$$

$$=\frac{2x^2-4x-5x+10-x^2+5x-7}{(x-2)^2}$$

$$=\frac{x^2-4x+10-7}{(x-2)^2}=\frac{x^2-4x+3}{(x-2)^2}$$

ឱ្យ $f'(x)=0\Leftrightarrow \frac{x^2-4x+3}{(x-2)^2}=0$

ដោយ $\forall\in D\ ,\ (x-2)^2>0$

នាំឱ្យ $x^2-4x+3=0$ មានឫសងាយ $x=1\,,\ x=3$

ចំពោះ $x=1:\ f(1)=\frac{1^2-5+7}{1-2}=-3$

$x=3:\ f(3)=\frac{3^2-5\cdot 3+7}{3-2}=1$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | 1 | | 2 | | 3 | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | + | 0 | − | ‖ | − | 0 | + |

•ត្រង់ $x=1$, $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$

បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើនឹង $f(1)=-3$ ។

•ត្រង់ $x=3$, $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើនឹង $f(3)=1$ ។

• លីមីត និងអាស៊ីមតូត

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\frac{x^2-5x+7}{x-2}=\lim_{x\to+\infty}\frac{x^2}{x}=+\infty$$

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\frac{x^2-5x+7}{x-2}=\lim_{x\to-\infty}\frac{x^2}{x}=-\infty$$

$$\lim_{x\to2^-} f(x)=\lim_{x\to2^-}\frac{x^2-5x+7}{x-2}=\frac{4-10+7}{2+0^--2}=-\infty$$

$$\lim_{x\to2^+} f(x)=\lim_{x\to2^+}\frac{x^2-5x+7}{x-2}=\frac{4-10+7}{2+0^+-2}=+\infty$$

ដោយ $\lim_{x\to2} f(x)=\pm\infty$ នោះបន្ទាត់ដែលមានសមីការ $x=2$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ។

ម្យ៉ាងទៀត $f(x)=\dfrac{x^2-5x+7}{x-2}=x-3+\dfrac{1}{x-2}$

ដោយ $\lim_{x\to\pm\infty}\dfrac{1}{x-2}=0$ នោះបន្ទាត់ដែលមានសមីការ $y=x-3$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

• តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-\infty$ | | $1$ | | $2$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-3$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $1$ | ↗ | $+\infty$ |

➤សង់ខ្សែកោង $(C)$ តាងអនុគមន៍




• ផ្ចិតឆ្លុះនៃក្រាប $(C)$ តាងអនុគមន៍ $f$

ដោយ អាស៊ីមតូតឈរ $x=2$ និងទ្រេត $y=x-3$ ប្រសព្វគ្នា ត្រង់ចំណុច $I(2,-1)$ នាំឱ្យ $I(2,-1)$ ជាផ្ចិតឆ្លុះនៃក្រាប $(C)$

ខ. កំណត់តម្លៃ $k$ ដើម្បីឱ្យខ្សែកោង $(C)$ ប៉ះបន្ទាត់ $y=1$

គេមាន $f(x)=\dfrac{(kx^2-5x+7)}{(kx-2)}$ និងបន្ទាត់ $y=1$

គេបាន សមីការអាប់ស៊ីស

$$\frac{kx^2-5x+7}{kx-2}=1$$

$$kx^2-5x+7=kx-2$$

$$kx^2+(-5-k)x+9=0$$

ដើម្បីឱ្យខ្សែកោង $(C)$ ប៉ះនឹងបន្ទាត់ $y=1$ លុះត្រាតែ $\begin{cases}a\neq0\\ \Delta=0\end{cases}$

នាំឱ្យ $a=k\neq0$

$$kx^2+(-5-k)x+9=0$$

$$\Delta=(-5-k)^2-36k=0$$

$$25+10k+k^2-36k=0$$

$$k^2-26k+25=0$$

សមីការមានឫសងាយ $k=1$ , $k=25$

ដូចនេះ៖ តម្លៃកំណត់បានគឺ $\boxed{k=1\,,\,k=25}$ ។

## II. ចម្លើយផ្នែកធរណីមាត្រ

1. ក. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ ៖

គេមាន $A(1,2,1)$ , $B(2,0,3)$ និង $C(-1,2,0)$

គេបាន $\overrightarrow{AB}=(1,-2,2)$ , $\overrightarrow{AC}=(-2,0,-1)$

នាំឱ្យ $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & -2 & 2\\ -2 & 0 & -1\end{vmatrix}=2\vec{i}-3\vec{j}-4\vec{k}$

ដូចនេះ៖ គណនាបាន $\boxed{\overrightarrow{AB}\times\overrightarrow{AC}=2\vec{i}-3\vec{j}-4\vec{k}}$ ។

➤បង្ហាញថា ចំណុច $A$ , $B$ និង $C$ មិននៅលើបន្ទាត់តែមួយ

ដោយ $\overrightarrow{AB}\times\overrightarrow{AC}=2\vec{i}-3\vec{j}-4\vec{k}\neq\vec{0}$

នាំឱ្យ បីចំណុច $A$ , $B$ , $C$ មិនរត់ត្រង់ជួរ

ដូចនេះ៖ $\boxed{\text{ចំណុច } A\,,\,B \text{ និង } C \text{ មិននៅលើបន្ទាត់តែមួយ}}$ ។

ខ. គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ។

តាមរូបមន្ត $S_{ABC}=\dfrac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AC}\right|$

$$=\frac{1}{2}\sqrt{2^2+(-3)^2+(-4)^2}=\frac{\sqrt{29}}{2}$$

ដូចនេះ៖ ផ្ទៃត្រីកោណ $\boxed{S_{ABC}=\dfrac{\sqrt{29}}{2}}$ ឯកតាផ្ទៃក្រឡា ។

**2. ក. រកសមីការស្តង់ដានៃប៉ារ៉ាបូល**

គេមាន ប៉ារ៉ាបូលមានកំពូលនៅត្រង់ចំណុច $(0\ ,\ 0)$

និងកំណុំស្ថិតនៅលើអ័ក្សអាប់ស៊ីស $(x'x)$

នោះ ប៉ារ៉ាបូលមានអ័ក្សឆ្លុះនៅលើអ័ក្សអាប់ស៊ីស

នាំឱ្យ ប៉ារ៉ាបូលមានសមីការស្តង់ដា $y^2 = 4px$

ដោយ ប៉ារ៉ាបូលកាត់តាមចំណុច $A(4\ ,\ 8)$

គេបាន $8^2 = 16p \Rightarrow p = 4$ នោះ $y^2 = 4 \cdot 4x$

ដូចនេះ សមីការស្តង់ដានៃប៉ារ៉ាបូលគឺ $\boxed{y^2 = 16x}$ ។

**ខ. គណនាតម្លៃ** $x_1$

គេមាន ចំណុច $B(x_1\ ,\ 4)$ ស្ថិតនៅលើប៉ារ៉ាបូលនោះ

គេបាន $y^2 = 16x$ ទៅជា $4^2 = 16x_1$ នោះ $x_1 = 1$

ដូចនេះ គណនាបាន $\boxed{x_1 = 1}$ ។

**ចប់ត្រឹមនេះ**

**ខ្ញុំសូមបន្ថែមក្រាបនៃប៉ារ៉ាបូលដើម្បីផ្ទៀងផ្ទាត់**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "

## សម័យប្រឡង : ០៧ ធ្នូ ២០១៤

**វិញ្ញាសា : គណិតវិទ្យា   រយៈពេល : ១២០ នាទី   ពិន្ទុ : ១០**

### ផ្នែកពីជគណិត

**I.** គណនាលីមីតខាងក្រោម ៖

ក. $A=\lim\limits_{x\to 1^+}|x+1|+2$   $B=\lim\limits_{x\to\infty}\dfrac{2x^3+3x+1}{x^3-2x^2+5}$   **(កន្លះពិន្ទុ)**

ខ. $C=\lim\limits_{x\to 3}\dfrac{x^2-9}{x-3}$   $D=\lim\limits_{x\to -3}\dfrac{\sqrt{x^2-1}}{|x+3|}$   **(កន្លះពិន្ទុ)**

**II.** គណនាអាំងតេក្រាលខាងក្រោម ៖

ក. $A=\int_1^2\left(x^2+3x+2\right)dx$   $B=\int_{\pi}^{\frac{\pi}{2}}\left(\dfrac{\cos^2 x-\sin^2 x}{(\cos x+\sin x)}\right)dx$   **(មួយពិន្ទុ)**

ខ. $C=\int_{\pi}^{\frac{\pi}{2}}\left(\dfrac{1-\sin^2 x}{\cos x}\right)dx$   $D=\int_2^1\left(\dfrac{1}{x^4}+\dfrac{1}{x^2}\right)dx$   **(មួយពិន្ទុ)**

**III.** ដោះស្រាយសមីការ និងវិសមីការខាងក្រោម ៖

ក. $9^{-2|x|}=\dfrac{1}{81}$ (កន្លះពិន្ទុ)   ខ. $\left(\dfrac{1}{4}\right)^{\frac{-x^2+1}{2}}>256$   **(កន្លះពិន្ទុ)**

**IV.** គេមានអនុគមន៍ $f(x)=\dfrac{x^2-mx+m}{x-1}$ ។

ក. កំណត់តម្លៃ $m$ ដើម្បីឱ្យចំណុច $A(1,2)$ ជាផ្ចិតឆ្លុះរបស់ខ្សែកោង $(C)$ នៃ $f(x)$ ។ **(កន្លះពិន្ទុ)**

ខ. សិក្សាអថេរភាព និងគូសខ្សែកោង $(C)$ នៃអនុគមន៍ $f(x)$ ចំពោះ $m=0$ ។ **(មួយពិន្ទុ)**

គ. កំណត់តម្លៃ $k$ ដើម្បីឱ្យបន្ទាត់ $y=k$ កាត់ខ្សែកោង $(C)$ ត្រង់ចំណុច $B$ និង $C$ ដែល $BC=\sqrt{5}$ ។ **(កន្លះពិន្ទុ)**

### ផ្នែកធរណីមាត្រ

**V.** គេមានសមីការ $25x^2+9y^2=225$ ។

ក. បង្ហាញថាសមីការនេះ ជាសមីការអេលីប រួចបញ្ជាក់ទីតាំងផ្ចិត និងអ័ក្សធំរបស់វាផង ។ **(មួយពិន្ទុ)**

ខ. រកប្រវែងអ័ក្សធំ និងអ័ក្សតូច នៃអេលីបនេះ រួចរកកូអរដោនេនៃចំណុចកំពូល និងកំណុំទាំងពីររបស់វា ។ **(មួយពិន្ទុ)**

**VI.** នៅក្នុងតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ ដែលមានទិសដៅវិជ្ជមានគេមានបីចំណុច $A(1,0,-2)$, $B(2,1,-1)$ និង $C(1,-2,2)$ ។

ក. គណនាប្រវែងជ្រុង $AB$ និង $BC$ នៃត្រីកោណ $ABC$ ។ **(មួយពិន្ទុ)**

ខ. $M$ និង $N$ ជាចំណុចកណ្ដាលរៀងគ្នានៃជ្រុង $AB$ និង $BC$ ។ ចូររកកូអរដោនេនៃចំណុច $M$ និង $N$ ។ **(មួយពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
# ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០១៤

**I.** គណនាលីមីតខាងក្រោម :

ក. $A=\lim_{x\to 1^+}|x+1|+2=|1+1|+2=\boxed{4}$

$B=\lim_{x\to\infty}\frac{2x^3+3x+1}{x^3-2x^2+5}=\lim_{x\to\infty}\frac{2x^3}{x^3}=\boxed{2}$

ខ. $C=\lim_{x\to 3}\frac{x^2-9}{x-3}=\lim_{x\to 3}\frac{(x-3)(x+3)}{x-3}=\boxed{6}$

$D=\lim_{x\to -3}\frac{\sqrt{x^2-1}}{|x+3|}=\frac{\sqrt{(-3)^2-1}}{0^+}=\boxed{+\infty}$

**II.** គណនាអាំងតេក្រាលខាងក្រោម :

ក. $A=\int_1^2\left(x^2+3x+2\right)dx$

$=\int_1^2\left(x^2+3x+2\right)dx$

$=\left[\frac{x^3}{3}+\frac{3x^2}{2}+2x\right]_1^2$

$=\left(\frac{8}{3}+6+4\right)-\left(\frac{1}{3}+\frac{3}{2}+2\right)$

$=\frac{38}{3}-\frac{23}{6}=\boxed{\frac{53}{6}}$

$B=\int_{\pi}^{\frac{\pi}{2}}\left(\frac{\cos^2 x-\sin^2 x}{(\cos x+\sin x)}\right)dx$

$=\int_{\pi}^{\frac{\pi}{2}}\left(\frac{(\cos x-\sin x)(\cos x+\sin x)}{(\cos x+\sin x)}\right)dx$

$=\int_{\pi}^{\frac{\pi}{2}}(\cos x-\sin x)dx=\left[\sin x+\cos x\right]_{\pi}^{\frac{\pi}{2}}$

$=(1+0)-(0-1)=\boxed{2}$

ខ. $C=\int_{\pi}^{\frac{\pi}{2}}\left(\frac{1-\sin^2 x}{\cos x}\right)dx$

$=\int_{\pi}^{\frac{\pi}{2}}\left(\frac{\cos^2 x}{\cos x}\right)dx=\int_{\pi}^{\frac{\pi}{2}}\cos x\,dx=\left[\sin x\right]_{\pi}^{\frac{\pi}{2}}=\boxed{1}$

$D=\int_2^1\left(\frac{1}{x^4}+\frac{1}{x^2}\right)dx=\int_2^1\left(x^{-4}+x^{-2}\right)dx$

$=\left[\frac{x^{-4+1}}{-4+1}+\frac{x^{-2+1}}{-2+1}\right]_2^1=\left[-\frac{1}{3x^3}-\frac{1}{x}\right]_2^1$

$=\left(-\frac{1}{3}-1\right)-\left(-\frac{1}{24}-\frac{1}{2}\right)=\frac{-4}{3}+\frac{13}{24}=\boxed{-\frac{19}{24}}$

**III.** ដោះស្រាយសមីការ និងវិសមីការខាងក្រោម :

ក. $9^{-2|x|}=\frac{1}{81}$

$9^{-2|x|}=9^{-2}$

$-2|x|=-2$

$|x|=1$ នាំឱ្យ $x=\pm 1$

ដូចនេះ សមីការមានឫស $\boxed{x=\pm 1}$ ។

ខ. $\left(\frac{1}{4}\right)^{\frac{-x^2+1}{2}}>256$

$4^{-\frac{-x^2+1}{2}}>4^4$

គេបាន $-\frac{-x^2+1}{2}>4$ ឬ $x^2-1>8$ ឬ $x^2-9>0$

ឱ្យ $x^2-9=0$ នោះ $x=\pm 3$

តារាងសញ្ញា

| $x$ | $-\infty$ | | $-3$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $x^2-9>0$ | | $+$ | $0$ | $-$ | $0$ | $+$ | |

ដូចនេះ វិសមីការមានចម្លើយ $\boxed{x\in(-\infty,-3)\cup(3,+\infty)}$ ។

**IV.** ក. កំណត់តម្លៃ $m$ :

ដើម្បីឱ្យចំណុច $A(1,2)$ ជាផ្ចិតឆ្លុះនៃខ្សែកោង $(C)$ នៃ $f(x)$ លុះត្រាតែវាផ្ទៀងផ្ទាត់ $f(2a-x)+f(x)=2b$ ឬ $f(2-x)+f(x)=4$

ដោយ $f(x)=\frac{x^2-mx+m}{x-1}$

នោះ $f(2-x)=\frac{(2-x)^2-m(2-x)+m}{(2-x)-1}$

$=\frac{4-4x+x^2-2m+mx+m}{-x+1}$

$=\frac{x^2+(m-4)x-m+4}{-(x-1)}$

$=\frac{-x^2-(m-4)x+m-4}{x-1}$

គេបាន $\frac{x^2-mx+m}{x-1}+\frac{-x^2-(m-4)x+m-4}{x-1}=4$

$$\frac{-(2m-4)x+2m-4}{x-1}=4$$

$$-(2m-4)x+2m-4=4x-4$$

$$-(2m-4)x+2m=4x$$

$$\begin{cases}-(2m-4)=4\\ 2m=0\end{cases} \Rightarrow \quad m=0$$

ដូចនេះ តម្លៃកំណត់បានគឺ $\boxed{m=0}$ ។

**ខ. សិក្សាអថេរភាព និងគូសខ្សែកោង $(C)$ នៃអនុគមន៍ $f(x)$**

ចំពោះ $m=0$ នោះ $f(x)=\dfrac{x^2}{x-1}$

• ដែនកំណត់

អនុគមន៍ $f$ មានន័យលុះត្រាតែ $x-1\neq 0$ នោះ $x\neq 1$

ដូចនេះ $\boxed{D=\mathbb{R}-\{1\}=(-\infty\,,1)\cup(1\,,+\infty)}$ ។

• ទិសដៅអថេរភាព

ដេរីវេ $f'(x)=\dfrac{(x^2)'(x-1)-(x-1)'x^2}{x-1}$

$$=\frac{2x(x-1)-x^2}{(x-1)^2}=\frac{x^2-2x}{(x-1)^2}$$

គេឱ្យ $f'(x)=0 \Leftrightarrow \dfrac{x^2-2x}{(x-1)^2}=0$

ដោយ $\forall x\in D\,,(x-1)^2>0$

នាំឱ្យ $x^2-2x=0$ នោះ $x=0\,,x=2$

ចំពោះ $x=0: f(0)=\dfrac{0^2}{0-1}=0$

ចំពោះ $x=2: f(2)=\dfrac{2^2}{2-1}=4$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $0$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |

• ត្រង់ $x=0$, $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$

បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើនឹង $f(0)=0$ ។

• ត្រង់ $x=2$, $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើនឹង $f(2)=4$ ។

• លីមីត និងអាសុីមតូត

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\frac{x^2}{x-1}=\lim_{x\to+\infty}\frac{x^2}{x}=+\infty$$

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\frac{x^2}{x-1}=\lim_{x\to-\infty}\frac{x^2}{x}=-\infty$$

$$\lim_{x\to1^-} f(x)=\lim_{x\to1^-}\frac{x^2}{x-1}=\frac{1}{1+0^- -1}=-\infty$$

$$\lim_{x\to1^+} f(x)=\lim_{x\to1^+}\frac{x^2}{x-1}=\frac{1}{1+0^+ -1}=+\infty$$

ដោយ $\lim\limits_{x\to1} f(x)=\pm\infty$ នោះបន្ទាត់ដែលមានសមីការ $x=1$ ជាអាសុីមតូតឈរនៃក្រាប $C$ ។

ម្យ៉ាងទៀត $f(x)=\dfrac{x^2}{x-1}=x+1+\dfrac{1}{x-1}$

ដោយ $\lim\limits_{x\to\pm\infty}\dfrac{1}{x-1}=0$ នោះបន្ទាត់ដែលមានសមីការ $y=x+1$ ជាអាសុីមតូតទ្រេតនៃក្រាប $(C)$ ។

• តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-\infty$ | | $0$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $0$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $4$ | ↗ | $+\infty$ |

➤**សង់ខ្សែកោង $(C)$ តាងអនុគមន៍ $f(x)$**




**គ. កំណត់តម្លៃ $k$**

គេមាន $f(x)=\dfrac{x^2}{x-1}$ និង $y=k$

គេបាន សមីការអាប់សុីស $\dfrac{x^2}{x-1}=k$ ឬ $x^2=kx-k$

ឬ $x^2-kx+k=0$ ទាញបាន $\begin{cases}x_1+x_2=k\\ x_1x_2=k\end{cases}$

ដែល $x_1$ និង $x_2$ ជាអាប់ស៊ីសរៀងគ្នានៃចំណុច $B$ និង $C$

ដោយ $BC=\sqrt{5}$

គេបាន $|x_2-x_1|=\sqrt{5}$

$$(|x_2-x_1|)^2=(\sqrt{5})^2$$

$$x_2^2-2x_2x_1+x_1^2=5$$

$$x_2^2+2x_2x_1+x_1^2-4x_2x=5$$

$$(x_2+x_1)^2-4x_2x=5$$

$$k^2-4k-5=0$$

សមីការមាន $a-b+c=0$ នោះ: $k=-1$ , $k=5$

ដូចនេះ: តម្លៃកំណត់បានគឺ $\boxed{k=-1\ ,\ k=5}$ ។

**V. ក. បង្ហាញថាសមីការនេះ ជាសមីការអេលីប :**

គេមាន $25x^2+9y^2=225$ (ចែកអង្គទាំងពីរនឹង $225$)

$$\frac{25x^2}{225}+\frac{9y^2}{225}=1$$

$$\frac{(x-0)^2}{3^2}+\frac{(y-0)^2}{5^2}=1$$

ជាសមីការស្តង់ដានៃអេលីប

ដូចនេះ: $\boxed{\text{សមីការនេះជាសមីការស្តង់ដានៃអេលីប}}$ ។

**បញ្ជាក់ទីតាំងផ្ចិត និងអ័ក្សធំរបស់វាផង**

គេមាន $\dfrac{(x-0)^2}{3^2}+\dfrac{(y-0)^2}{5^2}=1$

គេអាចសន្និដ្ឋានបានថា វាមានផ្ចិតជាគល់តម្រុយ និងមានអ័ក្សធំជាអ័ក្សឈរនៅលើអ័ក្សអរដោនេ

ដូចនេះ: អេលីបមានផ្ចិត $(0\ ,\ 0)$ និងអ័ក្សធំ ជាអ័ក្សឈរនៅលើអ័ក្សអរដោនេ ។

**ខ. រកប្រវែងអ័ក្សធំ និងអ័ក្សតូច នៃអេលីបនេះ រួចរកកូអរដោនេ នៃចំណុចកំពូល និងកំណុំទាំងពីររបស់វា**

គេមាន $\dfrac{(x-0)^2}{3^2}+\dfrac{(y-0)^2}{5^2}=1$

ផ្ទឹមនឹង $\dfrac{(x-h)^2}{b^2}+\dfrac{(y-k)^2}{a^2}=1$

គេបាន $h=0\ ,\ k=0\ ,\ a=5\ ,\ b=3$

នាំឱ្យ $c=\sqrt{a^2-b^2}=\sqrt{5^2-3^2}=\sqrt{16}=4$

ដូចនេះ: ប្រវែងអ័ក្សធំ $2a=10$

ប្រវែងអ័ក្សតូច $2b=6$

កំពូល $V(0\ ,\pm a)$ នោះ: $V_1(0,5)$ និង $V_2(0,-5)$

កំណុំ $F(0\ ,\pm c)$ នោះ: $F_1(0,4)$ និង $F_2(0,-4)$

(ប្រធានគ្មានឱ្យសង់អេលីបទេ តែខ្ញុំសង់ដើម្បីផ្ទៀងផ្ទាត់)



**VI. ក. គណនាប្រវែងជ្រុង $AB$ និង $BC$ នៃត្រីកោណ $ABC$ :**

គេមាន $A(1\ ,0\ ,-2)$ , $B(2\ ,1\ ,-1)$ និង $C(1,-2\ ,\ 2)$

នាំឱ្យ $\overrightarrow{AB}=(1\ ,1\ ,1)$ និង $\overrightarrow{BC}=(-1\ ,\ -3\ ,\ 3)$

គេបាន $AB=|\overrightarrow{AB}|=\sqrt{1^2+1^2+1^2}=\sqrt{3}$

$$BC=|\overrightarrow{BC}|=\sqrt{(-1)^2+(-3)^2+3^2}=\sqrt{19}$$

ដូចនេះ: ប្រវែងជ្រុង $AB=\sqrt{3}$ ឯកតាប្រវែង
ប្រវែងជ្រុង $BC=\sqrt{19}$ ឯកតាប្រវែង ។

**ខ. រកកូអរដោនេនៃចំណុច $M$ និង $N$**

គេមាន $A(1\ ,0\ ,-2)$ , $B(2\ ,1\ ,-1)$ និង $C(1,-2\ ,\ 2)$

ដោយ $M$ និង $N$ ជាចំណុចកណ្តាលរៀងគ្នានៃ $AB$ និង $BC$

គេបាន $M\left(\dfrac{x_A+x_B}{2}\ ,\ \dfrac{y_A+y_B}{2}\ ,\ \dfrac{z_A+z_B}{2}\right)$

$$M\left(\frac{3}{2}\ ,\ \frac{1}{2}\ ,\ -\frac{3}{2}\right)$$

ហើយ $N\left(\dfrac{x_B+x_C}{2}\ ,\ \dfrac{y_B+y_C}{2}\ ,\ \dfrac{z_B+z_C}{2}\right)$

$$N\left(\frac{3}{2}\ ,\ -\frac{1}{2}\ ,\ \frac{1}{2}\right)$$

ដូចនេះ: $\boxed{M\left(\frac{3}{2}\ ,\ \frac{1}{2}\ ,\ -\frac{3}{2}\right)\ ,\ N\left(\frac{3}{2}\ ,\ -\frac{1}{2}\ ,\ \frac{1}{2}\right)}$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "
## សម័យប្រឡង : ២១ វិច្ឆិកា ២០១៣

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** គណនាអាំងតេក្រាលខាងក្រោម ៖

ក. $\int \frac{x^{2001}}{\left(1+x^2\right)^{1002}}dx$ **(កន្លះពិន្ទុ)**

ខ. $\int \frac{3x-11}{x^2-6x+9}dx$ **(កន្លះពិន្ទុ)** ។

**II.** គេឱ្យអនុគមន៍ $f(x)=x^2+2x$ និង $g(x)=-x+4$ ។ គណនាមាឌនៃសូលីតបរិវត្តដែលកំណត់ដោយរង្វិលជុំវិញអ័ក្សអាប់ស៊ីស $(x'ox)$ នៃផ្ទៃក្រឡាដែលខ័ណ្ឌដោយក្រាបនៃអនុគមន៍ $f(x)$ និង $g(x)$ ។ **(២ ពិន្ទុ)**

**III.** គេឱ្យអនុគមន៍ $f(x)=\frac{x^2-3x+4}{2x-2}$

ក. សិក្សាអថេរភាព និងសង់ក្រាប $(C)$ នៃអនុគមន៍ $f(x)$ ។ **(២ ពិន្ទុ)**

ខ. $M(x_0, y_0)$ ជាចំណុចមួយនៅលើក្រាប $(C)$ ។ បន្ទាត់ $(d)$ ប៉ះនឹងក្រាប $(C)$ ត្រង់ចំណុច $M$ ហើយកាត់បន្ទាត់អាស៊ីមតូតឈរត្រង់ចំណុច $A$ និងអាស៊ីមតូតទ្រេតត្រង់ $B$ ។

១. ចូរសរសេរសមីការនៃបន្ទាត់ $(d)$ ។ **(១ ពិន្ទុ)**

២. រកកូអរដោនេនៃចំណុច $A$ និង $B$ រួចបង្ហាញថា $M$ ជាចំណុចកណ្ដាលនៃ $[AB]$ ។ **(១ ពិន្ទុ)**

**IV.** គេមានប៉ារ៉ាបូលមួយ មានកំពូលនៅត្រង់ចំណុច $O(0,0)$ ជាគល់នៃអ័ក្ស និងកំណុំស្ថិតនៅលើអ័ក្សអាប់ស៊ីស $(x'ox)$ ។

ក. ចូរសរសេរសមីការស្តង់ដានៃប៉ារ៉ាបូលនេះ ដោយដឹងថាក្រាបរបស់វាកាត់ចំណុច $A_1(-2,4)$ ។ **(១ ពិន្ទុ)**

ខ. រកតម្លៃនៃ $y_2$ បើចំណុច $A_2(-3, y_2)$ ស្ថិតនៅលើប៉ារ៉ាបូលនោះ ។ **(១ ពិន្ទុ)**

គ. ចូរសរសេរសមីការនៃបន្ទាត់ប្រាប់ទិស $(\Delta)$ របស់ប៉ារ៉ាបូល ។ **(១ ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
# ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០១៣

**I. គណនាអាំងតេក្រាលខាងក្រោម :**

ក. $\int \frac{x^{2001}}{(1+x^2)^{1002}}dx = \int \frac{x}{(1+x^2)^2} \times \frac{x^{2000}}{(1+x^2)^{1000}}dx$

$$= \int \frac{x}{(1+x^2)^2} \times \left(\frac{x^2}{1+x^2}\right)^{1000} dx \quad (1)$$

គេតាង $t = \frac{x^2}{1+x^2}$

នាំឱ្យ $dt = \frac{(x^2)'(1+x^2)-(1+x^2)'x^2}{(1+x^2)^2}dx$

$$= \frac{2x+2x^3-2x^3}{(1+x^2)^2}dx = \frac{2x}{(1+x^2)^2}dx$$

នោះ $(1)$ អាចសរសេរ

$$= \frac{1}{2}\int \frac{2x}{(1+x^2)^2} \times \left(\frac{x^2}{1+x^2}\right)^{1000} dx$$

$$= \frac{1}{2}\int t^{1000}dt = \frac{1}{2} \times \frac{t^{1001}}{1001} + c$$

$$= \frac{1}{2002}t^{1001} + c = \frac{1}{2002}\left(\frac{x^2}{1+x^2}\right)^{1001} + c$$ , ថេរ

ដូចនេះ $\boxed{\int \frac{x^{2001}}{(1+x^2)^{1002}}dx = \frac{1}{2002}\left(\frac{x^2}{1+x^2}\right)^{1001} + c \text{ , ថេរ}}$ ។

ខ. $\int \frac{3x-11}{x^2-6x+9}dx = \int \frac{3x-9-2}{(x-3)^2}dx$

$$= 3\int \frac{1}{(x-3)}dx - 2\int \frac{1}{(x-3)^2}dx$$

$$= 3\ln|x-3| + c_1 + 2 \cdot \frac{1}{(x-3)} + c_2$$

$$= 3\ln|x-3| + \frac{2}{(x-3)} + c \quad , \quad c_1 + c_2 = c$$ ថេរ

ដូចនេះ $\boxed{\int \frac{3x-11}{x^2-6x+9}dx = 3\ln|x-3| + \frac{2}{(x-3)} + c}$ ។

**II. គណនាមាឌនៃសូលីតបរិវត្ត :**

គេមាន $f(x) = x^2 + 2x$ និង $g(x) = -x + 4$

គេសង់ក្រាបនៃអនុគមន៍ទាំងពីរដើម្បីរកមើលចំណុចប្រសព្វ




ផ្ទៃខណ្ឌដោយខ្សែកោងទាំងពីរនៅចន្លោះ $[-4 , 1]$ នោះគេបាន មាឌនៃសូលីតបរិវត្តដែលកំណត់ដោយរង្វិលជុំវិញអ័ក្សអាប់ស៊ីស នៃផ្ទៃក្រឡាខណ្ឌដោយក្រាបនៃអនុគមន៍ $f(x)$ និង $g(x)$ គឺ

$$V = \pi\int_a^b [g(x)]^2 dx - \pi\int_a^b [f(x)]^2 dx$$

$$= \pi\int_a^b (-x+4)^2 dx - \pi\int_a^b (x^2+2x)^2 dx$$

$$= \pi\int_{-4}^1 (x^2-8x+16)dx - \pi\int_{-4}^1 (x^4+4x^3+4x^2)dx$$

$$= \pi\left[\frac{x^3}{3} - 4x^2 + 16x\right]_{-4}^1 - \pi\left[\frac{x^5}{5} + x^4 + \frac{4x^3}{3}\right]_{-4}^1$$

$$= \pi\left[\frac{x^3}{3} - 4x^2 + 16x - \frac{x^5}{5} - x^4 - \frac{4x^3}{3}\right]_{-4}^1$$

$$= \pi\left[-\frac{x^5}{5} - x^4 - x^3 - 4x^2 + 16x\right]_{-4}^1$$

$$= \pi\left[\left(-\frac{1}{5} - 1 - 1 - 4 + 16\right) - \left(\frac{1024}{5} - 256 + 64 - 64 - 64\right)\right]$$

$$= \pi\left[\left(10 - \frac{1}{5}\right) - \left(\frac{1024}{5} - 320\right)\right]$$

$$= \pi\left(330 - \frac{1025}{5}\right) = \pi(330 - 205) = 125\pi$$

ដូចនេះ មាឌសូលីត $\boxed{V = 125\pi}$ ។

**III.** ក. សិក្សាអថេរភាព និងសង់ក្រាប $(C)$ នៃអនុគមន៍ $f(x)$ :

គេមាន $f(x)=\dfrac{x^2-3x+4}{2x-2}$

• ដែនកំណត់ :

អនុគមន៍ $f$ មានន័យលុះត្រាតែ $2x-2\neq 0$ ឬ $x\neq 1$

ដូចនេះ $\boxed{D=\mathbb{R}-\{1\}=(-\infty\,,1)\cup(1\,,+\infty)}$ ។

• ទិសដៅអថេរភាព :

ដេរីវេ
$$f'(x)=\frac{(2x-3)(2x-2)-2(x^2-3x+4)}{(2x-2)^2}$$
$$=\frac{4x^2-4x-6x+6-2x^2+6x-8}{4(x-1)^2}$$
$$=\frac{2x^2-4x-2}{4(x-1)^2}=\frac{x^2-2x-1}{2(x-1)^2}$$

ចំពោះ $\forall x\in D$ ឱ្យ $f'(x)=0$ សមមូល $\dfrac{x^2-2x-1}{2(x-1)^2}=0$

នាំឱ្យ $x^2-2x-1=0$

$x^2-2x+1=2$

$(x-1)^2=2 \quad\Rightarrow\quad x=1\pm\sqrt{2}$

គេបាន
$$f\left(1-\sqrt{2}\right)=\frac{\left(1-\sqrt{2}\right)^2-3\left(1-\sqrt{2}\right)+4}{2\left(1-\sqrt{2}\right)-2}$$
$$=\frac{3-2\sqrt{2}-3+3\sqrt{2}+4}{-2\sqrt{2}}$$
$$=\frac{4+\sqrt{2}}{-2\sqrt{2}}=-\sqrt{2}-\frac{1}{2}$$
$$f\left(1+\sqrt{2}\right)=\frac{\left(1+\sqrt{2}\right)^2-3\left(1+\sqrt{2}\right)+4}{2\left(1+\sqrt{2}\right)-2}$$
$$=\frac{3+2\sqrt{2}-3-3\sqrt{2}+4}{2\sqrt{2}}$$
$$=\frac{4-\sqrt{2}}{2\sqrt{2}}=\sqrt{2}-\frac{1}{2}$$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | $1-\sqrt{2}$ | $1$ | $1+\sqrt{2}$ | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | $+$ | $0$ | $-$ ‖ $-$ | $0$ | $+$ |

• ត្រង់ $x=1-\sqrt{2}$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$ បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើនឹង

$f\left(1-\sqrt{2}\right)=-\sqrt{2}-\dfrac{1}{2}\approx-1.9$ ។

• ត្រង់ $x=1+\sqrt{2}$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$ បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើនឹង

$f\left(1+\sqrt{2}\right)=\sqrt{2}-\dfrac{1}{2}\approx 0.9$ ។

• លីមីត និងអាស៊ីមតូត

$$\lim_{x\to+\infty}f(x)=\lim_{x\to+\infty}\frac{x^2-3x+4}{2x-2}=\lim_{x\to+\infty}\frac{x^2}{2x}=+\infty$$
$$\lim_{x\to-\infty}f(x)=\lim_{x\to-\infty}\frac{x^2-3x+4}{2x-2}=\lim_{x\to-\infty}\frac{x^2}{2x}=-\infty$$
$$\lim_{x\to1^-}f(x)=\lim_{x\to1^-}\frac{x^2-3x+4}{2x-2}=\frac{1-3+4}{2+0^--2}=-\infty$$
$$\lim_{x\to1^+}f(x)=\lim_{x\to1^+}\frac{x^2-3x+4}{2x-2}=\frac{1-3+4}{2+0^+-2}=+\infty$$

ដោយ $\lim\limits_{x\to1}f(x)=\pm\infty$ នោះបន្ទាត់ដែលមានសមីការ $x=1$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ។

ម្យ៉ាងទៀត $f(x)=\dfrac{x^2-3x+4}{2x-2}=\dfrac{1}{2}x-1+\dfrac{2}{2x-2}$

ដោយ $\lim\limits_{x\to\pm\infty}\dfrac{2}{2x-2}=0$ នោះបន្ទាត់ដែលមានសមីការ

$y=\dfrac{1}{2}x-1$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

• តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-\infty$ | $1-\sqrt{2}$ | | $1$ | | $1+\sqrt{2}$ | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ |
| $f(x)$ | $-\infty$ ↗ | $-1.9$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $0.9$ | ↗ $+\infty$ |

➢សង់ខ្សែកោង $(C)$ តាងអនុគមន៍



ខ. ១. សរសេរសមីការនៃបន្ទាត់ $(d)$

សមីការបន្ទាត់ប៉ះរាង $(d): y=f'(x_0)(x-x_0)+f(x_0)$

ដោយ $(d)$ ប៉ះក្រាប $(C)$ ត្រង់ចំណុច $M(x_0\ ,\ y_0)$

គេបាន $f'(x_0)=\dfrac{x_0^2-2x_0-1}{2(x_0-1)^2}$

$$f(x_0)=\frac{x_0^2-3x_0+4}{2x_0-2}$$

នាំឱ្យ

$$y=\frac{x_0^2-2x_0-1}{2(x_0-1)^2}x\underbrace{-\frac{x_0^3-2x_0^2-x_0}{2(x_0-1)^2}+\frac{x_0^2-3x_0+4}{2(x_0-1)}}_{\text{តាង X}}$$

$$\text{X}=\frac{-x_0^3+2x_0^2+x_0+(x_0^2-3x_0+4)(x_0-1)}{2(x_0-1)^2}$$

$$=\frac{-x_0^3+2x_0^2+x_0+x_0^3-3x_0^2+4x_0-x_0^2+3x_0-4}{2(x_0-1)^2}$$

$$=\frac{-2x_0^2+8x_0-4}{2(x_0-1)^2}=\frac{-x_0^2+4x_0-2}{(x_0-1)^2}$$

ដូចនេះ $\boxed{(d): y=\left(\dfrac{x_0^2-2x_0-1}{2(x_0-1)^2}\right)x+\left(\dfrac{-x_0^2+4x_0-2}{(x_0-1)^2}\right)}$

២. រកកូអរដោនេនៃចំណុច $A$ និង $B$

ដោយ $(d)$ កាត់បន្ទាត់អាស៊ីមតូតឈរ $x=1$ ត្រង់ចំណុច $A$ នោះ $x_A=1$ គេបាន $A(1\ ,\ y_A)$

គេបាន $y_A=\left(\dfrac{x_0^2-2x_0-1}{2(x_0-1)^2}\right)\cdot 1+\left(\dfrac{-x_0^2+4x_0-2}{(x_0-1)^2}\right)$

$$y_A=\frac{x_0^2-2x_0-1-2x_0^2+8x_0-4}{2(x_0-1)^2}=\frac{-x_0^2+6x_0-5}{2(x_0-1)^2}$$

$$=\frac{(x_0-1)(-x_0+5)}{2(x_0-1)^2}=\frac{-x_0+5}{2(x_0-1)}$$

ដូចនេះ កូអរដោនេ $\boxed{A\left(1\ ,\ \dfrac{5-x_0}{2(x_0-1)}\right)}$ ។

ដោយ $(d)$ កាត់បន្ទាត់អាស៊ីមតូតទ្រេត $y=\dfrac{1}{2}x-1$ ត្រង់ចំណុច $B$ នោះ $y_B=\dfrac{1}{2}x_B-1$

គេបាន $y_B=\left(\dfrac{x_0^2-2x_0-1}{2(x_0-1)^2}\right)x_B+\left(\dfrac{-x_0^2+4x_0-2}{(x_0-1)^2}\right)$

$$\frac{1}{2}x_B-1=\left(\frac{x_0^2-2x_0-1}{2(x_0-1)^2}\right)x_B+\left(\frac{-x_0^2+4x_0-2}{(x_0-1)^2}\right)$$

$$\left[\frac{1}{2}-\frac{x_0^2-2x_0-1}{2(x_0-1)^2}\right]x_B=\frac{-x_0^2+4x_0-2}{(x_0-1)^2}+1$$

$$\frac{(x_0-1)^2-x_0^2+2x_0+1}{2(x_0-1)^2}x_B=\frac{-x_0^2+4x_0-2+(x_0-1)^2}{(x_0-1)^2}$$

$$\frac{2}{2(x_0-1)^2}x_B=\frac{2x_0-1}{(x_0-1)^2}$$

$$x_B=2x_0-1$$

នាំឱ្យ $y_B=\dfrac{1}{2}x_B-1=\dfrac{1}{2}(2x_0-1)-1=x_0-\dfrac{3}{2}$

ដូចនេះ កូអរដោនេ $\boxed{B\left(2x_0-1\ ,\ x_0-\dfrac{3}{2}\right)}$ ។

➤បង្ហាញថា $M$ ជាចំណុចកណ្ដាលនៃ $[AB]$

ដោយ $\dfrac{x_A+x_B}{2}=\dfrac{1+2x_0-1}{2}=x_0$

$$\frac{y_A+y_B}{2}=\frac{\dfrac{5-x_0}{2(x_0-1)}+x_0-\dfrac{3}{2}}{2}$$

$$=\frac{5-x_0+2x_0(x_0-1)-3(x_0-1)}{4(x_0-1)}$$

$$=\frac{5-x_0+2x_0^2-2x_0-3x_0+3}{4(x_0-1)}$$

$$=\frac{2x_0^2-6x_0+8}{4(x_0-1)}=\frac{x_0^2-3x_0+4}{2x_0-2}=y_0$$

នាំឱ្យ $M(x_0\ ,\ y_0)$ ជាចំណុចកណ្ដាលនៃអង្កត់ $AB$

ដូចនេះ $\boxed{M(x_0\ ,\ y_0)\ \text{ជាចំណុចកណ្ដាលនៃអង្កត់}\ AB}$ ។

**IV.** ក. ចូរសរសេរសមីការស្តង់ដានៃប៉ារ៉ាបូលនេះ :

ដោយ ប៉ារ៉ាបូលមានកំពូល $O(0,0)$ និងមានកំណុំស្ថិតនៅលើអ័ក្សអាប់ស៊ីស $(x'ox)$ នោះវាមានអ័ក្សឆ្លុះជាអ័ក្សអាប់ស៊ីស $(x'ox)$

គេបាន សមីការស្តង់ដា $y^2=4px$

ដោយ ប៉ារ៉ាបូលកាត់តាមចំណុច $A_1(-2,4)$

គេបាន $4^2=4p(-2)$ ឬ $16=-8p$ នាំឱ្យ $p=-2$

ដូចនេះ សមីការស្តង់ដា $\boxed{y^2=-8x}$ ។

**ខ. រកតម្លៃនៃ $y_2$**

ដោយ ចំណុច $A_2\left(-3, y_2\right)$ ស្ថិតនៅលើប៉ារ៉ាបូលនោះ

គេបាន $y_2^2 = -8(-3)$ ឬ $y_2^2 = 24$ នោះ $y_2 = \pm 2\sqrt{6}$

ដូចនេះ គណនាបាន $\boxed{y_2 = \pm 2\sqrt{6}}$ ។

**គ. សរសេរសមីការនៃបន្ទាត់ប្រាប់ទិស $(\Delta)$ របស់ប៉ារ៉ាបូល**

សមីការបន្ទាត់ប្រាប់ទិស $(\Delta)$ របស់ប៉ារ៉ាបូល $(P)$ មានរាង

$(\Delta): x = -p$ នោះ $x = -(-2)$ ឬ $x = 2$

ដូចនេះ សមីការបន្ទាត់ប្រាប់ទិសគឺ $\boxed{(\Delta): x = 2}$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "
## សម័យប្រឡង : ២៣ វិច្ឆិកា ២០១២

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** គេឱ្យ $z$ ជាចំនួនកុំផ្លិច ដែល $z=\left(\sqrt{2}-i\sqrt{2}\right)\left(\cos\frac{\pi}{6}-i\sin\frac{\pi}{6}\right)$ ។

ក. សរសេរ $z$ ជាទម្រង់ពីជគណិត រួច $z^2$ ជាទម្រង់ត្រីកោណមាត្រ ។

ខ. គណនា $\cos\frac{5\pi}{12}$ និង $\sin\frac{5\pi}{12}$ ។

**II.** អនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{x\sin x+x^2}{x^3-\sin^2 x}$ ចំពោះ $x\neq 0$ ហើយមាន $f(0)=\ln\left(\sqrt{a}\right)$ ។

កំណត់តម្លៃនៃ $a$ ដើម្បីឱ្យ $f$ ជាប់ត្រង់ $x=0$ ។

**III.** ក្នុងប្រអប់មួយមានឃ្លីពណ៌ខៀវ 7 គ្រាប់ និងពណ៌ក្រហម 5 គ្រាប់ ។ គេចាប់យកឃ្លី 4 គ្រាប់ដោយចៃដន្យ ។

ក. រកប្រូបាបដែលចាប់បានឃ្លីពណ៌ឃៀវទាំង 4 គ្រាប់ ។

ខ. រកប្រូបាបដែលចាប់បានឃ្លីពណ៌ខៀវ 3 និងឃ្លីពណ៌ក្រហម 1 ។

គ. រកប្រូបាបដែលចាប់បានឃ្លីពណ៌ក្រហមយ៉ាងតិច 1 ។

**IV.** ប្រអប់មួយមានរាងជាប្រលេពីប៉ែតកែងដែលមានវិមាត្រ $x$ , $2x$ និង $h$ គិតជាម៉ែត្រ ហើយមានផ្ទៃក្រឡាទាំងអស់ $1\text{m}^2$ ។

ក. គណនា $h$ ជាអនុគមន៍នៃ $x$ ។

ខ. គណនាមាឌប្រអប់ជាអនុគមន៍នៃ $x$ ។ កំណត់តម្លៃនៃ $x$ ដើម្បីឱ្យប្រអប់មានមាឌធំបំផុត ។

**V.** ក្នុងតម្រុយ $\left(O,\vec{i},\vec{j},\vec{k}\right)$ មាន $A(2,0,1)$, $B(0,1,-3)$ និង $C(1,2,0)$ ។

ក. គណនា $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$ ។

ខ. គណនាផ្ទៃក្រឡាត្រីកោណ $ABC$ ។

**VI.** $f$ ជាអនុគមន៍កំណត់ដោយ $f(x)=x+2+\dfrac{4}{x-1}$ មានក្រាបតំណាង $(C)$ ។

ក. រកដែនកំណត់នៃអនុគមន៍ $f$ ។ គណនា $f'(x)$ និងសិក្សាសញ្ញាដេរីវេ ។ បង្ហាញថា $f$ មានតម្លៃអតិបរមាមួយ និងអប្បបរមាមួយ ហើយគណនាតម្លៃបរមាទាំងនោះ ។

ខ. កំណត់សមីការអាស៊ីមតូតឈរ និងសមីការអាស៊ីតូតទ្រេតនៃក្រាប $(C)$ ។

គ. សិក្សាទីតាំងរវាង អាស៊ីមតូតទ្រេតនៃក្រាប $(C)$

ឃ. សង់តាងអថេរភាពនៃក្រាប $(C)$ ។

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០១២

**I.** **ក. សរសេរ $z$ ជាទម្រង់ពីជគណិត :**

គេមាន $z=\left(\sqrt{2}-i\sqrt{2}\right)\left(\cos\frac{\pi}{6}-i\sin\frac{\pi}{6}\right)$

$$=\left(\sqrt{2}-i\sqrt{2}\right)\left(\frac{\sqrt{3}}{2}-\frac{1}{2}i\right)$$

$$=\frac{\sqrt{6}}{2}-\frac{\sqrt{2}}{2}i-\frac{\sqrt{6}}{2}i+\frac{\sqrt{2}}{2}i^2$$

$$=\frac{\sqrt{6}-\sqrt{2}}{2}-\frac{\sqrt{6}+\sqrt{2}}{2}i$$

ដូចនេះ គណនាបាន $\boxed{z=\frac{\sqrt{6}-\sqrt{2}}{2}-\frac{\sqrt{6}+\sqrt{2}}{2}i}$ ។

**➤សរសេរ $z^2$ ជាទម្រង់ត្រីកោណមាត្រ**

គេមាន $z=\left(\sqrt{2}-i\sqrt{2}\right)\left(\cos\frac{\pi}{6}-i\sin\frac{\pi}{6}\right)$

$$=2\left(\frac{\sqrt{2}}{2}-i\frac{\sqrt{2}}{2}\right)\left[\cos\left(-\frac{\pi}{6}\right)+i\sin\left(-\frac{\pi}{6}\right)\right]$$

$$=2\left[\cos\left(-\frac{\pi}{4}\right)+i\sin\left(-\frac{\pi}{4}\right)\right]\left[\cos\left(-\frac{\pi}{6}\right)+i\sin\left(-\frac{\pi}{6}\right)\right]$$

$$=2\left[\cos\left(-\frac{\pi}{4}-\frac{\pi}{6}\right)+i\sin\left(-\frac{\pi}{4}-\frac{\pi}{6}\right)\right]$$

$$=2\left[\cos\left(-\frac{5\pi}{12}\right)+i\sin\left(-\frac{5\pi}{12}\right)\right]$$

នាំឱ្យ $z^2=4\left[\cos\left(-\frac{5\pi}{6}\right)+i\sin\left(-\frac{5\pi}{6}\right)\right]$

ដូចនេះ $\boxed{z^2=4\left[\cos\left(-\frac{5\pi}{6}\right)+i\sin\left(-\frac{5\pi}{6}\right)\right]}$ ។

**ខ. គណនា $\cos\frac{5\pi}{12}$ និង $\sin\frac{5\pi}{12}$**

គេមាន $z=\frac{\sqrt{6}-\sqrt{2}}{2}-\frac{\sqrt{6}+\sqrt{2}}{2}i$

និង $z=2\left[\cos\left(-\frac{5\pi}{12}\right)+i\sin\left(-\frac{5\pi}{12}\right)\right]$

$$=2\cos\frac{5\pi}{12}-i2\sin\frac{5\pi}{12}$$

គេផ្ទឹមផ្នែកពិត និងផ្នែកពិត រួចផ្នែកនិមិត្ត និងផ្នែកនិមិត្ត

$$\begin{cases}\frac{\sqrt{6}-\sqrt{2}}{2}=2\cos\frac{5\pi}{12}\\ \frac{\sqrt{6}+\sqrt{2}}{2}=2\cos\frac{5\pi}{12}\end{cases}\text{ នោះ: }\begin{cases}\cos\frac{5\pi}{12}=\frac{\sqrt{6}-\sqrt{2}}{4}\\ \cos\frac{5\pi}{12}=\frac{\sqrt{6}+\sqrt{2}}{4}\end{cases}$$

ដូចនេះ: $\boxed{\cos\frac{5\pi}{12}=\frac{\sqrt{6}-\sqrt{2}}{4}\ ,\ \sin\frac{5\pi}{12}=\frac{\sqrt{6}+\sqrt{2}}{4}}$ ។

**II.** **កំណត់តម្លៃនៃ $a$ ដើម្បីឱ្យ $f$ ជាប់ត្រង់ $x=0$ :**

គេមាន $f(x)=\frac{x\sin x+x^2}{x^3-\sin^2 x}$ ចំពោះ: $x\neq 0$

ហើយ $f(0)=\ln\left(\sqrt{a}\right)$

ដើម្បីឱ្យ $f$ ជាប់ត្រង់ $x=0$ លុះត្រាតែ វាផ្ទៀងផ្ទាត់

$$\lim_{x\to 0}f(x)=f(0)$$

$$\lim_{x\to 0}\frac{x\sin x+x^2}{x^3-\sin^2 x}=\ln\sqrt{a}$$

$$\lim_{x\to 0}\frac{\frac{\sin x}{x}+1}{x-\frac{\sin^2 x}{x^2}}=\ln\sqrt{a}$$

$$\frac{1+1}{0-1}=\frac{1}{2}\ln a$$

$$-4=\ln a\qquad\Rightarrow\quad a=e^{-4}=\frac{1}{e^4}$$

ដូចនេះ: កំណត់បាន $\boxed{a=e^{-4}=\frac{1}{e^4}}$ ។

**III.** គេមាន ឃ្លីខៀវ 7 និងក្រហម 5 ហើយគេចាប់យក 4 គ្រាប់

នាំឱ្យ ចំនួនករណីអាច គឺ $n(s)=C(12\ ,5)$ ដែល

$$C(12\ ,4)=\frac{12!}{(12-4)!\cdot 4!}=\frac{12\cdot 11\cdot 10\cdot 9\cdot 8!}{8!\cdot 4!}=495$$

**ក. រកប្រូបាបដែលចាប់បានឃ្លីពណ៌ខៀវទាំង 4 គ្រាប់ :**

ចំនួនករណីស្របតាមដោយ $n(A)=C(7,\ 4)$ ដែល

$$C(7,\ 4)=\frac{7!}{(7-4)!\cdot 3!}=\frac{7\cdot 6\cdot 5\cdot 4!}{3!\cdot 4!}=35$$

នាំឱ្យ $P(A)=\frac{n(A)}{n(S)}=\frac{35}{495}=\frac{7}{99}$

ដូចនេះ: ប្រូបាបចាប់បានឃ្លីខៀវទាំង 4 គឺ $\boxed{P(A)=\frac{35}{99}}$ ។

ខ. រកប្រូបាបដែលចាប់បានឃ្លីពណ៌ខៀវ 3 និងឃ្លីពណ៌ក្រហម1

ចំនួនករណីស្របតាងដោយ $n(B)=C(7,3)\times C(5,1)$

$$C(7,3)\times C(5,1)=\frac{7!}{4!\cdot 3!}\times 5=\frac{7\cdot 6\cdot 5\cdot 4!}{4!\cdot 3!}\times 5=175$$

នាំឱ្យ $P(B)=\frac{175}{495}=\frac{35}{99}$

ដូចនេះ $\boxed{P(B)=\frac{35}{99}}$ ។

គ. រកប្រូបាបដែលចាប់បានឃ្លីពណ៌ក្រហមយ៉ាងតិច 1

តាង $C$ ជាព្រឹត្តិការណ៍ចាប់បានឃ្លីក្រហមយ៉ាងតិច 1

ដោយ $C$ ជាព្រឹត្តិការណ៍បំពេញនឹងព្រឹត្តិការណ៍ $A$

គេបាន $P(C)=1-P(A)=1-\frac{35}{99}=\frac{65}{99}$

ដូចនេះ $\boxed{P(C)=\frac{65}{99}}$ ។

**IV.** ក. គណនា $h$ ជាអនុគមន៍នៃ $x$ :




ផ្ទៃក្រឡាទាំងអស់ តាងដោយ $S_t$ ដែល

$S_t=2(x\cdot 2x+x\cdot h+2x\cdot h)=4x^2+6xh$

តែតាមបម្រាប់ $S_t=1\text{ m}^2$

គេបាន $4x^2+6xh=1$ នាំឱ្យ $h=\frac{1-4x^2}{6x}\ (\text{m})$

ដូចនេះ គណនាបាន $\boxed{h=\frac{1-4x^2}{6x}\ (\text{m})}$ ។

ខ. គណនាមាឌប្រអប់ជាអនុគមន៍នៃ $x$

មាឌប្រអប់ $V=x\cdot 2x\cdot h=2x^2h$

$$V(x)=2x^2\cdot\frac{1-4x^2}{6x}=\frac{1}{3}(x-4x^3)$$

ដូចនេះ $\boxed{V(x)=\frac{1}{3}(x-4x^3)\quad (\text{m}^3)}$ ។

➤កំណត់តម្លៃនៃ $x$ ដើម្បីឱ្យប្រអប់មានមាឌធំបំផុត

គេមាន $V(x)=\frac{1}{3}(x-4x^3)$

នាំឱ្យ $V'(x)=\frac{1}{3}(1-12x^2)$ និង $V'(x)=-8x$

ដើម្បីឱ្យប្រអប់មានមាឌធំបំផុតលុះត្រាតែ $\begin{cases}V'(x)=0\\ V''(x)<0\end{cases}$

ឱ្យ $V'(x)=0 \Leftrightarrow \frac{1}{3}(1-12x^2)=0$ នោះ $x=\pm\frac{1}{2\sqrt{3}}$

ចំពោះ $x=-\frac{1}{2\sqrt{3}}<0$ មិនយក

ចំពោះ $x=\frac{1}{2\sqrt{3}}=\frac{\sqrt{3}}{6}$ : $V''\left(\frac{\sqrt{3}}{6}\right)=-8\cdot\frac{\sqrt{3}}{6}<0$ ពិត

ដូចនេះ តម្លៃនៃ $x$ គណនាបានគឺ $\boxed{x=\frac{\sqrt{3}}{6}\ (\text{m})}$ ។

**V.** ក. គណនា $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$ :

គេមាន $A(2,0,1)$ , $B(0,1,-3)$ និង $C(1,2,0)$

នាំឱ្យ $\overrightarrow{AB}=(-2,1,-4)$ , $\overrightarrow{AC}=(-1,2,-1)$

គេបាន $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ -2 & 1 & -4\\ -1 & 2 & -1\end{vmatrix}=7\vec{i}+2\vec{j}-3\vec{k}$

ដូចនេះ: គណនាបាន $\boxed{\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=7\vec{i}+2\vec{j}-3\vec{k}}$ ។

ខ. គណនាផ្ទៃក្រឡាត្រីកោណ $ABC$

ដោយ $S=\frac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AC}\right|=\frac{1}{2}\sqrt{7^2+2^2+(-3)^2}=\frac{\sqrt{62}}{2}$

ដូចនេះ ផ្ទៃត្រីកោណ $ABC$ គឺ $\boxed{S=\frac{\sqrt{62}}{2}}$ ឯកតាផ្ទៃ ។

**VI.** ក. រកដែនកំណត់នៃអនុគមន៍ $f$ :

គេមាន $f(x)=x+2+\frac{4}{x-1}$ មានក្រាប $(C)$

អនុគមន៍ $f$ មានន័យកាលណា $x-1\neq 0$ នោះ $x\neq 1$

ដូចនេះ $\boxed{D=\mathbb{R}-\{1\}=(-\infty,1)\cup(1,+\infty)}$ ។

➤គណនា $f'(x)$ និងសិក្សាសញ្ញាដេរីវេ

ដោយ $f(x)=x+2+\frac{4}{x-1}$

នាំឱ្យ $f'(x)=1-\frac{4}{(x-1)^2}=\frac{(x-1)^2-4}{(x-1)^2}$

$$f'(x)=\frac{(x-1-2)(x-1+2)}{(x-1)^2}=\frac{(x-3)(x+1)}{(x-1)^2}$$

ដូចនេះ $\boxed{f'(x)=\frac{(x-3)(x+1)}{(x-1)^2}}$ ។

ឱ្យ $f'(x)=0 \Leftrightarrow \dfrac{(x-3)(x+1)}{(x-1)^2}=0$ , $(x-1)^2>0$

នោះ $(x-3)(x+1)=0$ នោះ $x=-1$ , $x=3$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $-1$ | | $1$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |

ដូចនេះ $f'(x)>0$ កាលណា $x\in(-\infty,-1)\cup(3,+\infty)$

$f'(x)=0$ ចំពោះ $x=-1$ , $x=3$

$f'(x)<0$ កាលណា $x\in(-1,1)\cup(1,3)$

➤ **បង្ហាញថា $f$ មានតម្លៃអតិបរមាមួយ និងអប្បបរមាមួយ ហើយគណនាតម្លៃបរមាទាំងនោះ**

• ត្រង់ $x=-1$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$ បញ្ជាក់ថា $f$ មានអតិបរមាមួយស្មើ $f(-1)$ ដែល

$$f(-1)=-1+2+\frac{4}{-1-1}=-1 \text{ ។}$$

• ត្រង់ $x=3$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$ បញ្ជាក់ថា $f$ មានអប្បបរមាមួយស្មើ $f(3)$ ដែល

$$f(3)=3+2+\frac{4}{3-1}=7 \text{ ។}$$

**ខ. កំណត់សមីការអាស៊ីមតូតឈរ និងទ្រេតនៃក្រាប $(C)$**

គេមាន $f(x)=x+2+\dfrac{4}{x-1}$

$$\lim_{x\to1^-} f(x)=\lim_{x\to1^-}\left(x+2+\frac{4}{x-1}\right)=1+2+\frac{4}{0^-}=-\infty$$

$$\lim_{x\to1^+} f(x)=\lim_{x\to1^+}\left(x+2+\frac{4}{x-1}\right)=1+2+\frac{4}{0^+}=+\infty$$

ដោយ $\lim\limits_{x\to1} f(x)=\pm\infty$ នោះបន្ទាត់ដែលមានសមីការ $x=1$ ជាអាស៊ីមតូតឈរ នៃក្រាប $(C)$ ។

ម្យ៉ាងទៀត $\lim\limits_{x\to\pm\infty}\dfrac{4}{x-1}=0$ នោះបន្ទាត់ដែលមានសមីការ $y=x+2$ ជាសមីការអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

**គ. សិក្សាទីតាំងរវាង អាស៊ីមតូតទ្រេតនៃក្រាប $(C)$**

សិក្សាផលដករវាង សមីការ $f(x)$ និងអាស៊ីមតូតទ្រេត $y$

$$f(x)-y=\left(x+2+\frac{4}{x-1}\right)-(x+2)=\frac{4}{x-1}$$

• បើ $x<1$ នោះ $\dfrac{4}{x-1}<0$ មានន័យថា $f(x)-y<0$

គេបានក្រាប $(C)$ នៅពីខាងក្រោមបន្ទាត់អាស៊ីមតូតទ្រេត ។

• បើ $x>1$ នោះ $\dfrac{4}{x-1}>0$ មានន័យថា $f(x)-y>0$

គេបានក្រាប $(C)$ នៅពីខាងលើបន្ទាត់អាស៊ីមតូតទ្រេត ។

**ឃ. សង់តារាងអថេរភាពនៃក្រាប $(C)$**

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\left(x+2+\frac{4}{x-1}\right)=-\infty+2+0=-\infty$$

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\left(x+2+\frac{4}{x-1}\right)=+\infty+2+0=+\infty$$

តារាងអថេរភាពនៃក្រាប $(C)$

| $x$ | $-\infty$ | | $-1$ | | $1$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-1$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $7$ | ↗ | $+\infty$ |

**ចប់ត្រឹមនេះ**

**ខ្ញុំសូមបន្ថែមក្រាបដើម្បីធ្វើការផ្ទៀងផ្ទាត់**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
ឈ្មោះ : ................................
លេខបន្ទប់ : ................................
លេខតុ : ................................
ហត្ថលេខា : ................................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "**
**សម័យប្រឡង : ១៨ វិច្ឆិកា ២០១១**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** គេឱ្យចំនួនកុំផ្លិច $Z=\cos\frac{2\pi}{5}+i\sin\frac{2\pi}{5}$ ។

ក. គណនា $Z^5$ រួចទាញរកតម្លៃនៃ $1+Z+Z^2+Z^3+Z^4$ ។

ខ. សរសេរ $(1+Z)^4$ ជាទម្រង់ត្រីកោណមាត្រ ។

**II.** គេឱ្យសមីការ $(m+1)x^2-2mx+4(m+1)=0$ ។ កំណត់តម្លៃនៃ $m$ ដើម្បីឱ្យសមីការមានឫស $x_1$ និង $x_2$ ផ្ទៀងផ្ទាត់ $x_1<-1<x_2<1$ ។

**III.** រង្វង់មួយ និងការេមួយមានផលបូកប្រវែងបរិមាត្រស្មើនឹង 16 m ។ រកប្រវែងកាំរបស់រង្វង់ និងជ្រុងរបស់ការេ ដើម្បីឱ្យផលបូកផ្ទៃក្រឡារង្វង់ និងផ្ទៃក្រឡាការេមានតម្លៃអប្បបរមា ។

**IV.** គេប្រមៀលប៊ូលដែលមានសរសេរលេខ 1 , 2 , 3 , 4 , 5 , 6 តម្រង់ទៅរន្ធ 6 ដែលមានសរសេរលេខ 1 , 2 , 3 , 4 , 5 , 6 ដែរ ។ គេឧបមាថាប៊ូលទាំង 6 ចូលរន្ធទាំង 6 ខុសៗគ្នាជានិច្ច ។

ក. គណនាប្រូបាបដើម្បីឱ្យប៊ូលលេខ 3 ចូលរន្ធលេខ 3 ។

ខ. គណនាប្រូបាបដើម្បីឱ្យប៊ូលនីមួយៗចូលរន្ធ ដែលមានលេខដូចរបស់វា ។

**V.** ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(1,1,0)$ , $B(0,0,2)$ , $C(1,-2,3)$ និង $D(1,-2,0)$ ។ រកសមីការស្វ៊ែដែលកាត់តាមចំណុច $A$ , $B$ , $C$ និង $D$ ។

**VI.** គេឱ្យអនុគមន៍ $f(x)=ae^x+b$ មានខ្សែកោង $(C)$ ។

ក. កំណត់តម្លៃនៃ $a$ និង $b$ ដើម្បីឱ្យខ្សែកោង $(C)$ កាត់តាមគល់ $O$ នៃតម្រុយអរតូណរមេ និងបន្ទាត់ប៉ះខ្សែកោង $(C)$ ត្រង់ចំណុចនោះជាបន្ទាត់ដែលមានសមីការ $y=x$ ។

ខ. សិក្សាអថេរភាព និងសង់ខ្សែកោងតាងអនុគមន៍ ចំពោះតម្លៃ $a$ និង $b$ ដែលរកឃើញ ។

គ. គណនាផ្ទៃក្រឡាដែលខណ្ឌដោយខ្សែកោង $(C)$ អ័ក្សអាប់ស៊ីស បន្ទាត់ $x=-1$ និង $x=1$ ។

ឃ. រកសមីការបន្ទាត់ប៉ះខ្សែកោង $(C)$ ត្រង់ចំណុច $x=1$ ។

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
# ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ២០១១

**I.** ក. គណនា $Z^5$ :

គេមាន $Z=\cos\frac{2\pi}{5}+i\sin\frac{2\pi}{5}$

តាមដឺម័រ $\left(\cos\theta+i\sin\theta\right)^n=\cos n\theta+i\sin n\theta$

គេបាន
$$Z^5=\left(\cos\frac{2\pi}{5}+i\sin\frac{2\pi}{5}\right)^5$$
$$=\cos\left(5\cdot\frac{2\pi}{5}\right)+i\sin\left(5\cdot\frac{2\pi}{5}\right)$$
$$=\cos 2\pi+i\sin 2\pi$$
$$=\cos 0+i\sin 0$$
$$=1+0i$$

ដូចនេះ គណនាបាន $\boxed{Z^5=1}$ ។

➤ទាញរកតម្លៃនៃ $1+Z+Z^2+Z^3+Z^4$

តាមរូបមន្ត $1-Z^5=(1-Z)\left(1+Z+Z^2+Z^3+Z^4\right)$

គេបាន $(1-Z)\left(1+Z+Z^2+Z^3+Z^4\right)=1-1=0$

ដោយ $1-Z=1-\cos\frac{2\pi}{5}+i\sin\frac{2\pi}{5}\neq 0$

នាំឱ្យ $1+Z+Z^2+Z^3+Z^4=0$

ដូចនេះ $\boxed{1+Z+Z^2+Z^3+Z^4=0}$ ។

ខ. សរសេរ $(1+Z)^4$ ជាទម្រង់ត្រីកោណមាត្រ

គេមាន
$$1+Z=1+\cos\frac{2\pi}{5}+i\sin\frac{2\pi}{5}$$
$$=2\cos^2\frac{\pi}{5}+i2\sin\frac{\pi}{5}\cos\frac{\pi}{5}$$
$$=2\cos\frac{\pi}{5}\left(\cos\frac{\pi}{5}+i\sin\frac{\pi}{5}\right)$$

នាំឱ្យ
$$(1+Z)^4=\left[2\cos\frac{\pi}{5}\left(\cos\frac{\pi}{5}+i\sin\frac{\pi}{5}\right)\right]^4$$
$$=16\cos^4\frac{\pi}{5}\left(\cos\frac{4\pi}{5}+i\sin\frac{4\pi}{5}\right)$$

ដូចនេះ ទម្រង់ត្រីកោណមាត្រសរសេរបានគឺ

$$\boxed{(1+Z)^4=16\cos^4\frac{\pi}{5}\left(\cos\frac{4\pi}{5}+i\sin\frac{4\pi}{5}\right)}$$ ។

**II.** កំណត់តម្លៃនៃ $m$ ដើម្បីឱ្យផ្ទៀងផ្ទាត់ $x_1<-1<x_2<1$

គេមាន សមីការ $(m+1)x^2-2mx+4(m+1)=0$

គេតាង $f_m(x)=(m+1)x^2-2mx+4(m+1)$

ដើម្បីឱ្យ $f_m(x)$ មានឫស $x_1$ និង $x_2$ ផ្ទៀងផ្ទាត់

$x_1<-1<x_2<1$ លុះត្រាតែ ៖

$$\begin{cases}a\neq 0\\ \Delta'>0\\ af(-1)<0\\ af(1)>0\end{cases}$$

$$\begin{cases}m+1\neq 0\\ m^2-(m+1)^2>0\\ (m+1)(m+1+2m+4m+4)<0\\ (m+1)(m+1-2m+4m+4)>0\end{cases}$$

$$\begin{cases}m\neq -1\\ m^2-m^2-2m-1>0\\ (m+1)(7m+5)<0\\ (m+1)(3m+5)>0\end{cases} \text{ នាំឱ្យ } \begin{cases}m\neq -1\\ 2m+1<0\\ (m+1)(7m+5)<0\\ (m+1)(3m+5)>0\end{cases}$$

គេបាន $2m+1$ មានឫស $m=-\frac{1}{2}$

$(m+1)(7m+5)$ មានឫស $m=-1$ , $m=-\frac{5}{7}$

$(m+1)(3m+5)$ មានឫស $m=-1$ , $m=-\frac{5}{3}$

តារាងសញ្ញា 0

| $m$ | $-\infty$ $-\frac{5}{3}$ | $-1$ | $-\frac{5}{7}$ | $-\frac{1}{2}$ | $+\infty$ |
|---|---|---|---|---|---|
| $m+1\neq 0$ | - | - | + | + | + |
| $2m+1<0$ | - | - | - | - 0 | + |
| $(m+1)(7m+5)<0$ | + | + 0 | - 0 | + | + |
| $(m+1)(3m+5)>0$ | + 0 | - 0 | + | + | + |
| ចម្លើយ | | | | | |

ដូចនេះ តម្លៃកំណត់បាន $\boxed{m\in\left(-1,-\frac{5}{7}\right)}$ ។

## III. រកប្រវែងកាំរបស់រង្វង់ និងជ្រុងរបស់ការេ

គេតាង $a$ ជាជ្រុងនៃការេ និង $r$ ជាកាំនៃរង្វង់ , $a, r>0$

គេមាន បរិមាត្ររង្វង់ $+$ បរិមាត្រការេ $=16$

គេបាន $2\pi r+4a=16$ នាំឱ្យ $a=4-\frac{\pi}{2}r$

ផលបូកផ្ទៃក្រឡារង្វង់ និងការេគឺ $S=\pi r^2+a^2$

គេបាន $S(r)=\pi r^2+\left(4-\frac{\pi}{2}r\right)^2$

$$=\pi r^2+16-4\pi r+\frac{\pi^2}{4}r^2$$

$$=\left(\pi+\frac{\pi^2}{4}\right)r^2-4\pi r+16$$

នាំឱ្យ $S'(r)=2\left(\pi+\frac{\pi^2}{4}\right)r-4\pi$

$$S''(r)=2\left(\pi+\frac{\pi^2}{4}\right)$$

ដើម្បីឱ្យ $S$ មានតម្លៃអប្បបរមាលុះត្រាតែ $\begin{cases}S'(r)=0\\ S''(r)>0\end{cases}$

គេបាន $S'(r)=0 \Leftrightarrow 2\left(\pi+\frac{\pi^2}{4}\right)r-4\pi=0$

$$\left(\pi+\frac{\pi^2}{4}\right)r=2\pi$$

$$\frac{4+\pi}{4}r=2 \Rightarrow r=\frac{8}{4+\pi}$$

ហើយ $S''(r)=2\left(\pi+\frac{\pi^2}{4}\right)>0$ ពិត

នាំឱ្យ $a=4-\frac{\pi}{2}\cdot\frac{8}{4+\pi}=4-\frac{4\pi}{4+\pi}=\frac{16}{4+\pi}$

ដូចនេះ $\boxed{r=\frac{8}{4+\pi}\ ,\ a=\frac{16}{4+\pi}}$ ឯកតាប្រវែង ។

## IV. ក. គណនាប្រូបាបដើម្បីឱ្យប៊ូលលេខ 3 ចូលរន្ធលេខ 3

គេមាន រន្ធ 6 ដែលសរសេរលេខ 1 , 2 , 3 , 4 , 5 , 6

នាំឱ្យ ចំនួនករណីអាច $n(S)=6$

ហើយ ប៊ូលទាំងអស់ 1 , 2 , 3 , 4 , 5 , 6 មានប៊ូល លេខ 3 ចំនួន 1 នាំឱ្យ ចំនួនករណីស្រប $n(A)=1$

គេបាន $P(A)=\frac{n(A)}{n(S)}=\frac{1}{6}$

ដូចនេះ ប្រូបាបប៊ូលលេខ 3 ចូលរន្ធលេខ 3 គឺ $\boxed{P(A)=\frac{1}{6}}$

ខ. គណនាប្រូបាបដើម្បីឱ្យប៊ូលនីមួយៗចូលរន្ធ ដែលមានលេខដូចរបស់វា

ដោយ ប៊ូលមាន 6 ចូលរន្ធទាំង 6 ខុសៗគ្នាជានិច្ច

គេបាន ចំនួនករណីអាច $n(S)=P(6\ ,6)$ ដែល

$$P(6\ ,6)=\frac{6!}{(6-6)!}=6!=720$$ របៀប

ហើយ ចំនួនករណីដែលប៊ូលនីមួយៗចូលរន្ធ ដែលមានលេខដូចរបស់វាមានមួយករណី នោះ $n(B)=1$

គេបាន $P(B)=\frac{n(B)}{n(S)}=\frac{1}{720}$

ដូចនេះ ប្រូបាបប៊ូលចូលរន្ធដូចលេខរបស់វា $\boxed{P(B)=\frac{1}{720}}$ ។

## V. រកសមីការស្វ៊ែដែលកាត់តាម 4 ចំណុច : (ដូចគ្រូអនុ. 2006)

គេមាន $A(1\ ,1\ ,0)\ ,\ B(0,\ 2\ ,2)\ ,$

$C(1,-2,\ 3)$ និង $D(1\ ,-2\ ,0)$

សមីការស្វ៊ែរាង $(S):(x-a)^2+(y-b)^2+(z-c)^2=r^2$

$(S)\cap A$ គេបាន $(1-a)^2+(1-b)^2+c^2=r^2$ (1)

$(S)\cap B$ គេបាន $a^2+(2-b)^2+(2-c)^2=r^2$ (2)

$(S)\cap C$ គេបាន $(1-a)^2+(2+b)^2+(3-c)^2=r^2$ (3)

$(S)\cap D$ គេបាន $(1-a)^2+(2+b)^2+c^2=r^2$ (4)

គេយក $(3)-(4)$ គេបាន $(3-c)^2-c^2=0$

$$(3-c-c)(3-c+c)=0 \Rightarrow c=\frac{3}{2}$$

គេយក $(1)-(4)$ គេបាន $(1-b)^2-(2+b)^2=0$

$$(1-b+2+b)(1-b-2-b)=0 \Rightarrow b=-\frac{1}{2}$$

តាម(2) $a^2+\left(2+\frac{1}{2}\right)^2+\left(2-\frac{3}{2}\right)^2=r^2$

$a^2+\frac{25}{4}+\frac{1}{4}=r^2$ នោះ $a^2+\frac{13}{2}=r^2$ (5)

តាម(1) $(1-a)^2+\left(1+\frac{1}{2}\right)^2+\left(\frac{3}{2}\right)^2=r^2$

$1-2a+a^2+\frac{9}{4}+\frac{9}{4}=r^2 \Leftrightarrow -2a+a^2+\frac{11}{2}=r^2$ (6)

យក $(5)-(6)$ $2a+1=0$ នាំឱ្យ $a=-\frac{1}{2}$

តាម (5) $\left(-\frac{1}{2}\right)^2+\frac{13}{2}=r^2$ នាំឱ្យ $r^2=\frac{27}{4}$

ដូចនេះ $\boxed{(S):\left(x+\frac{1}{2}\right)^2+\left(y+\frac{1}{2}\right)^2+\left(z-\frac{3}{2}\right)^2=\frac{27}{4}}$ ។

**VI.** **ក. កំណត់តម្លៃនៃ $a$ និង $b$**

គេមាន $f(x)=ae^x+b$ មានខ្សែកោង $(C)$

$f'(x)=ae^x$

ដោយ ខ្សែកោងកាត់គល់ $O$ និងបន្ទាត់ប៉ះត្រង់ចំណុចនោះ

មានសមីការ $y=x$

គេបាន $\begin{cases} f(0)=0 \\ f'(0)=1 \end{cases} \Leftrightarrow \begin{cases} ae^0+b=0 \\ ae^0=1 \end{cases} \Rightarrow \begin{cases} b=-1 \\ a=1 \end{cases}$

ដូចនេះ កំណត់បាន $\boxed{a=1\,,\,b=-1}$ ។

**ខ. សិក្សាអថេរភាព និងសង់ខ្សែកោងតាងអនុគមន៍**

ចំពោះ $a=1\,,\,b=-1$ គេបាន $f(x)=e^x-1$

• ដែនកំណត់ : ដោយ $f$ មានន័យគ្រប់ $x\in\mathbb{R}$

ដូចនេះ $\boxed{D=\mathbb{R}=(-\infty\,,+\infty)}$

• ទិសដៅអថេរភាព :

ដេរីវេ $f'(x)=ae^x=e^x$

ដោយ $e^x>0\,,\,\forall x\in\mathbb{R}$ នោះ $f$ ជាអនុគមន៍កើន

ដូចនេះ $f$ ជាអនុគមន៍កើនជានិច្ចលើ $\mathbb{R}$ ។

• បរមា : ដោយ $f$ ជាអនុគមន៍កើនជានិច្ចលើ $\mathbb{R}$

នោះ $f$ គ្មានបរមាទេ ។

• លីមីតត្រង់ចុងដែនកំណត់ :

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\left(e^x-1\right)=+\infty-1=+\infty$$

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\left(e^x-1\right)=0-1=-1$$

• អាស៊ីមតូត :

ដោយ $\lim\limits_{x\to-\infty} f(x)=-1$ នោះបន្ទាត់ដែលមានសមីការ

$y=-1$ ជាអាស៊ីមតូតដេកនៃក្រាប $C$ ខាង $-\infty$ ។

• តារាងអថេរភាព :

| $x$ | $-\infty$ $\qquad$ $+\infty$ |
|---|---|
| $f'(x)$ | $+$ |
| $f(x)$ | $-1$ ↗ $-\infty$ |

• សង់ក្រាប :




**គ. គណនាផ្ទៃក្រឡាដែលខណ្ឌដោយខ្សែកោង $(C)$ អ័ក្សអាប់ស៊ីស បន្ទាត់ $x=-1$ និង $x=1$**

តាមក្រាបនៅចន្លោះ $-1\le x\le 1$ មានផ្ទៃក្រឡាពីរផ្នែកគឺ

• ចន្លោះ $-1\le x\le 0$ ក្រាប $C$ នៅខាងក្រោមអ័ក្សអាប់ស៊ីស

• ចន្លោះ $0\le x\le 1$ ក្រាប $C$ នៅខាងលើអ័ក្សអាប់ស៊ីស

គេបាន $S=-\int_{-1}^{0} f(x)\,dx+\int_{0}^{1} f(x)\,dx$

$=-\int_{-1}^{0}\left(e^x-1\right)dx+\int_{0}^{1}\left(e^x-1\right)dx$

$=-\left[e^x-x\right]_{-1}^{0}+\left[e^x-x\right]_{0}^{1}$

$=-\left[\left(e^0-0\right)-\left(e^{-1}+1\right)\right]+\left[\left(e^1-1\right)-\left(e^0-0\right)\right]$

$=-\left[1-\dfrac{1}{e}-1\right]+\left[e-1-1\right]$

$=\dfrac{1}{e}+e-2$

ដូចនេះ $\boxed{S=\dfrac{1}{e}+e-2}$ ឯកតាផ្ទៃក្រឡា ។

**ឃ. រកសមីការបន្ទាត់ប៉ះខ្សែកោង $(C)$ ត្រង់ចំណុច $x=1$**

បន្ទាត់ប៉ះមានរាង $T:y=f'(x_0)(x-x_0)+f(x_0)$

ដោយ បន្ទាត់ $T$ ប៉ះក្រាប $C$ ត្រង់ $x=1$ នោះ $x_0=1$

$f'(x_0)=f'(1)=e^1=e$

$f(x_0)=f(1)=e^1-1=e-1$

នាំឱ្យ $T:y=e(x-1)+(e-1)$

$y=ex-e+e-1=ex-1$

ដូចនេះ សមីការបន្ទាត់ប៉ះ $\boxed{T:y=ex-1}$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : .................................
លេខបន្ទប់ : .................................
លេខតុ : .................................
ហត្ថលេខា : .................................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមធ្យមសិក្សា " ១២ + ២ "**
**សម័យប្រឡង : ១២ វិច្ឆិកា ២០១០**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. គេឱ្យអនុគមន៍ $y=x\cos x$ ។ ស្រាយបញ្ជាក់ថា $y''+y+2\sin x=0$ ។

ខ. ដោះស្រាយសមីការ $4\cos^2 x-1=3\cos x-2\sin^2 x$ ។ **(១ពិន្ទុកន្លះ)**

**II.** ប្រអប់មួយមានរាងជាប្រលេពីប៉ែតកែង ដែលមានប្រវែងទ្រនុងទាំងបីគឺ $x\,,\,y\,,\,x+y$ (គិតជា cm) ។ គេដឹងថាទ្រនុងដែលវែងជាងគេមានប្រវែង $20\,\text{cm}$ ។ កំណត់តម្លៃ $x$ និង $y$ ដើម្បីឱ្យប្រអប់នេះមានមាឌធំបំផុត ។ **(១ពិន្ទុ)**

**III.** គណនាអាំងតេក្រាល $I=\int\left(\frac{2010}{\sqrt{x}}-\frac{2011e^x}{2+e^x}\right)dx$ និង $J=\int_{\frac{\pi}{6}}^{\frac{\pi}{4}}(\tan x+\cot x)^2\,dx$ ។ **(១ពិន្ទុ)**

**IV.** គេមានលេខ $0\,,1\,,2\,,3\,,4$ ។ គេយកលេខទាំងនេះទៅបង្កើតចំនួនដែលធំជាង $2000$ និងក្នុងចំនួននីមួយៗគ្មានលេខដដែលពីរដងទេ ។ តើគេអាចបង្កើតចំនួនធំជាង $2000$ បានប៉ុន្មាន ? **(២ពិន្ទុ)**

**V.** ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $\left(O\,,\vec{i}\,,\vec{j}\,,\vec{k}\right)$ នៃលំហ គេឱ្យចំណុច $A(1\,,1\,,1)$ និង $B(2\,,2\,,0)$ ។

ក. សរសេរសមីការប្លង់ $(P)$ កាត់តាមចំណុច $A$ និងមានវ៉ិចទ័រណរម៉ាល់ $\overrightarrow{OA}$ ។

ខ. បន្ទាត់ $(D)$ កាត់តាមចំណុច $B$ ហើយស្របនឹងវ៉ិចទ័រ $\overrightarrow{OA}$ ។ រកកូអរដោនេនៃ $H$ ជាចំណុចប្រសព្វរវាងប្លង់ $(P)$ និងបន្ទាត់ $(D)$ រួចរកចម្ងាយពីចំណុច $A$ ទៅបន្ទាត់ $(D)$ ។ **(២ពិន្ទុ)**

**VI.** គេឱ្យអនុគមន៍ $f(x)=e^x$ និង $g(x)=\ln(x+1)+1$ ។

ក. ផ្ទៀងផ្ទាត់ថា ខ្សែកោង $(C_1)$ តាង $y=f(x)$ និង $(C_2)$ តាង $y=g(x)$ មានចំណុចរួម $A(0\,,1)$ ។

ខ. គណនា $f'(0)$ និង $g'(0)$ រួចបង្ហាញថាខ្សែកោង $(C_1)$ និង $(C_2)$ ប៉ះគ្នាត្រង់ $A$ ។

គ. សរសេរសមីការបន្ទាត់ប៉ះរួមរវាងខ្សែកោង $(C_1)$ និង $(C_2)$ ។ **(២ពិន្ទុកន្លះ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០១០

**I.** ក. ស្រាយបញ្ជាក់ថា $y''+y+2\sin x=0$ :

គេមាន $y=x\cos x$

នាំឱ្យ $y'=x'\cos x+(\cos x)'x=\cos x-x\sin x$

$$y''=(\cos x)'-\left[x'\sin x+x(\sin x)'\right]$$

$$=-\sin x-(\sin x+x\cos x)$$

$$=-2\sin x-x\cos x$$

គេបាន $y''+y+2\sin x$

$$=(-2\sin x-x\cos x)+x\cos x+2\sin x=0$$

ដូចនេះ $\boxed{y''+y+2\sin x=0 \text{ ត្រូវបានបង្ហាញ}}$ ។

ខ. ដោះស្រាយសមីការ

គេបាន $4\cos^2 x-1=3\cos x-2\sin^2 x$

$$4\cos^2 x-1=3\cos x-2(1-\cos^2 x)$$

$$2\cos^2 x-3\cos x+1=0$$

សមីការមានមានគុណ $a+b+c=0$ នោះសមីការមានឫស

$$\left[\begin{array}{l}\cos x=1\\ \cos x=\frac{1}{2}\end{array}\right.\Rightarrow\left[\begin{array}{l}\cos x=\cos 0\\ \cos x=\cos\frac{\pi}{3}\end{array}\right.$$

នាំឱ្យ $\left[\begin{array}{l}x=2k\pi\ ,\ k\in\mathbb{Z}\\ x=\pm\frac{\pi}{3}+2k'\pi\ ,\ k'\in\mathbb{Z}\end{array}\right.$

ដូចនេះ សមីការមានឫស $\boxed{\left[\begin{array}{l}x=2k\pi\ ,\ k\in\mathbb{Z}\\ x=\pm\frac{\pi}{3}+2k'\pi\ ,\ k'\in\mathbb{Z}\end{array}\right.}$ ។

**II.** កំណត់តម្លៃ $x$ និង $y$ ដើម្បីឱ្យប្រអប់នេះមានមាឌធំបំផុត :

គេមាន $x+y=20$

នាំឱ្យ $y=20-x$




រូបមន្តមាឌប្រអប់រាងជាប្រលេពីប៉ែតកែងគឺ ៖

$$V=xy(x+y)=20xy$$

$$V(x)=20x(20-x)=400x-20x^2$$

$$V'(x)=400-40x$$

$$V''(x)=-40$$

ដើម្បីឱ្យប្រអប់មានមាឌអតិបរមាលុះត្រាតែ $\begin{cases}V'(x)=0\\ V''(x)<0\end{cases}$

គេបាន $V'(x)=0 \Leftrightarrow 400-40x=0 \Rightarrow x=10$

$V''(x)=-40<0$ ពិត

ចំពោះ $x=10$ នោះ $y=20-x=20-10=10$

ដូចនេះ $\boxed{x=y=10\text{ cm}}$ ។

**III.** គណនាអាំងតេក្រាល :

$$\mathbf{I}=\int\left(\frac{2010}{\sqrt{x}}-\frac{2011e^x}{2+e^x}\right)dx$$

$$=\int\left(2010x^{-\frac{1}{2}}-2011\frac{(2+e^x)'}{2+e^x}\right)dx$$

$$=2010\cdot\frac{x^{-\frac{1}{2}+1}}{-\frac{1}{2}+1}-2011\ln(2+e^x)+c\ ,\ c \text{ ថេរ}$$

$$=\boxed{4020\sqrt{x}-2011\ln(2+e^x)+c\ ,\ c \text{ ថេរ}}$$

$$\mathbf{J}=\int_{\frac{\pi}{6}}^{\frac{\pi}{4}}(\tan x+\cot x)^2\,dx$$

$$=\int_{\frac{\pi}{6}}^{\frac{\pi}{4}}(\tan^2 x+2\tan x\cot x+\cot^2 x)dx$$

$$=\int_{\frac{\pi}{6}}^{\frac{\pi}{4}}(1+\tan^2 x+1+\cot^2 x)dx=\left[\tan x-\text{cot}x\right]_{\frac{\pi}{6}}^{\frac{\pi}{4}}$$

$$=\left[\tan\frac{\pi}{4}-\cot\frac{\pi}{4}\right]-\left[\tan\frac{\pi}{6}-\cot\frac{\pi}{6}\right]$$

$$=(1-1)-\left(\frac{\sqrt{3}}{3}-\sqrt{3}\right)=\boxed{\frac{2\sqrt{3}}{3}}$$

**IV.** រកចំនួនដែលបង្កើតបានធំជាង 2000 : (ដូចគ្រូមធ្យម២០០៥)

ដោយលេខតាមខ្ទង់ដែលត្រូវប្រើមាន៥លេខ 0 , 1 , 2 , 3 , 4

នោះចំនួនដែលធំជាង 2000 អាចជាលេខ 4 ខ្ទង់ ឬ 5 ខ្ទង់

• ចំពោះលេខ 4 ខ្ទង់ដែលធំជាង 2000 គឺ

ខ្ទង់ពាន់ មាន 3 ជម្រើស

ខ្ទង់រយ មាន 4 ជម្រើស

ខ្ទង់ដប់ មាន 3 ជម្រើស

ខ្ទង់រាយ មាន 2 ជម្រើស

តាមគោលការណ៍ផលគុណ $3\times4\times3\times2=72$ ចំនួន

• ចំពោះលេខ 5 ខ្ទង់ដែលធំជាង 2000 គឺ

ខ្ទង់ម៉ឺន មាន 4 ជម្រើស

ខ្ទង់ពាន់ មាន 4 ជម្រើស

ខ្ទង់រយ មាន 3 ជម្រើស

ខ្ទង់ដប់ មាន 2 ជម្រើស

ខ្ទង់រាយ មាន 1 ជម្រើស

តាមគោលការណ៍ផលគុណ $4\times4\times3\times2\times1=96$ ចំនួន

សរុបចំនួនដែលធំជាង $2000=72+96=168$ ចំនួន

ដូចនេះ **ចំនួនដែលអាចបង្កើតបានមាន 168 ចំនួន** ។

**V.** **ក. សរសេរសមីការប្លង់ $(P)$ :**

ប្លង់រាង $(P): a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយ $(P)$ កាត់តាមចំណុច $A(1,1,1)$

នោះ $x_0=1,\ y_0=1,\ z_0=1$

ហើយ $(P)$ មានវ៉ិចទ័រណរម៉ាល់ $\overrightarrow{OA}=(1,1,1)$

នោះ $a=1,b=1,c=1$

នាំឱ្យ $(P):(x-1)+(y-1)+(z-1)=0$

$(P): x+y+z-3=0$

ដូចនេះ សមីការប្លង់ $\boxed{(P): x+y+z-3=0}$ ។

**ខ. រកកូអរដោនេនៃ $H$ ជាប្រសព្វរវាងប្លង់ $(P)$ និងបន្ទាត់ $(D)$**

បន្ទាត់រាង $(D):\begin{cases}x=x_0+at\\ y=y_0+bt,\ t\in\mathbb{R}\\ z=z_0+ct\end{cases}$

ដោយ $(D)$ កាត់តាមចំណុច $B(2,2,0)$

នោះ $x_0=2,\ y_0=2,\ z_0=0$

ហើយ $(D)$ មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{OA}=(1,1,1)$

នោះ $a=1,b=1,c=1$

នាំឱ្យ $(D):\begin{cases}x=2+t\\ y=2+t,\ t\in\mathbb{R}\\ z=t\end{cases}$

គេមាន $(P): x+y+z-3=0$

គេបាន $(2+t)+(2+t)+t-3=0$ នោះ $t=-\frac{1}{3}$

នាំឱ្យ $H:\left(x=y=2-\frac{1}{3}=\frac{5}{3}\ ,\ z=-\frac{1}{3}\right)$

ដូចនេះ ចំណុចប្រសព្វ $\boxed{H\left(\frac{5}{3},\frac{5}{3},-\frac{1}{3}\right)}$ ។

**រួចរកចម្ងាយពីចំណុច $A$ ទៅបន្ទាត់ $(D)$**

រូបមន្ត $d(A,(D))=\dfrac{\left|\overrightarrow{AB}\times\overrightarrow{OA}\right|}{\left|\overrightarrow{OA}\right|}$

គេមាន $\overrightarrow{AB}=(1,1-1)$ និង $\overrightarrow{OA}=(1,1,1)$

ដោយ $\overrightarrow{AB}\times\overrightarrow{OA}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\1&1&-1\\1&1&1\end{vmatrix}=2\vec{i}-2\vec{j}+0\vec{k}$

នាំឱ្យ $d(A,(D))=\dfrac{\sqrt{2^2+2^2+0^2}}{\sqrt{1^2+1^2+1^2}}=\dfrac{2\sqrt{2}}{\sqrt{3}}=\dfrac{2\sqrt{6}}{3}$

ដូចនេះ $\boxed{d(A,(D))=\dfrac{2\sqrt{6}}{3}}$ ឯកតាប្រវែង ។

**VI.** **ក. ផ្ទៀងផ្ទាត់ថា $(C_1)$ និង $(C_2)$ មានចំណុចរួម $A(0,1)$ :**

គេមាន $(C_1): f(x)=e^x$

$(C_2): g(x)=\ln(x+1)+1$

ចំពោះ $A(0,1)$ គេបាន $(C_1): 1=e^0$ ពិត

នោះខ្សែកោង $(C_1)$ កាត់ចំណុច $A(0,1)$

ចំពោះ $A(0,1)$ គេបាន $(C_2): 1=\ln(0+1)+1$ ពិត

នោះខ្សែកោង $(C_2)$ កាត់ចំណុច $A(0,1)$

ដូចនេះ **$(C_1)$ និង $(C_2)$ មានចំណុចរួម $A(0,1)$** ។

**ខ. គណនា $f'(0)$ និង $g'(0)$**

គេមាន $f(x)=e^x$ នោះ $f'(x)=e^x$

នាំឱ្យ $f'(0)=e^0=1$

ហើយ $g(x)=\ln(x+1)+1$

នោះ $g'(x)=\dfrac{(x+1)'}{(x+1)}=\dfrac{1}{x+1}$

នាំឱ្យ $g'(0)=\dfrac{1}{0+1}=1$

ដូចនេះ គណនាបាន $\boxed{f'(0)=1\ ,\ g'(0)=1}$ ។

**បង្ហាញថាខ្សែកោង $(C_1)$ និង $(C_2)$ ប៉ះគ្នាត្រង់ $A$**

ដោយ បន្ទាត់ប៉ះនៃខ្សែកោង $(C_1)$ និង $(C_2)$ ត្រង់ចំណុច $A(0,1)$ មានតម្លៃស្មើគ្នាគឺ $f'(0)=g'(0)=1$

នាំឱ្យ ខ្សែកោង $(C_1)$ និង $(C_2)$ មានបន្ទាត់ប៉ះរួមត្រង់ $A$

ដូចនេះ **ខ្សែកោង $(C_1)$ និង $(C_2)$ ប៉ះគ្នាត្រង់ $A$** ។

**គ. សរសេរសមីការបន្ទាត់ប៉ះរួមរវាងខ្សែកោង $(C_1)$ និង $(C_2)$**

សមីការបន្ទាត់ប៉ះរាង $(T): y = f'(x_0)(x - x_0) + f(x_0)$

ដោយ $(T)$ កាត់តាមចំណុច $A(0\,,1)$

នោះ $x_0 = 0$ , $f(x_0) = 1$

ហើយ $(T)$ មានមេគុណប្រាប់ទិស $f'(x_0) = f'(0) = 1$

គេបាន $(T): y = 1(x - 0) + 1$

ដូចនេះ បន្ទាត់ប៉ះរួមនៃខ្សែកោង $(C_1)$ និង $(C_2)$ ត្រង់ $A$ គឺ

$\boxed{(T): y = x + 1}$ ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "**

**សម័យប្រឡង : ១៣ វិច្ឆិកា ២០០៩**

**វិញ្ញាសា : គណិតវិទ្យា  រយៈពេល : ១២០ នាទី  ពិន្ទុ : ១០**

**I.** ក. គណនាចំនួនកុំផ្លិច $z=\left(\frac{1+i}{\sqrt{2}}\right)^{2002}+\left(\frac{1+i}{1-i}\right)^{2001}$ ។

ខ. កំណត់តម្លៃ $m$ ដើម្បីឱ្យវិសមីការ $\frac{x^2-8x+20}{mx^2+2(m+1)x+9m+4}<0$ ចំពោះគ្រប់ $x$ ជារបស់ $\mathbb{R}$ ។ **(១ពិន្ទុកន្លះ)**

**II.** ចូរសង់ក្រាបនៃអនុគមន៍ $f(x)=|x|$ រួចស្រាយបញ្ជាក់ថាអនុគមន៍ $f$ ជាអនុគមន៍ជាប់ត្រង់ចំណុច $x=0$ និងគ្មានដេរីវេត្រង់ចំណុច $x=0$ ។ **(១ពិន្ទុកន្លះ)**

**III.** គេឱ្យអនុគមន៍ $f(x)=\frac{\sin x}{\cos x+\sin x}$ ។ កំណត់តម្លៃនៃ $a$ និង $b$ ដើម្បីឱ្យអនុគមន៍ $f(x)=a+b\left(\frac{\cos x-\sin x}{\cos x+\sin x}\right)$ រួចគណនា $I=\int_0^{\frac{\pi}{2}} f(x)dx$ ។ **(១ពិន្ទុកន្លះ)**

**IV.** គេចង់បង្កើតគណៈកម្មការមួយដែលមានសមាជិក 5 នាក់ ក្នុងចំណោមមនុស្សទាំងអស់ 15 នាក់ ។ ក្នុងចំណោមមនុស្ស ទាំងនេះមានពីរនាក់ $A$ និង $B$ ដែលអាចចូលជាសមាជិកគណៈកម្មការបាន លុះត្រាតែចូលទាំងពីរនាក់ ។ តើគេអាចបង្កើតគណៈកម្មការបានប៉ុន្មានរបៀប ? **(១ពិន្ទុ)**

**V.** ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(O,\vec{i},\vec{j},\vec{k})$ គេឱ្យប្លង់ $(P)$ មួយដែលកាត់តាមចំណុច $A(1,0,0)$ , $B(0,2,0)$ និង $C(0,0,3)$ ។

ក. គណនាចម្ងាយ $|OI|$ ពីគល់ $O$ មកប្លង់ $(P)$ ។

ខ. ផ្ទៀងផ្ទាត់ទំនាក់ទំនង $\frac{1}{|OI|^2}=\frac{1}{|OA|^2}+\frac{1}{|OB|^2}+\frac{1}{|OC|^2}$ ។ **(១ពិន្ទុកន្លះ)**

**VI.** ឱ្យអនុគមន៍មួយកំណត់ដោយ $f(x)=\frac{x^2-2x+1}{2x-4}$ មានខ្សែកោង $(C)$ ។

ក. សិក្សាអថេរភាព និងសង់ខ្សែកោងនៃអនុគមន៍ $f$ រួចស្រាយបញ្ជាក់ថា ខ្សែកោងនេះមានផ្ចិតឆ្លុះមួយ ។

ខ. កំណត់សមីការបន្ទាត់ប៉ះនៃខ្សែកោង $(C)$ ដោយដឹងថាបន្ទាត់ប៉ះនេះកាត់តាមចំណុច $A(0,2)$ ។

គ. គណនាផ្ទៃក្រឡា $S$ នៃផ្នែកប្លង់ដែលខណ្ឌដោយខ្សែកោង $(C)$ អាស៊ីមតូតទ្រេត និងបន្ទាត់ $x=3$ , $x=4$ ។ **(៣ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ២០០៩

**I.** ក. គណនាចំនួនកុំផ្លិច $z$ :

គេមាន $z=\left(\frac{1+i}{\sqrt{2}}\right)^{2002}+\left(\frac{1+i}{1-i}\right)^{2001}$

$$=\left[\left(\frac{1+i}{\sqrt{2}}\right)^{2}\right]^{1001}+\left(\frac{1+i}{1-i}\right)^{2001}$$

$$=\left(\frac{1+2i+i^2}{2}\right)^{1001}+\left(\frac{1+2i+i^2}{1-i^2}\right)^{2001}$$

$$=i^{1001}+i^{2001}=i^{1000}\cdot i+i^{2000}\cdot i=i+i=2i$$

ដូចនេះ គណនាបាន $\boxed{z=2i}$ ។

ខ. កំណត់តម្លៃ $m$ ដើម្បីឱ្យវិសមីការ ពិតគ្រប់ $x$ ជារបស់ $\mathbb{R}$

គេមាន $\dfrac{x^2-8x+20}{mx^2+2(m+1)x+9m+4}<0 \quad (E)$

ដោយ $x^2-8x+20$ មាន $\begin{cases} a=1>0 \\ \Delta'=(-4)^2-20=-4<0 \end{cases}$

នោះ $x^2-8x+20>0\ ,\ \forall x\in\mathbb{R}$

ហេតុនេះ ដើម្បីឱ្យ $(E)$ ផ្ទៀងផ្ទាត់លុះត្រាតែវាមានភាគបែង

$$mx^2+2(m+1)x+9m+4<0$$

គេបាន $\begin{cases} m<0 & (1) \\ \Delta'=(m+1)^2-m(9m+4)<0 & (2) \end{cases}$

តាម$(2)$ $m^2+2m+1-9m^2-4m<0$

$$-8m^2-2m+1<0$$

គេឱ្យ $-8m^2-2m+1=0$ មានឫស $x=-\frac{1}{2}\ ,\ x=\frac{1}{4}$

តារាងសញ្ញា

| $x$ | $0$ $\quad -\frac{1}{2}$ $\quad\quad \frac{1}{4}$ $\quad +\infty$ |
|---|---|
| $-8m^2-2m+1<0$ | $-$ $\quad 0 \quad$ $+$ $\quad 0 \quad$ $-$ |

តាមតារាង $m\in\left(-\infty\ ,-\frac{1}{2}\right)\cup\left(\frac{1}{4}\ ,+\infty\right) \quad (3)$

យក $(1)\cap(3)$ គេបានចម្លើយ $m\in\left(-\infty\ ,-\frac{1}{2}\right)$

ដូចនេះ តម្លៃនៃកំណត់បានគឺ $\boxed{m<-\frac{1}{2}}$ ។

**II.** សង់ក្រាបនៃអនុគមន៍ $f(x)=|x|$ : (ដូចគ្រូបឋម២០០៥)

• ចំពោះ $x\geq 0$ : $|x|=x$ នោះ $y=f(x)=x$

• ចំពោះ $x<0$ : $|x|=-x$ នោះ $y=f(x)=-x$

គេសង់ក្រាបបាន តាមករណីនីមួយៗដូចខាងក្រោម ៖




➤ស្រាយថាអនុគមន៍ $f(x)$ ជាអនុគមន៍ជាប់ត្រង់ $x=0$

គេមាន $f(x)=|x|=\begin{cases} x & \text{បើ } x\geq 0 \\ -x & \text{បើ } x<0 \end{cases}$

គេបាន $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+} x=0$

$\lim\limits_{x\to 0^-} f(x)=\lim\limits_{x\to 0^+}(-x)=0$

$f(0)=0$

ដោយ $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^-} f(x)=f(0)=0$

ដូចនេះ $\boxed{f \text{ ជាអនុគមន៍ជាប់ត្រង់ } x=0}$ ។

➤ស្រាយថាអនុគមន៍ $f(x)$ គ្មានដេរីវេត្រង់ចំណុច $x=0$

បើ $f$ មានដេរីវេត្រង់ $x=0$ លុះត្រាតែ $f'_-(0)=f'_+(0)$

តាមនិយមន័យដេរីវេ $f'(x_0)=\lim\limits_{x\to x_0}\dfrac{f(x)-f(x_0)}{x-x_0}$

គេបាន $f'_-(0)=\lim\limits_{x\to 0^-}\dfrac{-x-0}{x-0}=-1$

និង $f'_+(0)=\lim\limits_{x\to 0^+}\dfrac{x-0}{x-0}=1$

ដោយ $f'_-(0)\neq f'_+(0)$ នោះ $f$ គ្មានដេរីវេត្រង់ $x=0$ ទេ

ដូចនេះ $\boxed{f \text{ គ្មានដេរីវេត្រង់ } x=0 \text{ ទេ}}$ ។

**III.** កំណត់តម្លៃនៃ $a$ និង $b$ :

គេមាន $f(x)=a+b\left(\dfrac{\cos x-\sin x}{\cos x+\sin x}\right)$

$=\dfrac{a\cos x+a\sin x+b\cos x-b\sin x}{\cos x+\sin x}$

$=\dfrac{(a+b)\cos x+(a-b)\sin x}{\cos x+\sin x}$

ដោយ $f(x)=\dfrac{\sin x}{\cos x+\sin x}$

ផ្ទឹមបាន $\begin{cases}a+b=0\\ a-b=1\end{cases}\Rightarrow a=\dfrac{1}{2}\ ,\ b=-\dfrac{1}{2}$

ដូចនេះ កំណត់បាន $\boxed{a=\dfrac{1}{2}\ ,\ b=-\dfrac{1}{2}}$ ។

➤គណនាអាំងតេក្រាល $I=\int_0^{\frac{\pi}{2}} f(x)dx$

ចំពោះ $a=\dfrac{1}{2}, b=-\dfrac{1}{2}$ នោះ $f(x)=\dfrac{1}{2}-\dfrac{1}{2}\left(\dfrac{\cos x-\sin x}{\cos x+\sin x}\right)$

គេបាន $\mathbf{I}=\int_0^{\frac{\pi}{2}}\left[\dfrac{1}{2}-\dfrac{1}{2}\left(\dfrac{\cos x-\sin x}{\cos x+\sin x}\right)\right]dx$

$=\int_0^{\frac{\pi}{2}}\left[\dfrac{1}{2}-\dfrac{1}{2}\cdot\dfrac{(\cos x+\sin x)'}{\cos x+\sin x}\right]dx$

$=\left[\dfrac{1}{2}x-\dfrac{1}{2}\ln|\cos x+\sin x|\right]_0^{\frac{\pi}{2}}$

$=\left(\dfrac{\pi}{4}-\dfrac{1}{2}\ln 1\right)-\left(0-\dfrac{1}{2}\ln 1\right)=\dfrac{\pi}{4}$

ដូចនេះ គណនាបាន $\boxed{\mathbf{I}=\dfrac{\pi}{4}}$ ។

**IV.** រកចំនួនរបៀបនៃគណកម្មការដែលគេអាចបង្កើតបាន :

គេជ្រើសរើស 5 នាក់ ពីមនុស្សទាំងអស់ 15 នាក់ ដែល ពីរនាក់ $A$ និង $B$ ចូលទាំងពីរនាក់ នោះគេបាន ចំនួនគណកម្មការបង្កើតបានអាចជា ៖

- ជ្រើសរើស 5 នាក់ពីមនុស្ស 13 នាក់ មិនមែន $A,B$ ឬក៏
- ជ្រើសរើស 3 នាក់ពីមនុស្ស 13 នាក់ និង 2 នាក់ទៀតគឺជា $A$ និង $B$ នោះគេបានចំនួនរបៀបទាំងអស់ស្មើនឹង

$C(13,5)+C(13,3)\cdot C(2,2)$

$=\dfrac{13!}{8!\cdot 5!}+\dfrac{13!}{10!\cdot 3!}\cdot 1=1287+286=1573$

ដូចនេះ $\boxed{\text{ចំនួនគណកម្មការអាចបង្កើតបានគឺ 1573 របៀប}}$ ។

**V.** ក. គណនាចម្ងាយ $|OI|$ ពីគល់ $O$ មកប្លង់ $(P)$ :

គេមាន $A(1,0,0)$ , $B(0,2,0)$ និង $C(0,0,3)$

ដោយ ប្លង់ $(P)$ កាត់ $A,B,C$ នោះ $(P)$ មានវ៉ិចទ័រ ណរម៉ាល់ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$ ដែល

$\overrightarrow{AB}=(-1,2,0)$ , $\overrightarrow{AC}=(-1,0,3)$

នាំឱ្យ $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\-1&2&0\\-1&0&3\end{vmatrix}=6\vec{i}+3\vec{j}+2\vec{k}$

នោះ $a=6, b=3, c=2$

ហើយ ប្លង់ $(P)$ កាត់ $A(1,0,0)$

$x_0=1, y_0=0, z_0=0$

ប្លង់ $(P)$ រាង $a(x-x_0)+b(y-y_0)+c(z-z_0)=0$

គេបាន $(P):6(x-1)+3(y-0)+2(z-0)=0$

$(P):6x+3y+2z-6=0$

នោះ $a=6, b=3, c=2, d=-6$

តាមរូបមន្ត $|OI|=d(O,(P))=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$

ដោយ $O(0,0,0)$ នោះ $x_0=y_0=z_0=0$

គេបាន $|OI|=d(O,(P))=\dfrac{|-6|}{\sqrt{6^2+3^2+2^2}}=\dfrac{6}{7}$

ដូចនេះ $\boxed{|OI|=\dfrac{6}{7}}$ ឯកតាប្រវែង ។

ខ. ផ្ទៀងផ្ទាត់ទំនាក់ទំនង $\dfrac{1}{|OI|^2}=\dfrac{1}{|OA|^2}+\dfrac{1}{|OB|^2}+\dfrac{1}{|OC|^2}$

គេមាន $\overrightarrow{OA}=(1,0,0)$ , $\overrightarrow{OB}=(0,2,0)$ និង $\overrightarrow{OC}=(0,0,3)$

នាំឱ្យ $|OA|^2=\left|\overrightarrow{OA}\right|^2=1^2+0^2+0^2=1$

$|OB|^2=\left|\overrightarrow{OB}\right|^2=0^2+2^2+0^2=4$

$|OC|^2=\left|\overrightarrow{OC}\right|^2=0^2+0^2+3^2=9$

គេបាន $\dfrac{1}{|OA|^2}+\dfrac{1}{|OB|^2}+\dfrac{1}{|OC|^2}=\dfrac{1}{1}+\dfrac{1}{4}+\dfrac{1}{9}$

$=\dfrac{36+9+4}{36}=\dfrac{49}{36}=\dfrac{1}{\left(\frac{6}{7}\right)^2}=\dfrac{1}{|OI|^2}$

ដូចនេះ $\boxed{\dfrac{1}{|OI|^2}=\dfrac{1}{|OA|^2}+\dfrac{1}{|OB|^2}+\dfrac{1}{|OC|^2}}$ ត្រូវបានបង្ហាញ

## VI. ក. សិក្សាអថេរភាព និងសង់ខ្សែកោង $(C)$ តាងអនុគមន៍

គេមាន $y = f(x) = \dfrac{x^2-2x+1}{2x-4}$

• ដែនកំណត់ : អនុគមន៍ $f$ មានន័យលុះត្រាតែ $2x-4 \neq 0$

នាំឱ្យ $2x \neq 4$ នោះ $x \neq 2$

ដូចនេះ $\boxed{D = \mathbb{R} - \{2\} = (-\infty\,,\,2) \cup (2\,,\,+\infty)}$ ។

• ទិសដៅអថេរភាព

ដេរីវេ $f'(x) = \left(\dfrac{x^2-2x+1}{2x-4}\right)'$

$$= \frac{(2x-2)(2x-4)-2(x^2-2x+1)}{(2x-4)^2}$$

$$= \frac{2(x-1)(2x-4)-2(x-1)^2}{(2x-4)^2}$$

$$= \frac{2(x-1)(2x-4-x+1)}{(2x-4)^2}$$

$$= \frac{2(x-1)(x-3)}{(2x-4)^2}$$

គេឱ្យ $f'(x) = 0 \Leftrightarrow \dfrac{2(x-1)(x-3)}{(2x-4)^2} = 0$

$\forall x \in D\ ,\ \Leftrightarrow (2x-4)^2 > 0$

នាំឱ្យ $(x-1)(x-3) = 0$ នោះ $x = 1\,,\ x = 3$

គេបាន $f(1) = \dfrac{1^2 - 2\cdot 1 + 1}{2\cdot 1 - 4} = 0$

$f(3) = \dfrac{(3)^2 - 2(3) + 1}{2(3) - 4} = \dfrac{4}{2} = 2$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $1$ | | $2$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |

• ត្រង់ $x = 1$ , $f'(x) = 0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$

បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើនឹង $f(1) = 0$ ។

• ត្រង់ $x = 3$ , $f'(x) = 0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើនឹង $f(3) = 2$ ។

• លីមីត និងអាស៊ីមតូត

$$\lim_{x\to+\infty} f(x) = \lim_{x\to+\infty} \frac{x^2-2x+1}{2x-4} = \lim_{x\to+\infty} \frac{x^2}{2x} = +\infty$$

$$\lim_{x\to-\infty} f(x) = \lim_{x\to-\infty} \frac{x^2-2x+1}{2x-4} = \lim_{x\to-\infty} \frac{x^2}{2x} = -\infty$$

$$\lim_{x\to2^-} f(x) = \lim_{x\to2^-} \frac{x^2-2x+1}{2(x-2)} = \frac{9}{2(2+0^- + 2)} = -\infty$$

$$\lim_{x\to2^+} f(x) = \lim_{x\to2^+} \frac{x^2-2x+1}{2(x-2)} = \frac{9}{2(2+0^+ - 2)} = +\infty$$

ដោយ $\lim\limits_{x\to2} f(x) = \pm\infty$ នោះបន្ទាត់ដែលមានសមីការ $x = 2$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ។

ម្យ៉ាងទៀត $f(x) = \dfrac{x^2-2x+1}{2x-4} = \dfrac{1}{2}x + \dfrac{1}{2x-4}$

ដោយ $\lim\limits_{x\to\pm\infty} \dfrac{1}{2x-4} = 0$ នោះបន្ទាត់ដែលមានសមីការ $y = \dfrac{1}{2}x$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

• តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-\infty$ | | $1$ | | $2$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $0$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $2$ | ↗ | $+\infty$ |

➤សង់ខ្សែកោង $(C)$ តាងអនុគមន៍




➤ស្រាយថាខ្សែកោងនេះមានផ្ចិតឆ្លុះមួយ

របៀបទី១ តាមរូបមន្ត

ដោយ អាស៊ីមតូតទាំងពីរ $x = 2$ និង $y = \dfrac{1}{2}x$ ប្រសព្វគ្នាត្រង់ចំណុច $I(2\,,1)$ គេនឹងស្រាយថា $I$ ជាផ្ចិតឆ្លុះនៃក្រាប $(C)$

បើ $I(a\,,b)$ ជាផ្ចិតឆ្លុះនៃក្រាប $C$ តាងអនុគមន៍ $f$ លុះត្រាតែវាផ្ទៀងផ្ទាត់ $f(2a-x) + f(x) = 2b$

គេបាន $f(4-x)+f(x)=2$

ដោយ $f(4-x)=\dfrac{(4-x)^2-2(4-x)+1}{2(4-x)-4}$

$=\dfrac{16-8x+x^2-8+2x+1}{8-2x-4}$

$=\dfrac{x^2-6x+9}{-2x+4}=\dfrac{-x^2+6x-9}{2x-4}$

គេបាន $\dfrac{-x^2+6x-9}{2x-4}+\dfrac{x^2-2x+1}{2x-4}=\dfrac{4x-8}{2x-4}=2$ ពិត

ដូចនេះ **ក្រាប $(C)$ មានផ្ចិតឆ្លុះមួយគឺ $I(2,1)$** ។

**របៀបទី២ តាមវិធីរំកិលអ័ក្ស**

គេបំលែងកិលអ័ក្សពីតម្រុយ $xoy$ ទៅតម្រុយថ្មី $XIY$

តាមរូបមន្ត បំលែងកិលអ័ក្ស $\begin{cases}x=a+X\\y=b+Y\end{cases}$

ដោយ អាស៊ីមតូតទាំងពីរ $x=-2$ និង $y=-\dfrac{1}{2}x+2$

ប្រសព្វគ្នាត្រង់ចំណុច $I(a,b)=I(2,1)$

គេបាន $\begin{cases}x=2+X\\y=1+Y\end{cases}$

គេមាន $y=f(x)=\dfrac{x^2-2x+1}{2x-4}$

គេបាន $Y+1=\dfrac{x^2-2x+1}{2x-4}$

$Y+1=\dfrac{(2+X)^2-2(2+X)+1}{2(2+X)-4}$

$Y=\dfrac{4+4X+X^2-4-2X+1}{2X}-1$

$F(X)=\dfrac{X^2+1}{2X}$ , $Y=F(X)$

ដោយ $\forall X\neq 0$ គេបាន ៖

$F(-X)=\dfrac{(-X)^2+1}{2(-X)}=-\dfrac{X^2+1}{2X}=-F(X)$

នាំឱ្យ $F(X)$ ជាអនុគមន៍សេសមាន $I(2,1)$ ជាផ្ចិតឆ្លុះ

ដូចនេះ **ក្រាប $(C)$ មានផ្ចិតឆ្លុះមួយគឺ $I(2,1)$** ។

**ខ. កំណត់សមីការបន្ទាត់ប៉ះនឹងខ្សែកោង $(C)$**

សមីការបន្ទាត់ប៉ះមានរាង $(T):\ y=ax+b$

ដោយ $(T)$ កាត់ $A(0,2)$ នោះ $2=0\cdot a+b$ ឬ $b=2$

គេបាន $(T):\ y=ax+2$

ដោយ $(T)$ ប៉ះ $(C)$ គេផ្ទឹមបានសមីការអាប់ស៊ីស

$\dfrac{x^2-2x+1}{2x-4}=ax+2$

$x^2-2x+1=2ax^2+4x-4ax-8$

$(1-2a)x^2+(-6+4a)x+9=0$

ដើម្បីឱ្យ $(T)$ ប៉ះ $(C)$ លុះត្រាសមីការមានឫសឌុប $\begin{cases}\Delta'=0\\a\neq 1/2\end{cases}$

គេបាន $(-3+2a)^2-9(1-2a)=0$

$9-12a+4a^2-9+18a=0$

$4a^2+6a=0$

$2a(2a+3)=0$

នាំឱ្យ $a=0$ , $a=-\dfrac{3}{2}$

ដូចនេះ សមីការបន្ទាត់ប៉ះរកបានមានពីរគឺ

**$y=2$ , $y=-\dfrac{3}{2}x+2$** ។

**គ. គណនាក្រឡាផ្ទៃ $S$ ផ្នែកប្លង់ខណ្ឌដោយខ្សែកោង $(C)$ អាស៊ីមតូតទ្រេត និងបន្ទាត់ $x=3$ , $x=4$**

តាមក្រាប នៅចន្លោះ $3\le x\le 4$ ក្រាបនៅពីលើអាស៊ីមតូតទ្រេត

គេបាន ផ្ទៃកំណត់ដោយ $S=\int_3^4\left[(C)-y\right]dx$ គេបាន ៖

$S=\int_3^4\left[\left(\dfrac{1}{2}x+\dfrac{1}{2x-4}\right)-\dfrac{1}{2}x\right]dx$

$=\int_3^4\dfrac{1}{2x-4}dx=\dfrac{1}{2}\int_3^4\dfrac{(x-2)'}{x-2}dx$

$=\dfrac{1}{2}\left[\ln|x-2|\right]_3^4=\dfrac{1}{2}(\ln 2-\ln 1)=\dfrac{\ln 2}{2}$

ដូចនេះ **ផ្ទៃប្លង់កំណត់បាន $S=\dfrac{\ln 2}{2}$ ឯកតាផ្ទៃក្រឡា** ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "
## សម័យប្រឡង : ២០ វិច្ឆិកា ២០០៨

**វិញ្ញាសា** : **គណិតវិទ្យា** **រយៈពេល** : **១២០ នាទី** **ពិន្ទុ** : **១០**

**I.** ក. រកដែនកំណត់នៃអនុគមន៍ $y=\log\left(1-\sqrt{4-x^2}\right)$ ។

ខ. ស្រាយបញ្ជាក់ថា $x^2+5y^2-4xy+2x-6y+3>0$ ចំពោះគ្រប់ចំនួនពិត $x$ , $y$ ជារបស់ $\mathbb{R}$ ។

គ. គេឱ្យសមីការ $x^2+ax+1=0$ ។ រកតម្លៃនៃ $a$ ដើម្បីឱ្យសមីការមានឫសពីរផ្សេងគ្នា $x_1$ និង $x_2$ ដែលផ្ទៀងផ្ទាត់ $x_1^2+x_2^2>7$ ។ **(២ពិន្ទុ)**

**II.** ក. គណនាអាំងតេក្រាល : $I=\int(\tan x-\cot x)^2\,dx$ , $J=\int\frac{1}{x^2-5x+6}\,dx$ ។

ខ. គណនាផ្ទៃក្រឡានៃផ្នែកប្លង់ដែលខណ្ឌដោយខ្សែកោង $y=x^3-x^2-2x$ និងអ័ក្សអាប់ស៊ីស ។ **(២ពិន្ទុ)**

**III.** ក្នុងថង់មួយមានប៊ូលស $7$ និងប៊ូលពណ៌ខ្មៅ $10$ ។ គេចាប់យកចេញនូវប៊ូលពីរជាមួយគ្នា ។ តើគេមានប៉ុន្មានរបៀប ដើម្បីចាប់យកប៊ូលចេញឱ្យបានយ៉ាងតិចបំផុតនូវប៊ូលសមួយ ? **(១ពិន្ទុកន្លះ)**

**IV.** គេឱ្យស្វ៊ែមួយមានប្រវែងកាំ $9\text{dm}$ ។ កោណមួយចារឹកក្នុងស្វ៊ែនោះ ។ រកកម្ពស់នៃកោណ ដើម្បីឱ្យកោណនោះមានមាឌ អតិបរមា ។ **(២ពិន្ទុ)**

**V.** គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x>0$ ដោយ $f(x)=\frac{x+\ln x}{x}$ និងមានខ្សែកោង $(C)$ ។

ក. គណនាដេរីវេនៃអនុគមន៍ $f$ ។ បង្ហាញថា អនុគមន៍ $f$ មានអតិបរមាមួយ ហើយគណនាតម្លៃអតិបរមានោះ ។

ខ. គណនាលីមីត $\lim\limits_{x\to0^+}f(x)$ និង $\lim\limits_{x\to+\infty}f(x)$ ។ កំណត់សមីការអាស៊ីមតូតឈរ និងដេក នៃខ្សែកោង $(C)$ ។

គ. សង់តារាងអថេរភាពនៃអនុគមន៍ $f$ ។ **(២ពិន្ទុកន្លះ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០០៨

**I.** **ក. រកដែនកំណត់នៃអនុគមន៍** :

គេមាន $y=\log\left(1-\sqrt{4-x^2}\right)$ មានន័យលុះត្រាតែ

$$\begin{cases}4-x^2\ge 0 & (1)\\ 1-\sqrt{4-x^2}>0 & (2)\end{cases}$$

តាម $(1)$ ឱ្យ $4-x^2=0$ សមីការមានឫស $x=\pm 2$

តាម $(2)$ ឱ្យ $1-\sqrt{4-x^2}=0$ ឬ $1=\sqrt{4-x^2}$

$4-x^2=1$ មានឫស $x=\pm\sqrt{3}$

តារាងសញ្ញា

| $x$ | $-\infty$   $-2$ | $-2$   $-\sqrt{3}$ | $-\sqrt{3}$   $\sqrt{3}$ | $\sqrt{3}$   $2$ | $2$   $+\infty$ |
|---|---|---|---|---|---|
| $4-x^2\ge 0$ | $-$   0 | $+$ | $+$ | $+$   0 | $-$ |
| $1-\sqrt{4-x^2}>0$ | | $+$   0 | $-$   0 | $+$ | |
| ចម្លើយ | | (shaded) | | (shaded) | |

ដូចនេះ ដែនកំណត់ $\boxed{D=[-2\,,\,-)\cup\left(\sqrt{3}\,,\,2\right]}$ ។

**ខ. ស្រាយបញ្ជាក់ថា វិសមភាពពិតគ្រប់**

គេមាន $x^2+5y^2-4xy+2x-6y+3>0$

$x^2+2(1-2y)x+\left(5y^2-6y+3\right)>0$

វិសមីការនេះពិត ឬផ្ទៀងផ្ទាត់លុះត្រាតែ $\begin{cases}a>0\\ \Delta'<0\end{cases}$

គេមាន $a=1>0$

ហើយ $\Delta'=(1-2y)^2-\left(5y^2-6y+3\right)$

$=1-4y+4y^2-5y^2+6y-3$

$=-y^2+2y-2$

$=-\left(y^2-2y+1\right)-1$

$=-(y-1)^2-1<0\ ,\ \forall y\in\mathbb{R}$

ដូចនេះ $\boxed{x^2+5y^2-4xy+2x-6y+3>0}$ ពិត គ្រប់តម្លៃនៃ $x\,,\,y\in\mathbb{R}$ ។

**គ. រកតម្លៃនៃ $a$ ដើម្បីឱ្យសមីការមានឫសពីរផ្សេងគ្នា $x_1\,,\,x_2$**

គេមាន សមីការ $x^2+ax+1=0$ មាន $S=-a\ ,\ P=1$

សមីការមានឫសពីរផ្សេងគ្នា និងផ្ទៀងផ្ទាត់ $x_1^2+x_2^2>7$

លុះត្រាតែ $\begin{cases}\Delta>0\\ x_1^2+x_2^2>7\end{cases}$ ឬ $\begin{cases}a^2-4>0\\ (x_1+x_2)^2-2x_1x_2-7>0\end{cases}$

គេបាន $\begin{cases}a^2-4>0\\ S^2-2P-7>0\end{cases}$ ឬ $\begin{cases}a^2-4>0\\ (-a)^2-2\cdot 1-7>0\end{cases}$

$\begin{cases}a^2-4>0\\ a^2-9>0\end{cases}$

កន្សោម $a^2-4$ មានឫស $a=\pm 2$

កន្សោម $a^2-9$ មានឫស $a=\pm 3$

តារាងសញ្ញា

| $a$ | $-\infty$   $-3$ | $-3$   $-2$ | $-2$   $2$ | $2$   $3$ | $3$   $+\infty$ |
|---|---|---|---|---|---|
| $a^2-4>0$ | $+$ | $+$   0 | $-$   0 | $+$ | $+$ |
| $a^2-9>0$ | $+$   0 | $-$ | $-$ | $-$   0 | $+$ |
| ចម្លើយ | (shaded) | | | | (shaded) |

ដូចនេះ $\boxed{a\in(-\infty\,,\,-3)\cup(3\,,\,+\infty)}$ ។

**II.** **គណនាអាំងតេក្រាល** :

$\mathbf{I}=\int(\tan x-\cot x)^2\,dx$

$=\int\left(\tan^2 x-2\tan x\cot x+\cot x\right)dx$

$=\int\left(\tan^2 x-2+\cot^2 x\right)dx$

$=\int\left[\left(1+\tan^2 x\right)+\left(1+\cot^2 x\right)-4\right]dx$

$=\tan x-\cot x-4x+c\ ,\ c$ ថេរ

ដូចនេះ $\boxed{\mathbf{I}=\tan x-\cot x-4x+c}$ , $c$ ជាចំនួនថេរ ។

$\mathbf{J}=\int\dfrac{dx}{x^2-5x+6}$ (លំហាត់ដូចប្រឡងគ្រូមធ្យម ២០០៥)

$=\int\dfrac{dx}{(x-2)(x-3)}$

$=\int\dfrac{(x-2)-(x-3)}{(x-2)(x-3)}dx$

$=\int\dfrac{1}{(x-3)}dx-\int\dfrac{1}{(x-2)}dx$

$=\ln|x-3|-\ln|x-2|+c$

$=\ln\left|\dfrac{x-3}{x-2}\right|+c$

ដូចនេះ $\boxed{\mathbf{J}=\ln\left|\dfrac{x-3}{x-2}\right|+c}$ , $c$ ជាចំនួនថេរ ។

ខ. គណនាផ្ទៃក្រឡាខណ្ឌដោយខ្សែកោង និងអ័ក្សអាប់ស៊ីស

គេមាន $y=x^3-x^2-2x$ ជាខ្សែកោង

តារាងតម្លៃលេខត្រូវគ្នានៃ $x$ និង $y$

| | | | | | |
|---|---|---|---|---|---|
| $x$ | $-2$ | $-1$ | $0$ | $1$ | $2$ |
| $y$ | $-8$ | $0$ | $0$ | $-2$ | $0$ |

គេសង់ខ្សែកោងបានដូចខាងក្រោម ៖




តាមក្រាប ផ្ទៃក្រឡាមានពីរផ្នែក គេបាន ៖

$$S=\int_{-1}^{0}\left(x^3-x^2-2x\right)dx-\int_{0}^{2}\left(x^3-x^2-2x\right)dx$$

$$=\left[\frac{x^4}{4}-\frac{x^3}{3}-x^2\right]_{-1}^{0}-\left[\frac{x^4}{4}-\frac{x^3}{3}-x^2\right]_{0}^{2}$$

$$=\left[0-\left(\frac{1}{4}+\frac{1}{3}-1\right)\right]-\left[\left(4-\frac{8}{3}-4\right)-0\right]$$

$$=\frac{5}{12}+\frac{8}{3}=\frac{37}{12}$$

ដូចនេះ ផ្ទៃក្រឡាគណនាបាន $\boxed{S=\frac{37}{12}}$ ឯកតាផ្ទៃក្រឡា ។

**III. រកចំនួនរបៀបយកបានប៊ូលពណ៌សមួយយ៉ាងតិចបំផុត :**

គេមាន ប៊ូលពណ៌ស 7 និងប៊ូលពណ៌ខ្មៅ 10

ព្រឹត្តិការណ៍យកបានប៊ូលពណ៌សមួយយ៉ាងតិចបំផុតមានន័យថា យកបានប៊ូលសមួយ ឬប៊ូលសពីរ គេបាន ៖

ចំនួនរបៀបយកបានប៊ូលសមួយយ៉ាងតិចបំផុតគឺ

$$=C(7\,,1)C(10\,,1)+C(7\,,2)$$

$$=7\times10+\frac{7!}{(7-2)!\cdot2!}=70+\frac{7\cdot6\cdot5!}{5!\cdot2}=70+21=91$$

ដូចនេះ: $\boxed{\text{របៀបយកបានប៊ូលសយ៉ាងតិចមួយគឺ 91 របៀប}}$ ។

**IV. រកកម្ពស់នៃកោណ ដើម្បីឱ្យកោណនោះមានមាឌ អតិបរមា :**

គេតាង $h$ ជាកម្ពស់នៃកោណ

$x=OH$ ដែល $x<9$ ហើយ $h=9+x$

$r$ ជាកាំបាតរបស់កោណ




មាឌកោណ $V=\frac{1}{3}\pi r^2 h$ (តាមពីតាគ័រ $r^2=9^2-x^2$)

គេបាន $V(x)=\frac{1}{3}\pi\left(81-x^2\right)\left(x+9\right)$

$V(x)=\frac{\pi}{3}\left(-x^3-9x^2+81x+729\right)$

នាំឱ្យ $V'(x)=\frac{\pi}{3}\left(-3x^2-18x+81\right)$

$V'(x)=\pi\left(-x^2-6x+27\right)$

$V''(x)=\pi\left(-2x-6\right)$

ដើម្បីឱ្យមាឌ $V$ អតិបរមា លុះត្រាតែ $\begin{cases}V'(x)=0\\V''(x)<0\end{cases}$

គេបាន $V'(x)=0 \Leftrightarrow \pi\left(-x^2-6x+27\right)=0$

$\Delta'=(-3)^2+27=36=6^2$

នោះ $x=3$ , $x=9$ មិនយក

ចំពោះ: $x=3:\ V''(3)=\pi\left(-2\cdot3-6\right)=-12\pi<0$ ពិត

នាំឱ្យ $h=x+9=3+9=12$ dm

ដូចនេះ: កម្ពស់កោណគឺ $\boxed{h=12\ \text{dm}}$ ។

**V. ក. គណនាដេរីវេនៃអនុគមន៍ $f$ :**

គេមាន $x>0$ , $f(x)=\frac{x+\ln x}{x}$ មានខ្សែកោង $(C)$

គេបាន $f'(x)=\frac{(x+\ln x)'\,x-x'(x+\ln x)}{x^2}$

$=\frac{x+1-x-\ln x}{x^2}$

$=\frac{1-\ln x}{x^2}$

ដូចនេះ: គណនាបានដេរីវេ $\boxed{f'(x)=\frac{1-\ln x}{x^2}}$ ។

**➢បង្ហាញថា $f$ មានអតិបរមាមួយ ដែលត្រូវរក**

គេឱ្យ $f'(x)=0 \Leftrightarrow \dfrac{1-\ln x}{x^2}=0$

ដោយ $\forall x>0$ , $x^2>0$ គេបាន $1-\ln x=0$ នោះ $x=e$

គេបាន $f(e)=\dfrac{e-\ln e}{e}=\dfrac{e-1}{e}$

តារាងសញ្ញា $f'(x)$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |

ត្រង់ $x=e$ , $f'(x)=0$ ហើយប្តូរសញ្ញាពីរ $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានតម្លៃអតិបរមាមួយស្មើនឹង $f(e)=\dfrac{e-1}{e}$ ។

**ខ. គណនាលីមីត**

$$\lim_{x\to 0^+} f(x)=\lim_{x\to 0^+}\frac{x+\ln x}{x}=\lim_{x\to 0^+}\left(1+\frac{1}{x}\ln x\right)$$

$$=1+(+\infty)(-\infty)=1-\infty=-\infty$$

$$\lim_{x\to +\infty} f(x)=\lim_{x\to +\infty}\frac{x+\ln x}{x}=\lim_{x\to +\infty}\left(1+\frac{\ln x}{x}\right)=1+0=1$$

ដូចនេះ $\boxed{\lim_{x\to 0^+} f(x)=-\infty}$ និង $\boxed{\lim_{x\to +\infty} f(x)=1}$ ។

**កំណត់សមីការអាសុីមតូតឈរ និងដេក នៃខ្សែកោង $(C)$**

ដោយ $\lim_{x\to 0^+} f(x)=-\infty$ នោះបន្ទាត់ដែលមានសមីការ

$x=0$ ជាអាសុីមតូតឈរ នៃខ្សែកោង $(C)$ ។

ដោយ $\lim_{x\to +\infty} f(x)=1$ នោះបន្ទាត់ដែលមានសមីការ

$y=1$ ជាអាសុីមតូតដេក នៃខ្សែកោង $(C)$ ។

**គ. សង់តារាងអថេរភាពនៃអនុគមន៍ $f$**

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $\dfrac{e-1}{e}$ | $\searrow$ | $1$ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................
លេខបន្ទប់ : ..................................
លេខតុ : ..................................
ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "**
**សម័យប្រឡង : ១៦ វិច្ឆិកា ២០០៧**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. គេឱ្យ $P(z)=z^2+2(2+i)z+3+4i$ ដែល $z$ ជាចំនួនកុំផ្លិច ។ បញ្ជាក់ថា $P(z)$ ជាការេនៃពហុធាដឺក្រេទី១ ។

ខ. គេឱ្យចំនួនកុំផ្លិច $z=1+i$ ។ បង្ហាញថា $z^3=-2+2i$ ។ ចំពោះតម្លៃនៃ $z$ នេះ ចូររកចំនួនពិត $a$ និង $b$ ដោយដឹងថា $\frac{a}{1+z}+\frac{b}{1+z^3}=2i$ ។ **(១ពិន្ទុកន្លះ)**

**II.** ក. គណនាអាំងតេក្រាលមិនកំណត់ : $I=\int x^2\ln x dx$ , $J=\int\frac{\sin 2x-\cos x}{\cos x}dx$ ។

ខ. គេឱ្យ $g(x)=\frac{x^2+x-6}{x^2-2x-3}$ ។ កំណត់ចំនួនពិត $m$ , $n$ , $p$ ដើម្បីឱ្យបាន $g(x)=m+\frac{n}{x+1}+\frac{p}{x-3}$ ចំពោះគ្រប់ $x\in(-1\,,3)$ រួចគណនា $\int_0^2 g(x)dx$ ។ **(២ពិន្ទុ)**

**III.** គេចង់ជ្រើសរើសសិស្ស 3 នាក់ ក្នុងចំណោមសិស្ស 12 នាក់ ដែលក្នុងនោះមានសិស្សប្រុស 7 នាក់ និងសិស្សស្រី 5 នាក់ ។ រកប្រូបាបដែលគេជ្រើសរើសបានសិស្សប្រុស 2 នាក់ និងសិស្សស្រី 1 នាក់ ។ **(១ពិន្ទុកន្លះ)**

**IV.** គេឱ្យអនុគមន៍ $f(x)=1+2x+3x^2+...+nx^{n-1}$ ។

ក. កំណត់តម្លៃ $a_1$ , $a_2$ , $a_3$ , ... , $a_n$ ដើម្បីឱ្យ $F(x)=a_1x+a_2x^2+a_3x^3+...+a_nx^n$ ជាព្រីមីទីវនៃ $f(x)$ ។

ខ. ចំពោះតម្លៃ $a_1$ , $a_2$ , $a_3$ , ... , $a_n$ ដែលរកឃើញក្នុងសំណួរខាងលើ បង្ហាញថា $f(x)=\frac{nx^{n+1}-(n+1)x^n+1}{(1-x)^2}$ ។ **(២ពិន្ទុ)**

**V.** ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(O\,,\vec{i}\,,\vec{j}\,,\vec{k})$ គេឱ្យបន្ទាត់ពីរដែលមានសមីការ :

$(D_1):\frac{x}{1}=\frac{y-1}{-2}=\frac{z}{3}$ និង $(D_2):\begin{cases}3x+y-5z+1=0\\2x+3y-8z+3=0\end{cases}$ ។

ក. ស្រាយបញ្ជាក់ថាបន្ទាត់ $(D_1)$ និងបន្ទាត់ $(D_2)$ អរតូកូណាល់គ្នា ។

ខ. តើបន្ទាត់ $(D_1)$ និង បន្ទាត់ $(D_2)$ កាត់គ្នាឬទេ ?

គ. ប្លង់ $(P)$ មួយមានសមីការ $2x+3y+z-12=0$ ។ រកចម្ងាយពីគល់តម្រុយ $O$ ទៅប្លង់ $(P)$ ។ **(៣ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ២០០៧

**I.** **ក. បញ្ជាក់ថា** $P(z)$ **ជាការេនៃពហុធាដឺក្រេទី១** :

គេមាន $P(z)=z^2+2(2+i)z+3+4i$

$\Delta'=(2+i)^2-(3+4i)$

$=4+4i+i^2-3-4i=0$

នាំឱ្យ សមីការមានឫសឌុប $z_0=\dfrac{-b'}{a}=-(2+i)$

តាមទ្រឹស្តីបទផលគុណកត្តាគេអាចដាក់ $P(z)$ ជាផលគុណកត្តា

គេបាន $P(z)=(z-z_0)(z-z_0)=(z-z_0)^2$

នាំឱ្យ $P(z)=(z+2+i)^2$

ដូចនេះ $\boxed{P(z) \text{ ជាការេនៃពហុធាដឺក្រេទី១}}$ ។

**ខ. បង្ហាញថា** $z^3=-2+2i$

គេមាន $z=1+i$

នាំឱ្យ $z^3=(1+i)^3=1+3i+3i^2+i^3=-2+2i$

ដូចនេះ $\boxed{z^3=-2+2i}$ ត្រូវបានបង្ហាញ ។

**➤រកចំនួនពិត** $a$ **និង** $b$

គេមាន $\dfrac{a}{1+z}+\dfrac{b}{1+z^3}=2i$

ដោយ $z=1+i$ និង $z^3=-2+2i$

គេបាន $\dfrac{a}{1+1+i}+\dfrac{b}{1-2+2i}=2i$

$\dfrac{a}{2+i}+\dfrac{b}{-1+2i}=2i$

$\dfrac{a(2-i)}{2^2-i^2}+\dfrac{b(-1-2i)}{(-1)^2-(2i)^2}=2i$

$\dfrac{2a-ai}{5}+\dfrac{-b-2bi}{5}=2i$

$(2a-b)+(-a-2b)i=10i$

ផ្ទឹមបាន $\begin{cases}2a-b=0\\-a-2b=10\end{cases}\Bigg|\times 2 \Rightarrow \begin{cases}2a-b=0 & (1)\\-2a-4b=20 & (2)\end{cases}$

បូកអង្គនិងអង្គនៃ $(1)+(2)$ គេបាន $-5b=20$ ឬ $b=-4$

ចំពោះ $b=-4$ នាំឱ្យ $(1):2a-(-4)=0 \Rightarrow a=-2$

ដូចនេះ ចំនួនពិតរកបាន $\boxed{a=-2\ ,\ b=-4}$ ។

**II.** **ក. គណនាអាំងតេក្រាលមិនកំណត់** :

គេមាន $\mathbf{I}=\int x^2\ln x\,dx$

គេតាង $u=\ln x$ នោះ $du=\dfrac{1}{x}dx$

$dv=x^2dx$ នោះ $v=\dfrac{1}{3}x^3$

តាមរូបមន្ត អាំងតេក្រាលដោយផ្នែក $\int u\,dv=uv-\int v\,du$

$\mathbf{I}=\int x^2\ln x\,dx=\dfrac{1}{3}x^3\ln x-\int\dfrac{1}{3}x^2dx$

$=\dfrac{1}{3}x^3\ln x-\dfrac{1}{3}\cdot\dfrac{x^3}{3}+c$ , $c$ ថេរ

$=\dfrac{1}{3}x^3\ln x-\dfrac{1}{9}x^3+c$

ដូចនេះ គណនាបាន $\boxed{\mathbf{I}=\dfrac{1}{3}x^3\ln x-\dfrac{1}{9}x^3+c}$ ។

គេមាន $\mathbf{J}=\int\dfrac{\sin 2x-\cos x}{\cos x}dx$

$=\int\dfrac{2\sin x\cos x-\cos x}{\cos x}dx$

$=\int(2\sin x-1)dx$

$=-2\cos x-x+c$ , $c$ ថេរ

ដូចនេះ គណនាបាន $\boxed{\mathbf{J}=-2\cos x-x+c\ ,\ c \text{ ថេរ}}$ ។

**ខ. កំណត់ចំនួនពិត** $m$ , $n$ , $p$

គេមាន $g(x)=m+\dfrac{n}{x+1}+\dfrac{p}{x-3}$

$g(x)=\dfrac{m(x+1)(x-3)+n(x-3)+p(x+1)}{(x+1)(x-3)}$

$=\dfrac{m(x^2-2x-3)+n(x-3)+p(x+1)}{x^2-2x-3}$

$=\dfrac{mx^2+(-2m+n+p)x+(-3m-3n+p)}{x^2-2x-3}$

ផ្ទឹមនឹង $g(x)=\dfrac{x^2+x-6}{x^2-2x-3}$

គេបាន $\begin{cases}m=1\\-2m+n+p=1\\-3m-3n+p=-6\end{cases} \Rightarrow \begin{cases}m=1\\n=3/2\\p=3/2\end{cases}$

ដូចនេះ កំណត់បាន $\boxed{m=1\ ,\ n=\dfrac{3}{2}\ ,\ p=\dfrac{3}{2}}$ ។

➤គណនា $\int_0^2 g(x)dx$

ចំពោះ $m=1\,,\,n=\frac{3}{2}\,,\;p=\frac{3}{2}$

គេបាន $g(x)=1+\frac{\frac{3}{2}}{x+1}+\frac{\frac{3}{2}}{x-3}$

នាំឱ្យ $\int_0^2 g(x)dx=1+\frac{\frac{3}{2}}{x+1}+\frac{\frac{3}{2}}{x-3}$

$=\int_0^2\left[1+\frac{3}{2}\cdot\frac{1}{x+1}+\frac{3}{2}\cdot\frac{1}{x-3}\right]dx$

$=\left[x+\frac{3}{2}\ln|x+1|+\frac{3}{2}\ln|x-3|\right]_0^2$

$=\left(2+\frac{3}{2}\ln x+0\right)-\left(0+0+\frac{3}{2}\ln 3\right)=2$

ដូចនេះ គណនាបាន $\boxed{\int_0^2 g(x)dx=2}$ ។

**III.** **រកប្រូបាបជ្រើសរើសបានសិស្សប្រុស 2 នាក់ និងសិស្សស្រី 1 :**

គេមាន សិស្សប្រុស 7 នាក់ និងសិស្សស្រី 5 នាក់

គេចង់ជ្រើសរើសសិស្ស 3 នាក់

នាំឱ្យ ចំនួនករណីអាចតាងដោយ៖

$n(S)=C(12\,,\,3)=\frac{12!}{(12-3)^2\cdot 3!}$

$=\frac{12\cdot 11\cdot 10\cdot 9!}{9^2\cdot 3\cdot 2}=220$

ដោយ ជ្រើសរើសបានសិស្សប្រុស 2 នាក់ និងស្រី 1 នាក់

នាំឱ្យ ចំនួនករណីស្របតាងដោយ៖

$n(A)=C(7\,,\,2)\times C(5\,,1)$

$=\frac{7!}{5!\times 2!}\times 5=105$

គេបាន $P(A)=\frac{n(A)}{n(S)}=\frac{105}{220}=\frac{21}{44}$

ដូចនេះ គណនាបានប្រូបាប $\boxed{P(A)=\frac{21}{44}}$ ។

**IV.** **ក. កំណត់តម្លៃ** $a_1\,,\,a_2\,,\,a_3\,,\ldots,\,a_n$ :

គេមាន $f(x)=1+2x+3x^2+\ldots+nx^{n-1}$

$F(x)=a_1x+a_2x^2+a_3x^3+\ldots+a_nx^n$

នាំឱ្យ $F'(x)=a_1+2a_2x+3a_3x^2+\ldots+na_nx^{n-1}$

ដើម្បីឱ្យ $F(x)$ ជាព្រីមីទីវនៃ $f(x)$ លុះត្រាតែ $F'(x)=f(x)$

$a_1+2a_2x+3a_3x^2+\ldots+na_nx^{n-1}=1+2x+3x^2+\ldots+nx^{n-1}$

ផ្ទឹមមេគុណត្រូវគ្នានៃអថេរ $x$ គេបាន ៖

$\begin{cases}a_1=1\\2a_2=2\\3a_3=3\\\ldots\ldots\ldots\ldots\\na_n=n\end{cases}\Rightarrow\begin{cases}a_1=1\\a_2=1\\a_3=1\\\ldots\ldots\ldots\\a_n=1\end{cases}$

ដូចនេះ កំណត់បាន $\boxed{a_1=a_2=a_3=\ldots=a_n=1}$ ។

**ខ. បង្ហាញថា** $f(x)=\frac{nx^{n+1}-(n+1)x^n+1}{(1-x)^2}$

ចំពោះ $a_1=a_2=a_3=\ldots=a_n=1$

គេបាន $F(x)=x+x^2+x^3+\ldots+x^n$ (ផលបូកស្ទីតធរ.)

$=\frac{x(x^n-1)}{x-1}=\frac{x^{n+1}-x}{x-1}$

នាំឱ្យ $F'(x)=\left(\frac{x^{n+1}-x}{x-1}\right)'$

$=\frac{[(n+1)x^n-1](x-1)-(x^{n+1}-x)}{(x-1)^2}$

$=\frac{(n+1)x^{n+1}-(n+1)x^n-x+1-x^{n+1}+x}{(x-1)^2}$

$=\frac{nx^{n+1}-(n+1)x^n+1}{(x-1)^2}$

តែ $F'(x)=f(x)$ នោះ $f(x)=\frac{nx^{n+1}-(n+1)x^n+1}{(1-x)^2}$

ដូចនេះ $\boxed{f(x)=\frac{nx^{n+1}-(n+1)x^n+1}{(1-x)^2}}$ ត្រូវបានបង្ហាញ ។

**V.** **ក. ស្រាយបញ្ជាក់ថាបន្ទាត់ $(D_1)$ និង $(D_2)$ អរតូកូណាល់គ្នា :**

គេមាន $(D_1):\frac{x}{1}=\frac{y-1}{-2}=\frac{z}{3}$

មានវ៉ិចទ័រប្រាប់ទិស $\vec{u}_1=(1\,,-2\,,\,3)$

ហើយ $(D_2):\begin{cases}3x+y-5z+1=0\\2x+3y-8z+3=0\end{cases}$ យក $z=t$

គេបាន $(D_2):\begin{cases}3x+y=5t-1\\2x+3y=8t-3\end{cases}\Big|\times(-3)$

$+\begin{cases}-9x-3y=-15t+3\\2x+3y=8t-3\end{cases}$

$-7x=-7t\quad\Rightarrow x=t$

ចំពោះ $x=t:\;2t+3y=8t-3\Rightarrow y=2t-1$

គេបាន $(D_2): x=t\ ,\ y=-1+2t\ ,\ z=t\ \ ,\ t\in\mathbb{R}$

មានមេគុណប្រាប់ទិស $\vec{u}_2=(1\ ,\ 2\ ,\ 1)$

ដោយ $\vec{u}_1\cdot\vec{u}_2=(1)(1)+(-2)(2)+(3)(1)=0$

នាំឱ្យ $\vec{u}_1\perp\vec{u}_2$ មានន័យថា $(D_1)\perp(D_2)$

ដូចនេះ ស្រាយបានថា $\boxed{(D_1)\perp(D_2)}$ ។

**ខ. តើបន្ទាត់ $(D_1)$ និង បន្ទាត់ $(D_2)$ កាត់គ្នាឬទេ ?**

គេមាន $(D_1): \dfrac{x}{1}=\dfrac{y-1}{-2}=\dfrac{z}{3}$

$$(D_1):\begin{cases}x=t'\\ y=1-2t'\ ,\ t'\in\mathbb{R}\\ z=3t'\end{cases}$$

ហើយ $(D_2):\begin{cases}x=t\\ y=-1+2t\ \ ,\ \ t\in\mathbb{R}\\ z=t\end{cases}$

បើបន្ទាត់ទាំងពីរប្រសព្វគ្នា គេបាន ៖

$$\begin{cases}t'=t & (1)\\ 1-2t'=-1+2t & (2)\\ 3t'=t & (3)\end{cases}$$

តាម $(1)$ និង $(3)$ ជាករណីមិនផ្ទៀងផ្ទាត់ព្រមគ្នា

នាំឱ្យ បន្ទាត់ទាំងពីរគ្មានចំណុចប្រសព្វទេ

ដូចនេះ | បន្ទាត់ទាំងពីរ $(D_1)$ និង $(D_2)$ មិនកាត់គ្នាទេ | ។

**គ. រកចម្ងាយពីគល់តម្រុយ $O$ ទៅប្លង់ $(P)$**

គេមាន ប្លង់ $(P):\ 2x+3y+z-12=0$

មាន $a=2\ ,\ b=3\ ,\ c=1\ ,\ d=-12$

ចំណុច គល់ $O(0\ ,\ 0\ ,\ 0)$ នោះ $x_0=y_0=z_0=0$

តាមរូបមន្ត $d\left(O,(P)\right)=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$

គេបាន $d\left(O\ ,\ (P)\right)=\dfrac{|0+0+0-12|}{\sqrt{2^2+3^2+1^2}}=\dfrac{12}{\sqrt{14}}=\dfrac{6\sqrt{14}}{7}$

ដូចនេះ $\boxed{d\left(O\ ,\ (P)\right)=\dfrac{6\sqrt{14}}{7}}$ ឯកតាប្រវែង ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "**

**សម័យប្រឡង : ១៨ វិច្ឆិកា ២០០៦**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. កំណត់ចំនួនកុំផ្លិច $z$ ដែល $z$ , $\frac{1}{z}$ និង $1-z$ មានម៉ូឌុលស្មើគ្នា ។

ខ. ដោះស្រាយសមីការ $|x|-x=1+2i$ ដែល $x$ ជាចំនួនកុំផ្លិច ។

គ. គេឱ្យបីចំនួន $a$ , $b$ និង $c$ ដែលផ្ទៀងផ្ទាត់ទំនាក់ទំនង $abc=1$ ។

ស្រាយបញ្ជាក់ថា $\frac{1}{1+a+ab}+\frac{1}{1+b+bc}+\frac{1}{1+c+ca}=1$ ។ **(២ពិន្ទុ)**

**II.** គេឱ្យអនុគមន៍ $f(x)=\ln\left(x+\sqrt{1+x^2}\right)$ ។

ក. រកដែនកំណត់នៃអនុគមន៍ $f$ ។

ខ. បង្ហាញថាអនុគមន៍ $f$ ជាអនុគមន៍សេស និងជាអនុគមន៍កើន ។ **(២ពិន្ទុ)**

**III.** ក. រកសមីការបន្ទាត់ $(T)$ ដែលប៉ះនឹងខ្សែកោងតាងអនុគមន៍ $y=\frac{e^x}{1-\sin x}$ ត្រង់ចំណុចដែលមានអាប់ស៊ីស $x=0$ ។

ខ. រកកូអរដោនេនៃចំណុចប្រសព្វ $M$ រវាងបន្ទាត់ $(T)$ និងខ្សែកោងតាងអនុគមន៍ $y=2x+1+\ln(x-1)$ ។ **(១ពិន្ទុកន្លះ)**

**IV.** គេមានការេមួយមានរង្វាស់ជ្រុងស្មើ $a$ ។ នៅក្នុងការេនោះគេសង់ការេមួយទៀត ដែលមានកំពូលវាជាចំណុចកណ្តាលនៃ ជ្រុងការេមុន ។ គេសង់ការេរបៀបនេះរហូតដល់ការេទី $n$ ។

ក. គណនាផ្ទៃក្រឡាការេទី $n$ ។

ខ. គណនាផលបូកផ្ទៃក្រឡាការេទាំងអស់ ។ **(១ពិន្ទុកន្លះ)**

**V.** ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(O, \vec{i}, \vec{j}, \vec{k})$ គេឱ្យចំណុច $A(3,2,0)$ និង $B(0,-1,3)$ ។

ក. រកសមីការប្លង់ $(Q)$ ដែលកាត់តាមចំណុច $A$ ហើយកែងនឹងបន្ទាត់ $(AB)$ ។

ខ. គេឱ្យចំណុច $R(5,0,0)$ , $S(0,5,0)$ និង $T(0,0,-5)$ ។ ផ្ទៀងផ្ទាត់ថាចំណុច $R$ , $S$ និង $T$ ជាចំណុច ដែលស្ថិតនៅលើប្លង់ $(Q)$ ។

គ. គណនាប្រវែង $AB$ និងផ្ទៃក្រឡាត្រីកោណ $RST$ ។ **(៣ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០០៦

**I.** **ក. កំណត់ចំនួនកុំផ្លិច** $z$ : (ដូចគ្រូមធ្យមឆ្នាំ ២០១១)

គេតាង $z=a+bi$

នាំឱ្យ $\frac{1}{z}=\frac{1}{a+bi}=\frac{a-bi}{a^2+b^2}=\frac{a}{a^2+b^2}-\frac{b}{a^2+b^2}i$

$1-z=(1-a)-bi$

គេបាន $|z|=\sqrt{a^2+b^2}$

$\left|\frac{1}{z}\right|=\frac{1}{|z|}=\frac{1}{\sqrt{a^2+b^2}}$

$|1-z|=\sqrt{(1-a)^2+(-b)^2}$

ដោយ $z$ , $\frac{1}{z}$ និង $1-z$ មានម៉ូឌុលស្មើគ្នា គេបាន ៖

$\sqrt{a^2+b^2}=\frac{1}{\sqrt{a^2+b^2}}=\sqrt{(1-a)^2+(-b)^2}$

នាំឱ្យ $\begin{cases} a^2+b^2=1 & (1) \\ \sqrt{a^2+b^2}=\sqrt{(1-a)^2+(-b)^2} & (2) \end{cases}$

តាម $(2)$ $a^2+b^2=(1-a)^2+b^2$

$a^2=1-2a+a^2$ នាំឱ្យ $a=\frac{1}{2}$

តាម $(1)$ $\left(\frac{1}{2}\right)^2+b^2=1 \Rightarrow b=\pm\frac{\sqrt{3}}{2}$

ដូចនេះ កំណត់បានចំនួនកុំផ្លិច $\boxed{z=\frac{1}{2}\pm\frac{\sqrt{3}}{2}i}$ ។

**ខ. ដោះស្រាយសមីការ**

គេមាន $|x|-x=1+2i$ ដែល $x$ ជាចំនួនកុំផ្លិច

តាង $x=a+bi$ នាំឱ្យ $|x|=\sqrt{a^2+b^2}$

គេបាន $\sqrt{a^2+b^2}-(a+ib)=1+2i$

$\left(\sqrt{a^2+b^2}-a\right)-bi=1+2i$

ផ្ទឹមបាន $\begin{cases} \sqrt{a^2+b^2}-a=1 \\ -b=2 \end{cases}$ នាំឱ្យ $\begin{cases} \sqrt{a^2+(-2)^2}-a=1 \\ b=-2 \end{cases}$

គេបាន $\sqrt{a^2+4}=1+a$ (លើកអង្គទាំងពីរជាការេ)

$a^2+4=1+2a+a^2 \Rightarrow a=\frac{3}{2}$

ដូចនេះ សមីការមានឫស $\boxed{x=\frac{3}{2}-2i}$ ។

**គ. ស្រាយថា** $\frac{1}{1+a+ab}+\frac{1}{1+b+bc}+\frac{1}{1+c+ca}=1$

គេមាន $abc=1$ នោះគេបាន ៖

$\frac{1}{1+a+ab}+\frac{1}{1+b+bc}+\frac{1}{1+c+ca}$

$=\frac{1}{1+a+ab}+\frac{a}{a+ab+abc}+\frac{ab}{ab+abc+abca}$

$=\frac{1}{1+a+ab}+\frac{a}{a+ab+1}+\frac{ab}{ab+1+a}$

$=\frac{1+a+ab}{1+a+ab}=1$

ដូចនេះ: $\boxed{\frac{1}{1+a+ab}+\frac{1}{1+b+bc}+\frac{1}{1+c+ca}=1}$ ។

**II.** **ក. រកដែនកំណត់នៃអនុគមន៍** $f$ : (ដូចគ្រូមធ្យមឆ្នាំ ២០១១)

គេមាន $f(x)=\ln\left(x+\sqrt{1+x^2}\right)$

អនុគមន៍ $f$ មានន័យលុះត្រាតែ $\begin{cases} 1+x^2\ge 0 & (1) \\ x+\sqrt{1+x^2}>0 & (2) \end{cases}$

តាម $(1)$ $1+x^2\ge 0$ , $\forall x\in\mathbb{R}$

តាម $(2)$ $x+\sqrt{1+x^2}>0$ ដោយ $\forall x\in\mathbb{R}$

$1+x^2>x^2$

$\sqrt{1+x^2}>\sqrt{x^2}$

$x+\sqrt{1+x^2}>x+|x|$

តែ $\forall x\in\mathbb{R}$ , $x+|x|\ge 0$

នាំឱ្យ $x+\sqrt{1+x^2}>0$ , $\forall x\in\mathbb{R}$

ដូចនេះ: $\boxed{\text{អនុគមន៍ } f \text{ មានដែនកំណត់ } D=\mathbb{R}}$ ។

**ខ. ➢បង្ហាញថា** $f$ **ជាអនុគមន៍សេស**

គេមាន $f(x)=\ln\left(x+\sqrt{1+x^2}\right)$

នាំឱ្យ $f(-x)=\ln\left(-x+\sqrt{1+(-x)^2}\right)$

$=\ln\left(\sqrt{1+x^2}-x\right)$

$=\ln\frac{\left(\sqrt{1+x^2}-x\right)\left(\sqrt{1+x^2}+x\right)}{\left(\sqrt{1+x^2}+x\right)}$

$$= \ln \frac{1+x^2-x^2}{\sqrt{1+x^2}+x} = \ln \frac{1}{\sqrt{1+x^2}+x}$$

$$= \ln\left(\sqrt{1+x^2}+x\right)^{-1}$$

$$= -\ln\left(x+\sqrt{1+x^2}\right) = -f(x)$$

ដោយ $f(-x)= f(x)$

ដូចនេះ $\boxed{f \text{ ជាអនុគមន៍សេស}}$ ។

**➤បង្ហាញថា $f$ ជាអនុគមន៍កើន**

គេមាន $f(x)=\ln\left(x+\sqrt{1+x^2}\right)$

តាមរូបមន្ត $y=\ln(u) \Rightarrow y'=\frac{u'}{u}$

នាំឱ្យ $$f'(x)=\frac{\left(x+\sqrt{1+x^2}\right)'}{x+\sqrt{1+x^2}}=\frac{1+\frac{\left(1+x^2\right)'}{2\sqrt{1+x^2}}}{x+\sqrt{1+x^2}}$$

$$=\frac{1+\frac{x}{\sqrt{1+x^2}}}{x+\sqrt{1+x^2}}=\frac{\frac{\sqrt{1+x^2}+x}{\sqrt{1+x^2}}}{x+\sqrt{1+x^2}}=\frac{1}{\sqrt{1+x^2}}$$

ដោយ $\forall x\in\mathbb{R}$ , $\frac{1}{\sqrt{1+x^2}}>0$ នាំឱ្យ $f'(x)>0$

ដូចនេះ $\boxed{f \text{ ជាអនុគមន៍កើន } \forall x\in\mathbb{R}}$ ។

**III. ក. រកសមីការបន្ទាត់ $(T)$ ដែលប៉ះនឹងខ្សែកោងតាងអនុគមន៍**

គេមាន $y=\frac{e^x}{1-\sin x}$

$$y'=\frac{\left(e^x\right)'(1-\sin x)-(1-\sin x)'e^x}{(1-\sin x)^2}$$

$$=\frac{e^x(1-\sin x)+e^x\cos x}{(1-\sin x)^2}=\frac{e^x(1-\sin x+\cos x)}{(1-\sin x)^2}$$

បន្ទាត់ប៉ះមានរាង $(T): y=y'(x_0)(x-x_0)+y(x_0)$

ដោយ $(T)$ ប៉ះក្រាបត្រង់ចំណុចដែលមានអាប់ស៊ីស $x=0$

គេបាន $x=x_0=0$

$$y'(x_0)=y'(0)=\frac{e^0(1-0+1)}{(1-0)^2}=\frac{2}{1}=2$$

$$y(x_0)=y(0)=\frac{e^0}{1-\sin 0}=\frac{1}{1}=1$$

នាំឱ្យ $(T): y=2(x-0)+1=2x+1$

ដូចនេះ បន្ទាត់ប៉ះរកបានគឺ $\boxed{(T): y=2x+1}$ ។

**ខ. រកកូអរដោនេនៃចំណុចប្រសព្វ $M$**

គេមាន បន្ទាត់ $(T)$ : $y=2x+1$

ខ្សែកោងតាងអនុគមន៍ $y=2x+1+\ln(x-1)$

នោះគេផ្ទឹមបានសមីការអាប់ស៊ីសដូចខាងក្រោម ៖

$2x+1+\ln(x-1)=2x+1$

$\ln(x-1)=0$

$x-1=e^0$

$x=2$

ចំពោះ $x=2$ : $y=2\cdot2+1=5$

ដូចនេះ កូអរដោនេនៃចំណុចប្រសព្វគឺ $\boxed{x=2 , y=5}$ ។

**IV. ក. គណនាផ្ទៃក្រឡាការេទី $n$ :**




គេបានជ្រុងនៃការេបន្តបន្ទាប់ ពីការេទី១ ទី២ ទី៣ ... ទី$n$ គឺ៖

$$\left(\frac{\sqrt2}{2}\right)^0 a , \left(\frac{\sqrt2}{2}\right)^1 a , \left(\frac{\sqrt2}{2}\right)^2 a , \ldots , \left(\frac{\sqrt2}{2}\right)^{n-1} a$$

ផ្ទៃការេទី១ $s_1=\left(\frac{\sqrt2}{2}\right)^{0\times2}a^2$ ឬ $s_1=\left(\frac{1}{2}\right)^0 a^2$

ផ្ទៃការេទី២ $s_2=\left(\frac{\sqrt2}{2}\right)^{1\times2}a^2$ ឬ $s_2=\left(\frac{1}{2}\right)^1 a^2$

ផ្ទៃការេទី៣ $s_3=\left(\frac{\sqrt2}{2}\right)^{2\times2}a^2$ ឬ $s_3=\left(\frac{1}{2}\right)^2 a^2$

............................................

ផ្ទៃការេទី$n$ $s_n=\left(\frac{\sqrt2}{2}\right)^{(n-1)\times2}a^2$ នាំឱ្យ $s_n=\frac{a^2}{2^{n-1}}$

ដូចនេះ ផ្ទៃក្រឡាការេទី $n$ គឺ $\boxed{s_n=\frac{a^2}{2^{n-1}}}$ ឯកតាផ្ទៃក្រឡា ។

ខ. គណនាផលបូកផ្ទៃក្រឡាការេទាំងអស់

$S = s_1 + s_2 + s_3 + \ldots + s_n$

$= \left(\frac{1}{2}\right)^0 a^2 + \left(\frac{1}{2}\right)^1 a^2 + \left(\frac{1}{2}\right)^2 a^2 + \ldots + \left(\frac{1}{2}\right)^{n-1} a^2$

$= a^2\left[\left(\frac{1}{2}\right)^0 + \left(\frac{1}{2}\right)^1 + \left(\frac{1}{2}\right)^2 + \ldots + \left(\frac{1}{2}\right)^{n-1}\right]$

$= a^2\left(\frac{s_1\left(q^n - 1\right)}{q-1}\right) = a^2\left[\frac{1\left(\left(\frac{1}{2}\right)^n - 1\right)}{\frac{1}{2} - 1}\right]$

$= 2a^2\left(1 - \frac{1}{2^n}\right)$

ដូចនេះ គណនាបានផលបូក $\boxed{S = 2a^2\left(1 - \frac{1}{2^n}\right)}$ ។

**V.** ក. រកសមីការប្លង់ $(Q)$ :

ប្លង់ $(Q)$ រាង $a(x - x_0) + b(y - y_0) + c(z - z_0) = 0$

ដោយ $(Q)$ កាត់ $A(3, 2, 0)$

នោះ $x_0 = 3$ , $y_0 = 2$ , $z_0 = 0$

ហើយ $(Q)$ កែងនឹងវ៉ិចទ័រ $(AB)$ នាំឱ្យ $(Q)$ មានវ៉ិចទ័រ

ណរម៉ាល់ $\vec{n} = \overrightarrow{AB} = (-3, -3, 3)$

នោះ $a = -3$ , $b = -3$ , $c = 3$

នាំឱ្យ $(Q): -3(x-3) - 3(y-2) + 3(z-0) = 0$

$(x-3) + (y-2) - (z-0) = 0$

$x + y - z - 5 = 0$

ដូចនេះ សមីការប្លង់កំណត់បាន $\boxed{(Q): x + y - z - 5 = 0}$ ។

ខ. ផ្ទៀងផ្ទាត់ថា $R$ , $S$ និង $T$ ជាចំណុចស្ថិតនៅលើប្លង់ $(Q)$

គេមាន $R(5, 0, 0)$ , $S(0, 5, 0)$ , $T(0, 0, -5)$

និងប្លង់ $(Q): x + y - z - 5 = 0$

បើចំណុច $R, S, T$ ជាចំណុចស្ថិតនៅលើប្លង់ $(Q)$ លុះត្រាតែកូអរដោនេចំណុចទាំងនេះផ្ទៀងផ្ទាត់សមីការប្លង់ $(Q)$ គេបាន ៖

- ចំពោះ $R(5, 0, 0)$ នោះ $(Q): 5 + 0 - 0 - 5 = 0$ ពិត
- ចំពោះ $S(0, 5, 0)$ នោះ $(Q): 0 + 5 - 0 - 5 = 0$ ពិត
- ចំពោះ $T(0, 0, -5)$ នោះ $(Q): 0 + 0 + 5 - 5 = 0$ ពិត

ដូចនេះ $\boxed{R \in (Q), S \in (Q), T \in (Q)}$ ។

គ. គណនាប្រវែង $AB$

ដោយ $\overrightarrow{AB} = (-3, -3, 3)$

នាំឱ្យ $AB = \left|\overrightarrow{AB}\right| = \sqrt{(-3)^2 + (-3)^2 + 3^2} = 3\sqrt{3}$

ដូចនេះ $\boxed{AB = 3\sqrt{3}}$ ឯកតាប្រវែង ។

➢គណនាផ្ទៃក្រឡាត្រីកោណ $RST$

តាមរូបមន្ត $S_{RST} = \frac{1}{2}\left|\overrightarrow{RS} \times \overrightarrow{RT}\right|$

ដោយ $\overrightarrow{RS} = (-5, 5, 0)$ , $\overrightarrow{RT} = (-5, 0, -5)$

គេបាន $\overrightarrow{RS} \times \overrightarrow{RT} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ -5 & 5 & 0 \\ -5 & 0 & -5 \end{vmatrix} = -25\vec{i} - 25\vec{j} + 25\vec{k}$

នាំឱ្យ $\left|\overrightarrow{RS} \times \overrightarrow{RT}\right| = \sqrt{(-25)^2 + (-25)^2 + 25^2} = 25\sqrt{3}$

ដូចនេះ $\boxed{S_{RST} = \frac{25\sqrt{3}}{2}}$ ឯកតាផ្ទៃក្រឡា ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "

## សម័យប្រឡង : ១៥ ធ្នូ ២០០៥

**វិញ្ញាសា** : **គណិតវិទ្យា** **រយៈពេល** : **១២០ នាទី** **ពិន្ទុ** : **១០**

**I.** ក. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច : $x^2-2x+5=0$ ។

ខ. កំណត់តម្លៃនៃ $a$ និង $b$ ដើម្បីឱ្យ $2-i$ ជាឫសនៃសមីការ $ax^2+bx-20=0$ ។

គ. សរសេរ $z=\left(\dfrac{1+i}{1-i}\right)^3$ ជាទម្រង់ត្រីកោណមាត្រ ។ **(២ពិន្ទុ)**

**II.** ចូរសង់ក្រាបនៃអនុគមន៍ : $f(x)=|x|$ រួចស្រាយថាអនុគមន៍ $f(x)$ ជាអនុគមន៍ជាប់ តែគ្មានដេរីវេត្រង់ចំណុច $x=0$ ។ **(២ពិន្ទុ)**

**III.** ក្នុងថង់មួយមានប៊ូលពណ៌ស 12 និងប៊ូលពណ៌ខ្មៅ 15 ។ គេចាប់យកពីក្នុងថង់នូវប៊ូលពីរជាមួយគ្នា ។ តើគេមានប៉ុន្មានរបៀបដើម្បីចាប់យកចេញឱ្យបានយ៉ាងតិចបំផុតប៊ូលពណ៌ ស មួយ ។ **(២ពិន្ទុ)**

**IV.** ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(4,-2,0)$ , $B(1,2,2)$ , $C(2,-1,0)$ និង $D(2,-2,-1)$ ។

ក. កំណត់សមីការប៉ារ៉ាម៉ែតនៃបន្ទាត់ $(d)$ ដែលកាត់តាមចំណុច $A$ ហើយមានវ៉ិចទ័រប្រាប់ទិស $\overrightarrow{CD}$ ។

ខ. សរសេរសមីការប្លង់ $(P)$ ដែលកាត់តាមចំណុច $B$ ហើយកែងនឹងបន្ទាត់ $(CD)$ ។

គ. រកកូអរដោនេនៃចំណុចប្រសព្វរវាងបន្ទាត់ $(d)$ និងប្លង់ $(P)$ ។ **(២ពិន្ទុ)**

**V.** គេឱ្យអនុគមន៍ $f_m(x)=\ln\left(x^2+4x+m\right)$ ។

ក. កំណត់តម្លៃនៃ $m$ ដើម្បីឱ្យអនុគមន៍នេះមានដែនកំណត់ស្មើនឹងចំនួនពិត $\mathbb{R}$ ។

ខ. ចំពោះតម្លៃនៃ $m=0$ ដោះស្រាយសមីការ $f(x)=\ln(x+2)+\ln 2$ ។

គ. ស្រាយបញ្ជាក់ថាអនុគមន៍ $F(x)=2\left[(x+2)\ln|x+2|-x\right]$ ជាព្រីមីទីវនៃអនុគមន៍ $f(x)=\ln\left(x^2+4x+4\right)$ ។ **(២ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០០៥

**I.** **ក. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច :**

គេមាន $x^2-2x+5=0$

$x^2-2x+1=-4$

$(x-1)^2=(2i)^2$

$x-1=\pm 2i$

$x=1\pm 2i$

ដូចនេះ សមីការមានឫសពីរគឺ $\boxed{x=1\pm 2i}$ ។

**ខ. កំណត់តម្លៃនៃ $a$ និង $b$**

បើ $2-i$ ជាឫសនៃសមីការ $ax^2+bx-20=0$

គេបាន $a(2-i)^2+b(2-i)-20=0$

$a(2-i)^2+b(2-i)-20=0$

$a(4-4i+i^2)+2b-bi-20=0$

$(3a+2b-20)+(-4a-b)i=0$

ផ្ទឹមបាន $\begin{cases}3a+2b-20=0\\-4a-b=0\end{cases}\Rightarrow\begin{cases}a=-4\\b=16\end{cases}$

ដូចនេះ កំណត់បាន $\boxed{a=-4\ ,\ b=16}$ ។

**គ. សរសេរ $z$ ជាទម្រង់ត្រីកោណមាត្រ**

គេមាន $z=\left(\dfrac{1+i}{1-i}\right)^3$ ដែល $\dfrac{1+i}{1-i}=\dfrac{1+2i+i^2}{1^2-i^2}=i$

នាំឱ្យ $z=\left(\dfrac{1+i}{1-i}\right)^3=i^3=-i=\cos\dfrac{3\pi}{2}+i\sin\dfrac{3\pi}{2}$

ដូចនេះ ទម្រង់ត្រីកោណមាត្រគឺ $\boxed{z=\cos\dfrac{3\pi}{2}+i\sin\dfrac{3\pi}{2}}$ ។

**II.** **សង់ក្រាបនៃអនុគមន៍** $f(x)=|x|$ : (ដូចគ្រូបឋម២០០៩)

• ចំពោះ $x\geq 0$ : $|x|=x$ នោះ $y=f(x)=x$

• ចំពោះ $x<0$ : $|x|=-x$ នោះ $y=f(x)=-x$

គេសង់ក្រាបបាន តាមករណីនីមួយៗដូចខាងក្រោម ៖




**➢ស្រាយថាអនុគមន៍ $f(x)$ ជាអនុគមន៍ជាប់ត្រង់ $x=0$**

គេមាន $f(x)=|x|=\begin{cases}x & \text{បើ } x\geq 0\\-x & \text{បើ } x<0\end{cases}$

គេបាន $\lim\limits_{x\to 0^+}f(x)=\lim\limits_{x\to 0^+}x=0$

$\lim\limits_{x\to 0^-}f(x)=\lim\limits_{x\to 0^+}(-x)=0$

$f(0)=0$

ដោយ $\lim\limits_{x\to 0^+}f(x)=\lim\limits_{x\to 0^-}f(x)=f(0)=0$

ដូចនេះ $\boxed{f \text{ ជាអនុគមន៍ជាប់ត្រង់ } x=0}$ ។

**➢ស្រាយថាអនុគមន៍ $f(x)$ គ្មានដេរីវេត្រង់ចំណុច $x=0$**

បើ $f$ មានដេរីវេត្រង់ $x=0$ លុះត្រាតែ $f'_-(0)=f'_+(0)$

តាមនិយមន័យដេរីវេ $f'(x_0)=\lim\limits_{x\to x_0}\dfrac{f(x)-f(x_0)}{x-x_0}$

គេបាន $f'_-(0)=\lim\limits_{x\to 0^-}\dfrac{-x-0}{x-0}=-1$

និង $f'_+(0)=\lim\limits_{x\to 0^+}\dfrac{x-0}{x-0}=1$

ដោយ $f'_-(0)\neq f'_+(0)$ នោះ $f$ គ្មានដេរីវេត្រង់ $x=0$ ទេ

ដូចនេះ $\boxed{f \text{ គ្មានដេរីវេត្រង់ } x=0 \text{ ទេ}}$ ។

**III.** **រកចំនួនរបៀបយកបានប៊ូលពណ៌សមួយយ៉ាងតិចបំផុត :**

**របៀបទី១**

គេមាន ប៊ូលពណ៌ស 12 និងប៊ូលខ្មៅ 15 គេយកប៊ូលពីរ

នាំឱ្យ ចំនួនរបៀបចាប់ប៊ូលទាំងអស់ស្មើ $C(27\ ,\ 2)$ ដែល

$C(27\ ,\ 2)=\dfrac{27!}{(27-2)!\cdot 2!}=\dfrac{27\cdot 26\cdot 25!}{25!\cdot 2}=351$

ដោយ ព្រឹត្តិការណ៍យកបានប៊ូលពណ៌សមួយយ៉ាងតិចបំផុត បំពេញនឹងព្រឹត្តិការណ៍យកបានប៊ូលពណ៌ខ្មៅទាំងពីរ

ហើយ ព្រឹត្តិការណ៍យកបានប៊ូលពណ៌ខ្មៅទាំងពីរគឺ $C(15,\ 2)$

$C(15\ ,\ 2)=\dfrac{15!}{(15-2)!\cdot 2!}=\dfrac{15\cdot 14\cdot 13!}{13!\cdot 2}=105$

គេបាន ចំនួនរបៀបយកបានប៊ូលពណ៌សមួយយ៉ាងតិចបំផុតស្មើ $C(27,\ 2)=C(15,\ 2)=351-105=246$ របៀប

ដូចនេះ $\boxed{\text{របៀបយកបានប៊ូលសយ៉ាងតិចមួយគឺ } 246 \text{ របៀប}}$ ។

**របៀបទី២**

ព្រឹត្តិការណ៍យកបានប៊ូលពណ៌សមួយយ៉ាងតិចបំផុតមានន័យថា យកបានប៊ូលសមួយ ឬប៊ូលសពីរ គេបាន ៖

ចំនួនរបៀបយកបានប៊ូលសមួយយ៉ាងតិចបំផុតគឺ

$=C(12\,,1)C(15\,,1)+C(12\,,2)$

$=12\times15+\dfrac{12!}{(12-2)!\cdot 2!}$

$=180+\dfrac{12\cdot11\cdot10!}{10!\cdot 2}=180+66=246$

ដូចនេះ: | របៀបយកបានប៊ូលសយ៉ាងតិចមួយគឺ 246 របៀប | ។

**IV.** **ក. កំណត់សមីការប៉ារ៉ាម៉ែតនៃបន្ទាត់ $(d)$ :**

សមីការប៉ារ៉ាម៉ែតមានរាង $(d):\begin{cases}x=x_0+at\\ y=y_0+bt\,,\,t\in\mathbb{R}\\ z=z_0+ct\end{cases}$

ដោយ $(d)$ កាត់តាមចំណុច $A(4\,,-2\,,0)$

នោះ: $x_0=4\,,\,y_0=-2\,,\,z_0=0$

ហើយ $(d)$ មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{CD}=(0\,,-1\,,-1)$

នោះ: $a=0\,,b=-1\,,c=-1$

ដូចនេះ សមីការប៉ារ៉ាម៉ែត $\boxed{(d):\begin{cases}x=4\\ y=-2-t\,,\,t\in\mathbb{R}\\ z=-t\end{cases}}$ ។

**ខ. សរសេរសមីការប្លង់ $(P)$**

សមីការប្លង់ $(P):a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយ $(P)$ កាត់តាមចំណុច $B(1\,,2\,,2)$

នោះ: $x_0=1\,,\,y_0=2\,,\,z_0=2$

ហើយ $(P)$ កែងនឹងបន្ទាត់ $(CD)$ នាំឱ្យ $(P)$ មានវ៉ិចទ័រណរម៉ាល់ $\overrightarrow{CD}=(0\,,-1\,,-1)$

នោះ: $a=0\,,b=-1\,,c=-1$

គេបាន $(P):0(x-1)-(y-2)-(z-2)=0$

$(P):-(y-2)-(z-2)=0$

$(P):y+z-4=0$

ដូចនេះ សមីការប្លង់ $\boxed{(P):y+z-4=0}$ ។

**គ. រកកូអរដោនេនៃចំណុចប្រសព្វរវាងបន្ទាត់ $(d)$ និងប្លង់ $(P)$**

គេមាន $(d):\begin{cases}x=4\\ y=-2-t\\ z=-t\end{cases}$ និង $(P)\,:\,y+z-4=0$

គេបាន $(-2-t)-t-4=0$

$(-2-t)-t-4=0$

$-2t-6=0$

$t=-3$

ចំពោះ $t=-3$ គេបាន $\begin{cases}x=4\,,\\ y=-2-(-3)\\ z=-(-3)\end{cases}\Rightarrow\begin{cases}x=4\\ y=1\\ z=3\end{cases}$

ដូចនេះ: | កូអរដោនេចំណុចប្រសព្វគឺ $(4\,,1\,,3)$ | ។

**V.** **ក. កំណត់តម្លៃ $m$ ដើម្បីឱ្យអនុគមន៍ មានដែនកំណត់ស្មើ $\mathbb{R}$ :**

គេមាន $f_m(x)=\ln(x^2+4x+m)$

**របៀបទី១**

អនុគមន៍ $f$ មានន័យលុះត្រាតែ $x^2+4x+m>0$

គេបាន $(x^2+4x+4)+(m-4)>0$

$(x+2)^2+(m-4)>0$ , $(x+2)^2\geq0$

ដើម្បីឱ្យ វិសមីការពិតគ្រប់តម្លៃ $x\in\mathbb{R}$ លុះត្រា $m-4>0$

នាំឱ្យ $m>4$

ដូចនេះ: | តម្លៃ $m$ កំណត់បានគឺ $m>4$ | ។

**របៀបទី២**

អនុគមន៍ $f$ មានន័យលុះត្រាតែ $x^2+4x+m>0$

ដើម្បីឱ្យ វិសមីការពិតគ្រប់តម្លៃ $x\in\mathbb{R}$ លុះត្រា $\begin{cases}a>0\\ \Delta'<0\end{cases}$

គេបាន $a=1>0$ , $4-m<0$ នោះ: $m>4$

ដូចនេះ: | តម្លៃ $m$ កំណត់បានគឺ $m>4$ | ។

**ខ. ចំពោះតម្លៃនៃ $m=0$ ដោះស្រាយសមីការ**

គេមាន $f(x)=\ln(x+2)+\ln 2$

គេបាន $\ln(x^2+4x)=\ln(x+2)+\ln 2$

លក្ខខណ្ឌ សមីការមានន័យលុះត្រាតែ $\begin{cases}x^2+4x>0\\ x+2>0\end{cases}$

កន្សោម $x^2+4x$ មានឫស $x=0\,,\,x=-4$

កន្សោម $x+2$ មានឫស $x=-2$

តារាងសញ្ញាដើម្បីទាញរកលក្ខខណ្ឌ

| $x$ | $-\infty$ $-4$ | $-2$ | | $0$ $+\infty$ |
|---|---|---|---|---|
| $x^2+4x>0$ | $+$ | $0$ $-$ | $-$ | $0$ $+$ |
| $x+2>0$ | $-$ | $-$ | $0$ $+$ | $+$ |
| លក្ខខណ្ឌ | | | | |

ហេតុនេះ លក្ខខណ្ឌ $x>0$

គេបាន $\ln\left(x^2+4x\right)=\ln\left(2x+4\right)$

$$x^2+4x=2x+4$$

$$x^2+2x-4=0$$

មាន $\Delta'=1+4=5$

$x=-1+\sqrt{5}$ , $x=-1-\sqrt{5}<0$ មិនយក

ដូចនេះ សមីការមានឫស $\boxed{x=-1+\sqrt{5}}$ ។

**គ. ស្រាយបញ្ជាក់ថាអនុគមន៍ $F(x)$ ជាព្រីមីទីវនៃ $f(x)$**

គេមាន $F(x)=2\left[(x+2)\ln|x+2|-x\right]$

$$f(x)=\ln\left(x^2+4x+4\right)$$

គេបាន $F'(x)=\left(2\left[(x+2)\ln|x+2|-x\right]\right)'$

$$=2\left[(x+2)'\ln|x+2|+\left(\ln|x+2|\right)'(x+2)-1\right]$$

$$=2\left[\ln|x+2|+\frac{(x+2)'}{x+2}(x+2)-1\right]$$

$$=2\left[\ln|x+2|+1-1\right]=2\ln|x+2|$$

$$=\ln(x+2)^2=\ln\left(x^2+4x+4\right)=f(x)$$

ដោយ $F'(x)=f(x)$

នាំឱ្យ $F(x)$ ជាព្រីមីទីវនៃ $f(x)$

ដូចនេះ $\boxed{\text{អនុគមន៍ } F(x) \text{ ជាព្រីមីទីវនៃ } f(x)}$ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................
លេខបន្ទប់ : ..................................
លេខតុ : ..................................
ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "
## សម័យប្រឡង : ១៣ វិច្ឆិកា ២០០៤

**វិញ្ញាសា** : **គណិតវិទ្យា** **រយៈពេល** : ១២០ **នាទី** **ពិន្ទុ** : ១០

**I.** ចូរដោះស្រាយវិសមីការ :

ក. $\sin x+\sqrt{3}\cos x\geq 1$ បើ $-\pi<x<\pi$ ។

ខ. $\log_2(2-x)+\log_4(x+3)\leq 1$ ។ **(១ពិន្ទុកន្លះ)**

**II.** ក. កំណត់ចំនួនថេរ $a$ និង $b$ ដើម្បីឱ្យចំពោះគ្រប់ $x$ គេបាន : $\dfrac{1}{x(x+1)(x+2)}=\dfrac{a}{x(x+1)}+\dfrac{b}{(x+1)(x+2)}$ ។

ខ. គណនាផលបូក $S=\dfrac{1}{1\cdot2\cdot3}+\dfrac{1}{2\cdot3\cdot4}+\ldots+\dfrac{1}{n(n+1)(n+2)}$ រួចរកលីមីត $S$ កាលណា $n\to+\infty$ ។ **(១ពិន្ទុកន្លះ)**

**III.** គេបង្កើតគណៈកម្មការមួយមានសមាជិក 5 នាក់ ក្នុងចំណោម 12 នាក់ ។ ចំពោះមនុស្សទាំងនេះ មានពីរនាក់ $A$ និង $B$ អាចចូលជាសមាជិកបានលុះត្រាតែចូលទាំងពីរនាក់ ។

ក. តើគេអាចបង្កើតគណៈកម្មការនេះបានប៉ុន្មានរបៀប ?

ខ. រកប្រូបាបដើម្បីឱ្យ $A$ និង $B$ បានចូលជាសមាជិកគណៈកម្មការទាំងពីរនាក់ ។ **(២ពិន្ទុ)**

**IV.** ក្នុងតម្រុយអរតូណរម៉ាល់នៃលំហគេឱ្យប្លង់ $(P)$ និងស្វ៊ែ $(S)$ មានសមីការរៀងគ្នា : $(P): x+2y+2z+5=0$ និង $(S): x^2+y^2+z^2-2x-4y+4z=0$ ។

ក. កំណត់កូអរដោនេផ្ចិត $I$ និងកាំ $R$ នៃស្វ៊ែ $(S)$ ។

ខ. បង្ហាញថាប្លង់ $(P)$ កាត់ស្វ៊ែ $(S)$ រួចរកសមីការបណ្តាប្លង់ស្របនឹងប្លង់ $(P)$ ហើយប៉ះនឹងស្វ៊ែ $(S)$ ។ **(២ពិន្ទុ)**

**V.** គេឱ្យអនុគមន៍ $y=f(x)=\dfrac{x^2-2x+1}{-2x-4}$ ។

ក. សិក្សាអថេរភាព និងសង់ខ្សែកោង $(C)$ តាងអនុគមន៍ រួចស្រាយថាខ្សែកោងនេះមានផ្ចិតឆ្លុះមួយ ។

ខ. កំណត់សមីការបន្ទាត់ប៉ះនឹងខ្សែកោង $(C)$ ដោយដឹងថាបន្ទាត់ប៉ះនេះកាត់តាមចំណុច $A(0\,,\,2)$ ។

គ. គណនាក្រឡាផ្ទៃ $S$ ផ្នែកប្លង់ខណ្ឌដោយខ្សែកោង $(C)$ អាស៊ីមតូតទ្រេត និងបន្ទាត់ $x=3\,,\,x=4$ ។ **(៣ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០០៤

**I. ដោះស្រាយវិសមីការ :**

ក. $\sin x+\sqrt{3}\cos x\ge 1$ ( បើ $-\pi<x<\pi$ )

$$\frac{1}{2}\sin x+\frac{\sqrt{3}}{2}\cos x\ge\frac{1}{2}$$

$$\cos\frac{\pi}{3}\sin x+\sin\frac{\pi}{3}\cos x\ge\frac{1}{2}$$

$$\sin\left(x+\frac{\pi}{3}\right)\ge\frac{1}{2}$$

$$\frac{\pi}{6}\le x+\frac{\pi}{3}\le\frac{5\pi}{6}$$

$$\frac{\pi}{6}-\frac{\pi}{3}\le x\le\frac{5\pi}{6}-\frac{\pi}{3}$$

$$-\frac{\pi}{6}\le x\le\frac{\pi}{2}$$




ដូចនេះ វិសមីការមានចម្លើយ $\boxed{-\frac{\pi}{6}\le x\le\frac{\pi}{2}}$ ។

ខ. $\log_2(2-x)+\log_4(x+3)\le 1$

វិសមីការមានន័យលុះត្រាតែ $\begin{cases}2-x>0\\ x+3>0\end{cases}\Rightarrow -3<x<2$

គេបាន $\log_2(2-x)+\frac{1}{2}\log_2(x+3)\le 1$

$$2\log_2(2-x)+\log_2(x+3)\le 2$$

$$\log_2(2-x)^2+\log_2(x+3)\le 2$$

$$\log_2(4-4x+x^2)(x+3)\le\log_2 2^2$$

$$4x+12-4x^2-12x+x^3+3x^2\le 4$$

$$x^3-x^2-8x+8\le 0$$

$$x^2(x-1)-8(x-1)\le 0$$

$$(x-1)(x^2-8)\le 0$$

ឱ្យ $x-1=0\Rightarrow x=1$ និង $x^2-8=0\Rightarrow x=\pm 2\sqrt{2}$

តារាងសញ្ញា

| $x$ | $-\infty$   $-3$ | $-2\sqrt{2}$ | | $1$ | $2$   $2\sqrt{2}$ | $+\infty$ |
|---|---|---|---|---|---|---|
| $x-1$ | $-$ | $-$ | $-$ 0 | $+$ | $+$ | $+$ |
| $x^2-8$ | $+$ | $+$ 0 | $-$ | $-$ | $-$ 0 | $+$ |
| $(x-1)(x^2-8)\le 0$ | $-$ | $-$ 0 | $+$ 0 | $-$ | $-$ 0 | $+$ |
| $-3<x<2$ | | | | | | |
| ចម្លើយ | | | | | | |

ដូចនេះ $\boxed{x\in\left(-3\,,-2\sqrt{2}\right]\cup\left[1\,,2\right)}$ ជាចម្លើយ ។

**II.** ក. កំណត់ចំនួនថេរ $a$ និង $b$ : (ដូចគ្រូមធ្យមឆ្នាំ 2009)

គេមាន $\dfrac{1}{x(x+1)(x+2)}=\dfrac{a}{x(x+1)}+\dfrac{b}{(x+1)(x+2)}$

$$=\frac{a(x+2)+bx}{x(x+1)(x+2)}=\frac{(a+b)x+2a}{x(x+1)(x+2)}$$

ផ្ទឹមបាន $\begin{cases}a+b=0\\ 2a=1\end{cases}\Rightarrow a=\frac{1}{2}\ ,\ b=-\frac{1}{2}$

ដូចនេះ៖ កំណត់បាន $\boxed{a=\frac{1}{2}\ ,\ b=-\frac{1}{2}}$ ។

ខ. គណនាផលបូក $S$

គេមាន $S=\dfrac{1}{1\cdot2\cdot3}+\dfrac{1}{2\cdot3\cdot4}+.......+\dfrac{1}{n(n+1)(n+2)}$

ហើយ $\dfrac{1}{x(x+1)(x+2)}=\dfrac{1/2}{x(x+1)}+\dfrac{-1/2}{(x+1)(x+2)}$

$$\frac{1}{x(x+1)(x+2)}=\frac{1}{2}\left[\frac{1}{x(x+1)}-\frac{1}{(x+1)(x+2)}\right]$$

យក $x=1\,,2\,,3\,,\dots,n$ គេបាន ៖

$$+\begin{cases}\dfrac{1}{1\cdot2\cdot3}=\dfrac{1}{2}\left[\dfrac{1}{1\cdot2}-\dfrac{1}{2\cdot3}\right]\\ \dfrac{1}{2\cdot3\cdot4}=\dfrac{1}{2}\left[\dfrac{1}{2\cdot3}-\dfrac{1}{3\cdot4}\right]\\ \dfrac{1}{3\cdot4\cdot5}=\dfrac{1}{2}\left[\dfrac{1}{3\cdot4}-\dfrac{1}{4\cdot5}\right]\\ \dots\dots\dots\dots\\ \dfrac{1}{n(n+1)(n+2)}=\dfrac{1}{2}\left[\dfrac{1}{n(n+1)}-\dfrac{1}{(n+1)(n+2)}\right]\end{cases}$$

$$S=\frac{1}{2}\left(\frac{1}{1\cdot2}-\frac{1}{(n+1)(n+2)}\right)$$

ដូចនេះ៖ គណនាបាន $\boxed{S=\frac{1}{2}\left(\frac{1}{2}-\frac{1}{(n+1)(n+2)}\right)}$

➢រកលីមីត $S$ កាលណា $n\to+\infty$

គេមាន $\lim\limits_{n\to+\infty}S=\lim\limits_{n\to+\infty}\frac{1}{2}\left(\frac{1}{2}-\frac{1}{(n+1)(n+2)}\right)$

$$=\frac{1}{2}\left(\frac{1}{2}-0\right)=\frac{1}{4}$$

ដូចនេះ៖ គណនាបាន $\boxed{\lim\limits_{n\to+\infty}S=\frac{1}{4}}$ ។

**III.** **ក. តើគេអាចបង្កើតគណៈកម្មការនេះបានប៉ុន្មានរបៀប ?**

ដោយ មនុស្សទាំងអស់មាន 12 នាក់ ចង់បង្កើតគណៈកម្មការមានគ្នា 5 នាក់ វាជាបន្សំនៃ 5 ធាតុយកពី 12 ធាតុ

គេតាង $n(s)=C(12\,,5)=\dfrac{12!}{(12-5)!\cdot 5!}$

$=\dfrac{12\cdot 11\cdot 10\cdot 9\cdot 8\cdot 7!}{7!\cdot 5\cdot 4\cdot 3\cdot 2}=792$

ដូចនេះ | ចំនួនគណៈកម្មការបង្កើតបាន 792 របៀប | ។

**ខ. រកប្រូបាប $A$ និង $B$ ចូលជាសមាជិកទាំងពីរនាក់**

ដើម្បីជ្រើសរើសបាន $A$ និង $B$ ទាំងពីរនាក់ នោះគេត្រូវជ្រើសរើសមនុស្ស 3 ពី 10 នាក់ផ្សេងទៀត

តាង $A$ ជាព្រឹត្តិការណ៍ជ្រើសបានទាំង $A$ និង $B$

គេបាន $n(A)=C(2\,,2)\times C(10\,,3)$

$=1\times\dfrac{10!}{(10-3)!\cdot 3!}=\dfrac{10\cdot 9\cdot 8\cdot 7!}{7!\cdot 3\cdot 2}=120$

នាំឱ្យ $P(A)=\dfrac{n(A)}{n(S)}=\dfrac{120}{792}=\dfrac{5}{33}$

ដូចនេះ ប្រូបាបរកបានគឺ $\boxed{P(A)=\dfrac{5}{33}}$ ។

**IV.** **ក. កំណត់កូអរដោនេផ្ចិត $I$ និងកាំ $R$ នៃស្វ៊ែ $(S)$**

គេបំលែងងសមីការស្វ៊ែ $(S)$ ជាទម្រង់ស្តង់ដា

$(S):\ x^2+y^2+z^2-2x-4y+4z=0$

$(x^2-2x)+(y^2-4y)+(z^2+4z)=0$

$(x^2-2x+1)+(y^2-4y+4)+(z^2+4z+4)=9$

$(x-1)^2+(y-2)^2+(z+2)^2=3^2$

ផ្ទឹមនឹង $(x-a)^2+(y-b)^2+(z-c)^2=r^2$

នាំឱ្យ ផ្ចិត $I(a\,,b\,,c)=I(1\,,2\,,-2)$ , កាំ $r=3$

ដូចនេះ | ស្វ៊ែនេះមានផ្ចិត $I(1\,,2\,,-2)$ និងកាំ $r=3$ | ។

**ខ. បង្ហាញថាប្លង់ $(P)$ កាត់ស្វ៊ែ $(S)$**

តាមរូបមន្ត $d(I\,,(P))=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$

ដោយ $I(1\,,2\,,-2)$ និង $(P):x+2y+2z+5=0$

នាំឱ្យ $d(I\,,(P))=\dfrac{|1\cdot 1+2\cdot 2+2(-2)+5|}{\sqrt{1^2+2^2+2^2}}=\dfrac{|6|}{3}=2$

ដោយ $d=2<r=3$ នោះប្លង់ $(P)$ ត្រូវកាត់ស្វ៊ែ $(S)$

ដូចនេះ | ប្លង់ $(P)$ ត្រូវកាត់ស្វ៊ែ $(S)$ ត្រូវបានបង្ហាញ | ។

**➤រកសមីការបណ្តាប្លង់ស្របនឹងប្លង់ $(P)$ ហើយប៉ះនឹងស្វ៊ែ $(S)$**

គេតាង សមីការប្លង់ត្រូវរកមានរាង ៖

$(\alpha)\ :\ ax+by+cz+d=0$

ដោយ $(\alpha)\parallel(P)$ នោះ $(\alpha)$ មានវ៉ិចទ័រណរម៉ាល់ដូច $(P)$ គឺ $\vec{n}=(1\,,2\,,2)$ នោះគេបាន ៖

$(\alpha)\ :\ x+2y+2z+d=0$

តែប្លង់ $(\alpha)$ ប៉ះស្វ៊ែ $(S)$ នោះ $d(I\,,(\alpha))=r=3$

គេបាន $\dfrac{|1\cdot 1+2\cdot 2+2(-2)+d|}{\sqrt{1^2+2^2+2^2}}=3\Leftrightarrow\dfrac{|1+d|}{3}=3$

នាំឱ្យ $|1+d|=9\Leftrightarrow 1+d=\pm 9\Rightarrow\left[\begin{array}{l}d=-10\\ d=8\end{array}\right.$

ដូចនេះ បណ្តាសមីការប្លង់ត្រូវរកអាចសរសេរបានគឺ ៖

$\boxed{\begin{array}{l}(\alpha_1)\ :\ x+2y+2z-10=0\\ (\alpha_2)\ :\ x+2y+2z+8=0\end{array}}$ ។

**V.** **ក. សិក្សាអថេរភាព និងសង់ខ្សែកោង $(C)$ តាងអនុគមន៍**

គេមាន $y=f(x)=\dfrac{x^2-2x+1}{-2x-4}$

• ដែនកំណត់ : អនុគមន៍ $f$ មានន័យលុះត្រាតែ $-2x-4\neq 0$

នាំឱ្យ $-2x\neq 4$ នោះ $x\neq -2$

ដូចនេះ $\boxed{D=\mathbb{R}-\{-2\}=(-\infty\,,-2)\cup(-2\,,+\infty)}$ ។

• ទិសដៅអថេរភាព

ដេរីវេ $f'(x)=\left(\dfrac{x^2-2x+1}{-2x-4}\right)'$

$=\dfrac{(2x-2)(-2x-4)+2(x^2-2x+1)}{(2x+4)^2}$

$=\dfrac{2(x-1)(-2x-4)+2(x-1)^2}{(2x+4)^2}$

$=\dfrac{2(x-1)(-2x-4+x-1)}{(2x+4)^2}$

$=\dfrac{2(x-1)(-x-5)}{(2x+4)^2}$

គេឱ្យ $f'(x)=0 \Leftrightarrow \dfrac{2(x-1)(-x-5)}{(2x+4)^2}=0$

$\forall x\in D\ ,\ \Leftrightarrow (2x+4)^2>0$

នាំឱ្យ $(x-1)(-x-5)=0$ នោះ $x=1\ ,\ x=-5$

គេបាន $f(1)=\dfrac{1^2-2\cdot 1+1}{-2\cdot 1-4}=0$

$f(-5)=\dfrac{(-5)^2-2(-5)+1}{-2(-5)-4}=\dfrac{36}{6}=6$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $-5$ | | $-2$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | ‖ | $+$ | $0$ | $-$ | |

• ត្រង់ $x=-5\ ,\ f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$ បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើនឹង $f(-5)=6$ ។

• ត្រង់ $x=1\ ,\ f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$ បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើនឹង $f(1)=0$ ។

• លីមីត និងអាស៊ីមតូត

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\frac{x^2-2x+1}{-2x-4}=\lim_{x\to+\infty}\frac{x^2}{-2x}=-\infty$$

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\frac{x^2-2x+1}{-2x-4}=\lim_{x\to-\infty}\frac{x^2}{-2x}=+\infty$$

$$\lim_{x\to-2^-} f(x)=\lim_{x\to-2^-}\frac{x^2-2x+1}{-2(x+2)}=\frac{9}{-2(-2+0^-+2)}=+\infty$$

$$\lim_{x\to-2^+} f(x)=\lim_{x\to-2^+}\frac{x^2-2x+1}{-2(x+2)}=\frac{9}{-2(-2+0^++2)}=-\infty$$

ដោយ $\lim\limits_{x\to-2} f(x)=\pm\infty$ នោះបន្ទាត់ដែលមានសមីការ

$x=-2$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ។

ម្យ៉ាងទៀត $f(x)=\dfrac{x^2-2x+1}{-2x-4}=-\dfrac{1}{2}x+2+\dfrac{9}{-2x-4}$

ដោយ $\lim\limits_{x\to\pm\infty}\dfrac{9}{-2x-4}=0$ នោះបន្ទាត់ដែលមានសមីការ

$y=-\dfrac{1}{2}x+2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

• តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-\infty$ | | $-5$ | | $-2$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | $+\infty$ | ↘ | $6$ | ↗ $+\infty$ | ‖ | $-\infty$ ↗ | $0$ | ↘ | $-\infty$ |

➢សង់ខ្សែកោង $(C)$ តាងអនុគមន៍




➢ស្រាយថាខ្សែកោងនេះមានផ្ចិតបំលែងឆ្លុះមួយ

របៀបទី១ តាមរូបមន្ត

ដោយ អាស៊ីមតូតទាំងពីរ $x=-2$ និង $y=-\dfrac{1}{2}x+2$

ប្រសព្វគ្នាត្រង់ចំណុច $I(-2\ ,\ 3)$ គេនឹងស្រាយថា

$I$ ជាផ្ចិតបំលែងឆ្លុះនៃក្រាប $(C)$

បើ $I(a\ ,\ b)$ ជាផ្ចិតឆ្លុះនៃក្រាប $C$ តាងអនុគមន៍ $f$ លុះត្រាតែ

វាផ្ទៀងផ្ទាត់ $f(2a-x)+f(x)=2b$

គេបាន $f(-4-x)+f(x)=6$

ដោយ $f(-4-x)=\dfrac{(-4-x)^2-2(-4-x)+1}{-2(-4-x)-4}$

$=\dfrac{16+8x+x^2+8+2x+1}{8+2x-4}$

$=\dfrac{x^2+10x+25}{2x+4}=\dfrac{-x^2-10x-25}{-2x-4}$

គេបាន $\dfrac{-x^2-10x-25}{-2x-4}+\dfrac{x^2-2x+1}{-2x-4}=\dfrac{-12x-24}{-2x-4}=6$

ដូចនេះ **ក្រាប $(C)$ មានផ្ចិតឆ្លុះមួយគឺ $I(-2\ ,\ 3)$** ។

**របៀបទី២ តាមវិធីរំកិលអ័ក្ស**

គេបំលែងកិលអ័ក្សពីតម្រុយ $xoy$ ទៅតម្រុយថ្មី $XIY$

តាមរូបមន្ត បំលែងកិលអ័ក្ស $\begin{cases} x = a + X \\ y = b + Y \end{cases}$

ដោយ អាស៊ីមតូតទាំងពីរ $x = -2$ និង $y = -\frac{1}{2}x + 2$

ប្រសព្វគ្នាត្រង់ចំណុច $I(a, b) = I(-2, 3)$

គេបាន $\begin{cases} x = -2 + X \\ y = 3 + Y \end{cases}$

គេមាន $y = f(x) = \frac{x^2 - 2x + 1}{-2x - 4}$

គេបាន $Y + 3 = \frac{x^2 - 2x + 1}{-2x - 4}$

$$Y + 3 = \frac{(X-2)^2 - 2(X-2) + 1}{-2(X-2) - 4}$$

$$Y = \frac{X^2 - 4X + 4 - 2X + 4 + 1}{-2X} - 3$$

$$F(X) = \frac{X^2 + 9}{-2X} \quad , \quad Y = F(X)$$

ដោយ $\forall X \neq 0$ គេបាន ៖

$$F(-X) = \frac{(-X)^2 + 9}{2X} = -\frac{X^2 + 9}{-2X} = -F(X)$$

នាំឱ្យ $F(X)$ ជាអនុគមន៍សេសមាន $I(-2, 3)$ ជាផ្ចិតឆ្លុះ

ដូចនេះ ក្រាប $(C)$ មានផ្ចិតឆ្លុះមួយគឺ $I(-2, 3)$ ។

**ខ. កំណត់សមីការបន្ទាត់ប៉ះនឹងខ្សែកោង $(C)$**

**➤របៀបទី១**

សមីការបន្ទាត់ប៉ះមានរាង $y = f'(x_0)(x - x_0) + f(x_0)$

គេបាន $y = f'(x_0)x - f'(x_0)x_0 + f(x_0)$

ដោយ បន្ទាត់ប៉ះនេះកាត់តាមចំណុច $A(0, 2)$

$$f'(x_0)\cdot 0 - f'(x_0)x_0 + f(x_0) = 2$$

$$-f'(x_0)x_0 + f(x_0) = 2$$

តែ $-f'(x_0)x_0 = \frac{-2(x_0 - 1)(-x_0 - 5)x_0}{(2x_0 + 4)^2}$

$$= \frac{(2x_0^2 - 2x_0)(x_0 + 5)}{(2x_0 + 4)^2}$$

$$= \frac{2x_0^3 + 8x_0^2 - 10x_0}{(2x_0 + 4)^2}$$

$$f(x_0) = \frac{x_0^2 - 2x_0 + 1}{-2x_0 - 4} = \frac{(x_0^2 - 2x_0 + 1)(-2x_0 - 4)}{(2x_0 + 4)^2}$$

$$= \frac{-2x_0^3 + 6x_0 - 4}{(2x_0 + 4)^2}$$

គេបាន $\frac{2x_0^3 + 8x_0^2 - 10x_0}{(2x_0 + 4)^2} + \frac{-2x_0^3 + 6x_0 - 4}{(2x_0 + 4)^2} = 2$

$$\frac{2x_0^3 + 8x_0^2 - 10x_0}{(2x_0 + 4)^2} + \frac{-2x_0^3 + 6x_0 - 4}{(2x_0 + 4)^2} = 2$$

$$8x_0^2 - 4x_0 - 4 = 2(2x_0 + 4)^2$$

$$8x_0^2 - 4x_0 - 4 = 2(4x_0^2 + 16x_0 + 16)$$

$$8x_0^2 - 4x_0 - 4 = 8x_0^2 + 32x_0 + 32$$

$$36x_0 = -36$$

$$x_0 = -1$$

នាំឱ្យ $f'(x_0) = f'(-1) = \frac{2(-1-1)(1-5)}{(-2+4)^2} = 4$

$$f(x_0) = f(-1) = \frac{(-1)^2 - 2(-1) + 1}{-2(-1) - 4} = -2$$

នាំឱ្យ $y = 4(x+1) + (-2) = 4x + 2$

ដូចនេះ សមីការបន្ទាត់ប៉ះរកបានគឺ $\boxed{y = 4x + 2}$ ។

**➤របៀបទី២**

សមីការបន្ទាត់ប៉ះមានរាង $(T):\ y = ax + b$

ដោយ $(T)$ កាត់ $A(0, 2)$ នោះ $2 = 0\cdot a + b$ ឬ $b = 2$

គេបាន $(T):\ y = ax + 2$

ដោយ $(T)$ ប៉ះ $(C)$ គេផ្ទឹមបានសមីការអាប់ស៊ីស

$$\frac{x^2 - 2x + 1}{-2x - 4} = ax + 2$$

$$x^2 - 2x + 1 = -2ax^2 - 4x - 4ax - 8$$

$$(1 + 2a)x^2 + (2 + 4a)x + 9 = 0$$

ដើម្បីឱ្យ $(T)$ ប៉ះ $(C)$ លុះត្រាសមីការមានឫសឌុប $\begin{cases} \Delta' = 0 \\ a \neq -1/2 \end{cases}$

គេបាន $(1 + 2a)^2 - 9(1 + 2a) = 0$

$$(1 + 2a)(2a - 8) = 0$$

$a = 4$ , $a = -\frac{1}{2}$ មិនយក (ធ្វើឱ្យជាសមី.ដឺក្រេទី១)

ដូចនេះ សមីការបន្ទាត់ប៉ះរកបានគឺ $\boxed{y = 4x + 2}$ ។

**គ. គណនាក្រឡាផ្ទៃ $S$ ផ្នែកប្លង់ខណ្ឌដោយខ្សែកោង $(C)$ អាស៊ីមតូតទ្រេត និងបន្ទាត់ $x=3$ , $x=4$**

តាមក្រាប នៅចន្លោះ $3 \le x \le 4$ អាស៊ីមតូតទ្រេតនៅពីលើក្រាប

គេបាន ផ្ទៃកំណត់ដោយ $S=\int_3^4 \left[y-(c)\right]dx$ គេបាន ៖

$$S=\int_3^4 \left[-\frac{1}{2}x+2-\left(-\frac{1}{2}x+2+\frac{9}{-2x-4}\right)\right]dx$$

$$=\int_3^4 \frac{9}{2x+4}dx$$

$$=\frac{9}{2}\int_3^4 \frac{1}{x+2}dx$$

$$=\frac{9}{2}\left[\ln|x+2|\right]_3^4$$

$$=\frac{9}{2}(\ln 6-\ln 5)$$

$$=\frac{9}{2}\ln\frac{6}{5}$$

ដូចនេះ ផ្ទៃប្លង់កំណត់បាន $S=\frac{9}{2}\ln\frac{6}{5}$ ឯកតាផ្ទៃក្រឡា ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "**

**សម័យប្រឡង : ១៤ ធ្នូ ២០០៣**

**វិញ្ញាសា : គណិតវិទ្យា  រយៈពេល : ១២០ នាទី  ពិន្ទុ : ១០**

**I.** ក. គណនាដេរីវេនៃអនុគមន៍ : $f(x)=(x^2+3x+5)e^{6x}$ , $g(x)=\ln\dfrac{x+1}{x-1}$ ។

ខ. សរសេរសមីការបន្ទាត់ប៉ះនៃខ្សែកោងតាងអនុគមន៍ $h(x)=x\ln x+1$ ត្រង់ចំណុច $M(1,1)$ ។ **(២ពិន្ទុ)**

**II.** ក. គណនាអាំងតេក្រាលមិនកំណត់ : $I=\int(2\sin x+3\cos x)dx$ , $J=\int\dfrac{dx}{x^2-5x+6}$ ។

ខ. រកផ្ទៃក្រឡាខណ្ឌដោយខ្សែកោងតាងអនុគមន៍ $y=x^2+2x$ និងបន្ទាត់ $y=x+2$ ។ **(២ពិន្ទុ)**

**III.** ដោះស្រាយសមីការ : $\dfrac{4-x}{1986}+\dfrac{3-x}{1987}+\dfrac{2-x}{1988}+\dfrac{1-x}{1989}=-4$ ។ **(១ពិន្ទុ)**

**IV.** គេមានបីចំណុច $A(-1,1,2)$ , $B(0,2,4)$ និង $C(-1,3,1)$ ។

ក. គណនាផលគុណនៃពីរវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញបញ្ជាក់ថា ចំណុច $A$ , $B$ និង $C$ មិនរត់ត្រង់គ្នា ។

ខ. ចូររកផ្ទៃក្រឡានៃត្រីកោណ $ABC$ ។ **(២ពិន្ទុ)**

**V.** គេឱ្យអនុគមន៍ $y=\dfrac{3-x}{x}$ ។

ក. សិក្សាទិសដៅអថេរភាព និងសង់ខ្សែកោង $C$ តាងអនុគមន៍ ។

ខ. ចំណុច $A$ និង $B$ មានអាប់ស៊ីសរៀងគ្នា $1$ និង $3$ ស្ថិតនៅលើខ្សែកោង $C$ ។ ចូរកំណត់សមីការបន្ទាត់ $AB$ រួចទាញរកសមីការបន្ទាត់ប៉ះនឹងខ្សែកោង $C$ ទាំងអស់ដែលស្របនឹងបន្ទាត់ $AB$ ។ **(៣ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០០៣

**I.** **ក. គណនាដេរីវេនៃអនុគមន៍ :**

$$f(x)=\left(x^2+3x+5\right)e^{6x}$$

$$f'(x)=\left(x^2+3x+5\right)'e^{6x}+\left(e^{6x}\right)'\left(x^2+3x+5\right)$$

$$=(2x+3)e^{6x}+6e^{6x}\left(x^2+3x+5\right)$$

$$=\boxed{\left(6x^2+20x+33\right)e^{6x}}$$

$$g(x)=\ln\frac{x+1}{x-1}=\ln(x+1)-\ln(x-1)$$

$$g'(x)=\frac{(x+1)'}{x+1}-\frac{(x-1)'}{x-1}$$

$$=\frac{1}{x+1}-\frac{1}{x-1}=\frac{x-1-x-1}{x^2-1}=\boxed{-\frac{2}{x^2-1}}$$

**ខ. សរសេរសមីការបន្ទាត់ប៉ះនៃខ្សែកោងតាងអនុគមន៍ :**

គេមាន $h(x)=x\ln x+1$ និងចំណុច $M(1,1)$

សមីការបន្ទាត់ប៉ះមានរាង $y=h'(x_0)(x-x_0)+h(x_0)$

គេមាន បន្ទាត់ប៉ះក្រាបត្រង់ចំណុច $M(1,1)$

នោះ $x_0=1$ , $h(x_0)=1$

ហើយ $h'(x)=x'\ln x+x(\ln x)'=\ln x+1$

$h'(x_0)=h'(1)=\ln 1+1=1$

នាំឱ្យ $y=1(x-1)+1=x$

ដូចនេះ សមីការបន្ទាត់ប៉ះ $\boxed{y=x}$ ។

**II.** **ក. គណនាអាំងតេក្រាលមិនកំណត់ :**

$$\mathbf{I}=\int(2\sin x+3\cos x)\,dx$$

$=-2\cos x+3\sin x+c$ , $c$ ថេរ

ដូចនេះ $\boxed{\mathbf{I}=-2\cos x+3\sin x+c \;\; , c \text{ ថេរ}}$ ។

$$\mathbf{J}=\int\frac{dx}{x^2-5x+6}=\int\frac{dx}{(x-2)(x-3)}$$

$$=\int\left(\frac{1}{x-3}-\frac{1}{x-2}\right)dx=\int\left(\frac{(x-3)'}{x-3}-\frac{(x-2)'}{x-2}\right)dx$$

$=\ln|x-3|-\ln|x-2|+c$ , $c$ ថេរ

ដូចនេះ $\boxed{\mathbf{J}=\ln\left|\frac{x-3}{x-2}\right|+c \;\; , c \text{ ថេរ}}$ ។

**ខ. រកផ្ទៃក្រឡាខណ្ឌដោយខ្សែកោង និងបន្ទាត់**

គេមាន ខ្សែកោង $y=x^2+2x$ និងបន្ទាត់ $y=x+2$

គេសង់ក្រាបប៉ារ៉ាបូល និងបន្ទាត់ ដើម្បីដឹងទីតាំង និងប្រើរូបមន្ត




តាមក្រាបផ្ទៃក្រឡាប្លង់ដែលខណ្ឌដោយក្រាបទាំងពីរគឺ

$$S=\int_{-2}^{1}\left[(x+2)-\left(x^2+2x\right)\right]dx$$

$$=\int_{-2}^{1}\left(-x^2-x+2\right)dx$$

$$=\left[-\frac{x^3}{3}-\frac{x^2}{2}+2x\right]_{-2}^{1}$$

$$=\left(-\frac{1}{3}-\frac{1}{2}+2\right)-\left(\frac{8}{3}-\frac{4}{2}-4\right)=-3+\frac{3}{2}+6=\frac{9}{2}$$

ដូចនេះ $\boxed{\text{ផ្ទៃគណនាបាន } S=4.5 \text{ ឯកតាផ្ទៃ}}$ ។

**III.** **ដោះស្រាយសមីការ :**

$$\frac{4-x}{1986}+\frac{3-x}{1987}+\frac{2-x}{1988}+\frac{1-x}{1989}=-4$$

$$\frac{4-x}{1986}+1+\frac{3-x}{1987}+1+\frac{2-x}{1988}+1+\frac{1-x}{1989}+1=0$$

$$\frac{1990-x}{1986}+\frac{1990-x}{1987}+\frac{1990-x}{1988}+\frac{1990-x}{1989}=0$$

$$(1990-x)\left(\frac{1}{1986}+\frac{1}{1987}+\frac{1}{1988}+\frac{1}{1989}\right)=0$$

នាំឱ្យ $1990-x=0\Rightarrow x=1990$

ដូចនេះ សមីការមានឬសតែមួយគត់គឺ $\boxed{x=1990}$ ។

**IV.** ក. គណនាផលគុណនៃពីរវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ :

គេមាន $A(-1,1,2)$ , $B(0,2,4)$ និង $C(-1,3,1)$

នាំឱ្យ $\overrightarrow{AB}=(1,1,2)$ , $\overrightarrow{AC}=(0,2,-1)$

គេបាន $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & 1 & 2\\ 0 & 2 & -1\end{vmatrix}=-5\vec{i}+\vec{j}+2\vec{k}$

ដូចនេះ: គណនាបាន $\boxed{\overrightarrow{AB}\times\overrightarrow{AC}=-5\vec{i}+\vec{j}+2\vec{k}}$ ។

➤ **ទាញបញ្ជាក់ថា ចំណុច $A$ , $B$ និង $C$ មិនរត់ត្រង់គ្នា**

ដោយ $\overrightarrow{AB}\times\overrightarrow{AC}=-5\vec{i}+\vec{j}+2\vec{k}\neq\vec{0}$

ដូចនេះ: $\boxed{\text{បីចំណុច } A , B , C \text{ រត់មិនត្រង់ជួរ}}$ ។

**ខ. រកផ្ទៃក្រឡានៃត្រីកោណ $ABC$**

តាមរូបមន្ត $S=\dfrac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AC}\right|$

ដោយ $\overrightarrow{AB}\times\overrightarrow{AC}=(-5,1,2)$

គេបាន $S=\dfrac{1}{2}\sqrt{(-5)^2+1^2+2^2}=\dfrac{1}{2}\sqrt{30}$

ដូចនេះ: $\boxed{\text{ផ្ទៃនៃត្រីកោណគឺ } S=\dfrac{\sqrt{30}}{2} \text{ ឯកតាផ្ទៃក្រឡា}}$ ។

**V.** ក. សិក្សាទិសដៅអថេរភាព និងសង់ខ្សែកោង $C$ តាងអនុគមន៍ :

គេមាន $y=\dfrac{3-x}{x}=\dfrac{3}{x}-1$

• ដែនកំណត់ : អនុគមន៍ មានន័យលុះត្រាតែ $x\neq 0$

ដូចនេះ: ដែនកំណត់ $D=\mathbb{R}-\{0\}$ ។

• ទិសដៅអថេរភាព :

ដេរីវេ $y'=\left(\dfrac{3}{x}-1\right)'=-\dfrac{3}{x^2}<0$ , $\forall x\in D$

នាំឱ្យ $y$ ជាអនុគមន៍ចុះលើចន្លោះ $D$ និងគ្មានបរមាទេ

• លីមីត និងអាសុីមតូត

$$\lim_{x\to-\infty} y=\lim_{x\to-\infty}\left(\frac{3}{x}-1\right)=0-1=-1$$

$$\lim_{x\to+\infty} y=\lim_{x\to+\infty}\left(\frac{3}{x}-1\right)=0-1=-1$$

$$\lim_{x\to0^-} y=\lim_{x\to0^-}\left(\frac{3}{x}-1\right)=-\infty-1=-\infty$$

$$\lim_{x\to0^+} y=\lim_{x\to0^+}\left(\frac{3}{x}-1\right)=+\infty-1=+\infty$$

ដោយ $\lim\limits_{x\to\pm\infty} y=-1$ នោះបន្ទាត់ដែលមានសមីការ $y=-1$ ជាអាសុីមតូតដេកនៃក្រាប $(C)$ ។

ដោយ $\lim\limits_{x\to0} y=\pm\infty$ នោះបន្ទាត់ដែលមានសមីការ $x=0$ ជាអាសុីមតូតឈរនៃក្រាប $(C)$ ។

• តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-\infty$ | $0$ | $+\infty$ |
|---|---|---|---|
| $y'$ | $-$ | ‖ | $-$ |
| $y$ | $-1 \searrow -\infty$ | ‖ | $+\infty \searrow -1$ |

• **សង់ខ្សែកោង $(C)$**

បើ $y=0\Leftrightarrow\dfrac{3-x}{x}=0\Rightarrow x=3$




**ខ. កំណត់សមីការបន្ទាត់ $AB$**

គេមាន ចំណុច $A$ និង $B$ មានអាប់ស៊ីសរៀងគ្នា $1$ និង $3$ ស្ថិតនៅលើខ្សែកោង $C$ នោះគេបាន ៖

ចំពោះ $x=1$ : $y(1)=\dfrac{3}{1}-1=2$

ចំពោះ $x=3$ : $y(3)=\dfrac{3}{3}-1=0$

គេបាន កូអរដោនេចំណុច $A(1,2)$ និង $B(3,0)$

ដោយ $(AB): y=ax+b$ ដែលមានមេគុណប្រាប់ទិស

$a=\dfrac{y_2-y_1}{x_2-x_1}=\dfrac{0-2}{3-1}=-1$ និងកាត់ $A(1,2)$

គេបាន $2=(-1)(1)+b$ នាំឱ្យ $b=3$

ដូចនេះ: សមីការបន្ទាត់កំណត់បាន $\boxed{(AB): y=-x+3}$ ។

➢**ទាញរកសមីការ បន្ទាត់ប៉ះនឹងខ្សែកោង $C$ ទាំងអស់ស្របនឹងបន្ទាត់ $AB$**

បន្ទាត់ប៉ះមានរាង $y = y'(x_0)(x - x_0) + y(x_0)$

ដោយ បន្ទាត់ប៉ះស្របនឹងបន្ទាត់ $(AB)$ គេបាន $y'(x_0) = -1$

នាំឱ្យ $-\dfrac{3}{x_0^2} = -1$ នោះ $x_0 = \pm\sqrt{3}$

• ចំពោះ $x_0 = -\sqrt{3}$

នាំឱ្យ $y(x_0) = y(-\sqrt{3}) = \dfrac{3}{-\sqrt{3}} - 1 = -\sqrt{3} - 1$

គេបាន $y = -1(x + \sqrt{3}) - \sqrt{3} - 1 = -x - 2\sqrt{3} - 1$

• ចំពោះ $x_0 = \sqrt{3}$

នាំឱ្យ $y(x_0) = y(\sqrt{3}) = \dfrac{3}{\sqrt{3}} - 1 = \sqrt{3} - 1$

គេបាន $y = -1(x - \sqrt{3}) + \sqrt{3} - 1 = -x + 2\sqrt{3} - 1$

ដូចនេះ បន្ទាត់ប៉ះទាំងអស់ដែលរកបានគឺ ៖

$$\boxed{y = -x - 2\sqrt{3} - 1 \ , \ y = -x + 2\sqrt{3} - 1}$$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ................................
លេខបន្ទប់ : ................................
លេខតុ : ................................
ហត្ថលេខា : ................................

**ប្រឡងជ្រើសរើសគ្រូ បឋមសិក្សា និងមត្តេយ្យសិក្សា " ១២ + ២ "**
**សម័យប្រឡង : ១៤ ធ្នូ ២០០២**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. គណនាលីមីតនៃអនុគមន៍ : $f(x)=\dfrac{\sin 2x-\sin x}{\sin 2x+\sin x}$ កាលណា $x$ ខិតជិតសូន្យ ។

ខ. គណនាផ្នែកពិត និងផ្នែកនិមិត្ត នៃចំនួនកុំផ្លិច : $z=\dfrac{1+i}{\left(1+i\sqrt{3}\right)^4}$ ។ (**២ពិន្ទុ**)

**II.** សិក្សាភាពជាប់ និងភាពមានដេរីវេនៃអនុគមន៍ : $f(x)=\left|(x-1)(x^2-x)\right|$ ត្រង់ចំណុច $x=0$ ។ (**២ពិន្ទុ**)

**III.** $f$ ជាអនុគមន៍កំណត់លើ $\mathbb{R}$ ដែល $f(x)=\left|(x-1)(x-2)\right|$ ។ គណនា $J=\int_0^2 f(x)dx$ ។ (**១ពិន្ទុកន្លះ**)

**IV.** ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(1,1,1)$ , $B(2,3,4)$ , $C(6,5,2)$ និង $D(7,7,5)$ ។

ក. បង្ហាញថា $ABCD$ ជាកំពូលនៃប្រលេឡូក្រាម ។

ខ. គណនាផ្ទៃក្រឡានៃប្រលេឡូក្រាមនេះ ។ (**២ពិន្ទុ**)

**V.** គេឱ្យអនុគមន៍ $f(x)=2+\dfrac{1}{x+1}-\dfrac{1}{(x+1)^2}$ ដែលកំណត់ក្នុង $\mathbb{R}\setminus\{-1\}$ ។

ក. គណនាដេរីវេ $f'(x)$ នៃអនុគមន៍ $f(x)$ និងសិក្សាសញ្ញារបស់វា ។

ខ. រកឫសនៃសមីការ $f(x)=0$ ។

គ. សិក្សាអថេរភាព និងគូសខ្សែកោង $C$ តាងអនុគមន៍ $f$ ក្នុងតម្រុយអរតូណរមេ រួចរកកូអរដោនេនៃចំណុចរបត់ ។

ឃ. សរសេរសមីការបន្ទាត់ប៉ះទៅនឹងខ្សែកោង $C$ ត្រង់ចំណុចដែលមានអាប់ស៊ីសស្មើ $0$ ។ (**២ពិន្ទុកន្លះ**)

## ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០០២

**I.** **ក. គណនាលីមីតនៃអនុគមន៍ :**

$$\lim_{x\to0} f(x)=\lim_{x\to0}\frac{\sin 2x-\sin x}{\sin 2x+\sin x}$$

$$=\lim_{x\to0}\frac{2\times\frac{\sin 2x}{2x}-\frac{\sin x}{x}}{2\times\frac{\sin 2x}{2x}+\frac{\sin x}{x}}$$

$$=\frac{2\times1-1}{2\times1+1}=\frac{1}{3}$$

ដូចនេះ គណនាបាន $\boxed{\lim_{x\to0} f(x)=\frac{1}{3}}$

**ខ. គណនាផ្នែកពិត និងផ្នែកនិមិត្ត នៃចំនួនកុំផ្លិច $z$ :**

$$z=\frac{1+i}{\left(1+i\sqrt3\right)^4}=\frac{1+i}{\left[\left(1+i\sqrt3\right)^2\right]^2}$$

$$=\frac{1+i}{\left(1+2i\sqrt3+3i^2\right)^2}$$

$$=\frac{1+i}{\left(-2+2i\sqrt3\right)^2}$$

$$=\frac{1+i}{4\left(-1+i\sqrt3\right)^2}$$

$$=\frac{1+i}{4\left(1-2i\sqrt3+3i^2\right)}$$

$$=\frac{1+i}{4\left(-2-2i\sqrt3\right)}$$

$$=\frac{(1+i)\left(-1+i\sqrt3\right)}{8\left(-1-i\sqrt3\right)\left(-1+i\sqrt3\right)}$$

$$=\frac{-1+i\sqrt3-i-\sqrt3}{8\left(1-3i^2\right)}$$

$$=\frac{\left(-1-\sqrt3\right)+i\left(\sqrt3-1\right)}{32}$$

ដូចនេះ: $z$ មានផ្នែកពិតស្មើ $\frac{-1-\sqrt3}{32}$ និងមានផ្នែកនិមិត្តស្មើ $\frac{\sqrt3-1}{32}$ ។

**II. សិក្សាភាពមានដេរីវេនៃ $f$ ត្រង់ចំណុច $x=0$**

យើងមាន $f(x)=\left|(x-1)\left(x^2-x\right)\right|$

$$=\left|x(x-1)^2\right|=|x|(x-1)^2$$

ព្រោះ $(x-1)^2\ge0$ មិនចាំបាច់ដាក់តម្លៃដាច់ខាត

-សិក្សាភាពជាប់នៃអនុគមន៍ $f$ ត្រង់ចំណុច $x=0$ :

អនុគមន៍ $f$ ជាប់ត្រង់ $x=0$ លុះត្រាតែ

$$\lim_{x\to0^-} f(x)=\lim_{x\to0^+} f(x)=f(0)$$

• ចំពោះ $x\to0^-$ នោះ $|x|=-x$ យើងបាន :

$$\lim_{x\to0^-} f(x)=\lim_{x\to0^-}\left[-x(x-1)^2\right]=-0\cdot1=0$$

• ចំពោះ $x\to0^+$ នោះ $|x|=x$ យើងបាន :

$$\lim_{x\to0^-} f(x)=\lim_{x\to0^-} x(x-1)^2=0\cdot1=0$$

• ចំពោះ $x=0$ នោះយើងបាន

$$f(0)=|0|(0-1)^2=0$$

យើងឃើញថា $\lim_{x\to0^-} f(x)=\lim_{x\to0^+} f(x)=f(0)=0$

ដូចនេះ: $\boxed{f \text{ ជាអនុគមន៍ជាប់ត្រង់ } x=0 \text{ ជាប្រាកដ}}$ ។

-សិក្សាភាពមានដេរីវេនៃអនុគមន៍ $f$ ត្រង់ចំណុច $x=0$ :

$f$ មានដេរីវេត្រង់ $x=0$ លុះត្រាតែ $f'_-(0)=f'_+(0)$

$$\bullet\, f'_-(0)=\lim_{h\to0^-}\frac{f(0+h)-f(0)}{h}$$

$$=\lim_{h\to0^-}\frac{f(h)}{h}\ ,\ f(0)=0$$

$$=\lim_{h\to0^-}\frac{|h|(h-1)^2}{h}=\lim_{h\to0^-}\frac{-h(h-1)^2}{h}=-1$$

$$\bullet\, f'_+(0)=\lim_{h\to0^+}\frac{f(0+h)-f(0)}{h}$$

$$=\lim_{h\to0^+}\frac{f(h)}{h}\ ,\ f(0)=0$$

$$=\lim_{h\to0^+}\frac{|h|(h-1)^2}{h}=\lim_{h\to0^+}\frac{h(h-1)^2}{h}=1$$

ឃើញថា $f'_-(0)=-1\ne f'_+(0)=1$

ដូចនេះ: $\boxed{f \text{ គ្មានដេរីវេត្រង់ } x=0 \text{ ទេ}}$ ។

**III.** គណនាអាំងតេក្រាល $J=\int_0^2 f(x)dx$ ៖

យើងមាន $f(x)=\left|(x-1)(x-2)\right|=\left|x^2-3x+2\right|$

យើងនឹងសិក្សាសញ្ញានៃកន្សោម $x^2-3x+2$

ឱ្យ $x^2-3x+2=0$ មានឫស $x=1\,,\ x=2$

តារាងសញ្ញា

| $x$ | $-\infty$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $x^2-3x+2$ | | $+$ | $0$ | $-$ | $0$ | $+$ | |

យើងបានតម្លៃនៃ $f(x)=\left|x^2-3x+2\right|$ គឺ

-ចំពោះ $0<x<1$ : $\left|x^2-3x+2\right|=x^2-3x+2$

-ចំពោះ $1<x<2$ : $\left|x^2-3x+2\right|=-\left(x^2-3x+2\right)$

$$\mathbf{J}=\int_0^2 f(x)dx$$

$$=\int_0^2\left|x^2-3x+2\right|dx$$

$$=\int_0^1\left(x^2-3x+2\right)dx-\int_1^2\left(x^2-3x+2\right)dx$$

$$=\left[\frac{x^3}{3}-\frac{3x^2}{2}+2x\right]_0^1-\left[\frac{x^3}{3}-\frac{3x^2}{2}+2x\right]_1^2$$

$$=\left(\frac{1}{3}-\frac{3}{2}+2-0\right)-\left[\left(\frac{8}{3}-\frac{12}{2}+4\right)-\left(\frac{1}{3}-\frac{3}{2}+2\right)\right]$$

$$=\frac{1}{3}-\frac{3}{2}+2-\frac{8}{3}+\frac{12}{2}-4+\frac{1}{3}-\frac{3}{2}+2=\boxed{1}$$

ដូចនេះ គណនាបាន $\boxed{J=1}$ ។

**IV.** ក. បង្ហាញថា $ABCD$ ជាកំពូលនៃប្រលេឡូក្រាម

យើងមាន $A(1\,,1\,,1)$ , $B(2\,,3\,,4)$, $C(6\,,5\,,2)$ និង $D(7,7,5)$

នាំឱ្យ $\overrightarrow{AB}=(1\,,2\,,3)$ និង $\overrightarrow{CD}=(1\,,2\,,3)$

ដោយចតុកោណ $ABCD$ មាន $\overrightarrow{AB}=\overrightarrow{CD}$

ដូចនេះ៖ **ចតុកោណ $ABCD$ ជាប្រលេឡូក្រាម** ។

ខ. គណនាផ្ទៃក្រឡាប្រលេឡូក្រាម $ABCD$ ៖

តាមរូបមន្ត $S=\left|\overrightarrow{AB}\times\overrightarrow{AC}\right|$ ដែល $\overrightarrow{AC}=(5\,,4\,,1)$

$$\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & 2 & 3\\ 5 & 4 & 1\end{vmatrix}=-10\vec{i}+14\vec{j}-6\vec{k}$$

នាំឱ្យ $\overrightarrow{AB}\times\overrightarrow{AC}=\sqrt{(-10)^2+(14)^2+\left(-6^2\right)}=2\sqrt{70}$

ដូចនេះ៖ **ផ្ទៃក្រឡាប្រលេឡូក្រាមគឺ $S=2\sqrt{70}$ ឯកតាផ្ទៃ** ។

**V.** ក. គណនាដេរីវេ $f'(x)$

គេមាន $f(x)=2+\frac{1}{x+1}-\frac{1}{(x+1)^2}$ ដែល $x\neq-1$

គេបាន $f'(x)=-\frac{1}{(x+1)^2}+\frac{2}{(x+1)^3}$

$$=\frac{-x-1+2}{(x+1)^3}$$

$$=\frac{-x+1}{(x+1)^3}$$

ដូចនេះ៖ $\boxed{f'(x)=\frac{-x+1}{(x+1)^3}}$ ។

➢សិក្សាសញ្ញារបស់វា

ឱ្យ $f'(x)=0 \Leftrightarrow \frac{-x+1}{(x+1)^3}=0$

គេបាន $\begin{cases}-x+1=0\\ x+1\neq0\end{cases}\Rightarrow\begin{cases}x=1\\ x\neq-1\end{cases}$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $-x+1$ | | $+$ | | $+$ | $0$ | $-$ | |
| $x+1$ | | $-$ | $0$ | $+$ | | $+$ | |
| $(x+1)^3$ | | $-$ | $0$ | $+$ | | $+$ | |
| $f'(x)=\frac{-x+1}{(x+1)^3}$ | | $-$ | ‖ | $+$ | $0$ | $-$ | |

ដូចនេះ៖ $f'(x)>0$ កាលណា $x\in(-1\,,1)$

$f'(x)<0$ កាលណា $x\in(-\infty,\,-1)\cup(1,\,+\infty)$

$f'(x)=0$ ចំពោះ៖ $x=1$

ខ. រកឫសនៃសមីការ $f(x)=0$

គេបាន $2+\frac{1}{x+1}-\frac{1}{(x+1)^2}=0$ (គុណនឹង $(x+1)^2$ )

$2(x+1)^2+(x+1)-1=0$

$2x^2+5x+2=0$

មាន $\Delta=5^2-4\cdot2\cdot2=25-16=9$

$$x=\frac{-5\pm\sqrt{9}}{2\cdot2}=\frac{-5\pm3}{4}=\left[\begin{array}{l}-2\\ -\frac{1}{2}\end{array}\right.$$

ដូនេះ៖ សមីការមានឫស $\boxed{x=-2\,,\ x=-\frac{1}{2}}$ ។

### គ. សិក្សាអថេរភាព និងគូសខ្សែកោង $C$ តាងអនុគមន៍ $f$

• លីមីតតាមចុងដែនកំណត់ និងអាស៊ីមតូត

គេមាន $f(x)=2+\dfrac{1}{x+1}-\dfrac{1}{(x+1)^2}=\dfrac{2x^2+5x+2}{(x+1)^2}$

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\frac{2x^2+5x+2}{(x+1)^2}=2$$

$$\lim_{x\to-1^-} f(x)=\lim_{x\to-1^-}\left(\frac{2x^2+5x+2}{(x+1)^2}\right)=\frac{-1}{0^+}=-\infty$$

$$\lim_{x\to-1^+} f(x)=\lim_{x\to-1^+}\left(\frac{2x^2+5x+2}{(x+1)^2}\right)=\frac{-1}{0^+}=-\infty$$

ដោយ $\lim\limits_{x\to\pm\infty} f(x)=2$ នោះបន្ទាត់ដែលមានសមីការ $y=2$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ។

ហើយ $\lim\limits_{x\to-1} f(x)=-\infty$ នោះបន្ទាត់ដែលមានសមីការ $x=-1$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។

• បរមានៃអនុគមន៍ $f$ : តាមតារាងសញ្ញា $f'(x)$

ត្រង់ $x=1$ , $f'(x)=0$ ហើយប្ដូរសញ្ញាពី $(+)$ ទៅ $(-)$ បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើ $f(1)=9/4$ ។

• តារាងអថេរភាពនៃ $f$

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | $2$ | ↘ $-\infty$ | ‖ | $-\infty$ ↗ | $9/4$ | ↘ | $2$ |

• **គូសខ្សែកោង $(C)$ តាងអនុគមន៍ $f$**




➢**រកកូអរដោនេនៃចំណុចរបត់**

ដោយ ឫសនៃដេរីវេទី២គឺជាអាប់ស៊ីសនៃចំណុចរបត់

គេមាន $f'(x)=\dfrac{-x+1}{(x+1)^3}$

$$f''(x)=\frac{-(x+1)^3-3(x+1)^2(-x+1)}{(x+1)^6}$$

$$=\frac{-(x+1)-3(-x+1)}{(x+1)^4}=\frac{2x-4}{(x+1)^4}$$

គេឱ្យ $f''(x)=0 \Leftrightarrow \dfrac{2x-4}{(x+1)^4}=0$ , $\forall x\in D$ ,

$(x+1)^4>0$ នាំឱ្យ $f''$ មានសញ្ញាដូច $2x-4$

គេបាន $2x-4=0$ នោះ $x=2$

$$f(2)=2+\frac{1}{2+1}-\frac{1}{(2+1)^2}=\frac{20}{9}$$

តារាងសញ្ញា $f''(x)$

| $x$ | $-\infty$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|
| $f''(x)$ | | $-$ | $0$ | $+$ | |

ត្រង់ $x=2$ , $f''(x)=0$ ហើយប្ដូរសញ្ញា នេះបញ្ជាក់ថា $f$ ផ្លាស់ប្ដូរភាពផតប៉ោង

ដូចនេះ៖ កូអរដោនេចំណុចរបត់គឺ $\left(2\,,\,\dfrac{20}{9}\right)$ ។

### ឃ. សរសេរសមីការបន្ទាត់ប៉ះទៅនឹងខ្សែកោង $C$

សមីការបន្ទាត់ប៉ះមានរាង $y=f'(x_0)(x-x_0)+f(x_0)$

ដោយ បន្ទាត់ប៉ះត្រង់ចំណុចដែលមានអាប់ស៊ីស $x_0=0$

គេបាន $f'(x_0)=f'(0)=\dfrac{-0+1}{(0+1)^3}=1$

$$f(x_0)=f(0)=2+\frac{1}{0+1}-\frac{1}{(0+1)^2}=2$$

នាំឱ្យ $y=1(x-0)+2=x+2$

ដូចនេះ៖ សមីការបន្ទាត់ប៉ះរកបានគឺ $\boxed{y=x+2}$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ

## សម័យប្រឡង : ១៨ តុលា ២០១៩

**វិញ្ញាសា : គណិតវិទ្យា (ឯកទេសទី១) រយៈពេល : ១២០ នាទី ពិន្ទុ : ២០**

## I. ផ្នែកពីជគណិត

**1.** សិប្បកម្មធ្វើទឹកត្រីមួយបានប្រើដបអស់ចំនួន 1400 ដប ដើម្បីច្រកទឹកត្រីទាំងអស់ដែលមានចំណុះ 600$\ell$ គត់ ។ គេដឹងថាក្នុងចំណោមដបទាំង 1400 នោះ មានដបខ្លះមានចំណុះ 500 $m\ell$ និងដបខ្លះមានចំណុះ 375 $m\ell$ ។ ចូររកចំនួនដបដែលបានប្រើតាមប្រភេទនៃចំណុះនីមួយៗ ។ ($\ell$ សម្គាល់លីត្រ , $m\ell$ សម្គាល់មិល្លីលីត្រ) **(២ ពិន្ទុ)**

**2.** ក្នុងថុងមួយមានកូនតុក្កតាខ្លាឃ្មុំចំនួន8 ដែលក្នុងនោះមានកូនតុក្កតាខ្លាឃ្មុំពណ៌សចំនួន3 និងពណ៌ខ្មៅចំនួន 5 ។ គេចាប់យកកូនតុក្កតាខ្លាឃ្មុំចំនួន3 ពីក្នុងថុងដោយចៃដន្យ ។ ចូររកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម ៖

A : «កូនតុក្កតាខ្លាឃ្មុំទាំងបីដែលចាប់បានមានពណ៌ស» ។ **(កន្លះពិន្ទុ)**

B : «កូនតុក្កតាខ្លាឃ្មុំទាំងបីដែលចាប់បានមានពណ៌ដូចគ្នា» ។ **(១ ពិន្ទុ)**

C : «កូនតុក្កតាខ្លាឃ្មុំទាំងបីដែលចាប់បានមានមួយយ៉ាងតិចមានពណ៌ស» ។ **(១ ពិន្ទុ)**

**3.** គណនាអាំងតេក្រាល ៖ ក. $I=\int_0^1 \frac{e^x}{1+e^x}dx$ **(១ ពិន្ទុ)** ខ. $J=\int_0^{\frac{\pi}{6}}\left(10\cos x\sin^4 x\right)dx$ **(១ ពិន្ទុ)**

**4.** គេមានចំនួនកុំផ្លិច $z_1=-6\sqrt{3}+\frac{9}{2}i$ និង $z_2=\frac{15\sqrt{3}}{2}-3i$ ។ គណនា $z_1+z_2$ និងសរសេរ $z_1+z_2$ ជាទម្រង់ត្រីកោណមាត្រ ។ សរសេរ $(z_1+z_2)^5$ ជាទម្រង់ពីជគណិត និងជាទម្រង់ត្រីកោណមាត្រ ។ **(២ ពិន្ទុ)**

**5.** គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=\frac{-3x^2+18x-25}{x^2-6x+8}$ ។ គេតាងដោយ $(C)$ ក្រាបរបស់អនុគមន៍ $f$ នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

១. រកដែនកំណត់ $D$ នៃអនុគមន៍ $f$ ។ **(១ ពិន្ទុ)**

២. គណនាលីមីតនៃអនុគមន៍ $f$ ត្រង់ $+\infty$ ត្រង់ $-\infty$ ត្រង់ $+2$ និងត្រង់ $+4$ ។ ទាញរកអាស៊ីមតូតដេក និងអាស៊ីមតូតឈរនៃក្រាប $(C)$ ។ **(២ ពិន្ទុ)**

៣. សិក្សាអថេរភាពនៃអនុគមន៍ $f$ និងសង់ក្រាប $(C)$ របស់វា ។ **(២ ពិន្ទុកន្លះ)**

## II. ផ្នែកធរណីមាត្រ

**1.** ក្នុងត្រីកោណ $ABC$ កន្លះបន្ទាត់ពុះនៃមុំ $\angle B$ និងមុំ $\angle C$ ប្រសព្វគ្នាត្រង់ $I$ ។ តាម $I$ គេគូសបន្ទាត់មួយស្របនឹងបន្ទាត់ $AB$ ហើយកាត់បន្ទាត់ $AC$ ត្រង់ $D$ និង $BC$ ត្រង់ $E$ ។ ស្រាយបំភ្លឺថា $DE=AD+BE$ ។ **(២ ពិន្ទុ)**

**2.** នៅក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់$(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $D(2,4,6)$, $E(6,4,2)$ និង $F(-2,-4,4)$ ។

*a.* រកវ៉ិចទ័រ $\overrightarrow{DE}$ , $\overrightarrow{DF}$ និង $\overrightarrow{EF}$ ។ **(១ ពិន្ទុ)**

*b.* បង្ហាញថា ចំណុច $D$ , $E$ , $F$ មិននៅលើបន្ទាត់តែមួយ ។ **(១ ពិន្ទុ)**

*c.* រកសមីការប្លង់ដែលកាត់តាមចំណុច $D$ , $E$ , $F$ ។ **(២ ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ២០១៩

## I. ផ្នែកពីជគណិត

### 1. រកចំនួនដបដែលបានប្រើតាមប្រភេទនៃចំណុះនីមួយៗ

គេតាង $x$ ជាចំនួនដបដែលមានចំណុះ $500\ m\ell$

$y$ ជាចំនួនដបដែលមានចំណុះ $375\ m\ell$

ដែល $1\ell = 1000\,m\ell$ ឬ $600\ell = 600\,000\,m\ell$

បម្រាប់ គេសរសេរបានប្រព័ន្ធសមីការ

$$\begin{cases} x+y=1400 \\ 500x+375y=600\,000 \end{cases} \text{ ឬ } \begin{cases} 3x+3y=4200 \\ 4x+3y=4800 \end{cases}$$

ដកអង្គនិងអង្គ $-x=-600$ ឬ $x=600$ ដប

នាំឱ្យ $y=1400-x=1400-600=800$ ដប

ផ្ទៀងផ្ទាត់ $\begin{cases} 600+800=1400 \\ 500\cdot 600+375\cdot 800=600\,000 \end{cases}$ ពិត

ដូចនេះ: ដបចំណុះ $500\ m\ell$ មានចំនួន $x=600$ ដប
ដបចំណុះ $375\ m\ell$ មានចំនួន $y=800$ ដប

### 2. រកប្រូបាបនៃព្រឹត្តិការណ៍

គេមាន កូនតុក្កតាខ្លាឃ្មុំចំនួន8 មានពណ៌ស3 និងពណ៌ខ្មៅ 5

គេចាប់យកកូនតុក្កតាខ្លាឃ្មុំចំនួន3 ពីក្នុងធុងដោយចៃដន្យ

នាំឱ្យ ចំនួនករណីអាច $n(S)=C(8\,,3)$

$$n(S)=\frac{8!}{5!\,3!}=\frac{8\cdot 7\cdot 6\cdot 5!}{5!\,3\cdot 2}=56$$

**A** : កូនតុក្កតាខ្លាឃ្មុំទាំងបីដែលចាប់បានមានពណ៌ស

ចំនួនករណីស្រប $n(A)=C(3\,,3)=1$

នាំឱ្យ $P(A)=\dfrac{n(A)}{n(S)}=\dfrac{1}{56}\approx 0.018$

ដូចនេះ: $\boxed{P(A)=\dfrac{1}{56}\approx 0.018}$ ។

**B** : កូនតុក្កតាខ្លាឃ្មុំទាំងបីដែលចាប់បានមានពណ៌ដូចគ្នា

មានន័យថា ចាប់បានពណ៌សទាំងបី ឬពណ៌ខ្មៅទាំងបី

នាំឱ្យ $n(B)=C(3\,,3)+C(5\,,3)=1+\dfrac{5!}{2!\,3!}=11$

គេបាន $P(B)=\dfrac{n(B)}{n(S)}=\dfrac{11}{56}\approx 0.196$

ដូចនេះ: $\boxed{P(B)=\dfrac{11}{56}\approx 0.196}$ ។

**C** : កូនតុក្កតាខ្លាឃ្មុំទាំងបីមានមួយយ៉ាងតិចមានពណ៌ស

តាង $D$ ជាព្រឹត្តិការណ៍ចាប់បានកូនតុក្កតាខ្លាឃ្មុំទាំងបីពណ៌ខ្មៅ

នាំឱ្យ $n(D)=C(5\,,3)=\dfrac{5!}{2!\,3!}=10$

ដោយ ព្រឹត្តិការណ៍ $C$ និង $D$ ជាព្រឹត្តិការណ៍បំពេញគ្នា

គេបាន $P(C)=1-P(D)=1-\dfrac{n(D)}{n(S)}=1-\dfrac{10}{56}=\dfrac{23}{28}$

ដូចនេះ: $\boxed{P(C)=\dfrac{23}{28}\approx 0.821}$ ។

### 3. គណនាអាំងតេក្រាលខាងក្រោម

$$\mathbf{I}=\int_0^1 \frac{e^x}{1+e^x}dx=\int_0^1 \frac{(1+e^x)'}{1+e^x}dx$$
$$=\Big[\ln(1+e^x)\Big]_0^1$$
$$=\ln(1+e)-\ln 2$$
$$=\boxed{\ln\left(\frac{1+e}{2}\right)}$$

$$\mathbf{J}=\int_0^{\frac{\pi}{6}}\left(10\cos x\sin^4 x\right)dx=10\int_0^{\frac{\pi}{6}}\left(\cos x\sin^4 x\right)dx$$

តាង $u=\sin x$ នោះ: $du=\cos x dx$

បើ $x=0$ នោះ: $u=0$

$x=\dfrac{\pi}{6}$ នោះ: $u=\dfrac{1}{2}$

$$\mathbf{J}=10\int_0^{\frac{1}{2}}u^4du=10\left[\frac{u^5}{5}\right]_0^{\frac{1}{2}}$$
$$=2\left[u^5\right]_0^{\frac{1}{2}}=2\left(\frac{1}{32}-0\right)=\boxed{\mathbf{\frac{1}{16}}}$$

### 4. គណនា $z_1+z_2$

គេមាន $z_1=-6\sqrt{3}+\dfrac{9}{2}i$ និង $z_2=\dfrac{15\sqrt{3}}{2}-3i$

គេបាន $z_1+z_2=\left(-6\sqrt{3}+\dfrac{9}{2}i\right)+\left(\dfrac{15\sqrt{3}}{2}-3i\right)$

$$z_1+z_2=\frac{-12\sqrt{3}+15\sqrt{3}}{2}+\frac{9-6}{2}i$$

ដូចនេះ: $z_1+z_2=\boxed{\dfrac{3\sqrt{3}}{2}+\dfrac{3}{2}i}$ ។

សរសេរ $z_1+z_2$ ជាទម្រង់ត្រីកោណមាត្រ

ដោយ $z_1+z_2=\frac{3\sqrt{3}}{2}+\frac{3}{2}i=3\left(\frac{\sqrt{3}}{2}+\frac{1}{2}i\right)$

$=3\left(\cos\frac{\pi}{6}+i\sin\frac{\pi}{6}\right)$

ដូចនេះ $\boxed{z_1+z_2=3\left(\cos\frac{\pi}{6}+i\sin\frac{\pi}{6}\right)}$ ។

សរសេរ $(z_1+z_2)^5$ ជាទម្រង់ពីជគណិត និងជាទម្រង់ត្រីកោណមាត្រ

$(z_1+z_2)^5=\left[3\left(\cos\frac{\pi}{6}+i\sin\frac{\pi}{6}\right)\right]^5$ តាមរូបមន្តដឺម័រ

$=3^5\left(\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}\right)$

$=\boxed{243\left(\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}\right)}$ ទម្រង់ត្រី.មាត្រ

$=243\left(-\frac{\sqrt{3}}{2}+\frac{1}{2}i\right)$

$=\boxed{-\frac{243\sqrt{3}}{2}+\frac{243}{2}i}$ ទម្រង់ពីជគណិត

**5.** **១. រកដែនកំណត់ $D$ នៃអនុគមន៍ $f$**

គេមាន $f(x)=\frac{-3x^2+18x-25}{x^2-6x+8}$ មានក្រាប $(C)$

ដោយ $f$ មានន័យលុះត្រាតែ $x^2-6x+8\neq 0$

$(x-2)(x-4)\neq 0$ នោះ $x\neq 2$ , $x\neq 4$

ដូចនេះ $\boxed{\begin{array}{l}D=\mathbb{R}-\{2\,,\,4\}\\ D=(-\infty\,,\,2)\cup(2\,,\,4)\cup(4\,,\,+\infty)\end{array}}$ ។

**២. គណនាលីមីតនៃអនុគមន៍ $f$ ត្រង់ $+\infty$ ត្រង់ $-\infty$**

$\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to+\infty}\left(\frac{-3x^2+18x-25}{x^2-6x+8}\right)$

$=\lim\limits_{x\to+\infty}\frac{x^2\left(-3+\frac{18}{x}-\frac{25}{x^2}\right)}{x^2\left(1-\frac{6}{x}+\frac{8}{x^2}\right)}=\frac{-3}{1}=\boxed{-3}$

$\lim\limits_{x\to-\infty}f(x)=\lim\limits_{x\to-\infty}\left(\frac{-3x^2+18x-25}{x^2-6x+8}\right)$

$=\lim\limits_{x\to-\infty}\frac{x^2\left(-3+\frac{18}{x}-\frac{25}{x^2}\right)}{x^2\left(1-\frac{6}{x}+\frac{8}{x^2}\right)}=\frac{-3}{1}=\boxed{-3}$

ត្រង់ $+2$ និងត្រង់ $+4$

ដោយ $f(x)=\frac{-3x^2+18x-25}{x^2-6x+8}=\frac{-3x^2+18x-25}{(x-2)(x-4)}$

• ចំពោះ: $x\to 2^-$ នាំឱ្យ $x-2\to 0^-$

$\lim\limits_{x\to 2^-}f(x)=\lim\limits_{x\to 2^-}\frac{-3x^2+18x-25}{(x-2)(x-4)}$

$=\frac{-3\cdot 4+18\cdot 2-25}{0^-(-2)}=\frac{-1}{0^+}=\boxed{-\infty}$

• ចំពោះ: $x\to 2^+$ នាំឱ្យ $x-2\to 0^+$

$\lim\limits_{x\to 2^+}f(x)=\lim\limits_{x\to 2^+}\frac{-3x^2+18x-25}{(x-2)(x-4)}$

$=\frac{-3\cdot 4+18\cdot 2-25}{0^+(-2)}=\frac{-1}{0^-}=\boxed{+\infty}$

• ចំពោះ: $x\to 4^-$ នាំឱ្យ $x-4\to 0^-$

$\lim\limits_{x\to 4^-}f(x)=\lim\limits_{x\to 4^-}\frac{-3x^2+18x-25}{(x-2)(x-4)}$

$=\frac{-3\cdot 16+18\cdot 4-25}{(2)(0^-)}=\frac{-1}{0^-}=\boxed{+\infty}$

• ចំពោះ: $x\to 4^+$ នាំឱ្យ $x-4\to 0^+$

$\lim\limits_{x\to 4^+}f(x)=\lim\limits_{x\to 4^+}\frac{-3x^2+18x-25}{(x-2)(x-4)}$

$=\frac{-3\cdot 16+18\cdot 4-25}{(2)(0^+)}=\frac{-1}{0^+}=\boxed{-\infty}$

**ទាញរកអាស៊ីមតូតដេក និងអាស៊ីមតូតឈរ នៃក្រាប $(C)$**

ដោយ $\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to-\infty}f(x)=-3$

នាំឱ្យ បន្ទាត់ដែលមានសមីការ $y=-3$ ជាអាស៊ីមតូតដេក នៃក្រាប $(C)$ ទាំងខាង $+\infty$ និងខាង $-\infty$ ។

ដោយ $\lim\limits_{x\to 2}f(x)=\pm\infty$ និង $\lim\limits_{x\to 4}f(x)=\pm\infty$

នាំឱ្យ បន្ទាត់ដែលមានសមីការ $x=2$ និង $x=4$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។

**៣. សិក្សាអថេរភាពនៃអនុគមន៍ $f$ និងសង់ក្រាប $(C)$ របស់វា**

• ដែនកំណត់ : បានរករួចក្នុងសំណួរ ១.

• ទិសដៅអថេរភាព

$f(x)=\frac{-3x^2+18x-25}{x^2-6x+8}$ មានរាង $\left(\frac{u}{v}\right)'=\frac{u'v-v'u}{v^2}$

គេតាង $u=-3x^2+18x-25$ នោះ $u'=-6x+18$

$v=x^2-6x+8$ នោះ $v'=2x-6$

$$f'(x)=\frac{(-6x+18)(x^2-6x+8)-(2x-6)(-3x^2+18x-25)}{(x^2-6x+8)^2}$$

$$=\frac{-6x^3+36x^2-48x+18x^2-108x+144-(-6x^3+36x^2-50x+18x^2-108x+150)}{(x^2-6x+8)^2}$$

$$=\frac{-6x^3+54x^2-156x+144-(-6x^3+54x^2-158x+150)}{(x^2-6x+8)^2}=\frac{2x-6}{(x^2-6x+8)^2}$$

ដោយ $(x^2-6x+8)^2>0\ ,\ \forall x\in D$

នាំឱ្យ $f'(x)$ មានសញ្ញាដូច $2x-6$

គេឱ្យ $f'(x)=0$ សមមូល $2x-6=0$ នោះ $x=3$

គេបាន $f(3)=\dfrac{-3\cdot 9+18\cdot 3-25}{9-6\cdot 3+8}=\dfrac{2}{-1}=-2$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | 2 | | 3 | | 4 | | $+\infty$ |
|---|---|---|---|---|---|---|---|---|
| $f'(x)$ | $-$ | ‖ | $-$ | 0 | $+$ | ‖ | $+$ | |

• បរមា

ត្រង់ $x=3$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ$(+)$

បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើ $f(3)=-2$ ។

• លីមីត : បានគណនារួចក្នុងសំណួរ ២.

• តារាងអថេរភាព

| $x$ | $-\infty$ | 2 | | 3 | | 4 | | $+\infty$ |
|---|---|---|---|---|---|---|---|---|
| $f'(x)$ | $-$ | ‖ | $-$ | 0 | $+$ | ‖ | $+$ | |
| $f(x)$ | $-3\searrow-\infty$ | ‖ | $+\infty\searrow$ | $-2$ | $\nearrow+\infty$ | ‖ | $-\infty\nearrow$ | $-3$ |

• សង់ក្រាប (សូមសង់តារាងតម្លៃលេខដោយខ្លួនឯង)




## II. ផ្នែកធរណីមាត្រ

**1.** ស្រាយបំភ្លឺថា $DE=AD+BE$




គេមាន $\angle B_1=\angle B_2$ (ព្រោះ $[BI)$ ជាកន្លះបន្ទាត់ពុះមុំ $\angle B$)

$\angle I_1=\angle B_2$ (មុំឆ្លាស់ក្នុង ព្រោះ $AB\,//\,DE$ )

នាំឱ្យ $\angle B_1=\angle I_1$ នោះ $BEI$ ជាត្រីកោណសមបាតមាន

កំពូល $E$ ហេតុនេះ $BE=EI$ (1)

គេគូស $[AI)$ គេបាន $[AI)$ ជាកន្លះបន្ទាត់ពុះមុំ $\angle A$ ព្រោះថា

កន្លះបន្ទាត់ពុះមុំទាំងបីត្រូវប្រសព្វគ្នាត្រង់មួយចំណុចគត់

គេបាន $\angle A_1=\angle A_2$ (ព្រោះ $[AI)$ ជាកន្លះបន្ទាត់ពុះមុំ $\angle A$)

$\angle A_1=\angle I_2$ (មុំឆ្លាស់ក្នុង ព្រោះ $AB\,//\,DE$ )

នាំឱ្យ $\angle A_2=\angle I_2$ នោះ $ADE$ ជាត្រីកោណសមបាតមាន

កំពូល $D$ ហេតុនេះ $AD=ID$ (2)

បូកអង្គ នៃ (1) និង (2) : $AD+BE=EI+ID$

ដោយ $EI+ID=DE$ នាំឱ្យ $AD+BE=DE$

ដូចនេះ $\boxed{DE=AD+BE}$ ត្រូវបានស្រាយបំភ្លឺ ។

**2. a.** **រកវ៉ិចទ័រ** $\overrightarrow{DE}$ , $\overrightarrow{DF}$ **និង** $\overrightarrow{EF}$

គេមាន $D(2,4,6)$ , $E(6,4,2)$ និង $F(-2,-4,4)$

$$\overrightarrow{DE}=(x_E-x_D\ ,\ y_E-y_D\ ,\ z_E-z_D)$$
$$=(6-2\ ,\ 4-4\ ,\ 2-6)$$
$$=\boxed{(\mathbf{4}\ ,\ \mathbf{0}\ ,\ \mathbf{-4})}$$

$$\overrightarrow{DF}=(x_F-x_D\ ,\ y_F-y_D\ ,\ z_F-z_D)$$
$$=(-2-2\ ,\ -4-4\ ,\ 4-6)$$
$$=\boxed{(\mathbf{-4}\ ,\ \mathbf{-8}\ ,\ \mathbf{-2})}$$

$$\overrightarrow{EF}=(x_F-x_E\ ,\ y_F-y_E\ ,\ z_F-z_E)$$
$$=(-2-6\ ,\ -4-4\ ,\ 4-2)$$
$$=\boxed{(\mathbf{-8}\ ,\ \mathbf{-8}\ ,\ \mathbf{2})}$$

**b.** **បង្ហាញថា ចំណុច $D$ , $E$ , $F$ មិននៅលើបន្ទាត់តែមួយ**

គេមាន $\overrightarrow{DE}=(4\ ,0\ ,-4)$ , $\overrightarrow{DF}=(-4\ ,-8\ ,-2)$

$$\overrightarrow{DE}\times\overrightarrow{DF}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 4 & 0 & -4\\ -4 & -8 & -2\end{vmatrix}$$

$$=(0-32)\vec{i}-(-8-16)\vec{j}+(-32-0)\vec{k}$$

$$=-32\vec{i}+24\vec{j}-32\vec{k}$$

ដោយ $\overrightarrow{DE}\times\overrightarrow{DF}=-32\vec{i}+24\vec{j}-32\vec{k}\neq\vec{0}$

ដូចនេះ ចំណុច $D$ , $E$ , $F$ មិននៅលើបន្ទាត់តែមួយ ។

**c.** **រកសមីការប្លង់ដែលកាត់តាមចំណុច $D$ , $E$ , $F$**

ប្លង់ដែលកាត់តាមចំណុច $D$ , $E$ , $F$ ត្រូវតែជាប្លង់កាត់តាម ចំណុច $D$ និងមានវ៉ិចទ័រណរម៉ាល់ $\vec{n}=\overrightarrow{DE}\times\overrightarrow{DF}$

សមីការប្លង់ $(DEF)$ ដែលត្រូវរកមានរាង

$(DEF): a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយ $(DEF)$ កាត់ $D(2\ ,4\ ,6)$

នោះ $x_0=2\ ,\ y_0=4\ ,\ z_0=6$

ហើយ $(DEF)$ មានវ៉ិចទ័រណរម៉ាល់

$\vec{n}=\overrightarrow{DE}\times\overrightarrow{DF}=(-32\ ,24\ ,-32)$

នោះ $a=-32\ ,\ b=24\ ,\ c=-32$

គេបាន សមីការប្លង់ $(DEF)$ សរសេរបាន

$$-32(x-2)+24(y-4)-24(z-6)=0$$
$$4(x-2)-3(y-4)+4(z-6)=0$$
$$4x-3y+4z-8+12-24=0$$
$$4x-3y+4z-20=0$$

ដូចនេះ សមីការប្លង់កំណត់បានគឺ

$(DEF): 4x-3y+4z-20=0$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ................................
លេខបន្ទប់ : ................................
លេខតុ : ................................
ហត្ថលេខា : ................................

**ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ**

**សម័យប្រឡង : ០៤ វិច្ឆិកា ២០១៨**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ២០**

## I. ផ្នែកពីជគណិត

1. គេមានដីមួយកន្លែងមានរាងជាចតុកោណកែង ដែលមានផ្ទៃក្រឡា $72\text{ m}^2$ និងបរិមាត្រ $36\text{ m}$ ។ រកប្រវែងបណ្តោយ និងទទឹងនៃចតុកោណកែងនេះ ។ **(២ ពិន្ទុ)**

2. គេមានចំនួនកុំផ្លិច $z_1 = 3 + 2\left(\dfrac{1}{2} - i\dfrac{\sqrt{3}}{2}\right)$ និង $z_2 = -3 + 2i\sqrt{3}$ ។ **(២ ពិន្ទុ)**

   គណនា $z_1 + z_2$ រួចសរសេរជាទម្រង់ត្រីកោណមាត្រ ។ សរសេរ $\left(\dfrac{z_1 + z_2}{2}\right)^{36}$ ជាទម្រង់ពីជគណិត ។

3. ថ្នាក់រៀនមួយមានសិស្ស 12 នាក់ ស្រី 5 នាក់ និងប្រុស 7 នាក់ ។ គេជ្រើសរើសក្រុមសម្អាត ដោយមួយក្រុមមាន 4 នាក់ ។ រកប្រូបាបនៃព្រឹត្តិការណ៍ ៖

   $A$ : ជ្រើសរើសបានក្រុម សិស្សប្រុសទាំងអស់ ។ **(១ ពិន្ទុ)**

   $B$ : ជ្រើសរើសបានក្រុម សិស្សស្រីពាក់កណ្តាល ។ **(១ ពិន្ទុ)**

4. គណនាអាំងតេក្រាលខាងក្រោម ៖ **(២ ពិន្ទុ)**

   ក. $I = \int_0^3 (2x+1)(x+3)\,dx$ ខ. $J = \int_0^{\frac{\pi}{4}} \dfrac{\sin^2 2x}{4}\,dx$ គ. $K = \int_{-6}^{6} \left(2xe^{x^2}\right)dx$ ។

5. គេមានអនុគមន៍ $f(x) = \dfrac{x^2 - \ln x + x}{x}$ មានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j})$ ។

   ក. បង្ហាញថា $f(x) = x + 1 - \dfrac{\ln x}{x}$ កំណត់លើ $(0, +\infty)$ រួចរកលីមីតនៃអនុគមន៍ $f$ ត្រង់ 0 និង $+\infty$ ។ **(២ ពិន្ទុ)**

   ខ. ដោយយក $f'(x)$ ជាដេរីវេនៃ $f(x)$ ចូរបង្ហាញថា $f'(x) = \dfrac{x^2 - 1 + \ln x}{x^2}$ លើចន្លោះ $(0, +\infty)$ ។ **(១ ពិន្ទុ)**

   គ. ដោយដឹងថាកន្សោម $(x^2 - 1 + \ln x)$ យកតម្លៃអវិជ្ជមានដាច់ខាតលើចន្លោះ $(0, 1)$ សិក្សាសញ្ញា $f'(x)$ និងសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។ **(១ ពិន្ទុ)**

   ឃ. បង្ហាញថាបន្ទាត់ $(\Delta): y = x + 1$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ត្រង់ $+\infty$ ។ សិក្សាទីតាំងធៀបនៃ $(\Delta)$ និង $(C)$ ។ សង់ក្រាប $(C)$ និង $(\Delta)$ ។ **(១ ពិន្ទុ)**

## II. ផ្នែកធរណីមាត្រ

1. នៅក្នុងតម្រុយ $(O, \vec{i}, \vec{j}, \vec{k})$ មានទិសដៅវិជ្ជមាន គេមានចំណុច $A(4, 3, 2)$, $B(6, 5, 3)$, $C(7, 6, 4)$ និង $D(5, 4, 3)$ ។ រក $\overrightarrow{AD}$ និង $\overrightarrow{BC}$ រួចទាញបញ្ជាក់ថា ចតុកោណ $ABCD$ ជាប្រលេឡូក្រាម ។ **(៣ ពិន្ទុ)**

2. គេឱ្យសមីការ $\left(\dfrac{2y - 3x}{18}\right)\left(\dfrac{2y + 3x}{2}\right) = 1$ ។

   បង្ហាញថាសមីការខាងលើជាមីការអ៊ីពែបូល រួចរកកូអរដោនេកំពូលទាំងពីរ កំណុំទាំងពីរ និងសមីការអាស៊ីមតូតទាំងពីរនៃអ៊ីពែបូល រួចសង់អ៊ីពែបូល និងអាស៊ីមតូត ។ **(៤ ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
# ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ២០១៨

## I. ផ្នែកពីជគណិត

### 1. រកប្រវែងបណ្តោយ និងទទឹងនៃចតុកោណកែង

គេតាង $x$ ជាប្រវែងបណ្តោយ និង $y$ ជាប្រវែងទទឹង

មានតម្លៃវិជ្ជមាន ដែល $x>y$ (គិតជា m)




ផ្ទៃក្រឡា $72\ \mathrm{m}^2$

បរិមាត្រ $36$ m

បម្រាប់ គេសរសេរបានប្រព័ន្ធសមីការ

$$\begin{cases} xy=72 \\ 2(x+y)=36 \end{cases} \quad \text{ឬ} \quad \begin{cases} xy=72 \\ x+y=18 \end{cases}$$

តាមវៀត $x$ , $y$ ជាឫសនៃសមីការ $X^2-SX+P=0$

$X^2-18X+72=0$ មាន $\Delta'=81-72=9$

នាំឱ្យ $x=\dfrac{-(-9)+\sqrt{9}}{1}=12$ m

$y=\dfrac{-(-9)-\sqrt{9}}{1}=6$ m

ផ្ទៀងផ្ទាត់ $\begin{cases} xy=12\cdot 6=72 \\ x+y=12+6=18 \end{cases}$ ពិត

ដូចនេះ $\boxed{\text{បណ្តោយ } x=12\text{m} \ , \ \text{ទទឹង } y=6\text{m}}$ ។

### 2. គណនា $z_1+z_2$ រួចសរសេរជាទម្រង់ត្រីកោណមាត្រ

គេមាន $z_1=3+2\left(\dfrac{1}{2}-i\dfrac{\sqrt{3}}{2}\right)=4-i\sqrt{3}$

$z_2=-3+2i\sqrt{3}$

គេបាន $z_1+z_2=\left(4-i\sqrt{3}\right)+\left(-3+2i\sqrt{3}\right)=\boxed{\mathbf{1+i\sqrt{3}}}$

ដោយ $z_1+z_2=1+i\sqrt{3}=2\left(\dfrac{1}{2}+i\dfrac{\sqrt{3}}{2}\right)$

$$=\boxed{2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)}$$

**សរសេរ** $\left(\dfrac{z_1+z_2}{2}\right)^{36}$ **ជាទម្រង់ពីជគណិត**

$$\frac{z_1+z_2}{2}=\frac{2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)}{2}=\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)$$

$$\left(\frac{z_1+z_2}{2}\right)^{36}=\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)^{36} \quad \text{តាមរូបមន្តដឺម័រ}$$

$=\cos 12\pi+i\sin 12\pi$

$=\cos 0+i\sin 0$

$=1+0\cdot i$

ព្រោះ $\cos(2k\pi)=\cos 0$ , $\sin(2k\pi)=\sin 0$, $k\in\mathbb{Z}$

ដូចនេះ ទម្រង់ពីជគណិតគឺ $\boxed{\left(\dfrac{z_1+z_2}{2}\right)^{36}=1+0\cdot i}$ ។

### 3. រកប្រូបាបនៃព្រឹត្តិការណ៍

គេមានសិស្ស 12 នាក់ ស្រី 5 នាក់ និងប្រុស 7 នាក់

គេជ្រើសរើសក្រុមសម្អាត ដោយមួយក្រុមមាន 4 នាក់

នាំឱ្យ ចំនួនករណីអាច $n(S)=C(12\ ,\ 4)$

$$n(S)=\frac{12!}{8!\cdot 4!}=\frac{12\cdot 11\cdot 10\cdot 9\cdot 8!}{8!\cdot 4\cdot 3\cdot 2}=495$$

**A : រកប្រូបាបជ្រើសរើសបានក្រុម សិស្សប្រុសទាំងអស់**

ចំនួនករណីស្រប $n(A)=C(7\ ,\ 4)$

នាំឱ្យ $n(A)=\dfrac{7!}{3!\cdot 4!}=\dfrac{7\cdot 6\cdot 5\cdot 4!}{3\cdot 2\cdot 4!}=35$

គេបាន $P(A)=\dfrac{n(A)}{n(S)}=\dfrac{35}{495}=\dfrac{7}{99}\approx 0.071$

ដូចនេះ $\boxed{P(A)=\dfrac{7}{99}\approx 0.071}$ ។

**B : រកប្រូបាបជ្រើសរើសបានក្រុម សិស្សស្រីពាក់កណ្តាល**

មានន័យថា គេជ្រើសរើសបានស្រីពីរនាក់ និងប្រុសពីរនាក់

នាំឱ្យ $n(B)=C(5\ ,\ 2)\times C(7\ ,\ 2)$

$=\dfrac{5!}{3!\cdot 2!}\times\dfrac{7!}{5!\cdot 2!}$

$=\dfrac{7\cdot 6\cdot 5\cdot 4\cdot 3!}{3!\cdot 2\cdot 2}=210$

គេបាន $P(B)=\dfrac{n(B)}{n(S)}=\dfrac{210}{495}=\dfrac{42}{99}=\dfrac{14}{33}\approx 0.424$

ដូចនេះ $\boxed{P(B)=\dfrac{14}{33}\approx 0.424}$ ។

**4. គណនាអាំងតេក្រាលខាងក្រោម**

$$\mathbf{I}=\int_0^3 (2x+1)(x+3)\,dx$$
$$=\int_0^3 (2x^2+7x+3)\,dx$$
$$=\left[\frac{2x^3}{3}+\frac{7x^2}{2}+3x\right]_0^3$$
$$=\left(18+\frac{63}{2}+9\right)-(0)=\boxed{\mathbf{\frac{117}{2}}}$$

$$\mathbf{J}=\int_0^{\frac{\pi}{4}}\frac{\sin^2 2x}{4}\,dx \quad , \quad 1-\cos 4x=2\sin^2 2x$$
$$=\frac{1}{4}\int_0^{\frac{\pi}{4}}\left(\frac{1-\cos 4x}{2}\right)dx=\frac{1}{8}\int_0^{\frac{\pi}{4}}(1-\cos 4x)\,dx$$
$$=\frac{1}{8}\left[x-\frac{1}{4}\sin 4x\right]_0^{\frac{\pi}{4}}$$
$$=\frac{1}{8}\left[\left(\frac{\pi}{4}-\frac{1}{4}\sin\pi\right)-\left(0-\frac{1}{4}\sin 0\right)\right]$$
$$=\frac{1}{8}\left[\left(\frac{\pi}{4}-0\right)-(0)\right]=\boxed{\frac{\pi}{\mathbf{32}}}$$

$$\mathbf{K}=\int_{-6}^{6}\left(2xe^{x^2}\right)dx \quad , \quad \int f'(x)e^{f(x)}dx=e^{f(x)}+c$$
$$=\int_{-6}^{6}\left(\left(x^2\right)' e^{x^2}\right)dx$$
$$=\left[e^{x^2}\right]_{-6}^{6}=e^{36}-e^{36}=\boxed{\mathbf{0}}$$

**5. បង្ហាញថា** $f(x)=x+1-\dfrac{\ln x}{x}$ **កំណត់លើ** $(0\,,+\infty)$

គេមាន $f(x)=\dfrac{x^2-\ln x+x}{x}$ , $f$ មានន័យលុះត្រាតែ

$\begin{cases}x>0\\ x\neq 0\end{cases}$ ឬ $x>0$ ឬ $x\in(0\,,+\infty)$

គេបាន $f(x)=\dfrac{x^2}{x}-\dfrac{\ln x}{x}+\dfrac{x}{x}=x+1-\dfrac{\ln x}{x}$

ដូចនេះ $\boxed{f(x)=x+1-\dfrac{\ln x}{x}\text{ កំណត់លើ }(0\,,+\infty)}$ ។

**រកលីមីតនៃអនុគមន៍** $f$ **ត្រង់** $0$ **និង** $+\infty$

$$\lim_{x\to 0^+} f(x)=\lim_{x\to 0^+}\left(x+1-\frac{\ln x}{x}\right)=0+1+\infty=\boxed{+\infty}$$

$$\lim_{x\to +\infty} f(x)=\lim_{x\to +\infty}\left(x+1-\frac{\ln x}{x}\right)=+\infty+1-0=\boxed{+\infty}$$

(ព្រោះ $\lim\limits_{x\to 0^+}\dfrac{1}{x}=+\infty$ , $\lim\limits_{x\to 0^+}\ln x=-\infty$ , $\lim\limits_{x\to +\infty}\dfrac{\ln x}{x}=0$ )

**ខ. បង្ហាញថា** $f'(x)=\dfrac{x^2-1+\ln x}{x^2}$

គេមាន $f(x)=x+1-\dfrac{\ln x}{x}$

$$f'(x)=1+-\frac{(\ln x)' x-(x)'\ln x}{x^2}$$
$$=\frac{x^2-1+\ln x}{x^2}$$

ដូចនេះ $\boxed{f'(x)=\dfrac{x^2-1+\ln x}{x^2}}$ ចំពោះ $x\in(0\,,+\infty)$ ។

**គ. សិក្សាសញ្ញា** $f'(x)$

ចំពោះ $x\in(0\,,1)$ បម្រាប់ $x^2-1+\ln x<0$ , $x^2>0$

នោះ $f'(x)=\dfrac{x^2-1+\ln x}{x^2}<0$

ចំពោះ $x=1$ គេបាន

$$f'(x)=\frac{1^2-1+\ln 1}{1^2}=\frac{0}{1}=0$$

( $f(1)=1+1-\dfrac{\ln 1}{1}=2$ )

ចំពោះ $x>1$ ឬ $x\in(1\,,+\infty)$ នោះ $\ln x>\ln 1=0$

ហើយ $x^2>1$ ឬ $x^2-1>0$

គេបាន $f'(x)=\dfrac{x^2-1+\ln x}{x^2}>0$

ដូចនេះ សិក្សាសញ្ញា $f'(x)$ បានដូចខាងក្រោម៖

| | |
|---|---|
| $x\in(0\,,1)$ | $: f'(x)<0$ |
| $x=1$ | $: f'(x)=0$ |
| $x\in(1\,,+\infty)$ | $: f'(x)>0$ |

។

សន្និដ្ឋានត្រង់ $x=1$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$ នោះ $f$ មានអប្បបរមាធៀបមួយស្មើ $f(1)=2$

**សង់តារាងអថេរភាពនៃអនុគមន៍** $f$

| $x$ | $0$ | $1$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $-$ | $0$ | $+$ |
| $f(x)$ | $+\infty$ ↘ | $2$ | ↗ $+\infty$ |

**ឃ. បង្ហាញថា $(\Delta): y = x+1$ ជាអាស៊ីមតូតទ្រេតត្រង់ $+\infty$**

គេមាន $f(x) = x+1-\dfrac{\ln x}{x}$ និង $\lim\limits_{x\to+\infty}\left(-\dfrac{\ln x}{x}\right) = 0$

នាំឱ្យ បន្ទាត់ដែលមានសមីការ $(\Delta): y = x+1$

ជាអាស៊ីមតូតទ្រេតនៃក្រាប $C$ ត្រង់ $+\infty$ ។

**សិក្សាទីតាំងធៀបនៃ $(\Delta)$ និង $(C)$**

គេមាន $(\Delta): y = x+1$ និង $(C): f(x) = x+1-\dfrac{\ln x}{x}$

សិក្សា ផលដកនៃសមីការ $(C)$ និង $(\Delta)$ គេបាន

$$(C)-(\Delta): f(x)-y = \left(x+1-\frac{\ln x}{x}\right)-(x+1) = -\frac{\ln x}{x}$$

សញ្ញានៃ $(C)-(\Delta)$ អាស្រ័យ $-\dfrac{\ln x}{x}$

-ចំពោះ $x=1$ គេបាន $-\dfrac{\ln 1}{1} = 0$ មានន័យថា

ក្រាប $(C)$ កាត់អាស៊ីមតូតទ្រេត $(\Delta)$ ។

-ចំពោះ $x>1$ គេបាន $\ln x > \ln 1$ ឬ $\ln x > 0$

នាំឱ្យ $-\dfrac{\ln x}{x} < 0$ មានន័យថា

ក្រាប $(C)$ នៅខាងក្រោមអាស៊ីមតូតទ្រេត $(\Delta)$ ។

-ចំពោះ $0<x<1$ គេបាន $\ln x < \ln 1$ ឬ $\ln x < 0$

នាំឱ្យ $-\dfrac{\ln x}{x} > 0$ មានន័យថា

ក្រាប $(C)$ នៅខាងលើអាស៊ីមតូតទ្រេត $(\Delta)$ ។

**សង់ក្រាប $(C)$ និង $(\Delta)$**

(សង់តារាងតម្លៃលេខខ្លួនឯង)




**II. ផ្នែកធរណីមាត្រ**

**1. រក $\overrightarrow{AD}$ និង $\overrightarrow{BC}$**

គេមាន $A(4,3,2)$, $B(6,5,3)$, $C(7,6,4)$

និង $D(5,4,3)$

គេបាន $\overrightarrow{AD} = (5-4, 4-3, 3-2) = \boxed{(\mathbf{1},\mathbf{1},\mathbf{1})}$

$\overrightarrow{BC} = (7-6, 6-5, 4-3) = \boxed{(\mathbf{1},\mathbf{1},\mathbf{1})}$

**ទាញបញ្ជាក់ថា ចតុកោណ $ABCD$ ជាប្រលេឡូក្រាម**

ដោយ $\overrightarrow{AD} = \overrightarrow{BC} = (1,1,1)$ មានន័យថា

$AD = BC$ និង $AD // BC$

ដូចនេះ: $\boxed{\text{ចតុកោណ } ABCD \text{ ជាប្រលេឡូក្រាម}}$ ។

**2. បង្ហាញថាសមីការខាងលើជាមីការអ៊ីពែបូល**

គេមាន $\left(\dfrac{2y-3x}{18}\right)\left(\dfrac{2y+3x}{2}\right) = 1$ ឬ $\dfrac{4y^2-9x^2}{36} = 1$

គេបាន $\dfrac{y^2}{9}-\dfrac{x^2}{4} = 1$ មានទម្រង់ដូចសមីការ $\dfrac{y^2}{a^2}-\dfrac{x^2}{b^2} = 1$

ដែលជាសមីការស្តង់ដាផ្ចិត $O$ នៃអ៊ីពែបូលដែល

មានអ័ក្សទទឹង នៅលើអ័ក្សអរដោនេ ។

ដូចនេះ: $\left(\dfrac{2y-3x}{18}\right)\left(\dfrac{2y+3x}{2}\right) = 1$ ជាសមីការអ៊ីពែបូល ។

**រកកូអរដោនេកំពូលទាំងពីរ កំណុំទាំងពីរ និងស.អាស៊ីមតូតទាំងពីរ**

គេមាន $\dfrac{y^2}{9}-\dfrac{x^2}{4} = 1$ ផ្ទឹមនឹង $\dfrac{y^2}{a^2}-\dfrac{x^2}{b^2} = 1$

នាំឱ្យ $a = 3$, $b = 2$, $c = \sqrt{9+4} = \sqrt{13}$

កំពូល $V(0, \pm a)$ នាំឱ្យ $\boxed{V_1(0,3)\ ,\ V_2(0,-3)}$

កំណុំ $F(0, \pm c)$ នាំឱ្យ $\boxed{F_1(0,\sqrt{13}), F_2(0,-\sqrt{13})}$

អា.តូត $y = \pm\dfrac{a}{b}x$ នាំឱ្យ $\boxed{d_1: y = \dfrac{3}{2}x\ ,\ d_2: y = -\dfrac{3}{2}x}$

**សង់អ៊ីពែបូល និងអាស៊ីមតូត**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ**

**សម័យប្រឡង : ២៧ តុលា ២០១៧**

**វិញ្ញាសា : គណិតវិទ្យា  រយៈពេល : ១២០ នាទី  ពិន្ទុ : ២០**

## I. ផ្នែកពីជគណិត

**1.** គេមានអនុគមន៍ $f(x)=\ln\left(x+\sqrt{x^2+2}\right)$ ។ ចូររកដេរីវេនៃអនុគមន៍ $f(x)$ រួចគណនាកន្សោម

$I=\int_0^1\left(\frac{1}{\sqrt{x^2+2}}\right)dx$ ។ **(២ ពិន្ទុ)**

**2.** ចូរដោះស្រាយសមីការឌីផេរ៉ង់ស្យែលខាងក្រោម ៖ **(២ ពិន្ទុ)**

ក. $y'-y\sin x=0$ ចំពោះ $y(0)=e$ ។

ខ. $y''+2y'-15y=0$ ចំពោះ $y(0)=5$ និង $y'(0)=-1$ ។

**3.** ក្នុងប្រអប់មួយមានប៊ិចខៀវ 8 ដើម និងប៊ិចក្រហម 7 ដើម ។ អ្នកគ្រូលីដាចាប់យកប៊ិច 5 ដើមព្រមគ្នាពីប្រអប់នោះដោយចៃដន្យទុកសម្រាប់លើកទឹកចិត្តសិស្សពេលបង្រៀននៅថ្ងៃស្អែក ។

ក. រកប្រូបាបដែលគាត់ចាប់បានប៊ិចខៀវ 2 ដើម និងប៊ិចក្រហម 3 ដើម ។ **(១ ពិន្ទុ)**

ខ. រកប្រូបាបដែលគាត់ចាប់បានប៊ិចក្រហម 1 ដើមយ៉ាងតិច ។ **(១ ពិន្ទុ)**

**4.** គេមានអនុគមន៍ $f(x)=-x^3-3x^2+1$ ។

ក. សិក្សាអថេរភាព និងគូសខ្សែកោង $C$ នៃអនុគមន៍ $f(x)$ ។ **(៣ ពិន្ទុ)**

ខ. ស្រាយបំភ្លឺថាចំណុចរបត់ $I$ របស់ខ្សែកោង $C$ ជាផ្ចិតឆ្លុះរបស់ខ្សែកោងនោះ ។ **(១ ពិន្ទុ)**

គ. ចូរសរសេរសមីការបន្ទាត់ប៉ះខ្សែកោង $C$ ស្របនឹងបន្ទាត់ $d: y=-9x+1$ ។ **(១ ពិន្ទុ)**

## II. ផ្នែកធរណីមាត្រ

**1.** នៅក្នុងលំហនៃតម្រុយអរតូណរម៉ាល់ $\left(O, \vec{i}, \vec{j}, \vec{k}\right)$ គេមានបន្ទាត់ $d$ កាត់តាមចំណុច $I(1,-3,3)$ ហើយស្របនឹងវ៉ិចទ័រ $\vec{v}=(-1,2,1)$ និងមានប្លង់ $P$ មួយដែលមានសមីការ $P: 2x+y-2z+9=0$ ។

ក. ចូរសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $d$ និងរកកូអរដោនេនៃចំណុច $D$ នៅលើបន្ទាត់ $d$ ដោយដឹងថា ចម្ងាយពីចំណុច $D$ ទៅប្លង់ $P$ ស្មើនឹង 2 ។ **(៣ ពិន្ទុ)**

ខ. រកកូអរដោនេចំណុចប្រសព្វ $A$ រវាងបន្ទាត់ $d$ និងប្លង់ $P$ ។ **(២ ពិន្ទុ)**

**2.** គេមានប៉ារ៉ាបូលដែលមានចំណុចកំណុំ $F(5,2)$ និងបន្ទាត់ប្រាប់ទិសមានសមីការ $x+1=0$ ។

ចូររកកំពូល $V$ នៃប៉ារ៉ាបូល រួចសរសេរសមីការស្តង់ដានៃប៉ារ៉ាបូលនេះ ។ **(៤ ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ ២០១៧

## I. ផ្នែកពិជគណិត

**1. រកដេរីវេនៃអនុគមន៍** $f(x)$

គេមាន $f(x)=\ln\left(x+\sqrt{x^2+2}\right)$ , តាមរូបមន្ត $\ln u=\dfrac{u'}{u}$

នាំឱ្យ $f'(x)=\dfrac{\left(x+\sqrt{x^2+2}\right)'}{x+\sqrt{x^2+2}}=\dfrac{1+\dfrac{\left(x^2+2\right)'}{2\sqrt{x^2+2}}}{x+\sqrt{x^2+2}}$

$$=\dfrac{1+\dfrac{x}{\sqrt{x^2+2}}}{x+\sqrt{x^2+2}}=\dfrac{\dfrac{\sqrt{x^2+2}+x}{\sqrt{x^2+2}}}{x+\sqrt{x^2+2}}=\dfrac{1}{\sqrt{x^2+2}}$$

ដូចនេះ $\boxed{f'(x)=\dfrac{1}{\sqrt{x^2+2}}}$ ។

**គណនាកន្សោម** $I$

គេមាន $I=\int_0^1\left(\dfrac{1}{\sqrt{x^2+2}}\right)dx$ ទាញពីលទ្ធផលខាងលើ

គេបាន $I=\int_0^1 f'(x)\,dx=\left[f(x)\right]_0^1$ ជាចំនួនថេរ

$$=\left[\ln\left(x+\sqrt{x^2+2}\right)\right]_0^1$$

$$=\ln\left(1+\sqrt{3}\right)-\ln\left(\sqrt{2}\right)$$

$$=\ln\left(\dfrac{1+\sqrt{3}}{\sqrt{2}}\right)=\ln\left(\dfrac{\sqrt{2}+\sqrt{6}}{2}\right)$$

ដូចនេះ $\boxed{I=\ln\left(\dfrac{\sqrt{2}+\sqrt{6}}{2}\right)}$ ។

**2. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល**

**ក. គេមាន** $y'-y\sin x=0$ **ចំពោះ:** $y(0)=e$

គេបាន $\dfrac{y'}{y}=\sin x$ (បំពាក់អាំងតេក្រាលលើអង្គទាំងពីរ)

$\ln|y|=-\cos x+c$

$|y|=e^{-\cos x+c}$

$y=\pm e^{-\cos x+c}$

$y=\pm e^{c}\cdot e^{-\cos x}=Ae^{-\cos x}$ ដែល $A=\pm e^{c}$ ថេរ

ដោយ $y(0)=e$ នោះ $Ae^{-\cos 0}=e$ នាំឱ្យ $A=e^2$

គេបាន $y=Ae^{-\cos x}=e^2\cdot e^{-\cos x}=e^{2-\cos x}$

ដូចនេះ $\boxed{y=e^{2-\cos x}}$ ជាចម្លើយផ្ទៀងផ្ទាត់លក្ខខណ្ឌដើម ។

ខ. គេមានសមីការ $y''+2y'-15y=0$

មានសមីការសម្គាល់ $\lambda^2+2\lambda-15=0$

គេបាន $\Delta'=1+15=16$

នាំឱ្យ $\lambda_1=\dfrac{-b'-\sqrt{\Delta'}}{a}=-1-\sqrt{16}=-5$

$\lambda_2=\dfrac{-b'+\sqrt{\Delta'}}{a}=-1+\sqrt{16}=3$

ចម្លើយទូទៅមានរាង $y=Ae^{\lambda_1 x}+Be^{\lambda_2 x}$ ដែល $A$ , $B$ ថេរ

នាំឱ្យ $y=Ae^{-5x}+Be^{3x}$

$y'=-5Ae^{-5x}+3Be^{3x}$

ដោយ $y(0)=5$ និង $y'(0)=-1$

គេបាន $\begin{cases}y(0)=Ae^0+Be^0=5\\ y'(0)=-5Ae^0+3Be^0=-1\end{cases}$

$\begin{cases}A+B=5\\ -5A+3B=-1\end{cases}\Rightarrow\ A=2\,,\ B=3$

ដូចនេះ $\boxed{y=2e^{-5x}+3e^{3x}}$ ។

**3. រកប្រូបាបដែលគាត់ចាប់បាន៖**

គេមាន ប៊ិចខៀវ 8 ដើម និងប៊ិចក្រហម 7 ដើម

អ្នកគ្រូលីដាចាប់យកប៊ិច 5 ដើម ដោយចៃដន្យ

នាំឱ្យ ចំនួនករណីអាច $n(S)=C(15,5)$

$$n(S)=\dfrac{15!}{10!\times 5!}=\dfrac{15\cdot 14\cdot 13\cdot 12\cdot 11\cdot \cancel{10!}}{\cancel{10!}\cdot 5\cdot 4\cdot 3\cdot 2}=3003$$

**ក. ប៊ិចខៀវ 2 ដើម និងប៊ិចក្រហម 3 ដើម**

តាង $A$: ជាព្រឹត្តិការណ៍ចាប់បានប៊ិចខៀវ 2 និងក្រហម 3 ដើម

គេបាន $n(A)=C(8\,,\,2)\times C(7\,,\,3)$

$$n(A)=\dfrac{8!}{6!\,2!}\times\dfrac{7!}{4!\,3!}=\dfrac{8\cdot 7\cdot 6!}{6!\cdot 2}\times\dfrac{7\cdot 6\cdot 5\cdot 4!}{4!\cdot 6}=980$$

ដូចនេះ: $P(A)=\dfrac{n(A)}{n(S)}=\dfrac{980}{3003}=\boxed{\dfrac{140}{429}}$ ។

**ខ. ប៊ិចក្រហម 1 ដើមយ៉ាងតិច**

តាង $B$: ជាព្រឹត្តិការណ៍ចាប់បានប៊ិចក្រហម 1 ដើមយ៉ាងតិច

នោះ $\overline{B}$: ជាព្រឹត្តិការណ៍ចាប់បានប៊ិចខៀវទាំងអស់ 5 ដើម

ដែល $B$ និង $\overline{B}$ ជាព្រឹត្តិការណ៍បំពេញគ្នា $P(B)+P(\overline{B})=1$

ដោយ $n(\overline{B})=C(8,5)=\frac{8!}{3!\cdot 5!}=\frac{8\cdot7\cdot6\cdot\cancel{5!}}{6\cdot\cancel{5!}}=56$

នាំឱ្យ $P(\overline{B})=\frac{n(\overline{B})}{n(S)}=\frac{56}{3003}=\frac{8}{429}$

គេបាន $P(B)=1-P(\overline{B})=1-\frac{8}{429}=\frac{421}{429}$

ដូចនេះ $\boxed{P(B)=\frac{421}{429}}$ ។

**4. ក. សិក្សាអថេរភាពនៃអនុគមន៍ $f$**

គេមាន $f(x)=-x^3-3x^2+1$ (**ដូចគ្រូអនុ. 2013**)

• ដែនកំណត់ : អនុគមន៍ $f$ មានន័យគ្រប់ $x\in\mathbb{R}$

ដូចនេះ ដែនកំណត់ $\boxed{D=\mathbb{R}=(-\infty\,,+\infty)}$ ។

• ទិសដៅអថេរភាព

គេមាន $f(x)=-x^3-3x^2+1$

ដេរីវេ : $f'(x)=-3x^2-6x=-3x(x+2)$

គេឱ្យ $f'(x)=0$

$-3x(x+2)=0$ នោះ $x=0\,,\ x=-2$

គេបាន $f(0)=-0^3-3\cdot0^2+1=1$

$f(-2)=-(-2)^3-3(-2)^2+1=-3$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $-2$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | $0$ | $-$ | |

• បរមា

-ត្រង់ $x=-2$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើ $f(-2)=-3$ ។

-ត្រង់ $x=0$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$

បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើ $f(0)=1$ ។

• លីមីត $\lim\limits_{x\to-\infty}f(x)=\lim\limits_{x\to-\infty}\left(-x^3-3x^2+1\right)=+\infty$

$\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to+\infty}\left(-x^3-3x^2+1\right)=-\infty$

• តារាងអថេរភាព

| $x$ | $-\infty$ | | $-2$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | $0$ | $-$ | |
| $f(x)$ | $+\infty$ | $\searrow$ | $-3$ | $\nearrow$ | $1$ | $\searrow$ | $-\infty$ |

• ភាពប៉ោង និងភាពផត

ដេរីវេទី២ $f''(x)=\left(-3x^2-6x\right)'=-6x-6$

គេឱ្យ $f''(x)=0 \Leftrightarrow -6x-6=0$ នោះ $x=-1$ ជាឫស

- បើ $x>-1$ នោះ $f''(x)<0$

  នាំឱ្យ ខ្សែកោងបែរភាពផតចុះខាងក្រោម

- បើ $x<-1$ នោះ $f''(x)>0$

  នាំឱ្យ ខ្សែកោងបែរភាពផតទៅខាងលើ

- បើ $x=-1$ , $f''(x)=0$ និងប្តូរសញ្ញា

  នាំឱ្យ $f$ មានចំណុចរបត់មួយតាងដោយ $I$ ដែល

  $I(-1,f(-1))$ ឬ $I(-1,-1)$

• សង់ក្រាប




**ខ. ស្រាយបំភ្លឺថាចំណុចរបត់ $I$ ជាផ្ចិតឆ្លុះរបស់ខ្សែកោងនោះ**

គេនឹង បង្ហាញថាចំណុចរបត់ $I(-1\,,-1)$ ជាផ្ចិតឆ្លុះនៃខ្សែកោង

បើ $I(a\,,b)$ ជាផ្ចិតឆ្លុះ លុះត្រាតែ $f(2a-x)+f(x)=2b$

គេបាន $f(-2-x)+f(x)=-2$

ដោយ $f(-2-x)=-(-2-x)^3-3(-2-x)^2+1$

$=(2+x)^3-3(2+x)^2+1$

$=8+12x+6x^2+x^3-12-12x-3x^2+1$

$=x^3+3x^2-3$

នាំឱ្យ $f(-x)+f(x)$

$=\left(x^3+3x^2-3\right)+\left(-x^3-3x^2+1\right)$

$=-2$ ពិត

ដូចនេះ $\boxed{I(-1\,,-1)\text{ ជាផ្ចិតឆ្លុះនៃខ្សែកោង } C}$ ។

គ. សរសេរសមីការបន្ទាត់ប៉ះខ្សែកោង $C$ ស្របនឹងបន្ទាត់ $d$

សមីការបន្ទាត់ប៉ះមានរាង $T : y = f'(x_0)(x - x_0) + f(x_0)$

ដោយ $T // d : y = -9x + 1$ នោះ $f'(x_0) = -9$

គេបាន $-3x_0^2 - 6x_0 = -9$ ឬ $x_0^2 + 2x_0 - 3 = 0$

ករណីពិសេស $a + b + c = 0$ នោះ $x_0 = 1$ , $x_0 = -3$

• ចំពោះ $x_0 = 1$ នោះគេបានសមីការបន្ទាត់ប៉ះគឺ

$$T_1 : y = -9(x - 1) + f(1)$$
$$= -9x + 9 + (-1^3 - 3\cdot 1^2 + 1)$$
$$= -9x + 6$$

• ចំពោះ $x_0 = -3$ នោះគេបានសមីការបន្ទាត់ប៉ះគឺ

$$T_2 : y = -9(x + 3) + f(-3)$$
$$= -9x - 27 + \left[-(-3)^3 - 3\cdot(-3)^2 + 1\right]$$
$$= -9x - 26$$

ដូចនេះ សមីការបន្ទាត់ប៉ះក្រាប $C$ ស្របនឹងបន្ទាត់ $d$ មានពីរបន្ទាត់គឺ $T_1 : y = -9x + 6$ , $T_2 : y = -9x - 26$

## II. ផ្នែកធរណីមាត្រ

**1.** ក. សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $d$

ដោយ $d$ កាត់តាមចំណុច $I(1 , -3 , 3)$

នោះ $x_0 = 1$ , $y_0 = -3$ , $z_0 = 3$

ហើយ $d$ ស្របនឹងវ៉ិចទ័រ $\vec{v} = (-1 , 2 , 1)$

នោះ $a = -1$ , $b = 2$ , $c = 1$

សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $d$ មានរាងទូទៅ

$$d : \begin{cases} x = x_0 + at \\ y = y_0 + bt \ , \ t \in \mathbb{R} \\ z = z_0 + ct \end{cases}$$

ដូចនេះ $d : \begin{cases} x = 1 - t \\ y = -3 + 2t \ , t \in \mathbb{R} \\ z = 3 + t \end{cases}$

**រកកូអរដោនេនៃចំណុច $D$ នៅលើបន្ទាត់ $d$**

ដោយដឹងថា ចម្ងាយពីចំណុច $D$ ទៅប្លង់ $(P)$ ស្មើនឹង 2

តាមរូបមន្ត ចម្ងាយពីចំណុច $D$ ទៅប្លង់ $(P)$ កំណត់ដោយ

$$d(D,(P)) = \frac{|ax_0 + by_0 + cz_0 + d|}{\sqrt{a^2 + b^2 + c^2}}$$

ដោយ $P : 2x + y - 2z + 9 = 0$

នោះ $a = 2$ , $b = 1$ , $c = -2$ , $d = 9$

ហើយ $D$ នៅលើបន្ទាត់ $d$

នោះ $x_0 = 1 - t$ , $y_0 = -3 + 2t$ , $z_0 = 3 + t$ , $t \in \mathbb{R}$

គេបាន $$\frac{|2(1-t) + (-3+2t) - 2(3+t) + 9|}{\sqrt{2^2 + 1^2 + (-2)^2}} = 2$$

$$\frac{|2 - 2t - 3 + 2t - 6 - 2t + 9|}{\sqrt{4 + 1 + 4}} = 2$$

$$|2 - 2t| = 6$$

$$|1 - t| = 3$$

$$\left[\begin{array}{l} 1 - t = 3 \\ 1 - t = -3 \end{array}\right. \Rightarrow \left[\begin{array}{l} t = -2 \\ t = 4 \end{array}\right.$$

• ចំពោះ $t = -2$ : នោះ $D(x_0 = 3 , y_0 = -7 , z_0 = 1)$

• ចំពោះ $t = 4$ : នោះ $D(x_0 = -3 , y_0 = 5 , z_0 = 7)$

ដូចនេះ ចំណុច $D$ នៅលើបន្ទាត់ $d$ មានពីរចំណុចគឺ

$D_1(3 , -7 , 1)$ , $D_2(-3 , 5 , 7)$ ។

ខ. រកកូអរដោនេចំណុចប្រសព្វ $A$ រវាងបន្ទាត់ $d$ និងប្លង់ $P$

គេមាន $d : x = 1 - t$ , $y = -3 + 2t$ , $z = 3 + t$, $t \in \mathbb{R}$

$P : 2x + y - 2z + 9 = 0$

គេបាន $2(1 - t) + (-3 + 2t) - 2(3 + t) + 9 = 0$

$2 - 2t - 3 + 2t - 6 - 2t + 9 = 0$

$2 - 2t = 0 \Rightarrow t = 1$

នាំឱ្យ $A(x = 1 - 1 , y = -3 + 2 , z = 3 + 1)$

ដូចនេះ កូអរដោនេចំណុចប្រសព្វ $A(0 , -1 , 4)$ ។

**2.** រកកំពូល $V$ នៃប៉ារ៉ាបូល

គេមាន កំណុំប៉ារ៉ាបូល $F(5,2)$ និងបន្ទាត់ប្រាប់ទិស $x = -1$

នាំឱ្យ ប៉ារ៉ាបូលមានអ័ក្សឆ្លុះដេក មានកំពូល $V(h , k)$

ដោយ បន្ទាត់ប្រាប់ទិស $x = h - p = -1$

$F(h + p, k) = F(5,2)$ នោះ $h + p = 5$ , $k = 2$

គេបាន $\begin{cases} h - p = -1 \\ h + p = 5 \end{cases} \Rightarrow h = 2$ , $p = 3$

ដូចនេះ កូអរដោនេកំពូលគឺ $V(h = 2 , k = 2)$ ។

**សរសេរសមីការស្តង់ដានៃប៉ារ៉ាបូលនេះ**

សមីការស្តង់ដានៃប៉ារ៉ាបូលដែលមានអ័ក្សឆ្លុះដេកកំណត់ដោយ

$(y - k)^2 = 4p(x - h)$ តែដោយ $h = 2$ , $k = 2$ , $p = 3$

ដូចនេះ សមីការស្តង់ដាគឺ $(y - 2)^2 = 12(x - 2)$ ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : .................................

លេខបន្ទប់ : .................................

លេខតុ : .................................

ហត្ថលេខា : .................................

**ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ**

**សម័យប្រឡង : 0៤ ធ្នូ ២០១៦**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ២០**

**ផ្នែកពីជគណិត**

**1.** ចូរគណនាអាំងតេក្រាលខាងក្រោម ៖ **(២ ពិន្ទុ)**

ក. $\int(1+\cos x)^2\,dx+\int(1-\sin x)^2\,dx$ ខ. $\int\left(\frac{8x-7}{(x-2)(x+1)}\right)dx$

គ. $\int_0^{\pi} e^x\left(1+\frac{e^{-x}}{\cos^2 x}\right)dx$ ឃ. $\int_{\frac{\pi}{6}}^{\frac{\pi}{3}}\left(\frac{1}{\sin^2 x\cos^2 x}\right)dx$ ។

**2.** ចូរដោះស្រាយសមីការឌីផេរ៉ង់ស្យែលខាងក្រោម ៖ **(២ ពិន្ទុ)**

ក. $y''-3y'+2y=0$ ដោយដឹងថា $y(0)=1$ និង $y'(0)=3$ ។

ខ. $y''-2y'+y=0$ ដោយដឹងថា $y(0)=-3$ និង $y'(0)=2$ ។

**3.** គេមានចំនួនកុំផ្លិច $z_1=\frac{\sqrt{3}}{2}-\frac{i}{2}$ , $z_2=\frac{\sqrt{3}}{2}+\frac{i}{2}$ និង $v=\frac{-(\sqrt{3}+1)}{2}+\frac{(1+\sqrt{3})}{2}i$ ។

ក. ចូរសរសេរ $z_1$ និង $z_2$ ជាទម្រង់ត្រីកោណមាត្រ ។ **(១ ពិន្ទុ)**

ខ. ចូរគណនាកន្សោម $A$ ដែល $A=v+z_1+z_1^2$ ។ **(១ ពិន្ទុ)**

គ. ចូរគណនា $w$ ដែល $w=z_1^{120}+z_2^{120}$ ។ **(១ ពិន្ទុ)**

**4.** ក្រុមហ៊ុនមួយត្រូវការជ្រើសរើសបុគ្គលិកបម្រើការងារ 5 នាក់ ។ ក្រោយពីផ្សព្វផ្សាយដំណឹងនេះ មាននិស្សិត 10 នាក់ ក្នុងនោះមានស្រី 4 នាក់ និងប្រុស 6 នាក់ មកដាក់ពាក្យសុំបម្រើការងារ ។ ចូររកប្រូបាបដែលជ្រើសរើសបានយ៉ាងតិចនិស្សិតស្រី 3 នាក់ ។ **(២ ពិន្ទុ)**

**5.** គេមានអនុគមន៍ $f(x):y=\frac{x^2+5x+15}{(x+3)}$ ។

ក. សិក្សាអថេរភាព និងគូសខ្សែកោងនៃអនុគមន៍ $f(x)$ ។ **(២ ពិន្ទុ)**

ខ. រកគ្រប់ចំណុចនៅលើខ្សែកោងនៃអនុគមន៍ $f(x)$ ដែលមានកូអរដោនេជាចំនួនគត់រ៉ឺឡាទីប ។ **(១ ពិន្ទុ)**

គ. រកគ្រប់ចំណុច $M$ នៅលើខ្សែកោងនៃអនុគមន៍ $f(x)$ ដែលមានចម្ងាយពីចំណុច $M$ ទៅអ័ក្សអាប់ស៊ីសស្មើ 2 ដងនៃចម្ងាយពី $M$ ទៅអ័ក្សអរដោនេ ។ **(២ ពិន្ទុ)**

ឃ. ចូរសរសេរសមីការនៃបន្ទាត់ $(d)$ ប៉ះនឹងខ្សែកោងនៃអនុគមន៍ $f(x)$ ត្រង់ចំណុច $A(-2\,,9)$ ។ **(១ ពិន្ទុ)**

**ផ្នែកធរណីមាត្រ**

គេមានចំណុច $A(2\,,1\,,3)$ និងប្លង់ $(P):2x+y+3z-28=0$ ។

ក. ចូររកចំណុច $H$ និង $A'$ ដោយ $H$ ជាចំណោលកែងនៃ $A$ មកលើប្លង់ $(P)$ និង $H$ ជាចំណុចកណ្ដាលនៃ $[AA']$ ។ **(២ ពិន្ទុ)**

ខ. គណនាចម្ងាយពីចំណុច $A$ មកលើប្លង់ $(P)$ និងសរសេរសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ $(\Delta)$ កាត់តាមចំណុច $M(3\,,2\,,5)$ ហើយកែងនឹងប្លង់ $(P)$ ។ **(២ ពិន្ទុ)**

គ. ចូរសរសេរសមីការទូទៅនៃប្លង់ $(H)$ កាត់តាមចំណុច $I(3\,,-1\,,5)$ ហើយកែងនឹងបន្ទាត់ $(AM)$ ។ **(១ ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
# ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ ២០១៦

## ផ្នែកពីជគណិត

**1.** គណនាអាំងតេក្រាលខាងក្រោម :

ក. $\int (1+\cos x)^2 dx + \int (1-\sin x)^2 dx$

$= \int \left(1+2\cos x+\cos^2 x\right)dx + \int \left(1-2\sin x+\sin^2 x\right)dx$

$= \int \left(1+2\cos x+\cos^2 x+1-2\sin x+\sin^2 x\right)dx$

$= \int \left(3+2\cos x-2\sin x\right)dx \quad , \ \cos^2 x+\sin^2 x=1$

$= \boxed{3x+2\sin x+2\cos x+c \ , c \ \text{ថេរ}}$

ខ. $\int (\frac{8x-7}{(x-2)(x+1)})dx$

$= \int (\frac{8x+8-15}{(x-2)(x+1)})dx$

$= \int (\frac{8(x+1)}{(x-2)(x+1)} - 15\cdot\frac{1}{(x-2)(x+1)})dx$

$= \int \left(\frac{8}{(x-2)} - 15\cdot\frac{1}{3}\left[\frac{1}{(x-2)} - \frac{1}{(x+1)}\right]\right)dx$

$= 8\ln|x-2| - 5\left(\ln|x-2| - \ln|x+1|\right) + c \ , c \ \text{ថេរ}$

$= \boxed{3\ln|x-2| + 5\ln|x+1| + c \ , c \ \text{ថេរ}}$

គ. $\int_0^{\pi} e^x \left(1+\frac{e^{-x}}{\cos^2 x}\right)dx$

$= \int_0^{\pi} \left(e^x + \frac{1}{\cos^2 x}\right)dx = \left[e^x + \tan x\right]_0^{\pi}$

$= \left(e^{\pi} + \tan\pi\right) - \left(e^0 + \tan 0\right)$

$= \left(e^{\pi}+0\right) - \left(e^0+0\right) = \boxed{e^{\pi}-1}$

ឃ. $\int_{\frac{\pi}{6}}^{\frac{\pi}{3}} (\frac{1}{\sin^2 x\cos^2 x})dx$

$= \int_{\frac{\pi}{6}}^{\frac{\pi}{3}} (\frac{\sin^2 x+\cos^2 x}{\sin^2 x\cos^2 x})dx = \int_{\frac{\pi}{6}}^{\frac{\pi}{3}} (\frac{1}{\cos^2 x} + \frac{1}{\sin^2 x})dx$

$= \left[\tan x - \cot x\right]_{\frac{\pi}{6}}^{\frac{\pi}{3}}$

$= \left(\tan\frac{\pi}{3} - \cot\frac{\pi}{3}\right) - \left(\tan\frac{\pi}{6} - \cot\frac{\pi}{6}\right)$

$= \left(\sqrt{3} - \frac{\sqrt{3}}{3}\right) - \left(\frac{\sqrt{3}}{3} - \sqrt{3}\right) = 2\sqrt{3} - \frac{2\sqrt{3}}{3} = \boxed{\frac{4\sqrt{3}}{3}}$

**2.** ដោះស្រាយសមីការឌីផេរ៉ង់ស្យែលខាងក្រោម :

ក. គេមាន $y''-3y'+2y=0$ មានសមីការសម្គាល់

$\lambda^2-3\lambda+2=0$ មានឫស $\lambda_1=1 \ , \ \lambda_2=2$

ចម្លើយទូទៅមានរាង $y = Ae^{\lambda_1 x} + Be^{\lambda_2 x}$ , $A$ , $B$ ថេរ

គេបាន $y = Ae^x + Be^{2x}$ , $A$ , $B$ ថេរ

នាំឱ្យ $y' = Ae^x + 2Be^{2x}$

ដោយ $\begin{cases} y(0)=1 \\ y'(0)=3 \end{cases} \Leftrightarrow \begin{cases} Ae^0+Be^0=1 \\ Ae^0+2Be^0=3 \end{cases}$

$\begin{cases} A+B=1 \\ A+2B=3 \end{cases} \Rightarrow \begin{cases} B=2 \\ A=-1 \end{cases}$

ដូចនេះ: $\boxed{y=-e^x+2e^{2x}}$ ។

ខ. គេមាន $y''-2y'+y=0$ មានសមីការសម្គាល់

$\lambda^2-2\lambda+1=0$ មានឫសឌុប $\lambda_1=\lambda_2=\lambda_0=1$

ចម្លើយទូទៅមានរាង $y = Axe^{\lambda_0 x} + Be^{\lambda_0 x}$ , $A$ , $B$ ថេរ

គេបាន $y = Axe^x + Be^x$ , $A$ , $B$ ថេរ

នាំឱ្យ $y' = A\left(e^x + xe^x\right) + Be^x$

ដោយ $\begin{cases} y(0)=-3 \\ y'(0)=2 \end{cases} \Leftrightarrow \begin{cases} A\cdot 0\cdot e^0+Be^0=-3 \\ A\left(e^0+0\cdot e^0\right)+Be^0=2 \end{cases}$

$\begin{cases} B=-3 \\ A+B=2 \end{cases} \Rightarrow \begin{cases} B=-3 \\ A=5 \end{cases}$

ដូចនេះ: $\boxed{y=5xe^x-3e^x}$ ។

**3.** ក. សរសេរ $z_1$ និង $z_2$ ជាទម្រង់ត្រីកោណមាត្រ :

គេមាន $z_1 = \frac{\sqrt{3}}{2} - \frac{i}{2} = \cos\left(-\frac{\pi}{6}\right) + i\sin\left(-\frac{\pi}{6}\right)$

$z_2 = \frac{\sqrt{3}}{2} + \frac{i}{2} = \cos\frac{\pi}{6} + i\sin\frac{\pi}{6}$

ដូចនេះ: ទម្រង់ត្រីកោណមាត្រដែលសរសេរបានគឺ ៖

$\boxed{z_1 = \cos\left(-\frac{\pi}{6}\right) + i\sin\left(-\frac{\pi}{6}\right)}$

$\boxed{z_2 = \cos\frac{\pi}{6} + i\sin\frac{\pi}{6}}$

**ខ. គណនាកន្សោម $A$**

គេមាន $z_1=\frac{\sqrt{3}}{2}-\frac{i}{2}$ និង $v=\frac{-\left(\sqrt{3}+1\right)}{2}+\frac{\left(1+\sqrt{3}\right)}{2}i$

ដោយ $$z_1+z_1^2=\frac{\sqrt{3}}{2}-\frac{i}{2}+\left(\frac{\sqrt{3}}{2}-\frac{i}{2}\right)^2$$

$$=\frac{\sqrt{3}}{2}-\frac{i}{2}+\frac{3}{4}-\frac{\sqrt{3}}{2}i-\frac{1}{4}$$

$$=\frac{\sqrt{3}+1}{2}-\frac{\sqrt{3}+1}{2}i$$

នាំឱ្យ $A=v+z_1+z_1^2$

$$=\frac{-\left(\sqrt{3}+1\right)}{2}+\frac{\left(1+\sqrt{3}\right)}{2}i+\frac{\sqrt{3}+1}{2}-\frac{\sqrt{3}+1}{2}i$$

$$=0$$

ដូចនេះ គណនាបាន $\boxed{A=0}$ ។

**គ. គណនា $w$ ដែល $w=z_1^{120}+z_2^{120}$**

$$w=z_1^{120}+z_2^{120}$$

$$=\left[\cos\left(-\frac{\pi}{6}\right)+i\sin\left(-\frac{\pi}{6}\right)\right]^{120}+\left[\cos\frac{\pi}{6}+i\sin\frac{\pi}{6}\right]^{120}$$

$$=\cos(-20\pi)+i\sin(-20\pi)+\cos(20\pi)+i\sin(20\pi)$$

$$=\cos 0+i\sin 0+\cos 0+i\sin 0$$

$$=1+i\cdot 0+1+i\cdot 0=2$$

ដូចនេះ គណនាបាន $\boxed{w=2}$ ។

**4. រកប្រូបាបដែលជ្រើសរើសបានយ៉ាងតិចនិស្សិតស្រី 3 នាក់ :**

គេមាន និស្សិត 10 នាក់ ប្រុស 6 នាក់ និងស្រី 4 នាក់

គេជ្រើសរើសបុគ្គលិក 5 នាក់

នាំឱ្យ ចំនួនករណីអាច $n(S)=C(10\,,5)$ ដែល

$$C(10\,,5)=\frac{10!}{5!\cdot 5!}=\frac{10\cdot 9\cdot 8\cdot 7\cdot 6\cdot 5!}{5!\cdot 5\cdot 4\cdot 3\cdot 2}=252$$

ហើយ ជ្រើសរើសបានយ៉ាងតិចនិស្សិតស្រី 3 នាក់មានន័យថា

អាចជ្រើសរើសបាននិស្សិតស្រី 3 នាក់ ឬ 4 នាក់ គេបាន៖

$$n(A)=C(4\,,3)C(6\,,2)+C(4\,,4)C(6\,,1)$$

$$=4\times\frac{6!}{4!\cdot 2!}+1\times 6=4\times\frac{6\cdot 5\cdot 4!}{4!\cdot 2}+6$$

$$=4\times 15+6=60+6=66$$

នាំឱ្យ $$P(A)=\frac{n(A)}{n(S)}=\frac{66}{252}=\frac{11}{42}$$

ដូចនេះ ប្រូបាប $\boxed{P(A)=\frac{11}{42}}$ ។

**5. ក. សិក្សាអថេរភាព និងគូសខ្សែកោងនៃអនុគមន៍ $f(x)$**

គេមាន អនុគមន៍ $f(x):y=\frac{x^2+5x+15}{(x+3)}$

• ដែនកំណត់ : អនុគមន៍ $f$ មានន័យលុះត្រាតែ $x\neq -3$

ដូចនេះ $\boxed{D=\mathbb{R}-\{-3\}=(-\infty,-3)\cup(-3,+\infty)}$ ។

• ទិសដៅអថេរភាព :

គេមាន $$f'(x)=\left[\frac{x^2+5x+15}{(x+3)}\right]'$$

$$=\frac{\left(x^2+5x+15\right)'(x+3)-(x+3)'\left(x^2+5x+15\right)}{(x+3)^2}$$

$$=\frac{(2x+5)(x+3)-\left(x^2+5x+15\right)}{(x+3)^2}$$

$$=\frac{2x^2+6x+5x+15-x^2-5x-15}{(x+3)^2}$$

$$=\frac{x^2+6x}{(x+3)^2}=\frac{x(x+6)}{(x+3)^2}$$

ដូចនេះ គណនាបាន $\boxed{f'(x)=\frac{x(x+6)}{(x+3)^2}}$ ។

គេឱ្យ $f'(x)=0 \Leftrightarrow \frac{x(x+6)}{(x+3)^2}=0$ , $(x+3)^2>0$

នាំឱ្យ $x(x+6)=0$ នោះ $x=0$ , $x=-6$

គេបាន $$f(0)=\frac{0^2+5\cdot 0+15}{(0+3)}=5$$

$$f(-6)=\frac{(-6)^2+5(-6)+15}{(-6+3)}=-7$$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ $-6$ $-3$ $0$ $+\infty$ |
|---|---|
| $f'(x)$ | $+$ 0 $-$ ‖ $-$ 0 $+$ |

• ត្រង់ $x=-6$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$

បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើនឹង $f(-6)=-7$ ។

• ត្រង់ $x=0$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើនឹង $f(0)=5$ ។

• លីមីត និងអាស៊ីមតូត

$$\lim_{x\to+\infty}f(x)=\lim_{x\to+\infty}\frac{x^2+5x+15}{(x+3)}=\lim_{x\to+\infty}\frac{x^2}{x}=+\infty$$

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\frac{x^2+5x+15}{(x+3)}=\lim_{x\to-\infty}\frac{x^2}{x}=-\infty$$

$$\lim_{x\to-3^-} f(x)=\lim_{x\to-3^-}\frac{x^2+5x+15}{(x+3)}=\frac{9-15+15}{-3+0^-+3}=-\infty$$

$$\lim_{x\to-3^+} f(x)=\lim_{x\to-3^+}\frac{x^2+5x+15}{(x+3)}=\frac{9-15+15}{-3+0^++3}=+\infty$$

ដោយ $\lim_{x\to-3} f(x)=\pm\infty$ នោះបន្ទាត់ដែលមានសមីការ

$x=-3$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ។

ម្យ៉ាងទៀត $f(x)=\frac{x^2+5x+15}{(x+3)}=x+2+\frac{9}{x+3}$

ដោយ $\lim_{x\to\pm\infty}\frac{9}{x+3}=0$ នោះបន្ទាត់ដែលមានសមីការ

$y=x+2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

• តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-\infty$ | | $-6$ | | $-3$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | | $-$ | ‖ | $-$ | | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-7$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $5$ | ↗ | $+\infty$ |

➤សង់ខ្សែកោង $(C)$ តាងអនុគមន៍




• ផ្ចិតឆ្លុះនៃក្រាប $(C)$ តាងអនុគមន៍ $f$

ដោយ អាស៊ីមតូតឈរ $x=-3$ និងទ្រេត $y=x+2$ ប្រសព្វគ្នាត្រង់ចំណុច $I(-3,-1)$ ដែលជាផ្ចិតឆ្លុះ នៃក្រាប $(C)$ ។

**ខ. រកគ្រប់ចំណុចនៅលើខ្សែកោងនៃអនុគមន៍ $f(x)$ ដែលមានកូអរដោនេជាចំនួនគត់រ៉ឺឡាទីប**

គេមាន $f(x)=y=x+2+\frac{9}{x+3}$

ដើម្បីឱ្យ $y$ ជាចំនួនគត់រ៉ឺឡាទីប លុះត្រាតែ $\frac{9}{x+3}$ ជាចំនួនគត់រ៉ឺឡាទីប មានន័យថា 9 ចែកដាច់នឹង $x+3$ នោះគេបាន ៖

$x+3=\{\pm1\,,\pm3\,,\pm9\}$

នាំឱ្យ $x=-4$ នាំឱ្យ $y=-4+2+\frac{9}{-4+3}=-11$

$x=-2$ នាំឱ្យ $y=-2+2+\frac{9}{-2+3}=9$

$x=-6$ នាំឱ្យ $y=-6+2+\frac{9}{-6+3}=-7$

$x=0$ នាំឱ្យ $y=0+2+\frac{9}{0+3}=5$

$x=-12$ នាំឱ្យ $y=-12+2+\frac{9}{-12+3}=-11$

$x=6$ នាំឱ្យ $y=6+2+\frac{9}{6+3}=9$

ដូចនេះ៖ ចំណុចដែលមានកូអរដោនេជាចំនួនគត់រ៉ឺឡាទីបមាន៖

$(-4\,,-11)\,,(-2\,,9)\,,(-6\,,-7)$
$(0\,,5)\,,(-12\,,-11)\,,(6\,,9)$ ។

**គ. រកគ្រប់ចំណុច $M$ នៅលើខ្សែកោងនៃអនុគមន៍ $f(x)$**

គេតាង $M(x_M\,,y_M)$ ជាចំណុចនៅលើខ្សែកោង

គេបាន $y_M=\frac{x_M^2+5x_M+15}{(x_M+3)}$ ដែល $x_M\neq-3$

$y_M(x_M+3)=x_M^2+5x_M+15$

ដោយ ចម្ងាយពីចំណុច $M$ ទៅអ័ក្សអាប់ស៊ីសស្មើ 2 ដងនៃចម្ងាយពី $M$ ទៅអ័ក្សអរដោនេ នាំឱ្យ $y_M=2x_M$

នាំឱ្យ $2x_M(x_M+3)=x_M^2+5x_M+15$

$2x_M^2+6x_M=x_M^2+5x_M+15$

$x_M^2+x_M-15=0$

មាន $\Delta=1-4(-15)=61$

នោះ៖ $x_M=\frac{-1-\sqrt{61}}{2}$ , $x_M=\frac{-1+\sqrt{61}}{2}$

ចំពោះ៖ $x_M=\frac{-1-\sqrt{61}}{2}$ នាំឱ្យ $y_M=-1-\sqrt{61}$

ចំពោះ៖ $x_M=\frac{-1+\sqrt{61}}{2}$ នាំឱ្យ $y_M=-1+\sqrt{61}$

ដូចនេះ $\boxed{M\left(\frac{-1-\sqrt{61}}{2}\ ,\ -1-\sqrt{61}\right)}$ ឬ

$\boxed{M\left(\frac{-1+\sqrt{61}}{2}\ ,\ -1+\sqrt{61}\right)}$ ។

**ឃ. សរសេរសមីការនៃបន្ទាត់ប៉ះ $(d)$**

សមីការបន្ទាត់ប៉ះរាង $(\mathrm{d}): y=f'(x_0)(x-x_0)+f(x_0)$

ដោយ បន្ទាត់ $(\mathrm{d})$ ប៉ះខ្សែកោងត្រង់ចំណុច $A(-2\ ,\ 9)$

នោះ $x_0=-2\ ,\ y_0=f(x_0)=9$

គេបាន $f'(x_0)=f'(-2)=\frac{-2(-2+6)}{(-2+3)^2}=-8$

នាំឱ្យ $(\mathrm{d}): y=-8(x+2)+9$ ឬ $y=-8x-7$

ដូចនេះ សរសេរបាន $\boxed{(\mathrm{d}): y=-8x-7}$ ។

**ផ្នែកធរណីមាត្រ**

**ក. រកចំណុច $H$**

គេតាង $H(x_H\ ,\ y_H\ ,\ z_H)$ ជាចំណុចដែលត្រូវរក

គេមាន ចំណុច $A(2\ ,1\ ,3)$

និងប្លង់ $(P): 2x+y+3z-28=0$ ដែលមាន

វ៉ិចទ័រណរម៉ាល់ $\vec{n}=(2\ ,1\ ,3)$

ហើយ $\overrightarrow{AH}=(x_H-2\ ,\ y_H-1\ ,\ z_H-3)$

ដោយ $H$ ជាចំណោលកែងនៃ $A$ លើប្លង់ $(P)$ មានន័យថា

$\overrightarrow{AH}\perp(P)$ នាំឱ្យ $\overrightarrow{AH}\parallel\vec{n}$ គេបាន ៖

$\frac{x_H-2}{2}=\frac{y_H-1}{1}=\frac{z_H-3}{3}$

ទាញបាន $\begin{cases}\frac{x_H-2}{2}=\frac{y_H-1}{1} \Rightarrow y_H=\frac{x_H}{2}\\ \frac{x_H-2}{2}=\frac{z_H-3}{3} \Rightarrow z_H=\frac{3x_H}{2}\end{cases}$

ម្យ៉ាងទៀត $H\in(P)$ នោះ $2x_H+y_H+3z_H-28=0$

គេបាន $2x_H+\frac{x_H}{2}+3\cdot\frac{3x_H}{2}-28=0$

$4x_H+x_H+9x_H-56=0$ នោះ $x_H=4$

នាំឱ្យ $\begin{cases}y_H=\frac{x_H}{2}=\frac{4}{2}=2\\ z_H=\frac{3x_H}{2}=\frac{3\cdot4}{2}=6\end{cases}$

ដូចនេះ រកបានចំណុច $\boxed{H(4\ ,2,\ 6)}$ ។

➢**រកចំណុច $A'$**

ដោយ $H(4\ ,2\ ,6)$ ជាចំណុចកណ្តាលនៃអង្កត់ $AA'$

គេបាន $\left(\frac{x_A+x_{A'}}{2}\ ,\ \frac{y_A+y_{A'}}{2}\ ,\ \frac{z_A+z_{A'}}{2}\right)=(4\ ,2\ ,6)$

$\left(\frac{2+x_{A'}}{2}\ ,\ \frac{1+y_{A'}}{2}\ ,\ \frac{3+z_{A'}}{2}\right)=(4\ ,2\ ,6)$

នាំឱ្យ $\begin{cases}2+x_{A'}=8\\1+y_{A'}=4\\3+z_{A'}=12\end{cases}\Rightarrow\begin{cases}x_{A'}=6\\y_{A'}=3\\z_{A'}=9\end{cases}$

ដូចនេះ រកបានចំណុច $\boxed{A'(6\ ,3,\ 9)}$ ។

**ខ. គណនាចម្ងាយពីចំណុច $A$ មកលើប្លង់ $(P)$**

ដោយ $d(A\ ,(P))=AH$

ដែល $\left|\overrightarrow{AH}\right|=\sqrt{(x_H-2)^2+(y_H-1)^2+(z_H-3)^2}$

$=\sqrt{(4-2)^2+(2-1)^2+(6-3)^2}$

$=\sqrt{2^2+1^2+3^2}=\sqrt{14}$

ដូចនេះ $\boxed{d(A\ ,(P))=AH=\left|\overrightarrow{AH}\right|=\sqrt{14}}$ ឯកតាប្រវែង

➢**សរសេរសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ $(\Delta)$**

សមីការបន្ទាត់ត្រូវរកមានរាង $(\Delta):\begin{cases}x=x_0+at\\y=y_0+bt\ ,\ t\in\mathbb{R}\\z=z_0+ct\end{cases}$

ដោយ បន្ទាត់ $(\Delta)$ កាត់តាមចំណុច $M(3\ ,2\ ,5)$ និង

កែងនឹងប្លង់ $(P)$ នោះ $(\Delta)$ មានវ៉ិចទ័រប្រាប់ទិស

$\vec{u}=\vec{n}=(2\ ,1\ ,3)$

ដូចនេះ $\boxed{(\Delta):\begin{cases}x=3+2t\\y=2+t\quad ,\ t\in\mathbb{R}\\z=5+3t\end{cases}}$ ។

**គ. សរសេរសមីការទូទៅនៃប្លង់ $(H)$**

ប្លង់រាង $(H): a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយ ប្លង់ $(H)$ កាត់តាមចំណុច $I(3\ ,-1\ ,5)$ និង

កែងនឹងបន្ទាត់ $(AM)$ នោះប្លង់ $(H)$ មានវ៉ិចទ័រ

ណរម៉ាល់ $\overrightarrow{AM}=(1\ ,1\ ,2)$

គេបាន $(H):(x-3)+(y+1)+2(z-5)=0$

$(H): x+y+2z-12=0$

ដូចនេះ $\boxed{(H): x+y+2z-12=0}$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ..................................
លេខបន្ទប់ : ..................................
លេខតុ : ..................................
ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ**
**សម័យប្រឡង** : ..........................**២០១៥**

**វិញ្ញាសា** : **គណិតវិទ្យា** **រយៈពេល** : **១២០ នាទី** **ពិន្ទុ** : **២០**

**I.** ... (ក្នុងឆ្នាំ 2015 គ្មានការប្រឡងជ្រើសរើសគ្រូកម្រិតមូលដ្ឋានផ្នែកគណិតវិទ្យាទេ ជ្រើសរើសតែគ្រូកីឡា និងគ្រូបឋម-មតេយ្យ ព្រោះដោយសារតែគេឱ្យនិទ្ទេស $A$ , $B$ , $C$ ជាប់គ្រូដោយស្វ័យប្រវត្តិ ... ) ។

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
# ប្រឡងជ្រើសរើសមធ្យម ឆ្នាំ ២០១៥

**I.** (គ្មានចម្លើយ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ

**សម័យប្រឡង : ២០ វិច្ឆិកា ២០១៤**

**វិញ្ញាសា : គណិតវិទ្យា  រយៈពេល : ១២០ នាទី  ពិន្ទុ : ២០**

**I.** គណនាអាំងតេក្រាលខាងក្រោម ៖

ក. $A=\int_1^2 \frac{\left(\sqrt{x}-1\right)^2}{x}dx$  ខ. $B=\int_{\frac{\pi}{6}}^{\frac{\pi}{2}} \frac{1+\sin 2x+\cos 2x}{\sin x+\cos x}dx$  គ. $C=\int_0^{\frac{\pi}{2}}\left(\cos^3 x+\sin^3 x\right)dx$ ។ (3 **ពិន្ទុ**)

**II.** គេមានអនុគមន៍ពីរ $f(x)$ និង $g(x)$ ដែល $f(x)=x-\frac{x^2}{2}-\ln(1+x)$ និង $g(x)=x-\ln(1+x)$ ។

ក. គណនាដេរីវេ $f(x)$ និង $g(x)$ រួចស្រាយបំភ្លឺថា គ្រប់តម្លៃ $x>0$ គេបាន $x-\frac{x^2}{2}<\ln(1+x)<x$ ។ (2 **ពិន្ទុ**)

ខ. គេមាន $u_n=\ln\left(1+\frac{1}{n^2}\right)\left(1+\frac{2}{n^2}\right)...\left(1+\frac{n}{n^2}\right)$ ។ ចូរគណនា $\lim_{n\to\infty} u_n$ ។ (1 **ពិន្ទុ**)

**III.** គេមានចំនួនកុំផ្លិចពីរ $z$ និង $w$ ដែល $z=2\sqrt{2}+4\frac{\sqrt{2}}{2}i$ និង $w=x(x-i)+y(y+i)$ , $x,y\in\mathbb{R}$ ។

ក. សរសេរ $z$ ជាទម្រង់ត្រីកោណមាត្រ ។ (1 **ពិន្ទុ**)

ខ. សរសេរ $z^4$ ជាទម្រង់ $a+bi$ ។ (1 **ពិន្ទុ**)

គ. រកតម្លៃ $x$ និង $y$ បើ $w=-z^4$ ។ (1 **ពិន្ទុ**)

**IV.** គេមានអនុគមន៍ $y_1=-\frac{1}{4}x^4+2x^2+\frac{9}{4}$ ។

ក. រកតម្លៃ $a$ ដើម្បីឱ្យប៉ារ៉ាបូល $y_2=-x^2+a$ ប៉ះខ្សែកោងអនុគមន៍ $y_1$ ។ (1 **ពិន្ទុ**)

ខ. ចូរសរសេរសមីការនៃប៉ារ៉ាបូល ទៅតាមតម្លៃ $a$ ដែលបានរកឃើញក្នុងសំណួរ ក. ។ រួចបញ្ជាក់កូអរដោនេនៃចំណុចប៉ះរបស់វាជាមួយខ្សែកោង $y_1$ ។ (2 **ពិន្ទុ**)

**V.** នៅក្នុងតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ ដែលមានទិសដៅវិជ្ជមាន គេដៅ 4 ចំណុច

$A(2,1,3)$ , $B(3,6,1)$ , $C(2,0,2)$ , $D(1,-5,4)$ ។

ក. ប្រាប់ប្រភេទចតុកោណ $ABCD$ និងគណនា $S_{ABCD}$ ។ (4 **ពិន្ទុ**)

ខ. សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(D)$ កាត់តាមចំណុច $A$ និងស្របនឹង $\overrightarrow{BC}$ ។ (2 **ពិន្ទុ**)

គ. សរសេរសមីការនៃប្លង់ $(P)$ កាត់តាមចំណុច $A$ , $B$ និង $D$ ។ (2 **ពិន្ទុ**)

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ២០១៤

**I.** **គណនាអាំងតេក្រាលខាងក្រោម :**

**ក.** $\mathbf{A}=\int_1^2 \frac{\left(\sqrt{x}-1\right)^2}{x}dx=\int_1^2 \frac{x-2\sqrt{x}+1}{x}dx$

$=\int_1^2\left(1-\frac{2}{\sqrt{x}}+\frac{1}{x}\right)dx=\left[x-4\sqrt{x}+\ln|x|\right]_1^2$

$=\left(2-4\sqrt{2}+\ln 2\right)-\left(1-4+0\right)$

$=\boxed{5-4\sqrt{2}+\ln 2}$

**ខ.** $\mathbf{B}=\int_{\frac{\pi}{6}}^{\frac{\pi}{2}}\frac{1+\sin 2x+\cos 2x}{\sin x+\cos x}dx$

$=\int_{\frac{\pi}{6}}^{\frac{\pi}{2}}\frac{2\cos^2 x+2\sin x\cos x}{\sin x+\cos x}dx$

$=\int_{\frac{\pi}{6}}^{\frac{\pi}{2}}\frac{2\cos x\left(\cos x+2\sin x\right)}{\sin x+\cos x}dx$

$=\int_{\frac{\pi}{6}}^{\frac{\pi}{2}}2\cos x dx=2\left[\sin x\right]_{\frac{\pi}{6}}^{\frac{\pi}{2}}$

$=2\left(\sin\frac{\pi}{2}-\sin\frac{\pi}{6}\right)=2\left(1-\frac{1}{2}\right)=\boxed{1}$

**គ.** $\mathbf{C}=\int_0^{\frac{\pi}{2}}\left(\cos^3 x+\sin^3 x\right)dx$

$=\int_0^{\frac{\pi}{2}}\left(\cos x+\sin x\right)\left(\cos^2 x+\cos x\sin x+\sin^2 x\right)dx$

$=\int_0^{\frac{\pi}{2}}\left(\cos x+\sin x\right)\left(1+\cos x\sin x\right)dx$

$=\int_0^{\frac{\pi}{2}}\left(\cos x+\cos^2 x\sin x+\sin x+\cos x\sin^2 x\right)dx$

$=\left[\sin x-\frac{\cos^3 x}{3}-\cos x+\frac{\sin^3 x}{3}\right]_0^{\frac{\pi}{2}}$

$=\left(1-0-0+\frac{1}{3}\right)-\left(0-\frac{1}{3}-1+0\right)=\boxed{\frac{8}{3}}$

**II.** **ក. គណនាដេរីវេ** $f(x)$ **និង** $g(x)$ :

គេមាន $f(x)=x-\frac{x^2}{2}-\ln(1+x)$

ដូចនេះ $\boxed{f'(x)=1-x-\frac{1}{1+x}}$ ។

ហើយ $g(x)=x-\ln(1+x)$

ដូចនេះ $\boxed{g'(x)=1-\frac{1}{1+x}}$ ។

ស្រាយថា គ្រប់តម្លៃ $x>0$ គេបាន $x-\frac{x^2}{2}<\ln(1+x)<x$

ដោយ $f'(x)=1-x-\frac{1}{1+x}$

$=\frac{1-x^2-1}{1+x}=-\frac{x^2}{1+x}<0\ ,\ \forall x>0$

នាំឱ្យ $\forall x>0$, $f$ ជាអនុគមន៍ចុះ នាំឱ្យ $f(x)<0$

គេបាន $x-\frac{x^2}{2}-\ln(1+x)<0$

$x-\frac{x^2}{2}<\ln(1+x)\quad(1)$

ដោយ $g'(x)=1-\frac{1}{1+x}$

$=\frac{1+x-1}{1+x}=\frac{x}{1+x}>0\ ,\ \forall x>0$

នាំឱ្យ $\forall x>0$, $g$ ជាអនុគមន៍កើន នាំឱ្យ $g(x)>0$

គេបាន $x-\ln(1+x)>0$

$\ln(1+x)<x\quad(2)$

តាម $(1)$ និង $(2)$ គេបាន $x-\frac{x^2}{2}<\ln(1+x)<x$

ដូចនេះ: $\boxed{x-\frac{x^2}{2}<\ln(1+x)<x}$ ត្រូវបានបង្ហាញ ។

**ខ. គណនា** $\lim_{n\to\infty}u_n$

គេមាន $u_n=\ln\left(1+\frac{1}{n^2}\right)\left(1+\frac{2}{n^2}\right)\ldots\left(1+\frac{n}{n^2}\right)$

នោះ: $u_n=\ln\left(1+\frac{1}{n^2}\right)+\ln\left(1+\frac{2}{n^2}\right)+\ldots+\ln\left(1+\frac{n}{n^2}\right)$

$$+\begin{cases}\lim_{x\to\infty}\ln\left(1+\frac{1}{n^2}\right)=\ln(1+0)=0\\ \lim_{x\to\infty}\ln\left(1+\frac{2}{n^2}\right)=\ln(1+0)=0\\ \ldots\ldots\ldots\ldots\ldots\ldots\ldots\ldots\ldots\ldots\\ \lim_{x\to\infty}\ln\left(1+\frac{n}{n^2}\right)=\ln(1+0)=0\end{cases}$$

$\lim_{x\to\infty}u_n=0$

ដូចនេះ: គណនាបាន $\boxed{\lim_{x\to\infty}u_n=0}$ ។

**III.** ក. សរសេរ $z$ ជាទម្រង់ត្រីកោណមាត្រ :

គេមាន $z=2\sqrt{2}+4\dfrac{\sqrt{2}}{2}i$ ឬ $z=2\sqrt{2}+2\sqrt{2}i$

មាន $r=\sqrt{\left(2\sqrt{2}\right)^2+\left(2\sqrt{2}\right)^2}=4$

គេបាន $z=4\left(\dfrac{\sqrt{2}}{2}+\dfrac{\sqrt{2}}{2}i\right)=4\left(\cos\dfrac{\pi}{4}+i\sin\dfrac{\pi}{4}\right)$

ដូចនេះ $\boxed{z=4\left(\cos\dfrac{\pi}{4}+i\sin\dfrac{\pi}{4}\right)}$ ។

ខ. សរសេរ $z^4$ ជាទម្រង់ $a+bi$

គេមាន $z=4\left(\cos\dfrac{\pi}{4}+i\sin\dfrac{\pi}{4}\right)$

$$z^4=\left[4\left(\cos\frac{\pi}{2}+i\sin\frac{\pi}{2}\right)\right]^4$$

$$=4^4\left(\cos\pi+i\sin\pi\right)$$

$$=256\left(-1+0i\right)=-256+0i$$

ដូចនេះ $\boxed{z^4=-256+0i}$ ។

គ. រកតម្លៃ $x$ និង $y$ បើ $w=-z^4$

គេមាន $w=x(x-i)+y(y+i)$ , $x,y\in\mathbb{R}$

$$=x^2-xi+y^2+yi$$

$$=\left(x^2+y^2\right)+\left(-x+y\right)i$$

ដោយ $w=-z^4$ ដែល $-z^4=256+0i$ គេផ្ទឹមបាន ៖

$$\begin{cases}x^2+y^2=256\\-x+y=0\end{cases}\Leftrightarrow\begin{cases}x^2+y^2=256 & (1)\\x=y & (2)\end{cases}$$

គេយក $(2)$ ជំនួសក្នុង $(1)$

គេបាន $2x^2=256\Leftrightarrow x^2=128\Rightarrow x=\pm8\sqrt{2}$

ដូចនេះ កំណត់បាន $\boxed{x=y=8\sqrt{2}\ ,\ x=y=-8\sqrt{2}}$ ។

**IV.** ក. រកតម្លៃ $a$ :

គេមាន អនុគមន៍ $y_1=-\dfrac{1}{4}x^4+2x^2+\dfrac{9}{4}$

ប៉ារ៉ាបូល $y_2=-x^2+a$

គេបាន សមីការអាប់ស៊ីសរវាង $y_1$ និង $y_2$

$$-\frac{1}{4}x^4+2x^2+\frac{9}{4}=-x^2+a$$

$$-x^4+8x^2+9=-4x^2+4a$$

$$x^4-12x^2+4a-9=0$$

តាង $t=x^2$ ដែល $t\geq0$

គេបាន $t^2-12t+4a-9=0$

ដើម្បីឱ្យ $y_2$ ប៉ះជាមួយខ្សែកោង $y_1$ លុះត្រាសមីការមានឫសឌុប

នាំឱ្យ $\Delta'=0\Leftrightarrow(-6)^2-(4a-9)=0$

គេបាន $36-4a+9=0\Rightarrow a=\dfrac{45}{4}$

ដូចនេះ តម្លៃរកបាន $\boxed{a=\dfrac{45}{4}}$ ។

ខ. សរសេរសមីការនៃប៉ារ៉ាបូល

ចំពោះ $a=\dfrac{45}{4}$ គេបាន សមីការប៉ារ៉ាបូល $y_2=-x^2+\dfrac{45}{4}$

ដូចនេះ សមីការប៉ារ៉ាបូលសរសេរបានគឺ $\boxed{y_2=-x^2+\dfrac{9}{4}}$ ។

➤បញ្ជាក់កូអរដោនេនៃចំណុចប៉ះ:

ចំពោះ $a=\dfrac{45}{4}$ នោះគេបាន $t^2-12t+45-9=0$

$t^2-12t+36=0$ មានឫសឌុប $t_1=t_2=t=6$

ចំពោះ $t=6$ សមមូល $x^2=6\Rightarrow x=\pm\sqrt{6}$

ករណី $x=\pm\sqrt{6}$ គេបាន $y=-\left(\pm\sqrt{6}\right)^2+\dfrac{45}{4}$

$y=-6+\dfrac{45}{4}$ នាំឱ្យ $y=\dfrac{21}{4}$

ដូចនេះ ចំណុចប៉ះមានពីរគឺ $\boxed{\left(-\sqrt{6},\dfrac{21}{4}\right),\left(\sqrt{6},\dfrac{21}{4}\right)}$ ។

**V.** ក. ប្រាប់ប្រភេទចតុកោណ $ABCD$ :

គេមាន $A(2,1,3)$ , $B(3,6,1)$ ,

$C(2,0,2)$ , $D(1,-5,4)$

គេបាន $\overrightarrow{AB}=(1,5,-2)$ និង $\overrightarrow{DC}=(1,5,-2)$

ដោយ ចតុកោណ $ABCD$ មាន $\overrightarrow{AB}=\overrightarrow{DC}=(1,5,-2)$

ដូចនេះ: $\boxed{\text{ចតុកោណ } ABCD \text{ ជាប្រលេឡូក្រាម}}$ ។

➤គណនា $S_{ABCD}$

តាមរូបមន្ត $S=\left|\overrightarrow{AB}\times\overrightarrow{AD}\right|$ ដែល $\overrightarrow{AD}=(-1,-6,1)$

ដោយ $\overrightarrow{AB}\times\overrightarrow{AD}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\1&5&-2\\-1&-6&1\end{vmatrix}=-7\vec{i}+\vec{j}-\vec{k}$

នាំឱ្យ $\left|\overrightarrow{AB}\times\overrightarrow{AD}\right|=\sqrt{(-7)^2+(1)^2+(-1)^2}=\sqrt{51}$

ដូចនេះ: $\boxed{\text{គណនាបាន } S=\sqrt{51} \text{ ឯកតាផ្ទៃក្រឡា}}$ ។

**ខ. សរសេរសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ $(D)$**

សមីការប៉ារ៉ាម៉ែតរាង $(D):\begin{cases} x = x_0 + at \\ y = y_0 + bt \ , t \in \mathbb{R} \\ z = z_0 + ct \end{cases}$

ដោយ $(D)$ កាត់ $A(2 , 1 , 3)$

នោះ $x_0 = 2$ , $y_0 = 1$ , $z_0 = 3$

ហើយ $(D)$ មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{BC} = (-1 , -6 , 1)$

នោះ $a = -1$ , $b = -6$ , $c = 1$

គេបាន $(D):\begin{cases} x = 2 - t \\ y = 1 - 6t \ , t \in \mathbb{R} \\ z = 3 + t \end{cases}$

ដូចនេះ សមីការប៉ារ៉ាមែត $\boxed{(D):\begin{cases} x = 2 - t \\ y = 1 - 6t \ , t \in \mathbb{R} \\ z = 3 + t \end{cases}}$ ។

**គ. សរសេរសមីការប្លង់ $(P)$ កាត់តាមចំណុច $A$ , $B$ និង $D$**

សមីកាប្លង់ $(P): a(x - x_0) + b(y - y_0) + c(z - z_0) = 0$

ដោយ $(P)$ កាត់ $A(2 , 1 , 3)$

នោះ $x_0 = 2$ , $y_0 = 1$ , $z_0 = 3$

ហើយ $(P)$ កាត់បីចំណុច $A, B, D$ នាំឱ្យ $(P)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n} = \overrightarrow{AB} \times \overrightarrow{AD} = (-7 , 1 , -1)$ នោះ

$a = -7$ , $b = 1$ , $c = -1$

គេបាន $(P): -7(x - 2) + (y - 1) - (z - 3) = 0$

$$-7x + y - z + 17 = 0$$

ដូចនេះ សមីការប្លង់គឺ $\boxed{(P): -7x + y - z + 17 = 0}$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ...............................

លេខបន្ទប់ : ...............................

លេខតុ : ...............................

ហត្ថលេខា : ...............................

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ

**សម័យប្រឡង : ១៩ តុលា ២០១៣**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ២០**

## I. ផ្នែកពីជគណិត

១. សហគ្រាសដំឡើងទោចក្រយានយន្តមួយបានចំណាយទឹកប្រាក់សរុបក្នុងមួយថ្ងៃសម្រាប់ដំឡើងទោចក្រយានយន្ត $x$ គ្រឿង ចំនួន $f(x)=6x^2+22x+100$ គិតជាម៉ឺនរៀល ហើយសហគ្រាសនេះ បានទទួលប្រាក់ចំណូលមកវិញ ចំនួន $I(x)=5x^2+112x+200$ គិតជាម៉ឺនរៀល ។

ក. សរសេរអនុគមន៍ប្រាក់ចំណេញ $P(x)$ ។ **(១ពិន្ទុ)**

ខ .ចូរប៉ាន់ស្មានតម្លៃប្រហែលនៃកំណើនប្រាក់ចំណេញ បើបរិមាត្រទោចក្រយានយន្តដែលបានលក់ កើនពី 30 គ្រឿង ទៅ 50 គ្រឿង ។ **(១ពិន្ទុ)**

២. ចូរគណនាតម្លៃប្រហែលនៃផ្ទៃក្រឡាដែលខ័ណ្ឌដោយក្រាប $(C)$ នៃអនុគមន៍ $f(x):\ x=2-y-y^2$ និងអ័ក្សអរដោនេ $(y'y)$ ។ **(២ពិន្ទុ)**

៣. ដោះស្រាយសមីការ $y'=-y\sin x$ ដោយដឹងថា $y(2\pi)=3e$ ។ **(២ពិន្ទុ)**

៤. គេឱ្យអនុគមន៍ $f(x)=x^3-3x+2$ ។

ក. សិក្សាអថេរភាព និងសង់ក្រាប $(C)$ នៃអនុគមន៍ $f(x)$ ។ **(២ពិន្ទុ)**

ខ. ដោះស្រាយ និងពិភាក្សាតាមតម្លៃ $m$ អត្ថិភាពនៃឫសរបស់សមីការ $x^3-3x+2-m=0$ ។ **(៤ពិន្ទុ)**

## II. ផ្នែកធរណីមាត្រ

គេឱ្យពីរ៉ាមីត $SABCD$ មានបាត $ABCD$ ជាចតុកោណកែង ដែលមានបណ្តោយ $AB=a$ ទទឹង $AD=b$ ទ្រនុង $(SA)\perp$ ប្លង់ $(ABCD)$ និងប្រវែង $SA=2a$ ។ $M$ ជាចំណុចមួយ នៅលើទ្រនុង $(SA)$ ដែល $AM=x$ ដោយ $0\le x\le 2a$ ។ ប្លង់ $(MBC)$ កាត់ទ្រនុង $(SD)$ នៃពីរ៉ាមីត $SABCD$ ត្រង់ $N$ ។

ក. កំណត់រាងរបស់ចតុកោណ $BCNM$ ។ **(២ពិន្ទុ)**

ខ. កំណត់តម្លៃ $x$ ដើម្បីឱ្យចតុកោណ $BCNM$ មានផ្ទៃក្រឡាធំបំផុត និងតូចបំផុត ។ **(៦ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
# ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ២០១៣

**I. ចម្លើយផ្នែកពីជគណិត :**

**១. ក. សរសេរអនុគមន៍ប្រាក់ចំណេញ $P(x)$**

គេមាន អនុគមន៍ប្រាក់ចំណាយ $f(x)=6x^2+22x+100$

អនុគមន៍ប្រាក់ចំណូល $I(x)=5x^2+112x+200$

(គិតជាម៉ឺនរៀល , $x$ ជាចំនួនទោចក្រយានយន្ត)

នាំឱ្យ អនុគមន៍ប្រាក់ចំណេញគឺ $P(x)$ ដែល

$$P(x)=I(x)-f(x)$$
$$=\left(5x^2+112x+200\right)-\left(6x^2+22x+100\right)$$
$$=-x^2+90x+100$$

ដូចនេះ អនុគមន៍ប្រាក់ចំណេញ $\boxed{P(x)=-x^2+90x+100}$

**ខ .ចូរប៉ាន់ស្មានតម្លៃប្រហែលនៃកំណើនប្រាក់ចំណេញ**

ប្រាក់ចំណេញបានពីការលក់ទោចក្រយានយន្តកើនពី 30 គ្រឿង ទៅ 50 គ្រឿង គឺ $\int_{30}^{50}P(x)\,dx$

$$=\int_{30}^{50}\left(-x^2+90x+100\right)dx$$
$$=\left[-\frac{x^3}{3}+45x^2+100x\right]_{30}^{50}$$
$$=\left(-\frac{50^3}{3}+45\cdot 50^2+100\cdot 50\right)-\left(-\frac{30^3}{3}+45\cdot 30^2+100\cdot 30\right)$$
$$=\frac{227500}{3}-34500=\frac{124000}{3}$$
$$=41333.333333 \text{ ម៉ឺនរៀល}$$

ដូចនេះ តម្លៃប្រហែលនៃកំណើនប្រាក់ចំណេញគឺ

$\boxed{413333333}$ រៀល ។

**២. គណនាផ្ទៃក្រឡាដែលខ័ណ្ឌដោយក្រាប $(C)$ និងអ័ក្សអរដោនេ**

គេមាន $f(x):\ x=2-y-y^2$

រកចំណុចប្រសព្វរវាងអ័ក្ស $y'y$ និងក្រាប $(C)$ នោះ $x=0$

គេបាន $2-y-y^2=0$ នោះ $y=1$ , $y=-2$

ក្រាប $(C)$ ជាប៉ារ៉ាបូលដែលមានអ័ក្សឆ្លុះស្របអ័ក្សអាប់ស៊ីស

គេសង់រូបបាន ដូចខាងក្រោម ៖




នាំឱ្យ $S=\int_{-2}^{1}\left(2-y-y^2\right)dy$

$$S=\int_{-2}^{1}\left(2-y-y^2\right)dy$$
$$=\left[2y-\frac{y^2}{2}-\frac{y^3}{3}\right]_{-2}^{1}$$
$$=\left(2-\frac{1}{2}-\frac{1}{3}\right)-\left(-4-2+\frac{8}{3}\right)$$
$$=5-\frac{1}{2}=\frac{9}{2}$$

ដូចនេះ $\boxed{\text{ផ្ទៃគណនាបាន } S=\frac{9}{2} \text{ ឯកតាផ្ទៃក្រឡា}}$ ។

**៣. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល**

គេមាន $y'=-y\sin x$

$\frac{y'}{y}=-\sin x$ (បំពាក់អាំងតេក្រាលលើអង្គទាំងពីរ)

$\ln y=\cos x+c$ , $c$ ថេរ

នាំឱ្យ $y=e^{\cos x+c}$

ដោយ $y(2\pi)=3e$

គេបាន $e^{\cos 2\pi+c}=3e$ ដែល $\cos 2\pi=\cos 0=1$

$e^{1+c}=3e \Leftrightarrow e^c=3 \Rightarrow c=\ln 3$

នាំឱ្យ $y=e^{\cos x+\ln 3}=e^{\cos x}\cdot e^{\ln 3}=3e^{\cos x}$

ដូនេះ សមីការមានឫស $\boxed{y=3e^{\cos x}}$ ។

**៤. ក. សិក្សាអថេរភាព និងសង់ក្រាប $(C)$ នៃអនុគមន៍ $f(x)$**

គេមាន $f(x)=x^3-3x+2$ (**ដូចគ្រូបឋម 2016**)

• ដែនកំណត់ : អនុគមន៍ $f$ មានន័យគ្រប់ $x\in\mathbb{R}$

ដូចនេះ ដែនកំណត់ $\boxed{D=\mathbb{R}=(-\infty\ ,+\infty)}$ ។

• ទិសដៅអថេរភាព

គេមាន $f(x)=x^3-3x+2$

ដេរីវេ : $f'(x)=3x^2-3=3(x-1)(x+1)$

គេឱ្យ $f'(x)=0$

$3(x-1)(x+1)=0$ នោះ $x=1\ ,\ x=-1$

គេបាន $f(1)=1^3-3\cdot1+2=0$

$f(-1)=(-1)^3-3(-1)+2=4$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |

• បរមា

-ត្រង់ $x=-1$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$

បញ្ជាក់ថា $f$ មានអតិបរមាធៀបមួយស្មើ $f(-1)=4$ ។

-ត្រង់ $x=1$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានអប្បបរមាធៀបមួយស្មើ $f(1)=0$ ។

• លីមីត $\lim_{x\to-\infty} f(x)=\lim_{x\to-\infty}(x^3-3x+2)=-\infty$

$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}(x^3-3x+2)=+\infty$

• តារាងអថេរភាព

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $4$ | $\searrow$ | $0$ | $\nearrow$ | $+\infty$ |

• ភាពប៉ោងផត និងចំណុចរបត់

ដេរីវេទី២ $f''(x)=(3x^2-3)'=6x$

គេឱ្យ $f''(x)=0 \Leftrightarrow 6x=0$ នោះ $x=0$

- បើ $x>0$ នោះ $f''(x)>0$

នាំឱ្យ ខ្សែកោងបែរភាពផតទៅខាងលើ

- បើ $x<0$ នោះ $f''(x)<0$

នាំឱ្យ ខ្សែកោងបែរភាពផតទៅខាងក្រោម

- បើ $x=0$ , $f''(x)=0$ និងប្តូរសញ្ញា

នាំឱ្យ $f$ មានចំណុចរបត់ $I(0,f(0))=I(0,2)$

• ផ្ចិតឆ្លុះ

គេនឹង បង្ហាញថា ចំណុចរបត់ $I(0\ ,\ 2)$ ជាផ្ចិតឆ្លុះនៃខ្សែកោង

បើ $I(a\ ,\ b)$ ជាផ្ចិតឆ្លុះលុះត្រាតែ $f(2a-x)+f(x)=2b$

គេបាន $f(-x)+f(x)=4$

ដោយ $f(-x)+f(x)$

$=(-x)^3-3(-x)+2+x^3-3x+2$

$=-x^3+3x+2+x^3-3x+2=4$ ពិត

ដូចនេះ $I(0\ ,\ 2)$ ជាផ្ចិតឆ្លុះនៃខ្សែកោងតាងអនុគមន៍ $f$ ។

• សង់ក្រាប

តារាងតម្លៃលេខ

| $x$ | $-2$ | $-1$ | $0$ | $1$ | $2$ |
|---|---|---|---|---|---|
| $y$ | $0$ | $4$ | $2$ | $0$ | $4$ |




ខ. ដោះស្រាយ និងពិភាក្សាតាមតម្លៃ $m$ អត្ថិភាពនៃឫស

គេមាន សមីការ $x^3-3x+2-m=0$

គេបាន $m=x^3-3x+2$

ឫសនៃសមីការនេះបានពីប្រសព្វរវាង បន្ទាត់ដេក $y=m$ និង ក្រាប $C$ ។ តាមក្រាបគេបានអត្ថិភាពនៃឫសដូចខាងក្រោម ៖

•$m\in(-\infty\ ,\ 0)$ : សមីការមានឫសតែមួយគត់ $x_1<0$

•$m=0$ : សមីការមានឫសបី $x_1=-2\ ,\ x_2=x_3=1$

•$m\in(0\ ,\ 4)$ : សមីការមានឫសបីផ្សេងគ្នា

•$m=4$ : សមីការមានឫសបី $x_1=x_2=-1\ ,\ x_3=2$

•$m\in(4\ ,\ +\infty)$ : សមីការមានឫសតែមួយគត់ $0<x_1$ ។

## II. ចម្លើយផ្នែកធរណីមាត្រ :

### ក. កំណត់រាងរបស់ចតុកោណ $BCNM$




គេមាន $(SA)\perp$ ប្លង់ $(ABCD)$ នាំឱ្យ ប្លង់ $(SAB)\perp[BC]$

នោះ $\begin{cases}(SAB)\perp[BC]\\ [MB]\subset(SAB)\end{cases}\Rightarrow [MB]\perp[BC]\ (1)$

គេមាន $\begin{cases}(SAD)\cap(BCNM)=[MN]\\ (BCNM)\perp(SAB)\\ (SAD)\perp(SAB)\end{cases}\Rightarrow[MN]\perp(SAB)$

នាំឱ្យ $[MN]\perp[MB]\ (2)$

តាម $(1)$ និង $(2)$ ចតុកោណ $BCNM$ ជាចតុ.ញាយកែង

ដូចនេះ $\boxed{BCNM \text{ ជាចតុកោណញាយកែង}}$ ។

### ខ. កំណត់តម្លៃ $x$ ដើម្បីឱ្យចតុកោណ $BCNM$ មានផ្ទៃក្រឡាធំបំផុត និងតូចបំផុត

ដោយ $BCNM$ ជាចតុកោណញាយកែង

នាំឱ្យ $S=S_{BCNM}=\frac{1}{2}(MN+BC)\cdot MB$

ដោយ $\Delta SMN$ និង $\Delta SAD$ ជាត្រីកោណកែងដែលមានមុំ $\angle S$ ជាមុំរួម នោះ $\Delta SMN\sim\Delta SAD$ (ម.ម)

វិបាក $\frac{MN}{AD}=\frac{SM}{SA}$ ឬ $\frac{MN}{b}=\frac{2a-x}{2a}$

នោះ $MN=\frac{2ab-xb}{2a}$ ដែល $0\le x\le 2a$

ម្យ៉ាងទៀត តាមទ្រឹស្តីបទពីតាគ័រ $MB=\sqrt{MA^2+AB^2}$

នោះ $MB=\sqrt{x^2+a^2}$

គេបាន $S(x)=\frac{1}{2}\left(\frac{2ab-xb}{2a}+b\right)\cdot\sqrt{x^2+a^2}$

$$S(x)=\frac{1}{2}\left(2b-\frac{b}{2a}x\right)\sqrt{x^2+a^2}$$

$$S(x)=\left(b-\frac{b}{4a}x\right)\sqrt{x^2+a^2}$$

$$S'(x)=\left(-\frac{b}{4a}\right)\sqrt{x^2+a^2}+\frac{2x}{2\sqrt{x^2+a^2}}\left(b-\frac{b}{4a}x\right)$$

$$=\left(-\frac{b}{4a}\right)\sqrt{x^2+a^2}+\frac{x}{\sqrt{x^2+a^2}}\left(\frac{4ba-bx}{4a}\right)$$

$$=\frac{-b\left(x^2+a^2\right)}{4a\sqrt{x^2+a^2}}+\frac{4abx-bx^2}{4a\sqrt{x^2+a^2}}$$

$$=\frac{-2bx^2+4abx-ba^2}{4a\sqrt{x^2+a^2}}$$

$$=\frac{b\left(-2x^2+4ax-a^2\right)}{4a\sqrt{x^2+a^2}}$$

ឱ្យ $S'(x)=0$ តែ $a,b,\ x>0$ , $\frac{b}{4a\sqrt{x^2+a^2}}>0$

នោះ $-2x^2+4ax-a^2=0$ មាន

$$\Delta'=4a^2-2a^2=2a^2$$

$$x=\frac{-2a\pm\sqrt{2a^2}}{-2}=\frac{\left(2\pm\sqrt{2}\right)a}{2}$$

តារាងសញ្ញា $S'(x)$

| $x$ | $0$ | | $\frac{\left(2-\sqrt{2}\right)a}{2}$ | | $\frac{\left(2+\sqrt{2}\right)a}{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $S'(x)$ | | $-$ | $0$ | $+$ | $0$ | $-$ | |

• ត្រង់ $x=\frac{\left(2-\sqrt{2}\right)a}{2}$ , $S'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$ បញ្ជាក់ថា $S$ មានតម្លៃតូចបំផុតមួយ ។

• ត្រង់ $x=\frac{\left(2+\sqrt{2}\right)a}{2}$ , $S'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$ បញ្ជាក់ថា $S$ មានតម្លៃធំបំផុតមួយ ។

ដូចនេះ គេកំណត់តម្លៃនៃ $x$ បានដូចខាងក្រោម ៖

បើ $x=\frac{\left(2-\sqrt{2}\right)a}{2}$ នោះ $S_{BCNM}$ តូចបំផុត

បើ $x=\frac{\left(2+\sqrt{2}\right)a}{2}$ នោះ $S_{BCNM}$ ធំបំផុត ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ

**សម័យប្រឡង : ២៥ តុលា ២០១២**

**វិញ្ញាសា : គណិតវិទ្យា  រយៈពេល : ១២០ នាទី  ពិន្ទុ : ២០**

**I.** (៣ ពិន្ទុ) គេឱ្យចំនួនកុំផ្លិច $z_1=-\frac{1}{2}+i\frac{\sqrt{3}}{2}$ និង $z_2=-\frac{1}{2}-i\frac{\sqrt{3}}{2}$ ។

ក. គណនាកន្សោម $A=1+z_1+z_1^2$ ។

ខ. សរសេរ $z_1$ , $z_2$ ជាទម្រង់ត្រីកោណមាត្រ ។ គណនា $z_1^{2010}+z_2^{2010}$ ។

**II.** (២ ពិន្ទុ) ក. ដោះស្រាយសមីការ $2y''-3y'+y=0 \quad (E)$ ។

ខ. រកចម្លើយមួយនៃ $(E)$ ដោយដឹងថាក្រាបនៃចម្លើយ ប៉ះទៅនឹងបន្ទាត់ដែលមានសមីការ $y=2x+1$ ត្រង់ចំណុច $A(0,1)$ ។

**III.** (៣ ពិន្ទុ) គេឱ្យអនុគមន៍ $f(x)=\frac{5x^2-14x+13}{(x+1)(x-3)^2}$ , $x\neq -1$ , $x\neq 3$ ។

ក. រក $A$ , $B$ និង $C$ ដែល $f(x)=\frac{A}{x+1}+\frac{B}{x-3}+\frac{C}{(x-3)^2}$ ។

ខ. គណនា $I=\int f(x)dx$ ។

**IV.** (៣ ពិន្ទុ) គេបោះគ្រាប់ឡុកឡាក់ 2 គ្រាប់ព្រមគ្នា ដែលគ្រាប់ឡុកឡាក់មួយមានពណ៌ខៀវ និងមួយទៀតពណ៌ក្រហម ។ រកប្រូបាប ៖

ក. លេខចេញលើគ្រាប់ពណ៌ខៀវ ស្មើនឹង 2 ដងនៃលេខចេញលើគ្រាប់ពណ៌ក្រហម ។

ខ. ផលបូកលេខលើគ្រាប់ឡុកឡាក់ទាំងពីរស្មើនឹង 5 ។

**V.** (៤ ពិន្ទុ) ក្នុងតម្រុយ $(O,\vec{i},\vec{j},\vec{k})$ គេមានស្វ៊ែ $(S)$ : $(x-1)^2+(y-2)^2+(z+2)^2=16$ ។

ក. រកកូអរដោនេនៃចំណុចប្រសព្វរវាងស្វ៊ែ $(S)$ ជាមួយ $\overrightarrow{Ox}$ , $\overrightarrow{Oy}$ , $\overrightarrow{Oz}$ ។

ខ. តាង $A_1$ , $A_2$ ជាចំណុចប្រសព្វរវាង $(S)$ និង $\overrightarrow{Ox}$ ។ រកសមីការប្លង់ដែលប៉ះស្វ៊ែ $(S)$ ត្រង់ចំណុច $A_1$ និង $A_2$ ។

**VI.** (៥ ពិន្ទុ) $f$ ជាអនុគមន៍កំណត់លើ $\mathbb{R}$ ដោយ $f(x)=\frac{e^{2x}-5e^x+4}{e^x}$ និងមានក្រាប $(C)$ ។

ក. គណនាលីមីតនៃ $f$ ត្រង់ចុងដែនកំណត់ ។ សិក្សាអថេរភាពនៃ $f$ រួចសង់តារាងអថេរភាពរបស់វា ។

ខ. រកចំណុចប្រសព្វរវាងក្រាប $(C)$ ជាមួយអ័ក្សអាប់ស៊ីស រួចសរសេរសមីការបន្ទាត់ប៉ះទៅនឹងក្រាប $(C)$ ត្រង់ចំណុចនោះ ។

គ. សង់ក្រាប $(C)$ និងបន្ទាត់ប៉ះនោះ ។

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសមធ្យម ឆ្នាំ ២០១២

**I.** **ក. គណនាកន្សោម** $A=1+z_1+z_1^2$ :

គេមាន $z_1=-\frac{1}{2}+i\frac{\sqrt{3}}{2}$ និង $z_2=-\frac{1}{2}-i\frac{\sqrt{3}}{2}$

នាំឱ្យ $z_1^2=\left(-\frac{1}{2}+i\frac{\sqrt{3}}{2}\right)^2=\frac{1}{4}-i\frac{\sqrt{3}}{2}-\frac{3}{4}=-\frac{1}{2}-i\frac{\sqrt{3}}{2}$

គេបាន $A=1+z_1+z_1^2$

$$=1+\left(-\frac{1}{2}+i\frac{\sqrt{3}}{2}\right)+\left(-\frac{1}{2}-i\frac{\sqrt{3}}{2}\right)=0$$

ដូចនេះ៖ គណនាបានកន្សោម $\boxed{A=0}$ ។

**ខ. សរសេរ** $z_1$ , $z_2$ **ជាទម្រង់ត្រីកោណមាត្រ**

ដោយ $z_1=-\frac{1}{2}+i\frac{\sqrt{3}}{2}=\boxed{\cos\frac{2\pi}{3}+i\sin\frac{2\pi}{3}}$

និង $z_2=-\frac{1}{2}-i\frac{\sqrt{3}}{2}=\boxed{\cos\frac{4\pi}{3}+i\sin\frac{4\pi}{3}}$

➢**គណនា** $z_1^{2010}+z_2^{2010}$

- $z_1^{2010}+z_2^{2010}$

$=\left(\cos\frac{2\pi}{3}+i\sin\frac{2\pi}{3}\right)^{2010}+\left(\cos\frac{4\pi}{3}+i\sin\frac{4\pi}{3}\right)^{2010}$

$=(\cos 1340\pi+i\sin 1340\pi)+(\cos 2680\pi+i\sin 2680\pi)$

$=(\cos 0+i\sin 0)+(\cos 0+i\sin 0)$

$=(1+0i)+(1+0i)=2$

ដូចនេះ៖ គណនាបាន $\boxed{z_1^{2010}+z_2^{2010}=2}$ ។

**II.** **ក. ដោះស្រាយសមីការ** $(E)$ :

គេមាន $(E):\ 2y''-3y'+y=0$

សមីការសម្គាល់ $2\lambda^2-3\lambda+1=0$ មានឫស $\lambda=1$ , $\lambda=\frac{1}{2}$

ចម្លើយទូទៅនៃ $(E)$ រាង $y=Ae^{\lambda_1 x}+Be^{\lambda_2 x}$ , $A,B$ ថេរ

ដូចនេះ៖ សមីការមានចម្លើយ $\boxed{y=Ae^{x}+Be^{\frac{1}{2}x}}$ ។

**ខ. រកចម្លើយមួយនៃ** $(E)$

គេមាន $y=Ae^{x}+Be^{\frac{1}{2}x}$ នោះ៖ $y'=Ae^{x}+\frac{1}{2}Be^{\frac{1}{2}x}$

ដោយ ក្រាបនៃចម្លើយ ប៉ះទៅនឹងបន្ទាត់ដែលមានសមីការ $y=2x+1$ ត្រង់ចំណុច $A(0\ ,1)$

គេបាន $\begin{cases}y'(0)=2\\ y(0)=1\end{cases}\Leftrightarrow\begin{cases}A+\frac{1}{2}B=2\\ A+B=1\end{cases}\Rightarrow\begin{cases}B=-2\\ A=3\end{cases}$

ដូចនេះ៖ ចម្លើយមួយនៃ $(E)$ គឺ $\boxed{y=3e^{x}-2e^{\frac{1}{2}x}}$ ។

**III.** **ក. រក** $A$ , $B$ **និង** $C$ :

$$f(x)=\frac{A}{x+1}+\frac{B}{x-3}+\frac{C}{(x-3)^2}$$

$$=\frac{A(x-3)^2+B(x+1)(x-3)+C(x+1)}{(x+1)(x-3)^2}$$

$$=\frac{A(x^2-6x+9)+B(x^2-2x-3)+C(x+1)}{(x+1)(x-3)^2}$$

$$=\frac{(A+B)x^2+(-6A-2B+C)+(9A-3B+C)}{(x+1)(x-3)^2}$$

ផ្ទឹមនឹង $f(x)=\frac{5x^2-14x+13}{(x+1)(x-3)^2}$ , $x\neq-1$ , $x\neq 3$

គេបាន $\begin{cases}A+B=5 & (1)\\ -6A-2B+C=-14 & (2)\\ 9A-3B+C=13 & (3)\end{cases}$

យក $(3)-(2)$ គេបាន $15A-B=27$ $(4)$

យក $(1)+(4)$ គេបាន $16A=32$ នោះ៖ $A=2$

តាម $(1): 2+B=5\ \Rightarrow\ B=3$

តាម $(3): 9\cdot2-3\cdot3+C=13\Rightarrow C=4$

ដូចនេះ៖ រកបាន $\boxed{A=2\ ,\ B=3\ ,\ C=4}$ ។

**ខ. គណនា** $I=\int f(x)dx$

ចំពោះ៖ $A=2$ , $B=3$ , $C=4$

គេបាន $f(x)=\frac{2}{x+1}+\frac{3}{x-3}+\frac{4}{(x-3)^2}$

នាំឱ្យ $\mathbf{I}=\int\left(\frac{2}{x+1}+\frac{3}{x-3}+\frac{4}{(x-3)^2}\right)dx$

$=2\ln|x+1|+3\ln|x-3|-\frac{4}{x-3}+c$ , $c$ ថេរ

ដូចនេះ៖ $\boxed{\mathbf{I}=2\ln|x+1|+3\ln|x-3|-\frac{4}{x-3}+c}$ ។

**IV.** **រកប្រូបាប**

គ្រាប់ឡុកឡាក់ 2 មួយខៀវ មួយក្រហម គេបោះព្រមគ្នា

នាំឱ្យ ចំនួនករណីអាចតាងដោយ $n(S)=6\times 6=36$

**ក. លេខចេញលើគ្រាប់ខៀវ ស្មើនឹង 2 ដងនៃលេខគ្រាប់ក្រហម**

លេខចេញលើគ្រាប់ខៀវ ស្មើនឹង 2 ដងនៃលេខគ្រាប់ក្រហម

មានបីករណីរួមមាន ៖ (ខ1ក្រ 2) ឬ(ខ 2 ក្រ 4) ឬ(ខ 3 ក្រ 6)

នាំឱ្យ ចំនួនករណីស្របតាងដោយ $n(A)=3$

គេបាន $P(A)=\dfrac{n(A)}{n(S)}=\dfrac{3}{36}=\dfrac{1}{12}$

ដូចនេះ $\boxed{P(A)=\dfrac{1}{12}}$ ។

**ខ. ផលបូកលេខលើគ្រាប់ឡុកឡាក់ទាំងពីរស្មើនឹង 5**

ផលបូកស្មើ 5 មាន 4 ករណីគឺ ៖

(ខ1ក្រ 4) ឬ (ខ 2 ក្រ 3) ឬ (ខ 3 ក្រ 2) ឬ (ខ 4 ក្រ1)

នាំឱ្យ ចំនួនករណីស្របតាងដោយ $n(B)=4$

គេបាន $P(B)=\dfrac{n(B)}{n(S)}=\dfrac{4}{36}=\dfrac{1}{9}$

ដូចនេះ $\boxed{P(B)=\dfrac{1}{9}}$ ។

**V.** **ក. រកកូអរដោនេនៃចំណុចប្រសព្វរវាងស្វ៊ែ $(S)$ ជាមួយ $\overrightarrow{Ox}$ , $\overrightarrow{Oy}$ , $\overrightarrow{Oz}$**

គេមាន $(S):(x-1)^2+(y-2)^2+(z+2)^2=16$

• ស្វ៊ែ $(S)$ ប្រសព្វនឹង $\overrightarrow{Ox}$ លុះត្រាតែ $y=0$ , $z=0$

គេបាន $(x-1)^2+(0-2)^2+(0+2)^2=16$

$(x-1)^2=8 \Rightarrow x=1\pm 2\sqrt{2}$

ដូចនេះ ស្វ៊ែ $(S)$ ប្រសព្វអ័ក្ស $\overrightarrow{Ox}$ ត្រង់ពីរចំណុចគឺ

$\boxed{\left(1+2\sqrt{2}\,,0\,,0\right),\left(1-2\sqrt{2}\,,0\,,0\right)}$ ។

• ស្វ៊ែ $(S)$ ប្រសព្វនឹង $\overrightarrow{Oy}$ លុះត្រាតែ $x=0$ , $z=0$

គេបាន $(0-1)^2+(y-2)^2+(0+2)^2=16$

$(y-2)^2=11 \Rightarrow y=2\pm\sqrt{11}$

ដូចនេះ ស្វ៊ែ $(S)$ ប្រសព្វអ័ក្ស $\overrightarrow{Oy}$ ត្រង់ពីរចំណុចគឺ

$\boxed{\left(0\,,2+\sqrt{11}\,,0\right),\left(0\,,2-\sqrt{11}\,,0\right)}$ ។

• ស្វ៊ែ $(S)$ ប្រសព្វនឹង $\overrightarrow{Oz}$ លុះត្រាតែ $x=0$ , $y=0$

គេបាន $(0-1)^2+(0-2)^2+(z+2)^2=16$

$(z+2)^2=11 \Rightarrow z=-2\pm\sqrt{11}$

ដូចនេះ ស្វ៊ែ $(S)$ ប្រសព្វអ័ក្ស $\overrightarrow{Oz}$ ត្រង់ពីរចំណុចគឺ

$\boxed{\left(0\,,0\,,2+\sqrt{11}\right),\left(0\,,0\,,2-\sqrt{11}\right)}$ ។

**ខ. រកសមីការប្លង់ដែលប៉ះស្វ៊ែ $(S)$ ត្រង់ចំណុច $A_1$ និង $A_2$**

ដោយ $(S):(x-1)^2+(y-2)^2+(z+2)^2=16$

នាំឱ្យ ស្វ៊ែមានផ្ចិត $I(1\,,2\,,-2)$

គេមាន $A_1\left(1+2\sqrt{2}\,,0\,,0\right)$, $A_2\left(1-2\sqrt{2}\,,0\,,0\right)$

ប្លង់ $(P)$ រាង $a(x-x_0)+b(y-y_0)+c(z-z_0)=0$

• ករណីប្លង់ $(P)$ កាត់តាមចំណុច $A_1\left(1+2\sqrt{2}\,,0\,,0\right)$

នោះគេបានប្លង់ $(P_1)$ ដែលមានវ៉ិចទ័រណរម៉ាល់ $\vec{n}_1=\overrightarrow{IA_1}$

ដែល $\vec{n}_1=\overrightarrow{IA_1}=\left(2\sqrt{2}\,,-2\,,2\right)$ នាំឱ្យ ៖

$(P_1):\ 2\sqrt{2}\left(x-1-2\sqrt{2}\right)-2(y-0)+2(z-0)=0$

$2\sqrt{2}x-2y+2z-2\sqrt{2}-8=0$

ដូចនេះ $\boxed{(P_1):\ 2\sqrt{2}x-2y+2z-2\sqrt{2}-8=0}$ ។

• ករណីប្លង់ $(P)$ កាត់តាមចំណុច $A_2\left(1-2\sqrt{2}\,,0\,,0\right)$

នោះគេបានប្លង់ $(P_2)$ ដែលមានវ៉ិចទ័រណរម៉ាល់ $\vec{n}_2=\overrightarrow{IA_2}$

ដែល $\vec{n}_2=\overrightarrow{IA_2}=\left(-2\sqrt{2}\,,-2\,,2\right)$ នាំឱ្យ ៖

$(P_2):\ -2\sqrt{2}\left(x-1-2\sqrt{2}\right)-2(y-0)+2(z-0)=0$

$-2\sqrt{2}x-2y+2z+2\sqrt{2}+8=0$

ដូចនេះ $\boxed{(P_2):\ -2\sqrt{2}x-2y+2z+2\sqrt{2}+8=0}$ ។

**VI.** **ក. គណនាលីមីតនៃ $f$ ត្រង់ចុងដែនកំណត់**

គេមាន $f(x)=\dfrac{e^{2x}-5e^x+4}{e^x}$ កំណត់លើ $\mathbb{R}$

គេបានលីមីតតត្រង់ចុងដែនកំណត់គឺ

$$\lim_{x\to+\infty}f(x)=\lim_{x\to+\infty}\frac{e^{2x}-5e^x+4}{e^x}=\lim_{x\to+\infty}\frac{e^{2x}}{e^x}=+\infty$$

$$\lim_{x\to-\infty}f(x)=\lim_{x\to-\infty}\frac{e^{2x}-5e^x+4}{e^x}=\frac{4}{0^+}=+\infty$$

ដូចនេះ $\boxed{\lim_{x\to+\infty}f(x)=+\infty\ ,\ \lim_{x\to-\infty}f(x)=+\infty}$ ។

➢សិក្សាអថេរភាពនៃ $f$ រួចសង់តារាងអថេរភាពរបស់វា

គេមាន $f(x)=\dfrac{e^{2x}-5e^x+4}{e^x}$

$$f'(x)=\frac{\left(2e^{2x}-5e^x\right)e^x-e^x\left(e^{2x}-5e^x+4\right)}{e^{2x}}$$

$$=\frac{\left(2e^{2x}-5e^x\right)-\left(e^{2x}-5e^x+4\right)}{e^x}$$

$$=\frac{e^{2x}-4}{e^x}=\frac{\left(e^x-2\right)\left(e^x+2\right)}{e^x}$$

គេឱ្យ $f'(x)=0 \Leftrightarrow \dfrac{\left(e^x-2\right)\left(e^x+2\right)}{e^x}=0$

ដោយ $\forall x\in\mathbb{R}\ ,\ e^x>0\ ,\ e^x+2>0$

នាំឱ្យ $e^x-2=0 \ \Rightarrow\ x=\ln 2$

$$f(\ln 2)=\frac{e^{2\ln 2}-5e^{\ln 2}+4}{e^{\ln 2}}=\frac{4-10+4}{2}=-1$$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | $\ln 2$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $-$ | 0 | $+$ |

ត្រង់ $x=\ln 2$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានអប្បបរមាមួយស្មើ $f(\ln 2)=-1$ ។

• សង់តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-\infty$ | | $\ln 2$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | 0 | $+$ | |
| $f(x)$ | $+\infty$ | ↘ | -1 | ↗ | $+\infty$ |

ខ. រកចំណុចប្រសព្វរវាងក្រាប $(C)$ ជាមួយអ័ក្សអាប់ស៊ីស

បើក្រាប $(C)$ ប្រសព្វអ័ក្ស $x'ox$ នោះ $y=f(x)=0$

គេបាន $\dfrac{e^{2x}-5e^x+4}{e^x}=0\ ,\ \forall x\in\mathbb{R}\ ,\ e^x>0$

នាំឱ្យ $e^{2x}-5e^x+4=0$ , តាង $t=e^x$ , $t>0$

គេបាន $t^2-5t+4=0$ មានឫសងាយ $t=1\ ,\ t=4$

$$\left[\begin{array}{l} t=1 \\ t=4 \end{array}\right. \Leftrightarrow \left[\begin{array}{l} e^x=1 \\ e^x=4 \end{array}\right. \Rightarrow \left[\begin{array}{l} x=0 \\ x=\ln 4 \end{array}\right.$$

ដូចនេះ ក្រាប $(C)$ ប្រសព្វអ័ក្ស $x'ox$ ត្រង់ពីរចំណុចគឺ

$\boxed{(0\ ,\ 0)\ ,\ (\ln 4\ ,\ 0)}$ ។

➢សរសេរសមីការបន្ទាត់ប៉ះទៅនឹងក្រាប $(C)$ ត្រង់ចំណុចនោះ

សមីការបន្ទាត់ប៉ះរាង $y=f'(x_0)(x-x_0)+f(x_0)$

• ករណីបន្ទាត់ប៉ះក្រាបត្រង់ចំណុច $(0\ ,\ 0)$ គេបាន ៖

$f'(0)=\dfrac{e^0-4}{e^0}=-3$ និង $f(0)=0$

នាំឱ្យ $y=-3(x-0)+0=-3x$

• ករណីបន្ទាត់ប៉ះក្រាបត្រង់ចំណុច $(\ln 4\ ,\ 0)$ គេបាន ៖

$f'(\ln 4)=\dfrac{e^{2\ln 4}-4}{e^{\ln 4}}=\dfrac{16-4}{4}=3$ និង $f(\ln 4)=0$

នាំឱ្យ $y=3(x-\ln 4)+0=3x-3\ln 4$

ដូចនេះ៖ សមីការបន្ទាត់ប៉ះត្រង់ចំណុចប្រសព្វទាំងពីរគឺ

$\boxed{y=-3x\ ,\ y=3x-3\ln 4}$ ។

គ. សង់ក្រាប $(C)$ និងបន្ទាត់ប៉ះនោះ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ**

**សម័យប្រឡង : ១៥ តុលា ២០១១**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច $(2+i)x^2-(5-i)x+2-2i=0$ ។

ខ. កំណត់ចំនួនកុំផ្លិច $z$ ដែល $z$ , $\frac{1}{z}$ និង $1-z$ មានម៉ូឌុលស្មើគ្នា ។ **(១ពិន្ទុកន្លះ)**

**II.** គេឱ្យអនុគមន៍ $f(x)=\ln\left(x+\sqrt{1+x^2}\right)$ ។

ក. រកដែនកំណត់នៃអនុគមន៍ $f$ ។

ខ. បង្ហាញថា អនុគមន៍ $f$ ជាអនុគមន៍សេស និងជាអនុគមន៍កើន ។ **(១ពិន្ទុកន្លះ)**

**III.** គណនាអាំងតេក្រាលខាងក្រោម ៖

ក. $I=\int_{-2}^{2}\left(4-x^2\right)(2+x)^n\,dx$ ។

ខ. $J=\int_{6}^{8}\frac{x}{x^2-6x+8}dx$ ។ **(១ពិន្ទុកន្លះ)**

**IV.** គេមានថង់បួន $A$ , $B$ , $C$ និង $D$ ។ ក្នុងថង់ $A$ មានប៊ូលស 30 ។ ក្នុងថង់ $B$ មានប៊ូលខ្មៅ 40 ។ ក្នុងថង់ $C$ មានប៊ូលស 10 និងប៊ូលពណ៌ក្រហម 25 ។ ក្នុងថង់ $D$ មានប៊ូលស 5 ប៊ូលពណ៌ខៀវ 3 និងប៊ូលពណ៌ក្រហម 2 ។ គេដាក់ថង់ទាំងបួននៅក្នុងថង់ធំមួយ ។ គេចាប់យកដោយចៃដន្យនូវថង់មួយចេញពីថង់ធំ ហើយលូកយកប៊ូលមួយចេញពីថង់នោះ ។ គណនាប្រូបាប ដើម្បីឱ្យប៊ូលដែលគេលូកយកចេញមានពណ៌ស ។ **(១ពិន្ទុកន្លះ)**

**V.** ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(O,\vec{i},\vec{j},\vec{k})$ គេឱ្យបន្ទាត់ $\ell$ មួយដែលកំណត់ដោយ $x=t$ , $y=-3+3t$ , $z=-2+2t$ និងប្លង់ $(P)$ ដែលកាត់តាមបន្ទាត់ $\ell$ និងកាត់តាមចំណុច $A(1,2,1)$ ។ រកកូអរដោនេនៃចំណុចប្រសព្វរវាងប្លង់ $(P)$ និងអ័ក្ស $z'oz$ ។ **(១ពិន្ទុកន្លះ)**

**VI.** គេឱ្យអនុគមន៍ $y=f(x)=\frac{x^2-3x+1}{x-2}$ មានខ្សែកោង $(C)$ ។

ក. សិក្សាអថេរភាព និងសង់ខ្សែកោង $(C)$ តាងអនុគមន៍ $f$ ។

ខ. សរសេរសមីការបន្ទាត់ប៉ះទៅនឹងខ្សែកោង $(C)$ ដែលមានមេគុណប្រាប់ទិសស្មើ 2 ។

គ. គណនាផ្ទៃក្រឡា $S$ ដែលខណ្ឌដោយខ្សែកោង $(C)$ អ័ក្ស $x'ox$ និងបន្ទាត់ $x=3$ និង $x=4$ ។ **(២ពិន្ទុកន្លះ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសមធ្យម ឆ្នាំ ២០១១

**I. ក. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច :**

គេមាន $(2+i)x^2-(5-i)x+2-2i=0$

$$\Delta=\left[-(5-i)^2\right]-4(2+i)(2-2i)$$
$$=25-10i+i^2-16+16i-8i+8i^2$$
$$=-2i=1-2i+i^2=(1-i)^2$$

នាំឱ្យ $x=\dfrac{(5-i)\pm\sqrt{(1-i)^2}}{2(2+i)}=\dfrac{5-i\pm(1-i)}{2(2+i)}$

$$=\left[\begin{array}{l}\dfrac{3-i}{2+i}=\dfrac{(3-i)(2-i)}{2^2-i^2}=\dfrac{6-3i-2i+i^2}{5}\\[2mm] \dfrac{2}{2+i}=\dfrac{2(2-i)}{2^2-i^2}=\dfrac{4-2i}{5}\end{array}\right.$$

$$=\left[\begin{array}{l}1-i\\ \dfrac{4}{5}-\dfrac{2}{5}i\end{array}\right.$$

ដូចនេះ សមីការមានឫស $\boxed{x=1-i\ ,\ x=\frac{4}{5}-\frac{2}{5}i}$ ។

**ខ. កំណត់ចំនួនកុំផ្លិច $z$** (លំហាត់ដូចគ្រូបឋមឆ្នាំ ២០០៦)

គេតាង $z=a+bi$

នាំឱ្យ $\dfrac{1}{z}=\dfrac{1}{a+bi}=\dfrac{a-bi}{a^2+b^2}=\dfrac{a}{a^2+b^2}-\dfrac{b}{a^2+b^2}i$

$1-z=(1-a)-bi$

គេបាន $|z|=\sqrt{a^2+b^2}$ , $\left|\dfrac{1}{z}\right|=\dfrac{1}{|z|}=\dfrac{1}{\sqrt{a^2+b^2}}$

$|1-z|=\sqrt{(1-a)^2+(-b)^2}$

ដោយ $z\ ,\ \dfrac{1}{z}$ និង $1-z$ មានម៉ូឌុលស្មើគ្នា គេបាន ៖

$$\sqrt{a^2+b^2}=\frac{1}{\sqrt{a^2+b^2}}=\sqrt{(1-a)^2+(-b)^2}$$

នាំឱ្យ $\begin{cases}a^2+b^2=1 & (1)\\ \sqrt{a^2+b^2}=\sqrt{(1-a)^2+(-b)^2} & (2)\end{cases}$

តាម$(2)$ $a^2+b^2=(1-a)^2+b^2$

$a^2=1-2a+a^2$ នាំឱ្យ $a=1/2$

តាម$(1)$ $\left(\dfrac{1}{2}\right)^2+b^2=1\ \Rightarrow\ b=\pm\dfrac{\sqrt{3}}{2}$

ដូចនេះ កំណត់បានចំនួនកុំផ្លិច $\boxed{z=\frac{1}{2}\pm\frac{\sqrt{3}}{2}i}$ ។

**II. ក. រកដែនកំណត់នៃអនុគមន៍ $f$ :**

គេមាន $f(x)=\ln\left(x+\sqrt{1+x^2}\right)$

អនុគមន៍ $f$ មានន័យលុះត្រាតែ $\begin{cases}1+x^2\geq 0 & (1)\\ x+\sqrt{1+x^2}>0 & (2)\end{cases}$

តាម$(1)$ $1+x^2\geq 0\ ,\ \forall x\in\mathbb{R}$

តាម$(2)$ $x+\sqrt{1+x^2}>0$ ដោយ $\forall x\in\mathbb{R}$

$1+x^2>x^2$

$\sqrt{1+x^2}>\sqrt{x^2}$

$x+\sqrt{1+x^2}>x+|x|$

តែ $\forall x\in\mathbb{R}$ , $x+|x|\geq 0$

នាំឱ្យ $x+\sqrt{1+x^2}>0$ , $\forall x\in\mathbb{R}$

ដូចនេះ $\boxed{\text{អនុគមន៍ } f \text{ មានដែនកំណត់ } D=\mathbb{R}}$ ។

**ខ. ➤បង្ហាញថា $f$ ជាអនុគមន៍សេស**

គេមាន $f(x)=\ln\left(x+\sqrt{1+x^2}\right)$

នាំឱ្យ $f(-x)=\ln\left(-x+\sqrt{1+(-x)^2}\right)$

$$=\ln\left(\sqrt{1+x^2}-x\right)$$
$$=\ln\frac{\left(\sqrt{1+x^2}-x\right)\left(\sqrt{1+x^2}+x\right)}{\left(\sqrt{1+x^2}+x\right)}$$
$$=\ln\frac{1+x^2-x^2}{\sqrt{1+x^2}+x}=\ln\frac{1}{\sqrt{1+x^2}+x}$$
$$=\ln\left(\sqrt{1+x^2}+x\right)^{-1}$$
$$=-\ln\left(x+\sqrt{1+x^2}\right)=-f(x)$$

ដោយ $f(-x)=f(x)$

ដូចនេះ $\boxed{f \text{ ជាអនុគមន៍សេស}}$ ។

**➤បង្ហាញថា $f$ ជាអនុគមន៍កើន**

គេមាន $f(x)=\ln\left(x+\sqrt{1+x^2}\right)$

តាមរូបមន្ត $y=\ln(u)\ \Rightarrow\ y'=\dfrac{u'}{u}$

នាំឱ្យ $f'(x)=\dfrac{\left(x+\sqrt{1+x^2}\right)'}{x+\sqrt{1+x^2}}=\dfrac{1+\dfrac{\left(1+x^2\right)'}{2\sqrt{1+x^2}}}{x+\sqrt{1+x^2}}$

$$=\dfrac{1+\dfrac{x}{\sqrt{1+x^2}}}{x+\sqrt{1+x^2}}=\dfrac{\dfrac{\sqrt{1+x^2}+x}{\sqrt{1+x^2}}}{x+\sqrt{1+x^2}}=\dfrac{1}{\sqrt{1+x^2}}$$

ដោយ $\forall x\in\mathbb{R}$ , $\dfrac{1}{\sqrt{1+x^2}}>0$ នាំឱ្យ $f'(x)>0$

ដូចនេះ $\boxed{f \text{ ជាអនុគមន៍កើន } \forall x\in\mathbb{R}}$ ។

## III. គណនាអាំងតេក្រាលខាងក្រោម :

$$\mathbf{I}=\int_{-2}^{2}\left(4-x^2\right)(2+x)^n\,dx$$
$$=\int_{-2}^{2}(2-x)(2+x)(2+x)^n\,dx$$
$$=\int_{-2}^{2}(2-x)(2+x)^{n+1}\,dx$$
$$=\int_{-2}^{2}(4-2-x)(2+x)^{n+1}\,dx$$
$$=4\int_{-2}^{2}(2+x)^{n+1}\,dx-\int_{-2}^{2}(2+x)^{n+2}\,dx$$
$$=4\int_{-2}^{2}(2+x)'(2+x)^{n+1}\,dx-\int_{-2}^{2}(2+x)'(2+x)^{n+2}\,dx$$
$$=4\left[\frac{(2+x)^{n+2}}{n+2}\right]_{-2}^{2}-\left[\frac{(2+x)^{n+3}}{n+3}\right]_{-2}^{2}$$
$$=4\left(\frac{4^{n+2}}{n+2}-0\right)-\left(\frac{4^{n+3}}{n+3}-0\right)=\frac{4^{n+3}}{n+2}-\frac{4^{n+3}}{n+3}$$
$$=4^{n+3}\left(\frac{n+3-n-2}{(n+2)(n+3)}\right)=\boxed{\frac{4^{n+3}}{(n+2)(n+3)}}$$

$$\mathbf{J}=\int_{6}^{8}\frac{x}{x^2-6x+8}dx$$
$$=\frac{1}{2}\int_{6}^{8}\frac{2x-6+6}{x^2-6x+8}dx$$
$$=\frac{1}{2}\left[\int_{6}^{8}\frac{2x-6}{x^2-6x+8}dx+\int_{6}^{8}\frac{6}{x^2-6x+8}dx\right]$$
$$=\frac{1}{2}\left[\int_{6}^{8}\frac{\left(x^2-6x+8\right)'}{x^2-6x+8}dx+6\int_{6}^{8}\frac{1}{(x-2)(x-4)}dx\right]$$
$$=\frac{1}{2}\left[\left[\ln\left|x^2-6x+8\right|\right]_{6}^{8}-3\int_{6}^{8}\left(\frac{1}{x-2}-\frac{1}{x-4}\right)dx\right]$$
$$=\frac{1}{2}\left[\left[\ln\left|x^2-6x+8\right|\right]_{6}^{8}-3\left[\ln\left|\frac{x-2}{x-4}\right|\right]_{6}^{8}\right]$$
$$=\frac{1}{2}\left[\ln 24-\ln 8-3\left(\ln\frac{3}{2}-\ln 2\right)\right]$$
$$=\frac{1}{2}\left[\ln 3-3(\ln 3-2\ln 2)\right]$$
$$=\frac{1}{2}\left[6\ln 2-2\ln 3\right]=\boxed{3\ln 2-\ln 3}$$

## IV. គណនាប្រូបាបដើម្បីឱ្យប៊ូលដែលគេលូកយកចេញមានពណ៌ស :

គេមាន ថង់ $A$ មានប៊ូល ស$30$

ថង់ $B$ មានប៊ូល ខ្មៅ$40$

ថង់ $C$ មានប៊ូល ស$10$ , ក្រហម$25$

ថង់ $D$ មានប៊ូល ស$5$ , ខៀវ$3$ និង ក្រហម$2$

ដើម្បីយកឱ្យបានឃ្លីស គេត្រូវចាប់ឱ្យបានថង់មួយ និងចាប់បាន ឃ្លីស គេបាន ៖

$P($ឃ្លីស$)=P(A$ស$)+P(C$ស$)+P(D$ស$)$

$$=\left(\frac{1}{4}\times\frac{30}{30}\right)+\left(\frac{1}{4}\times\frac{10}{35}\right)+\left(\frac{1}{4}\times\frac{5}{10}\right)$$
$$=\frac{1}{4}+\frac{1}{14}+\frac{1}{8}=\frac{25}{56}$$

ដូចនេះ $\boxed{\text{ប្រូបាបយកបានឃ្លីស } P(\text{ឃ្លីស})=\frac{25}{56}}$ ។

## V. រកកូអរដោនេនៃចំណុចប្រសព្វរវាងប្លង់ $(P)$ និងអ័ក្ស $z'oz$ :

គេមាន $(\ell): x=t\ ,\ y=-3+3t\ ,\ z=-2+2t\ ,\ t\in\mathbb{R}$

ប្លង់ $(P)$ កាត់តាមបន្ទាត់ $\ell$ និងកាត់ $A(1\,,2\,,1)$

ដោយ $(\ell)$ កាត់តាមចំណុចតាង $B(0\,,-3\,,-2)$ និងប្លង់ $(P)$ កាត់តាមបន្ទាត់ $(\ell)$ នោះ $(P)$ កាត់ $B$ ដែរ

ហេតុនេះ $(P)$ ជាប្លង់កាត់ $A$ និងមានវ៉ិចទ័រណរម៉ាល់ $\vec{n}$ ដែល

$\vec{n}=\vec{u}\times\overrightarrow{AB}$ , $\vec{u}$ ជាវ៉ិចទ័រប្រាប់ទិសនៃ $(\ell)$

គេមាន $\vec{u}=(1\,,3\,,2)$ និង $\overrightarrow{AB}=(-1\,,-5\,,-3)$

$$\vec{n}=\vec{u}\times\overrightarrow{AB}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & 3 & 2\\ -1 & -5 & -3\end{vmatrix}=\vec{i}+\vec{j}-2\vec{k}$$

នាំឱ្យ $(P): a(x-x_0)+b(y-y_0)+c(z-z_0)=0$

$$(x-1)+(y-2)-2(z-1)=0$$

ដោយ $(P)\cap(z'oz)$ នោះ $x=0\ ,\ y=0$

គេបាន $(0-1)+(0-2)-2(z-1)=0$ នោះ $z=-1/2$

ដូចនេះ $\boxed{\text{ចំណុចប្រសព្វ } (P) \text{ នឹងអ័ក្ស } z'oz \text{ គឺ } \left(0,0,-\frac{1}{2}\right)}$ ។

**VI.** **ក. សិក្សាអថេរភាព និងសង់ខ្សែកោង $(C)$ តាងអនុគមន៍ $f$ :**

គេមាន $y=f(x)=\dfrac{x^2-3x+1}{x-2}$ មានខ្សែកោង $(C)$

• ដែនកំណត់ : $f$ មានន័យលុះត្រាតែ $x-2\neq 0$ ឬ $x\neq 2$

ដូចនេះ ដែនកំណត់ $D=(-\infty\,,\,2)\cup(2\,,\,+\infty)$ ។

• លីមីត និងអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេត

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\frac{x^2-3x+1}{x-2}=\lim_{x\to-\infty}\frac{x^2}{x}=-\infty$$

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\frac{x^2-3x+1}{x-2}=\lim_{x\to+\infty}\frac{x^2}{x}=+\infty$$

$$\lim_{x\to2^-} f(x)=\lim_{x\to2^-}\frac{x^2-3x+1}{x-2}=\frac{-1}{0^-}=+\infty$$

$$\lim_{x\to2^+} f(x)=\lim_{x\to2^+}\frac{x^2-3x+1}{x-2}=\frac{-1}{0^+}=-\infty$$

ដោយ $\lim_{x\to2} f(x)=\pm\infty$ នោះ បន្ទាត់ដែលមានសមីការ $x=2$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។

ដោយ $f(x)=\dfrac{x^2-3x+1}{x-2}=x-1-\dfrac{1}{x-2}$ ហើយ $\lim_{x\to\pm\infty}\dfrac{1}{x-2}=0$ នោះបន្ទាត់ដែលមានសមីការ $y=x-1$ ជាអាស៊ីមតូតទ្រេត ។

• ទិសដៅអថេរភាព : ដេរីវេ

$$f'(x)=\frac{(x^2-3x+1)'(x-2)-(x-2)'(x^2-3x+1)}{(x-2)^2}$$

$$=\frac{(2x-3)(x-2)-(x^2-3x+1)}{(x-2)^2}$$

$$=\frac{2x^2-7x+6-x^2+3x-1}{(x-2)^2}=\frac{x^2-4x+5}{(x-2)^2}$$

$$=\frac{(x-2)^2+1}{(x-2)^2}=1+\frac{1}{(x-2)^2}>0\ ,\ \forall x\in D$$

នាំឱ្យ $f$ ជាអនុគមន៍កើនលើ $D$ គ្មានបរមាទេ

តារាងអថេរភាព

| $x$ | $-\infty$ | $2$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $+$ | ‖ | $+$ |
| $f(x)$ | $-\infty \nearrow +\infty$ | ‖ | $-\infty \nearrow +\infty$ |

• ផ្ចិតឆ្លុះ : ចំណុចប្រសព្វរវាងអាស៊ីមតូតឈរ និងទ្រេតគឺ $(2,1)$

• សង់ក្រាប អាស៊ីតមតូត




**ខ. សរសេរសមីការបន្ទាត់ប៉ះទៅនឹងខ្សែកោង $(C)$**

ដោយ បន្ទាត់ប៉ះមានមេគុណប្រាប់ទិសស្មើ $2$ នោះ $f'(x)=2$

គេបាន $1+\dfrac{1}{(x-2)^2}=2$ ឬ $(x-2)^2=1$ នោះ $\left[\begin{array}{l}x=1\\x=3\end{array}\right.$

គេរកបាន $f(1)=1$ និង $f(3)=1$

សមីការបន្ទាត់ប៉ះរាង $y=f'(x_0)(x-x_0)+f(x_0)$

• ករណីប៉ះត្រង់ $(1\,,1)$ គេបាន $y=2(x-1)+1=2x-1$

• ករណីប៉ះត្រង់ $(3\,,1)$ គេបាន $y=2(x-3)+1=2x-5$

ដូចនេះ: **បន្ទាត់ប៉ះគឺ $y=2x-1$ និង $y=2x-5$** ។

**គ. គណនាផ្ទៃក្រឡា $S$**

ផ្ទៃខណ្ឌដោយ $(C)$ អ័ក្ស $x'ox$ និងបន្ទាត់ $x=3$ និង $x=4$

$$S=\int_3^4 f(x)\,dx=\int_3^4\left(x-1-\frac{1}{x-2}\right)dx$$

$$=\left[\frac{x^2}{2}-x-\ln|x-2|\right]_3^4$$

$$=(8-4-\ln2)-\left(\frac{9}{2}-3-0\right)$$

$$=4-\ln2-\frac{3}{2}=\frac{5}{2}-\ln2$$

ដូចនេះ: **គណនាបាន $S=\dfrac{5}{2}-\ln2$ ឯកតាផ្ទៃក្រឡា** ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ

**សម័យប្រឡង : ១៥ តុលា ២០១០**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** គេឱ្យចំនួនពិត $\alpha$ មួយដែល $-\pi < \alpha < \pi$ ។

ក. បង្ហាញថា $\sin^2\alpha - 2(1+\cos\alpha) = -4\cos^4\frac{\alpha}{2}$ ។

ខ. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច $Z^2 - 2Z\sin\alpha + 2(1+\cos\alpha) = 0$ ។ **(១ពិន្ទុ)**

**II.** ចតុកោណកែងមួយមានផ្ទៃក្រឡា $2500\,\mathrm{m}^2$ ។ រកប្រវែងជ្រុងនៃចតុកោណកែង ដើម្បីឱ្យវាមានបរិមាត្រតូចបំផុត ។ **(១ពិន្ទុ)**

**III.** ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y'' - y = 0$ ។

ខ. កំណត់ចម្លើយមួយនៃសមីការ $(E)$ បើដឹងថាក្រាបនៃចម្លើយកាត់អ័ក្ស $(y'y)$ ត្រង់ចំណុច $y = 4$ ហើយបន្ទាត់ប៉ះក្រាបត្រង់ចំណុចនេះ ស្របទៅនឹងបន្ទាត់ $(D): y = 2x - 4$ ។ **(១ពិន្ទុ)**

**IV.** គេទាញយកអក្សរ បួន ពីតួអក្សរនៃពាក្យ STATISTIQUE ។ ចូរគណនាប្រូបាបនៃព្រឹត្តិការណ៍ដែលមានពាក្យ SITE តាមលំដាប់នៃតួអក្សរ បើគេទាញយកម្តងមួយៗ ក្នុងករណីទាំងពីរខាងក្រោម ៖

ក. គេមិនដាក់ទៅវិញទេនូវតួអក្សរដែលទាញយកមកហើយ ។

ខ. គេដាក់ទៅវិញនូវតួអក្សរដែលទាញយកមកហើយ មុននឹងទាញយកតួអក្សរមួយទៀត ។ **(២ពិន្ទុ)**

**V.** ក្នុងតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j}, \vec{k})$ នៃលំហគេមានចំណុច $A(6, 4, -2)$, $B(6, 2, 0)$, $C(4, 2, -2)$ ។

ក. បង្ហាញថា ត្រីកោណ $ABC$ ជាត្រីកោណសម័ង្ស ។

ខ. គេឱ្យចំណុច $S(3, y, z)$ ។ គណនាតម្លៃ $y$ និង $z$ ដើម្បីឱ្យ $SABC$ ជាពីរ៉ាមីតនិយ័តមានកំពូល $S$ ។ **(២ពិន្ទុ)**

**VI.** គេឱ្យអនុគមន៍ $f$ មានអថេរ $x$ កំណត់ដោយ $f(x) = \frac{5^x}{5^{2x} - 1}$ ។

ក. ផ្ទៀងផ្ទាត់ថា អនុគមន៍ $f$ កំណត់លើសំណុំចំនួនពិត $\mathbb{R}$ ខុសពីសូន្យ ។

ខ. បង្ហាញថា អនុគមន៍ $f$ ជាអនុគមន៍សេស ។

គ. សិក្សាទិសដៅអថេរភាពនៃអនុគមន៍ $f$ លើ $]0, +\infty[$ រួចទាញរកទិសដៅអថេរភាពនៃអនុគមន៍ $f$ លើ $]-\infty, 0[$ ។

ឃ.ដោះស្រាយសមីការ $f(x) = \frac{2}{3}$ ។ **(៣ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ២០១០

**I.** **ក. បង្ហាញថា** $\sin^2\alpha - 2(1+\cos\alpha) = -4\cos^4\frac{\alpha}{2}$ :

**របៀបទី១** $\sin^2\alpha - 2(1+\cos\alpha)$

$$= \left(2\sin\frac{\alpha}{2}\cos\frac{\alpha}{2}\right)^2 - 2\cdot 2\cos^2\frac{\alpha}{2}$$

$$= 4\cos^2\frac{\alpha}{2}\left(\sin^2\frac{\alpha}{2} - 1\right)$$

$$= -4\cos^2\frac{\alpha}{2}\left(1 - \sin^2\frac{\alpha}{2}\right)$$

$$= -4\cos^4\frac{\alpha}{2}$$

ដូចនេះ $\boxed{\sin^2\alpha - 2(1+\cos\alpha) = -4\cos^4\frac{\alpha}{2}}$ ។

**របៀបទី២** $\sin^2\alpha - 2(1+\cos\alpha)$

$$= (1-\cos^2\alpha) - 2 - 2\cos\alpha$$

$$= -\cos^2\alpha - 2\cos\alpha - 1$$

$$= -(\cos x + 1)^2$$

$$= -\left(2\cos^2\frac{\alpha}{2}\right)^2 = -4\cos^4\frac{\alpha}{2}$$

ដូចនេះ $\boxed{\sin^2\alpha - 2(1+\cos\alpha) = -4\cos^4\frac{\alpha}{2}}$ ។

**ខ. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច**

គេមាន $Z^2 - 2Z\sin\alpha + 2(1+\cos\alpha) = 0$

$$\Delta' = (-\sin\alpha)^2 - 2(1+\cos\alpha)$$

$$= \sin^2\alpha - 2(1+\cos\alpha) = -4\cos^4\frac{\alpha}{2}$$

នាំឱ្យ $Z = \dfrac{\sin\alpha \pm \sqrt{-4\cos^4\frac{\alpha}{2}}}{1} = \sin\alpha \pm 2i\cos^2\frac{\alpha}{2}$

ដូចនេះ សមីការមានឫស $\boxed{Z = \sin\alpha \pm 2i\cos^2\frac{\alpha}{2}}$ ។

**II.** **រកប្រវែងជ្រុងនៃចតុកោណកែង** :




គេតាង $x$ ជាបណ្តោយ , $x>0$

$y$ ជាទទឹង , $y>0$

គេបាន $xy = 2500$ នោះ $y = \dfrac{2500}{x}$

បរិមាត្រ $P = 2(x+y)$ នោះ $P(x) = 2\left(x + \dfrac{2500}{x}\right)$

នាំឱ្យ $P'(x) = 2\left(1 - \dfrac{2500}{x^2}\right) = 2\left(\dfrac{x^2-2500}{x^2}\right)$

ឱ្យ $P'(x) = 0 \Leftrightarrow 2\left(\dfrac{x^2-2500}{x^2}\right) = 0$

នាំឱ្យ $x^2 - 2500 = 0$ នោះ $x = \pm 50$

តារាងសញ្ញា $P'(x)$

| $x$ | $-\infty$ | $-50$ | $0$ | $50$ | $+\infty$ |
|---|---|---|---|---|---|
| $P'(x)$ | $+$ | $0$ | $-$ ‖ $-$ | $0$ | $+$ |

•ត្រង់ $x = 50$ , $P'(x) = 0$ និងប្តូរសញ្ញាពី $(-)$ ទៅ $(+)$ បញ្ជាក់ថា $P$ មានតម្លៃតូចបំផុតមួយ ។

គេបាន $y = \dfrac{2500}{x} = \dfrac{2500}{50} = 50\text{ m}$

ដូចនេះ $\boxed{\text{ប្រវែងបណ្តោយ} = \text{ប្រវែងទទឹង} = 50\text{m}}$ ។

**III.** **ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល** :

គេមាន $(E): y'' - y = 0$

សមីការសម្គាល់ $\lambda^2 - 1 = 0$ នោះ $\lambda = \pm 1$

ចម្លើយទូទៅនៃ $(E)$ រាង $y = Ae^{\lambda_1 x} + Be^{\lambda_2 x}$ , $A$ , $B$ ថេរ

ដូចនេះ $\boxed{y = Ae^{-x} + Be^{x}}$ ។

**ខ. កំណត់ចម្លើយមួយនៃសមីការ** $(E)$

គេមាន $y = Ae^{-x} + Be^{x}$ នាំឱ្យ $y' = -Ae^{-x} + Be^{x}$

ដោយ ក្រាបនៃចម្លើយកាត់អ័ក្ស $(y'y)$ ត្រង់ចំណុច $y = 4$

នោះ $y(0) = 4$

ហើយ បន្ទាត់ប៉ះក្រាបត្រង់ ចំណុចនេះ គឺ $(0\,,\,4)$ ស្របទៅ

នឹងបន្ទាត់ $(D): y = 2x - 4$ នោះ $y'(0) = 2$

គេបាន $\begin{cases} Ae^{-0} + Be^{0} = 4 \\ -Ae^{-0} + Be^{0} = 2 \end{cases} \Leftrightarrow \begin{cases} A + B = 4 \\ -A + B = 2 \end{cases} \Rightarrow \begin{cases} B = 3 \\ A = 1 \end{cases}$

ដូចនេះ ចម្លើយមួយនៃ $(E)$ កំណត់បានតាមលក្ខខណ្ឌគឺ

$\boxed{y = e^{-x} + 3e^{x}}$ ។

**IV.** **គណនាប្រូបាបចាប់បាន SITE តាមលំដាប់ នៃតួអក្សរ :**

**ក. គេមិនដាក់ទៅវិញទេនូវតួអក្សរដែលទាញយកមកហើយ**

គេមាន តួអក្សរនៃពាក្យ STATISTIQUE មាន 11 អក្សរ

គេបាន $P(\text{SITE})=\frac{2}{11}\times\frac{2}{10}\times\frac{3}{9}\times\frac{1}{8}=\frac{1}{660}$

ដូចនេះ ករណីចាប់ហើយមិនដាក់វិញ $\boxed{P(\text{SITE})=\frac{1}{660}}$ ។

**ខ. គេដាក់ទៅវិញមុនយកអក្សរមួយទៀត**

ករណីចាប់ហើយដាក់វិញ នោះចំនួនករណីអាចគឺនៅដដែល មិនប៉ះពាល់ដល់ការចាប់លើកក្រោយៗទៀត

គេបាន $P(\text{SITE})=\frac{2}{11}\times\frac{2}{11}\times\frac{3}{11}\times\frac{1}{11}=\frac{12}{14641}$

ដូចនេះ ករណីចាប់ហើយដាក់វិញ $\boxed{P(\text{SITE})=\frac{12}{14641}}$ ។

**V.** **ក. បង្ហាញថា ត្រីកោណ $ABC$ ជាត្រីកោណសម័ង្ស :**

គេមាន $A(6,4,-2)$ , $B(6,2,0)$ , $C(4,2,-2)$

នាំឱ្យ $\overrightarrow{AB}=(0,-2,2)$ , $\overrightarrow{AC}=(-2,-2,0)$ និង

$\overrightarrow{BC}=(-2,0,-2)$

គេបាន $\left|\overrightarrow{AB}\right|=\sqrt{0^2+(-2)^2+2^2}=2\sqrt{2}$ ឯកតាប្រវែង

$\left|\overrightarrow{AC}\right|=\sqrt{(-2)^2+(-2)^2+0^2}=2\sqrt{2}$ ឯកតាប្រវែង

$\left|\overrightarrow{BC}\right|=\sqrt{(-2)^2+0^2+(-2)^2}=2\sqrt{2}$ ឯកតាប្រវែង

ដោយ $\Delta ABC$ មាន $\left|\overrightarrow{AB}\right|=\left|\overrightarrow{AC}\right|=\left|\overrightarrow{BC}\right|=2\sqrt{2}$

ដូចនេះ $\boxed{ABC \text{ ជាត្រីកោណសម័ង្ស}}$ ។

**ខ. គណនាតម្លៃ $y$ និង $z$**

គេមាន $S(3,y,z)$ នោះ $\overrightarrow{SA}=(-3,y-4,z+2)$

$\overrightarrow{SB}=(-3,y-2,z)$ , $\overrightarrow{SC}=(-1,y-2,z+2)$

នាំឱ្យ $SA=\left|\overrightarrow{SA}\right|=\sqrt{(-3)^2+(y-4)^2+(z+2)^2}$

$SB=\left|\overrightarrow{SB}\right|=\sqrt{(-3)^2+(y-2)^2+z^2}$

$SC=\left|\overrightarrow{SC}\right|=\sqrt{(-1)^2+(y-2)^2+(z+2)^2}$

ដោយ $SABC$ ជាពីរ៉ាមីតនិយ័តនោះ $SB=SC=SA$

$$\sqrt{(-3)^2+(y-2)^2+z^2}=\sqrt{(-1)^2+(y-2)^2+(z+2)^2}$$

$$9+(y-2)^2+z^2=1+(y-2)^2+(z+2)^2$$

$$8+z^2=z^2+4z+4$$

$$z=1$$

ចំពោះ $SA=SB$ និង $z=1$ គេបាន ៖

$$\sqrt{(-3)^2+(y-4)^2+3^2}=\sqrt{(-3)^2+(y-2)^2+1^2}$$

$$9+(y-4)^2+9=9+(y-2)^2+1$$

$$8+(y-4)^2=(y-2)^2$$

$$8+y^2-8y+16=y^2-4y+4$$

$$-4y+20=0$$

$$y=5$$

ដូចនេះ គណនាបានតម្លៃ $\boxed{y=5\ ,\ z=1}$ ។

**VI.** **ក. ផ្ទៀងផ្ទាត់ថា $f$ កំណត់លើ $\mathbb{R}$ ខុសពីសូន្យ :**

គេមាន $f(x)=\frac{5^x}{5^{2x}-1}$ មានន័យ លុះត្រាតែ $5^{2x}-1\neq 0$

នាំឱ្យ $5^{2x}\neq 1$ ឬ $5^{2x}\neq 5^0$ នោះ $x\neq 0$

ដូចនេះ $\boxed{f \text{ កំណត់លើ } \mathbb{R}-\{0\}}$ ។

**ខ. បង្ហាញថា អនុគមន៍ $f$ ជាអនុគមន៍សេស**

គេមាន $f(x)=\frac{5^x}{5^{2x}-1}$

$$f(-x)=\frac{5^{-x}}{5^{-2x}-1}=\frac{\frac{1}{5^x}}{\frac{1}{5^{2x}}-1}=\frac{\frac{1}{5^x}}{\frac{1-5^{2x}}{5^{2x}}}$$

$$=\frac{1}{5^x}\times\frac{5^{2x}}{1-5^{2x}}=\frac{5^x}{1-5^{2x}}=-\frac{5^x}{5^{2x}-1}=-f(x)$$

ដោយ $f(-x)=-f(x)$ នោះ $f$ ជាអនុគមន៍សេស

ដូចនេះ $\boxed{f \text{ ជាអនុគមន៍សេស}}$ ។

**គ. សិក្សាទិសដៅអថេរភាពនៃអនុគមន៍ $f$ លើ $]0,+\infty[$**

គេមាន $f(x)=\frac{5^x}{5^{2x}-1}$ សិក្សាលើចន្លោះ $]0,+\infty[$

• លីមីត $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+}\frac{5^x}{5^{2x}-1}=\frac{5^0}{0^+}=+\infty$

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\frac{5^x}{5^{2x}-1}=\lim_{x\to+\infty}\frac{5^x}{5^{2x}}=0$$

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\frac{5^x}{5^{2x}-1}=\frac{0}{-1}=0$$

• អាស៊ីមតូត : ដោយ $\lim\limits_{x\to 0} f(x)=\pm\infty$ នោះបន្ទាត់ដែលមាន

សមីការ $x=0$ ជាអាស៊ីមតូតឈរ ។

• ទិសដៅអថេរភាព :

ដេរីវេ តាមរូបមន្ត $y=a^{u(x)}\ \Rightarrow\ y'=u'(x)a^{u(x)}\ln a$

ដោយ $f(x)=\dfrac{5^x}{5^{2x}-1}$ នោះគេបាន ៖

$$f'(x)=\frac{\left(5^x\right)'\left(5^{2x}-1\right)-\left(5^{2x}-1\right)'\left(5^x\right)}{\left(5^{2x}-1\right)^2}$$

$$=\frac{5^x\ln 5\cdot\left(5^{2x}-1\right)-2\cdot 5^{2x}\ln 5\cdot\left(5^x\right)}{\left(5^{2x}-1\right)^2}$$

$$=\frac{5^x\ln 5\cdot\left[5^{2x}-1-2\cdot 5^{2x}\right]}{\left(5^{2x}-1\right)^2}$$

$$=-\frac{5^x\ln 5\cdot\left(5^{2x}+1\right)}{\left(5^{2x}-1\right)^2}<0\ ,\ \forall x\in D$$

ដោយ $\forall x\in\mathbb{R}-\{0\}$ , $f'(x)<0$ នោះ $f$ ជាអនុគមន៍ ចុះលើចន្លោះ $]0\,,+\infty[$ និងចន្លោះ $]-\infty\,,0[$

• តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | $0$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $-$ | \|\| | $-$ |

ដោយ $f$ ជាអនុគមន៍សេស មានគល់ $O$ ជាផ្ចិតឆ្លុះនៃក្រាប គេទាញបាន ទិសដៅអថេរភាពនៃអនុគមន៍ $f$ លើ $]-\infty\,,0[$ ដូចខាងក្រោម :

-បើ $\lim\limits_{x\to 0^+} f(x)=+\infty$ នោះ $\lim\limits_{x\to 0^-} f(x)=-\infty$

-បើ $\lim\limits_{x\to +\infty} f(x)=0$ នោះ $\lim\limits_{x\to -\infty} f(x)=0$

• តារាងអថេរភាពនៃ $f$

| $x$ | $-\infty$ | $0$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $-$ | \|\| | $-$ |
| $f(x)$ | $0 \searrow -\infty$ | \|\| | $+\infty \searrow 0$ |

• សង់ក្រាបតាងអនុគមន៍ $f$




**ឃ. ដោះស្រាយសមីការ** $f(x)=\dfrac{2}{3}$

គេបាន $\dfrac{5^x}{5^{2x}-1}=\dfrac{2}{3}$ (សមីការមានន័យ $x\neq 0$)

$3\cdot 5^x=2\cdot 5^{2x}-2$

$-2\cdot 5^{2x}+3\cdot 5^x+2=0$

គេតាង $t=5^x$ ដែល $t>0$

គេបាន $-2t^2+3t+2=0$

$\Delta=9+16=25=5^2$

$$t=\frac{-3\pm 5}{2(-2)}=\left[\begin{array}{l}2\\-1/2\end{array}\right.$$

ចំពោះ $t=-\dfrac{1}{2}$ មិនយក ព្រោះ $t>0$

ចំពោះ $t=2$ សមមូល $5^x=2$ នាំឱ្យ $x=\log_5 2$

ដូចនេះ **សមីការមានឫស $x=\log_5 2$** ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ

**សម័យប្រឡង : ១៥ តុលា ២០០៩**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច $z^2-(5-i)z+8-i=0$ ។

ខ. គេឱ្យអនុគមន៍ $f(x)=29x^2+6x+2010$ ។ បើ $a>0$ , $b>0$

ស្រាយបញ្ជាក់ថា $f\left(\dfrac{a+b}{1+a+b}\right)<f\left(\dfrac{a}{1+a}+\dfrac{b}{1+b}\right)$ ។ **(១ពិន្ទុកន្លះ)**

**II.** ត្រីកោណកែងមួយមានប្រវែងអ៊ីប៉ូតេនុស $5\text{dm}$ ។ កំណត់ប្រវែងជ្រុងនៃមុំកែងរបស់ត្រីកោណកែង ដើម្បីឱ្យផ្ទៃក្រឡារបស់វាមានតម្លៃអតិបរមា ។ **(១ពិន្ទុ)**

**III.** ក. ចូរកំណត់ចំនួនថេរ $a$ និង $b$ ដើម្បីឱ្យចំពោះគ្រប់ $x$ គេបាន $\dfrac{1}{x(x+1)(x+2)}=\dfrac{a}{x(x+1)}+\dfrac{b}{(x+1)(x+2)}$ ។

ខ. គណនាផលបូក $\dfrac{1}{1\cdot2\cdot3}+\dfrac{1}{2\cdot3\cdot4}+.......+\dfrac{1}{n(n+1)(n+2)}$ ។ **(២ពិន្ទុ)**

**IV.** ក្នុងថង់មួយមានប៊ូលក្រហម 3 ប៊ូលខ្មៅ 3 និងប៊ូលស 3 ។ គេចាប់យកប៊ូល 3 ពីក្នុងថង់ ដោយយកម្តងមួយៗ ហើយមិនដាក់វិញ ។

ក. រកប្រូបាបដើម្បីឱ្យគេចាប់យកបានប៊ូលមានពណ៌ដូចគ្នា ។

ខ. រកប្រូបាបដើម្បីឱ្យគេចាប់យកបានប៊ូលមួយក្នុងមួយពណ៌ ។ **(១ពិន្ទុកន្លះ)**

**V.** ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(O,\vec{i},\vec{j},\vec{k})$ គេឱ្យចំណុច $A(1,4,3)$ , $B(2,11,4)$ , $C(-3,-5,4)$ ។

ក. បង្ហាញថា បីចំណុច $A$ , $B$ និង $C$ មិននៅលើបន្ទាត់តែមួយ ។

ខ. សរសេរសមីការប្លង់ $(P)$ ដែលកាត់តាមចំណុច $A$ , $B$ , $C$ ។

គ. គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ។ **(១ពិន្ទុកន្លះ)**

**VI.** គេឱ្យអនុគមន៍ $f(x)=\ln(ax+b)$ មានខ្សែកោង $(C)$ ។

ក. កំណត់តម្លៃ $a$ និង $b$ ដើម្បីឱ្យខ្សែកោង $(C)$ កាត់អ័ក្សអាប់ស៊ីសត្រង់ $x=-1$ និងកាត់អ័ក្សអរដោនេត្រង់ $y=\ln 2$ ។

ខ. សិក្សាអថេរភាព និងគូសខ្សែកោងតាងអនុគមន៍ $f$ ចំពោះតម្លៃ $a$ និង $b$ ដែលរកឃើញ រួចគណនាផ្ទៃក្រឡាផ្នែកនៃប្លង់ដែលខណ្ឌដោយខ្សែកោង $(C)$ អ័ក្សអាប់ស៊ីស បន្ទាត់ $x=-\dfrac{3}{2}$ និងបន្ទាត់ $x=0$ ។ **(២ពិន្ទុកន្លះ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ ២០០៩

**I.** ក. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច :

គេមាន $z^2-(5-i)z+8-i=0$

$$\Delta=\left[-(5-i)\right]^2-4\cdot1\cdot(8-i)$$
$$=25-10i+i^2-32+4i$$
$$=25-10i+i^2-32+4i$$
$$=-8-6i=(3i)^2-6i+1$$
$$=(3i-1)^2$$

នាំឱ្យ $z=\dfrac{(5-i)\pm(3i-1)}{2}=\left[\begin{array}{l}2+i\\3-2i\end{array}\right.$

ដូចនេះ សមីការមានឫស $\boxed{z=2+i\ ,\ z=3-2i}$ ។

ខ. ស្រាយបញ្ជាក់ថា $f\left(\dfrac{a+b}{1+a+b}\right)<f\left(\dfrac{a}{1+a}+\dfrac{b}{1+b}\right)$

គេមាន $f(x)=29x^2+6x+2010$

នាំឱ្យ $f'(x)=58x+6$

ចំពោះ $x>0$ នោះ $f'(x)=58x+6>0$

មានន័យថា $f$ ជាអនុគមន៍កើនលើចន្លោះ $(0\ ,+\infty)$

គេបាន បើ $0<x_1<x_2$ នោះ $f(x_1)<f(x_2)$

ម្យ៉ាងទៀត ចំពោះ $a>0\ ,\ b>0$ គេបាន ៖

$$0<\frac{a}{1+a+b}<\frac{a}{1+a}\quad(1)$$
$$0<\frac{b}{1+a+b}<\frac{b}{1+b}\quad(2)$$

បូកអង្គ និងអង្គនៃ $(1)$ និង $(2)$ គេបាន ៖

$$0<\frac{a}{1+a+b}+\frac{b}{1+a+b}<\frac{a}{1+a}+\frac{b}{1+b}$$
$$0<\frac{a+b}{1+a+b}<\frac{a}{1+a}+\frac{b}{1+b}$$

នាំឱ្យ $f\left(\dfrac{a+b}{1+a+b}\right)<f\left(\dfrac{a}{1+a}+\dfrac{b}{1+b}\right)$

ដូចនេះ $\boxed{f\left(\dfrac{a+b}{1+a+b}\right)<f\left(\dfrac{a}{1+a}+\dfrac{b}{1+b}\right)}$ ។

**II.** កំណត់ប្រវែងជ្រុងនៃមុំកែងរបស់ត្រីកោណកែង :

តាង $x\ ,\ y>0$ ជាជ្រុងជាប់មុំកែង គិតជា dm ដូចរូប ៖




តាមពីតាគ័រ $y=\sqrt{25-x^2}$ ដែល $0<x<5$

ផ្ទៃត្រីកោណ $S=\dfrac{1}{2}xy$ ឬ $S(x)=\dfrac{1}{2}x\sqrt{25-x^2}$

នាំឱ្យ $S'(x)=\dfrac{1}{2}\sqrt{25-x^2}+\dfrac{1}{2}x\cdot\dfrac{-2x}{2\sqrt{25-x^2}}$

$$=\frac{1}{2}\sqrt{25-x^2}-\frac{x^2}{2\sqrt{25-x^2}}$$
$$=\frac{25-x^2-x^2}{2\sqrt{25-x^2}}=\frac{25-2x^2}{2\sqrt{25-x^2}}$$

ឱ្យ $f'(x)=0$ សមមូល $\dfrac{25-2x^2}{2\sqrt{25-x^2}}=0$

នាំឱ្យ $25-2x^2=0$ នោះ $x=\pm\dfrac{5}{\sqrt{2}}=\pm\dfrac{5\sqrt{2}}{2}$

ហើយ $S\left(\dfrac{5\sqrt2}{2}\right)=\dfrac{1}{2}\left(\dfrac{5\sqrt2}{2}\right)\sqrt{25-\left(\dfrac{5\sqrt2}{2}\right)^2}=\dfrac{25}{4}$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $-\frac{5\sqrt{2}}{2}$ | | $0$ | | $\frac{5\sqrt{2}}{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $S'(x)$ | | $-$ | $0$ | $+$ | | $+$ | $0$ | $-$ | |

• ត្រង់ $x=\dfrac{5\sqrt2}{2}$ , $S'(x)=0$ និងប្តូរសញ្ញាពី $(+)$ ទៅ $(-)$

បញ្ជាក់ថា $S$ មានតម្លៃអតិបរមាមួយស្មើ $25/4$ ។

គេបាន $y=\sqrt{25-x^2}=\sqrt{25-\left(\dfrac{5\sqrt2}{2}\right)^2}=\dfrac{5\sqrt2}{2}$

ដូចនេះ ជ្រុងជាប់មុំកែង $\boxed{x=y=\dfrac{5\sqrt2}{2}\text{dm}}$ ។

**III.** **ក. កំណត់ចំនួនថេរ $a$ និង $b$** : (លំហាត់ដូចគ្រូបឋមឆ្នាំ 2004)

គេមាន $\dfrac{1}{x(x+1)(x+2)}=\dfrac{a}{x(x+1)}+\dfrac{b}{(x+1)(x+2)}$

$=\dfrac{a(x+2)+bx}{x(x+1)(x+2)}=\dfrac{(a+b)x+2a}{x(x+1)(x+2)}$

ផ្ទឹមបាន $\begin{cases}a+b=0\\ 2a=1\end{cases}\Rightarrow a=\dfrac{1}{2}\ ,\ b=-\dfrac{1}{2}$

ដូចនេះ កំណត់បាន $\boxed{a=\dfrac{1}{2}\ ,\ b=-\dfrac{1}{2}}$ ។

**ខ. គណនាផលបូក**

គេតាង $S=\dfrac{1}{1\cdot2\cdot3}+\dfrac{1}{2\cdot3\cdot4}+.......+\dfrac{1}{n(n+1)(n+2)}$

គេមាន $\dfrac{1}{x(x+1)(x+2)}=\dfrac{1/2}{x(x+1)}+\dfrac{-1/2}{(x+1)(x+2)}$

$\dfrac{1}{x(x+1)(x+2)}=\dfrac{1}{2}\left[\dfrac{1}{x(x+1)}-\dfrac{1}{(x+1)(x+2)}\right]$

យក $x=1,2,3,...,n$ គេបាន ៖

$$+\begin{cases}\dfrac{1}{1\cdot2\cdot3}=\dfrac{1}{2}\left[\dfrac{1}{1\cdot2}-\dfrac{1}{2\cdot3}\right]\\ \dfrac{1}{2\cdot3\cdot4}=\dfrac{1}{2}\left[\dfrac{1}{2\cdot3}-\dfrac{1}{3\cdot4}\right]\\ \dfrac{1}{3\cdot4\cdot5}=\dfrac{1}{2}\left[\dfrac{1}{3\cdot4}-\dfrac{1}{4\cdot5}\right]\\ \dots\dots\dots\dots\dots\dots\\ \dfrac{1}{n(n+1)(n+2)}=\dfrac{1}{2}\left[\dfrac{1}{n(n+1)}-\dfrac{1}{(n+1)(n+2)}\right]\end{cases}$$

$$S=\frac{1}{2}\left(\frac{1}{1\cdot2}-\frac{1}{(n+1)(n+2)}\right)$$

ដូចនេះ គណនាបាន $\boxed{S=\dfrac{1}{2}\left(\dfrac{1}{2}-\dfrac{1}{(n+1)(n+2)}\right)}$ ។

**IV.** **ក. រកប្រូបាបដើម្បីឱ្យគេចាប់យកបានប៊ូលមានពណ៌ដូចគ្នា** :

គេមាន ប៊ូលក្រហម 3 , ខ្មៅ 3 ,ស 3

គេចាប់ ប៊ូល 3 ពីក្នុងថង់ ម្ដងមួយៗ ហើយមិនដាក់វិញ

ចាប់បានឃ្លី 3 ពណ៌ដូចគ្នា អាចក្រហម 3ឬខ្មៅ 3 ឬស 3

គេបាន $P($ពណ៌ដូចគ្នា$)=P($ក្រ.3$)+P($ខ្ម3$)+P($ស3$)$

$=\left(\dfrac{3}{9}\cdot\dfrac{2}{8}\cdot\dfrac{1}{7}\right)+\left(\dfrac{3}{9}\cdot\dfrac{2}{8}\cdot\dfrac{1}{7}\right)+\left(\dfrac{3}{9}\cdot\dfrac{2}{8}\cdot\dfrac{1}{7}\right)=\dfrac{1}{28}$

ដូចនេះ $\boxed{P(\text{ពណ៌ដូចគ្នា})=\dfrac{1}{28}}$ ។

**ខ. រកប្រូបាបដើម្បីឱ្យគេចាប់យកបានប៊ូលមួយក្នុងមួយពណ៌**

ចាប់បានប៊ូលមួយក្នុងមួយពណ៌ អាចជា ៖

កខស ឬ កសខ ឬ ខកស ឬ ខសក ឬ សកខ ឬ សខក

(ដែល ក=ពណ៌ក្រហម , ខ=ពណ៌ខ្មៅ , ស=ពណ៌ស )

ដោយប្រូបាបនៃករណីនីមួយៗមានសតម្លៃស្មើៗគ្នា $\dfrac{3}{9}\cdot\dfrac{3}{8}\cdot\dfrac{3}{7}$

គេបាន $P($ប៊ូលមួយក្នុងមួយពណ៌$)=6\left(\dfrac{3}{9}\cdot\dfrac{3}{8}\cdot\dfrac{3}{7}\right)=\dfrac{9}{28}$

ដូចនេះ $\boxed{P(\text{ប៊ូលមួយក្នុងមួយពណ៌})=\dfrac{9}{28}}$ ។

**V.** **ក. បង្ហាញថា បីចំណុច $A$ , $B$ និង $C$ មិននៅលើបន្ទាត់តែមួយ**

គេមាន $A(1,4,3)$ , $B(2,11,4)$ , $C(-3,-5,4)$

គេបាន $\overrightarrow{AB}=(1,7,1)$ , $\overrightarrow{AC}=(-4,-9,1)$

នាំឱ្យ $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & 7 & 1\\ -4 & -9 & 1\end{vmatrix}=16\vec{i}-5\vec{j}+19\vec{k}$

ដោយ $\overrightarrow{AB}\times\overrightarrow{AC}=16\vec{i}-5\vec{j}+19\vec{k}\neq\vec{0}$

នាំឱ្យ $A$ , $B$ , $C$ មិននៅលើបន្ទាត់តែមួយ

ដូចនេះ $\boxed{\text{បីចំណុច } A , B \text{ និង } C \text{ មិននៅលើបន្ទាត់តែមួយ}}$ ។

**ខ. សរសេរសមីការប្លង់ $(P)$ ដែលកាត់តាមចំណុច $A$ , $B$ , $C$**

ប្លង់ $(P)$ រាង $a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយ $(P)$ កាត់តាមចំណុច $A(1,4,3)$

នាំឱ្យ $x_0=1$ , $y_0=4$ , $z_0=3$

ហើយ $(P)$ កាត់បីចំណុច $A$ , $B$ , $C$ នោះ $(P)$ មានវ៉ិចទ័រ

ណរម៉ាល់ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=16\vec{i}-5\vec{j}+19\vec{k}$

នាំឱ្យ $a=16$ , $b=-5$ , $c=19$

គេបាន $(P)$ : $16(x-1)-5(y-4)+19(z-3)=0$

ដូចនេះ $\boxed{(P):16x-5y+19z-53=0}$ ។

**គ. គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$**

តាមរូបមន្ត $S_{ABC}=\dfrac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AC}\right|$

ដោយ $\left|\overrightarrow{AB}\times\overrightarrow{AC}\right|=\sqrt{16^2+(-5)^2+19^2}=\sqrt{642}$

ដូចនេះ $\boxed{S_{ABC}=\dfrac{\sqrt{642}}{2}\ \text{ឯកតាផ្ទៃក្រឡា}}$ ។

**VI.** ក. កំណត់តម្លៃ $a$ និង $b$ :

គេមាន $f(x)=\ln(ax+b)$ មានខ្សែកោង $(C)$

ដោយ ខ្សែកោង $(C)$ កាត់អ័ក្សអាប់ស៊ីសត្រង់ $x=-1$

និងកាត់អ័ក្សអរដោនេត្រង់ $y=\ln 2$

គេបាន $\begin{cases} f(-1)=0 \\ f(0)=\ln 2 \end{cases}$ សមមូល $\begin{cases} \ln(-a+b)=0 \\ \ln b=\ln 2 \end{cases}$

នាំឱ្យ $\begin{cases} -a+b=1 \\ b=2 \end{cases} \Rightarrow \begin{cases} a=1 \\ b=2 \end{cases}$

ដូចនេះ កំណត់បាន $\boxed{a=1\,,\,b=2}$ ។

**ខ. សិក្សាអថេរភាព និងគូសខ្សែកោងតាងអនុគមន៍ $f$**

ចំពោះ $a=1\,,\,b=2$ នោះ $f(x)=\ln(x+2)$

• ដែនកំណត់ $x+2>0$ នោះ $x>-2$

នាំឱ្យ $D=(-2\,,+\infty)$

• លីមីត $\lim\limits_{x\to-2^+} f(x)=\lim\limits_{x\to-2^+}\ln(x+2)=-\infty$

$\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\ln(x+2)=+\infty$

• អាស៊ីមតូត ដោយ $\lim\limits_{x\to-2^+} f(x)=-\infty$ នោះបន្ទាត់ដែលមានសមីការ $x=-2$ ជាអាស៊ីមតូតឈរ ។

• ទិសដៅអថេរភាព : ដេរីវេ $f'(x)=\dfrac{1}{x+2}$

ចំពោះ $x>-2$ នោះ $f'(x)=\dfrac{1}{x+2}>0$

នាំឱ្យ $f$ ជាអនុគមន៍កើនលើចន្លោះ $D=(-2\,,+\infty)$

តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-2$ $\qquad$ $+\infty$ |
|---|---|
| $f'(x)$ | $+$ |
| $f(x)$ | $-\infty$ ↗ $+\infty$ |

• **សង់ក្រាប**




➢**គណនាផ្ទៃក្រឡាផ្នែកនៃប្លង់**

តាមក្រាប គេបានផ្ទៃក្រឡាផ្នែកប្លង់កំណត់ដោយ

$$S=-\int_{-3/2}^{-1} f(x)dx+\int_{-1}^{0} f(x)dx$$

$$=-\int_{-3/2}^{-1}\ln(x+2)dx+\int_{-1}^{0}\ln(x+2)dx$$

គណនា $\int\ln(x+2)dx$ តាមអាំងតេក្រាលដោយផ្នែក

គេតាង $u=\ln(x+2)\ \Rightarrow\ du=\dfrac{1}{x+2}dx$

$dv=dx\ \Rightarrow\ v=x$

តាមរូបមន្ត $\int udv=uv-\int vdu$

គេបាន $\int\ln(x+2)dx$

$$=x\ln(x+2)-\int\frac{x}{x+2}dx$$

$$=x\ln(x+2)-\int\frac{x+2-2}{x+2}dx$$

$$=x\ln(x+2)-\int\left(1-2\frac{1}{x+2}\right)dx$$

$$=x\ln(x+2)-x+2\ln(x+2)+c$$

$$=(x+2)\ln(x+2)-x+c$$

នាំឱ្យ $\int_{-3/2}^{-1}\ln(x+2)dx$

$$=\left[(x+2)\ln(x+2)-x\right]_{-3/2}^{-1}$$

$$=(0+1)-\left(\frac{1}{2}\ln\frac{1}{2}+\frac{3}{2}\right)=-\frac{1}{2}-\frac{1}{2}\ln\frac{1}{2}$$

ហើយ $\int_{-1}^{0}\ln(x+2)dx$

$$=\left[(x+2)\ln(x+2)-x\right]_{-1}^{0}$$

$$=(2\ln 2-0)-(0+1)=2\ln 2-1$$

$$S=-\left(-\frac{1}{2}-\frac{1}{2}\ln\frac{1}{2}\right)+(2\ln 2-1)$$

$$=\frac{1}{2}+\frac{1}{2}\ln\frac{1}{2}+2\ln 2-1$$

$$=\frac{1}{2}-\frac{1}{2}\ln 2+2\ln 2-1=\frac{3}{2}\ln 2-\frac{1}{2}$$

ដូចនេះ $\boxed{\text{ផ្ទៃក្រឡាផ្នែកប្លង់ } S=\dfrac{3\ln 2-1}{2} \text{ ឯកតាផ្ទៃ}}$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ...............................

លេខបន្ទប់ : ...............................

លេខតុ : ...............................

ហត្ថលេខា : ...............................

**ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ**

**សម័យប្រឡង : ១៦ តុលា ២០០៨**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. ដោះស្រាយសមីការ $\frac{x-1}{1991}+\frac{x-5}{1987}+\frac{x+7}{1999}+\frac{x-11}{1981}=4$ ។

ខ. ដោះស្រាយសមីការ $\ln\sqrt{x^2}=\sqrt{2\ln(-x)}$ ។

គ. ដោះស្រាយវិសមីការ $0<\frac{x^2-2x-3}{x-2}<4$ ។ **(១ពិន្ទុកន្លះ)**

**II.** គេឱ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\frac{5x^2+20x+6}{x^3+2x^2+x}$ ។

ក. កំណត់តម្លៃ $A, B, C$ ដើម្បីឱ្យ $f(x)=\frac{A}{x}+\frac{B}{x+1}+\frac{C}{(x+1)^2}$ ។

ខ. គណនា $F(x)=\int\frac{5x^2+20x+6}{x^3+2x^2+x}dx$ ។ **(២ពិន្ទុ)**

**III.** គេមានថង់ពីរ $A$ និង $B$ ។ ក្នុងថង់ $A$ មានប៊ូលពណ៌ស $1$ និងពណ៌ខ្មៅ $3$ ។ ក្នុងថង់ $B$ មានប៊ូលពណ៌ស $5$ និងពណ៌ខ្មៅ $3$ ។ គេទាញប៊ូលមួយពីថង់ $A$ និងប៊ូលមួយពីថង់ $B$ ហើយប្តូរគ្នា ។

ក. រកប្រូបាបដើម្បីឱ្យក្នុងថង់ $A$ មានតែប៊ូលពណ៌ខ្មៅបន្ទាប់ពីប្តូរគ្នា ។

ខ. រកប្រូបាបដើម្បីឱ្យពណ៌ប៊ូលនៅក្នុងថង់នីមួយៗនៅដដែលបន្ទាប់ពីប្តូរគ្នា ។ **(១ពិន្ទុកន្លះ)**

**IV.** ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''+4y'+4y=0$ ។

ខ. គេឱ្យសមីការឌីផេរ៉ង់ស្យែល $(F): y''+4y'+4y=-4x$ ។

កំណត់ចំនួនពិត $a$ និង $b$ ដើម្បីឱ្យ $x\mapsto ax+b$ ជាចម្លើយនៃ $(F)$ ។ **(១ពិន្ទុកន្លះ)**

**V.** ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់វិជ្ជមាន $(O,\vec{i},\vec{j},\vec{k})$ គេឱ្យបួនចំណុចគឺ $A(-2,0,1)$ , $B(0,10,3)$ , $C(2,0,-1)$ និង $D(5,3,-1)$ ។

ក. សរសេរសមីការប្លង់ $(P)$ ដែលកាត់តាមចំណុច $A, B$ និង $C$

ខ. សរសេរសមីការបន្ទាត់ដែលកាត់តាមចំណុច $D$ ហើយកែងនឹងប្លង់ $(P)$ ។

គ. សរសេរសមីការស្វ៊ែផ្ចិត $D$ ហើយប៉ះនឹងប្លង់ $(P)$ ។ **(១ពិន្ទុកន្លះ)**

**VI.** គេឱ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=3\sin x-2\sin^3 x$ ។

ក. សិក្សាអថេរភាព និងសង់ក្រាប $(C)$ នៃ $f$ ។

ខ. រកចំនួនពិត $a$ និង $b$ ដើម្បីឱ្យអនុគមន៍ $F$ កំណត់ដោយ $F(x)=a\cos x+b\cos^3 x$ ជាព្រីមីទីវនៃ $f$ ។ **(២ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
# ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ ២០០៨

**I.** **ក. ដោះស្រាយសមីការ :**

$$\frac{x-1}{1991}+\frac{x-5}{1987}+\frac{x+7}{1999}+\frac{x-11}{1981}=4$$

$$\frac{x-1}{1991}-1+\frac{x-5}{1987}-1+\frac{x+7}{1999}-1+\frac{x-11}{1981}-1=0$$

$$\frac{x-1992}{1991}+\frac{x-1992}{1987}+\frac{x-1992}{1999}+\frac{x-1992}{1981}=0$$

$$(x-1992)\left(\frac{1}{1991}+\frac{1}{1987}+\frac{1}{1999}+\frac{1}{1981}\right)=0$$

នាំឱ្យ $x-1992=0$ នោះ $x=1992$

ហើយ $\frac{1}{1991}+\frac{1}{1987}+\frac{1}{1999}+\frac{1}{1981}\neq 0$

ដូចនេះ សមីការមានឫស $\boxed{x=1992}$ ។

**ខ. ដោះស្រាយសមីការ**

សមីការ $\ln\sqrt{x^2}=\sqrt{2\ln(-x)}$ មានន័យលុះត្រាតែ

$$\begin{cases}x\neq 0\\ \ln(-x)\geq 0\\ -x>0\end{cases}\Leftrightarrow\begin{cases}x\neq 0\\ x\leq -1\\ x<0\end{cases}\Rightarrow x\leq -1$$

ចំពោះ $x\leq -1$ នោះ $\sqrt{x^2}=-x$

គេបាន $\ln(-x)=\sqrt{2\ln(-x)}$

គេតាង $t=\ln(-x)$

គេបាន $t=\sqrt{2t}$ សមមូល $t^2=2t$ ឬ $t(t-2)=0$

នាំឱ្យ $t=0\,,\,t=2$

គេបាន $\left[\begin{array}{l}\ln(-x)=0\\ \ln(-x)=2\end{array}\right.\Leftrightarrow\left[\begin{array}{l}-x=1\\ -x=e^2\end{array}\right.\Rightarrow\left[\begin{array}{l}x=-1\\ x=-e^2\end{array}\right.$

ដូចនេះ សមីការមានឫស $\boxed{x=-1\,,\ x=-e^2}$ ។

**គ. ដោះស្រាយវិសមីការ** $0<\frac{x^2-2x-3}{x-2}<4$

អាចសរសេរ $\begin{cases}\frac{x^2-2x-3}{x-2}>0\\ \frac{x^2-2x-3}{x-2}<4\end{cases}\Leftrightarrow\begin{cases}\frac{x^2-2x-3}{x-2}>0 & (1)\\ \frac{x^2-6x+5}{x-2}<0 & (2)\end{cases}$

កន្សោម $x^2-2x-3$ មានឫស $x=-1\,,\,x=3$

កន្សោម $x^2-6x+5$ មានឫស $x=1\,,\,x=5$

កន្សោម $x-2$ មានឫស $x=2$

ចម្លើយនៃប្រព័ន្ធវិសមីការ ជាតម្លៃនៃ $x$ បានពីប្រសព្វរវាងចម្លើយ $(1)$ និងចម្លើយ $(2)$ ។

តារាងសញ្ញា $(1)$

| $x$ | $-\infty$ | $-1$ | | $2$ | | $3$ | $+\infty$ |
|---|---|---|---|---|---|---|---|
| $x^2-2x-3$ | $+$ | $0$ | $-$ | | $-$ | $0$ | $+$ |
| $x-2$ | $-$ | | $-$ | $0$ | $+$ | | $+$ |
| $\frac{x^2-2x-3}{x-2}>0$ | $-$ | $0$ | $+$ | | $-$ | $0$ | $+$ |

ចម្លើយ $(1): x\in(-1\,,\,2)\cup(3\,,\,+\infty)$

តារាងសញ្ញា $(2)$

| $x$ | $-\infty$ | $1$ | | $2$ | | $5$ | $+\infty$ |
|---|---|---|---|---|---|---|---|
| $x^2-6x+5$ | $+$ | $0$ | $-$ | | $-$ | $0$ | $+$ |
| $x-2$ | $-$ | | $-$ | $0$ | $+$ | | $+$ |
| $\frac{x^2-6x+5}{x-2}<0$ | $-$ | $0$ | $+$ | | $-$ | $0$ | $+$ |

ចម្លើយ $(2): x\in(-\infty\,,\,1)\cup(2\,,\,5)$

ចម្លើយ $(1)$ :

ចម្លើយ $(2)$ :

ចម្លើយ




ដូចនេះ វិសមីការមានចម្លើយ $\boxed{x\in(-1\,,\,1)\cup(3\,,\,5)}$ ។

**II.** **ក. កំណត់តម្លៃ** $A\,,\,B\,,\,C$ :

គេមាន $f(x)=\frac{A}{x}+\frac{B}{x+1}+\frac{C}{(x+1)^2}$

$$=\frac{A(x+1)^2+Bx(x+1)+Cx}{x(x+1)^2}$$

$$=\frac{A(x^2+2x+1)+B(x^2+x)+Cx}{x(x^2+2x+1)}$$

$$=\frac{(A+B)x^2+(2A+B+C)x+A}{x^3+2x^2+x}$$

ផ្ទឹមនឹង $f(x)=\frac{5x^2+20x+6}{x^3+2x^2+x}$ នោះគេបាន ៖

$$\begin{cases} A+B=5 \\ 2A+B+C=20 \\ A=6 \end{cases} \Rightarrow \begin{cases} B=-1 \\ C=9 \\ A=6 \end{cases}$$

ដូចនេះ តម្លៃកំណត់បាន $\boxed{A=6\,,\,B=-1\,,\,C=9}$ ។

ខ. គណនា $F(x)=\int\frac{5x^2+20x+6}{x^3+2x^2+x}dx$

ចំពោះ $A=6\,,\,B=-1\,,\,C=9$ រកឃើញខាងលើ

គេបាន $f(x)=\frac{5x^2+20x+6}{x^3+2x^2+x}=\frac{6}{x}-\frac{1}{x+1}+\frac{9}{(x+1)^2}$

នាំឱ្យ $F(x)=\int\left(\frac{6}{x}-\frac{1}{x+1}+\frac{9}{(x+1)^2}\right)dx$

$=6\ln|x|-\ln|x+1|-\frac{9}{x+1}+c$ , $c$ ថេរ

**III.** ក. រកប្រូបាបដែលថង់ $A$ មានតែប៊ូលពណ៌ខ្មៅបន្ទាប់ពីប្តូរគ្នា

គេមាន ថង់ $A$ មានប៊ូលស $1$ និងខ្មៅ $3$

ថង់ $B$ មានប៊ូលស $5$ និងខ្មៅ $3$

ដើម្បីឱ្យ ថង់ $A$ មានតែប៊ូលពណ៌ខ្មៅបន្ទាប់ពីប្តូរគ្នា លុះត្រាតែចាប់បានប៊ូលពណ៌សពីថង់ $A$ និងប៊ូលពណ៌ខ្មៅពីថង់ $B$

គេបាន $P(\,A$ មានតែប៊ូលខ្មៅ$\,)=\frac{1}{4}\times\frac{3}{8}=\frac{3}{32}$

ដូចនេះ $\boxed{P(\,A \text{ មានតែប៊ូលខ្មៅ}\,)=\frac{3}{32}}$ ។

ខ. រកប្រូបាបពណ៌ប៊ូលក្នុងថង់នីមួយៗនៅដដែលបន្ទាប់ពីប្តូរគ្នា

ដើម្បីឱ្យពណ៌ប៊ូលនៅដដែលបន្ទាប់ពីប្តូរគ្នារួច គឺមានន័យថា ចាប់បានប៊ូលមានពណ៌ដូចគ្នា អាចជាសដូចគ្នា ឬខ្មៅដូចគ្នា

គេបាន $P(\,$សស ឬ ខខ$\,)=\left(\frac{1}{4}\times\frac{5}{8}\right)+\left(\frac{3}{4}\times\frac{3}{8}\right)=\frac{7}{16}$

ដូចនេះ $\boxed{P(\,\text{ប៊ូលនីមួយៗនៅដដែល}\,)=\frac{7}{16}}$ ។

**IV.** ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល :

គេមាន $(E): y''+4y'+4y=0$

សមីការសម្គាល់ $\lambda^2+4\lambda+4=0$

ឬ $(\lambda+2)^2=0$

មានឫសឌុប $\lambda_1=\lambda_2=\lambda_0=-2$

ចម្លើយទូទៅនៃ $(E)$ រាង $y=Axe^{\lambda_0x}+Be^{\lambda_0x}$ , $A\,,\,B$ ថេរ

ដូចនេះ ចម្លើយទូទៅគឺ $\boxed{y=Axe^{-2x}+Be^{-2x}}$ ។

ខ. កំណត់ចំនួនពិត $a$ និង $b$

តាង $f(x)=ax+b$ ជាចម្លើយនៃ $(F)$

នាំឱ្យ $f'(x)=a$ និង $f''(x)=0$

ដោយ $f$ ជាចម្លើយនៃ $(F): y''+4y'+4y=-4x$

គេបាន $f''+4f'+4f=-4x$

$0+4a+4(ax+b)=-4x$

$4ax+(4a+4b)=-4x+0$

ផ្ទឹមបាន $\begin{cases} 4a=-4 \\ 4a+4b=0 \end{cases} \Rightarrow \begin{cases} a=-1 \\ b=1 \end{cases}$

ដូចនេះ កំណត់បាន $\boxed{a=-1\,,\,b=1}$ ។

**V.** ក. សរសេរសមីការប្លង់ $(P)$

ប្លង់ត្រូវរករាង $(P): a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយ ប្លង់ $(P)$ កាត់ $A(-2\,,\,0\,,\,1)$

នោះ $x_0=-2\,,\,y_0=0\,,\,z_0=1$

ហើយ ប្លង់ $(P)$ កាត់បីចំណុច $A\,,\,B\,,\,C$ នោះ $(P)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$

គេមាន $\overrightarrow{AB}=(2\,,\,10\,,\,2)$ , $\overrightarrow{AC}=(4\,,\,0\,,\,-2)$

នាំឱ្យ $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 2 & 10 & 2 \\ 4 & 0 & -2 \end{vmatrix}=-20\vec{i}+12\vec{j}-40\vec{k}$

នោះ $a=-20\,,\,b=12\,,\,c=-40$

គេបាន $(P): -20(x+2)+12(y-0)-40(z-1)=0$

ដូចនេះ $\boxed{(P): 5x-3y+10z=0}$ ។

ខ. សរសេរសមីការបន្ទាត់កាត់តាម $D$ ហើយកែងនឹងប្លង់ $(P)$

សមីការបន្ទាត់ត្រូវរកតាង $(\ell): \begin{cases} x=x_0+at \\ y=y_0+bt\,,\,t\in\mathbb{R} \\ z=z_0+ct \end{cases}$

ដោយ $(\ell)$ កាត់តាម $D(5\,,\,3\,,\,-1)$

នោះ $x_0=5\,,\,y_0=3\,,\,z_0=-1$

ហើយ $(\ell)$ កែងនឹងប្លង់ $(P)$ នោះ $(\ell)$ មានវ៉ិចទ័រប្រាប់ទិសជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ គឺ $\vec{u}=(5\,,\,-3\,,\,10)$

នោះ $a=5\,,\,b=-3\,,\,c=10$

ដូចនេះ បន្ទាត់ត្រូវរករាង $\boxed{(\ell): \begin{cases} x=5+5t \\ y=3-3t \quad ,\,t\in\mathbb{R} \\ z=-1+10t \end{cases}}$ ។

**គ. សរសេរសមីការស្វ៊ែផ្ចិត $D$ ហើយប៉ះនឹងប្លង់ $(P)$**

ដោយស្វ៊ែ $(S)$ ប៉ះប្លង់ $(P)$ នោះកាំស្វ៊ែជាចម្ងាយពីផ្ចិតទៅប្លង់ $(P)$ នាំឱ្យ $R=d\left(D,(P)\right)=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$

ដោយ $D(5\,,3\,,-1)$ និង $(P):\ 5x-3y+10z=0$

$$R=\frac{|5\cdot 5-3\cdot 3+10(-1)|}{\sqrt{5^2+(-3)^2+10^2}}=\frac{|6|}{\sqrt{134}}\Rightarrow R^2=\frac{36}{134}=\frac{18}{67}$$

សមីការស្វ៊ែរាង $(S):(x-a)^2+(y-b)^2+(z-c)^2=R^2$

មានផ្ចិត $D(5\,,3\,,-1)$ នោះ $a=5\,,b=3\,,c=-1$

គេបាន $(S):(x-5)^2+(y-3)^2+(z+1)^2=\dfrac{18}{67}$

ដូចនេះ $\boxed{(S):(x-5)^2+(y-3)^2+(z+1)^2=\dfrac{18}{67}}$ ។

**VI. ក. សិក្សាអថេរភាព និងសង់ក្រាប $(C)$ នៃ $f$**

គេមាន $f(x)=3\sin x-2\sin^3 x$

• ដែនកំណត់ $D=\mathbb{R}$

• ខួបអនុគមន៍ $P=2\pi$ ព្រោះ $\forall x\in D$ គេបាន ៖

$$f(x+2\pi)=3\sin(x+2\pi)-2\sin^3(x+2\pi)$$
$$=3\sin x-2\sin^3 x=f(x)$$

• ភាពគូ-សេស : $f$ ជាអនុគមន៍ សេស ព្រោះ ៖

$$f(-x)=3\sin(-x)-2\sin^3(-x)$$
$$=-3\sin x+2\sin^3 x$$
$$=-\left(3\sin x-2\sin^3 x\right)=-f(x)$$

នាំឱ្យ ក្រាបតាងអនុគមន៍ $f$ មានគល់ $O$ ជាផ្ចិតឆ្លុះ

ហេតុនេះ គេសិក្សាតែក្នុងចន្លោះ $[0\,,\pi]$

• ទិសដៅអថេរភាព

ដេរីវេ $f'(x)=3\cos x-6\cos x\sin^2 x$

$$=3\cos x\left(1-2\sin^2 x\right)$$
$$=3\cos x\left(\cos^2 x+\sin^2 x-2\sin^2 x\right)$$
$$=3\cos x(\cos x-\sin x)(\cos x+\sin x)$$

គេឱ្យ $f'(x)=0$ ដើម្បីរកឫស

សមមូល $\left[\begin{array}{l}3\cos x=0\\ \cos x-\sin x=0\\ \cos x+\sin x=0\end{array}\right.\Rightarrow\left[\begin{array}{l}x=\pi/2\\ x=\pi/4\\ x=3\pi/4\end{array}\right.$

តារាងសញ្ញា $f'(x)$

| $x$ | $0$ | | $\frac{\pi}{4}$ | | $\frac{\pi}{2}$ | | $\frac{3\pi}{4}$ | | $\pi$ |
|---|---|---|---|---|---|---|---|---|---|
| $\cos x$ | | $+$ | | $+$ | $0$ | $-$ | | $-$ | |
| $\cos x-\sin x$ | | $+$ | $0$ | $-$ | | $-$ | | $-$ | |
| $\cos x+\sin x$ | | $+$ | | $+$ | | $+$ | $0$ | $-$ | |
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | $0$ | $-$ | |

-ត្រង់ $x=\pi/4\,,f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$ បញ្ជាក់ថា $f$ មានអតិបរមាស្មើ $f(\pi/4)=\sqrt{2}$

-ត្រង់ $x=\pi/2\,,f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$ បញ្ជាក់ថា $f$ មានអប្បបរមាស្មើ $f(\pi/2)=1$

-ត្រង់ $x=3\pi/4\,,f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$ បញ្ជាក់ថា $f$ មានអតិបរមាស្មើ $f(3\pi/4)=\sqrt{2}$

• តារាងអថេរភាព

| $x$ | $0$ | | $\frac{\pi}{4}$ | | $\frac{\pi}{2}$ | | $\frac{3\pi}{4}$ | | $\pi$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | $0$ | $-$ | |
| $f(x)$ | $0$ | $\nearrow$ | $\sqrt{2}$ | $\searrow$ | $1$ | $\nearrow$ | $\sqrt{2}$ | $\searrow$ | $0$ |

• សង់ក្រាប

ដំបូងសង់តែក្នុងចន្លោះ $[0\,,\pi]$ រួចសង់ក្រាបឆ្លុះធៀបគល់ $O$




**ខ. រកចំនួនពិត $a$ និង $b$**

បើ $F$ ជាព្រីមីទីវនៃ $f$ នោះគេបាន

$$F(x)=\int f(x)dx=\int\left(3\sin x-2\sin^3 x\right)dx$$
$$=\int\sin x\left(3-2\sin^2 x\right)dx=\int\sin x\left(1+2\cos^2 x\right)dx$$
$$=\int\sin x dx+2\int\sin x\cos^2 x dx$$
$$=-\cos x-2\int(\cos x)'\cos^2 x dx=-\cos x-\frac{2}{3}\cos^3 x$$

ផ្ទឹមនឹង $F(x)=a\cos x+b\cos^3 x$ នោះ $a=-1\,,b=-\dfrac{2}{3}$

ដូចនេះ រកបានចំនួនពិត $\boxed{a=-1\ ,\ b=-2/3}$ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ
## សម័យប្រឡង : ១៦ តុលា ២០០៧

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. កំណត់ចំនួនពិត $x$ និង $y$ ដើម្បីឱ្យ $2xi - y = \dfrac{(3-2i)(1+i)}{i(1+2i)}$ ។

ខ. គេឱ្យ $z = \cos\dfrac{2\pi}{9} + i\sin\dfrac{2\pi}{9}$ ។ សរសេរ $(1+z)^4$ ជាទម្រង់ត្រីកោណមាត្រ ។ **(១ពិន្ទុកន្លះ)**

**II.** ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): g''(x) - 5g'(x) + 6g(x) = 0$ ។

ខ. កំណត់ចម្លើយ $g(x)$ មួយនៃសមីការ $(E)$ ដែល $g(0) = 0$ និង $g'(0) = 1$ ។ **(១ពិន្ទុ)**

**III.** គេឱ្យអនុគមន៍ $f$ កំណត់ដោយ $f(x) = \dfrac{1-\cos 2x}{x^2}$ ចំពោះ $x \neq 0$ និង $f(0) = \ln(m-1)$ ។ គណនាលីមីត $f(x)$ កាលណា $x$ ខិតជិត $0$ ។ កំណត់តម្លៃនៃ $m$ ដើម្បីឱ្យ $f$ ជាអនុគមន៍ជាប់នៅត្រង់ $x = 0$ ។ **(១ពិន្ទុកន្លះ)**

**IV.** ក្នុងថង់មួយមានឃ្លី ស $3$ និងឃ្លីខ្មៅ $5$ ។ គេចាប់យកឃ្លីម្តង $3$ ចេញពីក្នុងថង់ ។ រកប្រូបាបដែលគេអាចចាប់យកបានឃ្លី ស $2$ និងឃ្លីខ្មៅ $1$ ។ **(១ពិន្ទុ)**

**V.** គេឱ្យអនុគមន៍ $g(x) = \dfrac{x^2 - 3x - 4}{x-2}$ មានក្រាប $(C)$ ។

ក. កំណត់ចំនួនពិត $a$ , $b$ , $c$ ដើម្បីឱ្យ $g(x) = ax + b + \dfrac{c}{x-2}$ ចំពោះ $x \neq 2$ ។

ខ. រកសមីការអាស៊ីមតូតឈរ និងទ្រេតនៃក្រាប $(C)$ ។

គ. បង្ហាញថាចំណុច $I(2\,,1)$ ជាផ្ចិតឆ្លុះនៃក្រាប $(C)$ ។ **(២ពិន្ទុកន្លះ)**

**VI.** ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(O\,,\vec{i}\,,\vec{j}\,,\vec{k})$ គេឱ្យប្លង់ $(P)$ និងស្វ៊ែ $(S)$ ដែលមានសមីការ $(P): x + 2y + 2z + 5 = 0$ , $(S):\ x^2 + y^2 + z^2 - 2x - 4y + 4z = 0$ ។

ក. កំណត់កូអរដោនេផ្ចិត និងប្រវែងកាំនៃស្វ៊ែ $(S)$ ។

ខ. បង្ហាញថាប្លង់ $(P)$ កាត់ស្វ៊ែ $(S)$ ។

គ. រកសមីការបណ្តាប្លង់ស្របនឹងប្លង់ $(P)$ ហើយប៉ះនឹងស្វ៊ែ $(S)$ ។ **(២ពិន្ទុកន្លះ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ២០០៧

**I.** ក. កំណត់ចំនួនពិត $x$ និង $y$ :

គេមាន $2xi - y = \dfrac{(3-2i)(1+i)}{i(1+2i)}$

$$= \frac{3+3i-2i-2i^2}{(i-2)} = \frac{5+i}{(i-2)}$$

$$= \frac{(5+i)(i+2)}{(i-2)(i+2)} = \frac{5i+10+i^2+2i}{-1-4}$$

$$= \frac{9+7i}{-5} = -\frac{9}{5} - \frac{7}{5}i$$

តាមនិយមន័យចំនួនកុំផ្លិចស្មើគ្នា គេបាន ៖

$$\begin{cases} 2x = -\dfrac{7}{5} \\ -y = -\dfrac{9}{5} \end{cases} \Rightarrow \begin{cases} x = -\dfrac{7}{10} \\ y = \dfrac{9}{5} \end{cases}$$

ដូចនេះ កំណត់បានចំនួនពិត $\boxed{x = -\dfrac{7}{10}\ ,\ y = \dfrac{9}{5}}$ ។

ខ. សរសេរ $(1+z)^4$ ជាទម្រង់ត្រីកោណមាត្រ

គេមាន $z = \cos\dfrac{2\pi}{9} + i\sin\dfrac{2\pi}{9}$

នោះ $1+z = 1+\cos\dfrac{2\pi}{9} + i\sin\dfrac{2\pi}{9}$

$$= 2\cos^2\frac{\pi}{9} + i2\sin\frac{\pi}{9}\cos\frac{\pi}{9}$$

$$= 2\cos\frac{\pi}{9}\left(\cos\frac{\pi}{9} + i\sin\frac{\pi}{9}\right)$$

នាំឱ្យ $(1+z)^4 = \left[2\cos\dfrac{\pi}{9}\left(\cos\dfrac{\pi}{9} + i\sin\dfrac{\pi}{9}\right)\right]^4$

$$(1+z)^4 = 16\cos^4\frac{\pi}{9}\left(\cos\frac{4\pi}{9} + i\sin\frac{4\pi}{9}\right)$$

ដូចនេះ $\boxed{(1+z)^4 = 16\cos^4\dfrac{\pi}{9}\left(\cos\dfrac{4\pi}{9} + i\sin\dfrac{4\pi}{9}\right)}$ ។

**II.** ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល :

គេមាន $(E): g''(x) - 5g'(x) + 6g(x) = 0$

សមីការសម្គាល់ $\lambda^2 - 5\lambda + 6 = 0$ មានឫស $\lambda = 2\ ,\ \lambda = 3$

ចម្លើយទូទៅនៃ $(E)$ រាង $y = Ae^{\lambda_1 x} + Be^{\lambda_2 x}$ , $A, B$ ថេរ

ដូចនេះ ចម្លើយទូទៅគឺ $\boxed{y = Ae^{2x} + Be^{3x}}$ ។

ខ. កំណត់ចម្លើយ $g(x)$ មួយនៃសមីការ $(E)$ ដែល

គេមាន $g(x) = Ae^{2x} + Be^{3x}$

នោះ: $g'(x) = 2Ae^{2x} + 3Be^{3x}$

ដោយ $\begin{cases} g(0) = 0 \\ g'(0) = 1 \end{cases} \Leftrightarrow \begin{cases} Ae^0 + Be^0 = 0 \\ 2Ae^0 + 3Be^0 = 1 \end{cases}$

$$\begin{cases} A + B = 0 \\ 2A + 3B = 1 \end{cases} \Bigg| \times(-2)$$

$$+\begin{cases} -2A - 2B = 0 \\ 2A + 3B = 1 \end{cases}$$

$$B = 1 \quad \Rightarrow \quad A = -1$$

ដូចនេះ ចម្លើយមួយគឺ $\boxed{g(x) = -e^{2x} + e^{3x}}$ ។

**III.** ➢គណនាលីមីត $f(x)$ កាលណា $x$ ខិតជិត $0$ :

គេមាន $f(x) = \dfrac{1-\cos 2x}{x^2}$ ចំពោះ $x \neq 0$

នាំឱ្យ $\lim\limits_{x\to 0} f(x) = \lim\limits_{x\to 0}\dfrac{1-\cos 2x}{x^2}$

$$= \lim_{x\to 0}\frac{2\sin^2 x}{x^2} = 2\times 1 = 2$$

ដូចនេះ គណនាបាន $\boxed{\lim\limits_{x\to 0} f(x) = 2}$ ។

➢ កំណត់តម្លៃ $m$ ដើម្បីឱ្យ $f$ ជាអនុគមន៍ជាប់ត្រង់ $x = 0$

$f$ ជាអនុគមន៍ជាប់ត្រង់ $x = 0$ លុះត្រាតែ $\lim\limits_{x\to 0} f(x) = f(0)$

ដោយ $\lim\limits_{x\to 0} f(x) = 2$ និង $f(0) = \ln(m-1)$

គេបាន $\ln(m-1) = 2$ ឬ $m - 1 = e^2$ នោះ: $m = e^2 + 1$

ដូចនេះ តម្លៃកំណត់បាន $\boxed{m = e^2 + 1}$ ។

**IV.** រកប្រូបាបដែលគេអាចចាប់យកបានឃ្លី ស $2$ និងឃ្លី ខ្មៅ $1$

គេមាន ឃ្លីស $3$ និងឃ្លីខ្មៅ $5$ ហើយគេចាប់យកឃ្លីម្តង $3$

នាំឱ្យ ចំនួនករណីអាច $n(s) = C(8\ ,\ 3) = \dfrac{8!}{3!\,5!} = 56$

ចំនួនករណីស្រប $n(A) = C(3,2)\times C(5,1) = 15$

គេបាន P( ស2 ,ខ1 ) $= \dfrac{n(A)}{n(S)} = \dfrac{15}{56}$

ដូចនេះ $\boxed{\text{ប្រូបាបគណនាបានគឺ P( ស2 ,ខ1 )} = \dfrac{15}{56}}$ ។

**V.** **ក. កំណត់ចំនួនពិត** $a , b , c$ :

គេមាន $g(x)=\dfrac{x^2-3x-4}{x-2}$ ចំពោះ $x\neq 2$

គេបាន $g(x)=x-1-\dfrac{6}{x-2}$ (បានពីចែកពហុធា)

ផ្ទឹមនឹង $g(x)=ax+b+\dfrac{c}{x-2}$ នោះគេទាញបាន

$a=1 , b=-1 , c=-6$

ដូចនេះ កំណត់បាន $\boxed{a=1 , b=-1 , c=-6}$ ។

**ខ. រកសមីការអាស៊ីមតូតឈរ និងទ្រេតនៃក្រាប** $(C)$

គេមាន $\lim\limits_{x\to 2^-} g(x)=\lim\limits_{x\to 2^-}\dfrac{x^2-3x-4}{x-2}=\dfrac{4-6-4}{2+0^- -2}=+\infty$

$\lim\limits_{x\to 2^+} g(x)=\lim\limits_{x\to 2^+}\dfrac{x^2-3x-4}{x-2}=\dfrac{4-6-4}{2+0^+ -2}=-\infty$

ដោយ $\lim\limits_{x\to 2} g(x)=\pm\infty$ នោះបន្ទាត់ដែលមានសមីការ

$x=2$ ជាអាស៊ីមតូតឈរ ។

ហើយ $g(x)=x-1-\dfrac{6}{x-2}$ និង $\lim\limits_{x\to\pm\infty}\left(-\dfrac{6}{x-2}\right)=0$

នោះបន្ទាត់ $y=x-1$ ជាអាស៊ីមតូតទ្រេត ។

**គ. បង្ហាញថាចំណុច** $I(2 , 1)$ **ជាផ្ចិតឆ្លុះនៃក្រាប** $(C)$

បើ $I(a , b)$ ជាផ្ចិតឆ្លុះនៃក្រាប $(C)$ តាងអនុគមន៍ $g$

លុះត្រាតែ $g(2a-x)+g(x)=2b$

ចំពោះ $I(2 , 1)$ គេនឹងបង្ហាញថា $g(4-x)+g(x)=2$

គេមាន $g(x)=x-1-\dfrac{6}{x-2}$

នាំឱ្យ $g(4-x)=(4-x)-1-\dfrac{6}{(4-x)-2}$

$=-x+3-\dfrac{6}{-x+2}$

$=-x+3+\dfrac{6}{x-2}$

គេបាន $g(4-x)+g(x)$

$=\left(-x+3+\dfrac{6}{x-2}\right)+\left(x-1-\dfrac{6}{x-2}\right)=2$

ដោយ $g(4-x)+g(x)=2$

ដូចនេះ $\boxed{\text{ចំណុច } I(2 , 1) \text{ ជាផ្ចិតឆ្លុះនៃក្រាប } (C)}$ ។

**VI.** **ក. កំណត់កូអរដោនេផ្ចិត និងប្រវែងកាំនៃស្វ៊ែ** $(S)$ :

គេមាន $(S): x^2+y^2+z^2-2x-4y+4z=0$

$(x^2-2x)+(y^2-4y)+(z^2+4z)=0$

$(x^2-2x+1)+(y^2-4y+4)+(z^2+4z+4)=9$

$(x-1)^2+(y-2)^2+(z+2)^2=3^2$

ទាញបាន $a=1 , b=2 , c=-2$ និងកាំ $r=3$

ដូចនេះ $\boxed{\begin{array}{l}\text{ស្វ៊ែ } (S) \text{ មានកូអរដោនេផ្ចិតតាង } I(1 , 2 , -2) \\ \text{និងប្រវែងកាំ } r=3 \text{ ឯកតាប្រវែង}\end{array}}$ ។

**ខ. បង្ហាញថាប្លង់** $(P)$ **កាត់ស្វ៊ែ** $(S)$

រកចម្ងាយពីផ្ចិតស្វ៊ែ ទៅប្លង់ $(P)$

តាមរូបមន្ត $d(I , (P))=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$

ដោយ $(P): x+2y+2z+5=0$ នោះ

$a=1 , b=2 , c=2$ និង $d=5$

ហើយ ផ្ចិត $I(1, 2,-2)$ នោះ $x_0=1 , y_0=2 , z_0=-2$

នាំឱ្យ $d(I , (P))=\dfrac{|1\cdot 1+2\cdot 2+2(-2)+5|}{\sqrt{1^2+2^2+2^2}}=\dfrac{|6|}{3}=2$

ដោយ $d(I, (P))=2<r=3$ នោះប្លង់ $(P)$ កាត់ស្វ៊ែ $(S)$

ដូចនេះ $\boxed{\text{ប្លង់ } (P) \text{ កាត់ស្វ៊ែ } (S)}$ ។

**គ. រកសមីការបណ្តាប្លង់ស្របនឹងប្លង់** $(P)$ **ហើយប៉ះនឹងស្វ៊ែ**$(S)$

តាង $(\alpha): ax+by+cz+d=0$ ជាបណ្តាសមីការប្លង់ត្រូវរក

ដោយ $(\alpha)\|(P)$ នោះ $(\alpha)$ មានវ៉ិចទ័រណរម៉ាល់ដូចប្លង់ $(P)$

គេបាន $(\alpha): x+2y+2z+d=0$

តែ $(\alpha)$ ប៉ះ $(S)$ មានន័យថា $d(I,(\alpha))=r=3$

គេបាន $\dfrac{|x_I+2y_I+2z_I+d|}{\sqrt{1^2+2^2+2^2}}=3$ ដែល $I(1 , 2 , -2)$

$\dfrac{|1+2\cdot 2+2(-2)+d|}{\sqrt{1^2+2^2+2^2}}=3$

$|1+d|=9$ នោះ $1+d=\pm 9$ នោះ $d=\left[\begin{array}{l}-10\\ 8\end{array}\right.$

ដូចនេះ បណ្តាប្លង់ស្របនឹងប្លង់ $(P)$ ហើយប៉ះនឹងស្វ៊ែ$(S)$ មាន

$\boxed{x+2y+2z-10=0 , \ x+2y+2z+8=0}$ ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ

**សម័យប្រឡង : ១៣ តុលា ២០០៦**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. ដោះស្រាយវិសមីការ $2^x + 2^{3-x} \leq 9$ ។

ខ. ស្រាយបញ្ជាក់ថា ចំពោះគ្រប់តម្លៃ $x$ , $y$ គេបាន : $x^2\left(1+\sin^2 y\right)+2x\left(\sin y+\cos y\right)+1+\cos^2 y>0$ ។ **(១ពិន្ទុកន្លះ)**

**II.** កំណត់តម្លៃនៃ $m$ ដើម្បីឱ្យសមីការ $(m+1)x^2-2mx+4(m+1)=0$ មានឫសដែលធំជាងគេនៅចន្លោះ $(-1\,,1)$ ។ **(១ពិន្ទុ)**

**III.** ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): 2y''-3y'+y=0$ ។

ខ. កំណត់ចម្លើយ $g(x)$ មួយរបស់សមីការ $(E)$ ដើម្បីឱ្យក្រាបតាងអនុគមន៍ $g$ ប៉ះនឹងបន្ទាត់ $(d)$ សមីការ $y=-\dfrac{1}{2}x$

នៅត្រង់ចំណុច $O(0\,,0)$ ។ **(១ពិន្ទុកន្លះ)**

**IV.** កោណមួយមានកម្ពស់ $15\text{cm}$ និងកាំបាត $6\text{cm}$ ។ រកកម្ពស់ និងកាំបាតនៃស៊ីឡាំងចារឹកក្នុងកោណនេះ ដើម្បីឱ្យវាមានមាឌអតិបរមា ។ **(១ពិន្ទុកន្លះ)**

**V.** ក្នុងតម្រុយអរតូណរម៉ាល់ ដែលមានទិសដៅវិជ្ជមាន $\left(O\,,\vec{i}\,,\vec{j}\,,\vec{k}\right)$ គេមានចំណុច $A(1\,,1\,,0)$ , $B(0,\,2\,,2)$ , $C(1,-2,\,3)$ និង $D(1\,,-2\,,0)$ ។ រកសមីការស្វ៊ែដែលកាត់តាមបួនចំណុច $A$ , $B$ , $C$ និង $D$ ។ **(១ពិន្ទុកន្លះ)**

**VI.** អនុគមន៍ $f$ កំណត់ដោយ $f(x)=(ax+1)^2$ ចំពោះ $x<2$ និង $f(x)=-ax$ ចំពោះ $x\geq 2$ ។

ចូររកតម្លៃនៃ $a$ ដើម្បីឱ្យ $f$ ជាអនុគមន៍ជាប់នៅត្រង់ $x=2$ ។ **(១ពិន្ទុ)**

**VII.** អនុគមន៍ $f$ កំណត់លើ $D=[2\,,+\infty)$ ដែល $f(x)=\dfrac{x^2-4x+4}{(2x-3)(x-1)^2}$ ។

ក. គណនា $a\,,b$ ដែល $f(x)=\dfrac{a}{(x-1)^2}+\dfrac{b}{(2x-3)}$ ។

ខ. រកព្រីមីទីវនៃអនុគមន៍ $g(x)=\dfrac{-1}{(x-1)^2}$ , $h(x)=\dfrac{1}{2x-3}$ ។

គ. ទាញរក $I=\int_2^3 f(x)\,dx$ ។ **(២ពិន្ទុ)**

## ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ២០០៦

**I.** **ក. ដោះស្រាយវិសមីការ**

គេមាន $2^x+2^{3-x}\le 9$

$2^x+\frac{8}{2^x}-9\le 0$

គេតាង $t=2^x$ ដែល $t>0$

គេបាន $t+\frac{8}{t}-9\le 0$ គុណនឹង $t$ មិនប្តូរទិសដៅ)

$t^2-9t+8\le 0$

ឱ្យ $t^2-9t+8=0$ តាមករណីពិសេស $t=1$ , $t=8$

តារាងសញ្ញា

| $t$ | $0$ | $1$ | | $8$ | $+\infty$ |
|---|---|---|---|---|---|
| $t^2-9t+8\le 0$ | $+$ | $0$ | $-$ | $0$ | $+$ |

តាមតារាង $1\le t\le 8$ សមមូល $1\le 2^x\le 8$

ឬ $2^0\le 2^x\le 2^3$ នាំឱ្យ $0\le x\le 3$

ដូចនេះ វិសមីការមានចម្លើយ $\boxed{0\le x\le 3}$ ។

**ខ. ស្រាយបញ្ជាក់ថា ចំពោះគ្រប់តម្លៃ $x$ , $y$ គេបាន $f(x)>0$**

$f(x)=x^2(1+\sin^2 y)+2x(\sin y+\cos y)+1+\cos^2 y$

មាន $\Delta'=(\sin y+\cos y)^2-(1+\sin^2 y)(1+\cos^2 y)$

$=\sin^2 y+2\sin y\cos y+\cos^2 y$

$-(1+\cos^2 y+\sin^2 y+\sin^2 y\cos^2 y)$

$=2\sin y\cos y-1-\sin^2 y\cos^2 y$

$=-(1-\sin y\cos y)^2$

ដោយ $\forall y\in\mathbb{R}$ , $\sin y\cos y\ne 1$

នោះ $\Delta'=-(1-\sin y\cos y)^2<0$ , $\forall y\in\mathbb{R}$

គេបាន កន្សោមមាន $\begin{cases}\Delta'<0\\ a=1+\sin^2 y>0\end{cases}$ នាំឱ្យ $f(x)>0$

ដូចនេះ $\boxed{x^2(1+\sin^2 y)+2x(\sin y+\cos y)+1+\cos^2 y>0}$

**II.** **កំណត់តម្លៃនៃ $m$**

គេមាន $(m+1)x^2-2mx+4(m+1)=0$

គេតាង $f(x)=(m+1)x^2-2mx+4(m+1)$

ដោយ សមីការមានឫសដែលធំជាងគេនៅចន្លោះ $(-1\,,1)$

លុះត្រាតែ $f(-1)\times f(1)<0$

ដោយ $f(-1)=(m+1)(-1)^2-2m(-1)+4(m+1)$

$=m+1+2m+4m+4=7m+5$

$f(1)=(m+1)(1)^2-2m(1)+4(m+1)$

$=m+1-2m+4m+4=3m+5$

គេបាន $(7m+5)(3m+5)<0$ (ជាត្រីធាដឺក្រេទី២)

គេឱ្យ $(7m+5)(3m+5)=0$ នោះ $m=-\frac{5}{7}$ , $m=-\frac{5}{3}$

តារាងសញ្ញា

| $t$ | $-\infty$ | $-\frac{5}{3}$ | | $-\frac{5}{7}$ | $+\infty$ |
|---|---|---|---|---|---|
| $(7m+5)(3m+5)<0$ | $+$ | $0$ | $-$ | $0$ | $+$ |

ដូចនេះ តម្លៃកំណត់បាន $\boxed{m\in\left(-\frac{5}{3}\,,-\frac{5}{7}\right)}$ ។

**III.** **ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល**

គេមាន $(E):\ 2y''-3y'+y=0$

សមីការសម្គាល់ $2\lambda^2-3\lambda+1=0$ តាមករណីពិសេស

សមីការមានឫស $\lambda=1$ , $\lambda=\frac{1}{2}$

ចម្លើយទូទៅនៃ $(E)$ គឺ $g(x)=Ae^{\lambda_1 x}+Be^{\lambda_2 x}$ , $A$ , $B$ ថេរ

ដូចនេះ សមីការមានចម្លើយ $\boxed{g(x)=Ae^x+Be^{\frac{1}{2}x}}$ ។

**ខ. កំណត់ចម្លើយ $g(x)$ មួយរបស់សមីការ $(E)$**

គេមាន $g(x)=Ae^x+Be^{\frac{1}{2}x}$ នោះ $g'(x)=Ae^x+\frac{B}{2}e^{\frac{1}{2}x}$

ដើម្បីឱ្យក្រាបតាងអនុគមន៍ $g$ ប៉ះនឹងបន្ទាត់ $(d)$ សមីការ

$y=-\frac{1}{2}x$ នៅត្រង់ចំណុច $O(0\,,0)$ លុះត្រាតែ

$\begin{cases}g'(0)=-\frac{1}{2}\\ g(0)=0\end{cases}\Leftrightarrow\begin{cases}Ae^0+\frac{B}{2}e^0=-\frac{1}{2}\\ Ae^0+Be^0=0\end{cases}\Rightarrow\begin{cases}B=1\\ A=-1\end{cases}$

ដូចនេះ ចម្លើយមួយនៃ $(E)$ គឺ $\boxed{g(x)=-e^x+e^{\frac{1}{2}x}}$ ។

**IV. រកកម្ពស់ និងកាំបាតនៃស៊ីឡាំងចារឹកក្នុងកោណនេះ**

តាង $h$ និង $r$ ជាកម្ពស់ និងកាំនៃស៊ីឡាំង (គិតជា cm)

នាំឱ្យមាឌនៃស៊ីឡាំង $V=\pi r^2 h$




ដោយ $\Delta ABC$ និង $\Delta SBO$ ជាត្រីកោណកែងមាន

$\angle B$ ជាមុំរួម នោះ $\Delta ABC \sim \Delta SBO$ (ម.ម)

វិបាក $\frac{AC}{SO}=\frac{BC}{BO}$ ឬ $\frac{h}{15}=\frac{6-r}{6}$ នោះ $h=\frac{5}{2}(6-r)$

គេបាន $V(r)=\pi r^2\times\frac{5}{2}(6-r)=\frac{5\pi}{2}(6r^2-r^3)$

$V'(r)=\frac{5\pi}{2}(12r-3r^2)$

$V''(r)=\frac{5\pi}{2}(12-6r)$

ដើម្បីឱ្យ $V$ មានតម្លៃអតិបរមា លុះត្រាតែ $\begin{cases}V(r)=0\\ V''(r)<0\end{cases}$

គេបាន $\frac{5\pi}{2}(12r-3r^2)=0$ ឬ $r(12-3r)=0$

នាំឱ្យ $r=0$ មិនយក , $r=4\text{cm}$ យក

គេបាន $V''(4)=\frac{5\pi}{2}(12-6\cdot 4)=-30\pi<0$ ពិត

$h=\frac{5}{2}(6-r)=\frac{5}{2}(6-4)=5\text{cm}$

ដូចនេះ គណនាបាន $\boxed{r=4\text{cm}\ ,\ h=5\text{cm}}$ ។

**V. រកសមីការស្វ៊ែដែលកាត់តាមបួនចំណុច (ដូចគ្រូបឋម 2011)**

គេមាន $A(1,1,0)$, $B(0,2,2)$,

$C(1,-2,3)$ និង $D(1,-2,0)$

សមីការស្វ៊ែរាង $(S):(x-a)^2+(y-b)^2+(z-c)^2=r^2$

$(S)\cap A$ គេបាន $(1-a)^2+(1-b)^2+c^2=r^2$ (1)

$(S)\cap B$ គេបាន $a^2+(2-b)^2+(2-c)^2=r^2$ (2)

$(S)\cap C$ គេបាន $(1-a)^2+(-2-b)^2+(3-c)^2=r^2$ (3)

$(S)\cap D$ គេបាន $(1-a)^2+(-2-b)^2+c^2=r^2$ (4)

គេយក $(3)-(4)$ គេបាន $(3-c)^2-c^2=0$

$(3-c-c)(3-c+c)=0 \Rightarrow c=\frac{3}{2}$

គេយក $(1)-(4)$ គេបាន $(1-b)^2-(-2-b)^2=0$

$(1-b+2+b)(1-b-2-b)=0 \Rightarrow b=-\frac{1}{2}$

តាម$(2)$ $a^2+\left(2+\frac{1}{2}\right)^2+\left(2-\frac{3}{2}\right)^2=r^2$

$a^2+\frac{25}{4}+\frac{1}{4}=r^2$ នោះ $a^2+\frac{13}{2}=r^2$ (5)

តាម$(1)$ $(1-a)^2+\left(1+\frac{1}{2}\right)^2+\left(\frac{3}{2}\right)^2=r^2$

$1-2a+a^2+\frac{9}{4}+\frac{9}{4}=r^2$

$-2a+a^2+\frac{11}{2}=r^2$ (6)

យក $(5)-(6)$ $2a+1=0$ នាំឱ្យ $a=-\frac{1}{2}$

តាម $(5)$ $\left(-\frac{1}{2}\right)^2+\frac{13}{2}=r^2 \Leftrightarrow r^2=\frac{27}{4}$

ដូចនេះ $\boxed{(S):\left(x+\frac{1}{2}\right)^2+\left(y+\frac{1}{2}\right)^2+\left(z-\frac{3}{2}\right)^2=\frac{27}{4}}$ ។

**VI. រកតម្លៃនៃ $a$ ដើម្បីឱ្យ $f$ ជាអនុគមន៍ជាប់នៅត្រង់ $x=2$**

គេមាន $f(x)=\begin{cases}(ax+1)^2 & \text{ចំពោះ } x<2\\ -ax & \text{ចំពោះ } x\geq 2\end{cases}$

ដើម្បីឱ្យ អនុគមន៍ $f$ ជាប់ត្រង់ $x=2$ លុះត្រាតែវាផ្ទៀងផ្ទាត់

$\lim_{x\to 2^-} f(x)=\lim_{x\to 2^+} f(x)=f(2)$

ដោយ $\lim_{x\to 2^-} f(x)=\lim_{x\to 2^-}(ax+1)^2=(2a+1)^2$

$\lim_{x\to 2^+}(-ax)=-2a$

$f(2)=-2\cdot a=-2a$

គេបាន $(2a+1)^2=-2a$

$4a^2+4a+1=-2a$

$4a^2+6a+1=0$

$\Delta'=3^2-4=5$ នោះ $a=\frac{-3\pm\sqrt{5}}{4}$

ដូចនេះ តម្លៃកំណត់បានគឺ $\boxed{a=\frac{-3\pm\sqrt{5}}{4}}$ ។

**VII.ក. គណនា** $a$ , $b$

គេមាន $f(x)=\dfrac{x^2-4x+4}{(2x-3)(x-1)^2}$ និង

$$f(x)=\frac{a}{(x-1)^2}+\frac{b}{(2x-3)}$$
$$=\frac{a(2x-3)+b(x-1)^2}{(2x-3)(x-1)^2}$$
$$=\frac{2ax-3a+bx^2-2bx+b}{(2x-3)(x-1)^2}$$
$$=\frac{bx^2+(2a-2b)x+(-3a+b)}{(2x-3)(x-1)^2}$$

ដោយផ្ទឹមមេគុណត្រូវគ្នានៃអថេរ $x$

គេបាន $\begin{cases}b=1\\2a-2b=-4\\-3a+b=4\end{cases}\Rightarrow\begin{cases}b=1\\a=-1\end{cases}$

ដូចនេះ គណនាបាន $\boxed{a=-1\,,\,b=1}$ ។

**ខ. រកព្រីមីទីវនៃអនុគមន៍** $g(x)$ **និង** $h(x)$

គេមាន $g(x)=\dfrac{-1}{(x-1)^2}$ , $h(x)=\dfrac{1}{2x-3}$

គេតាង $G(x)$ , $H(x)$ ជាព្រីមីទីវរៀងគ្នានៃ $g(x)$ , $h(x)$

គេបាន $G(x)=\int g(x)dx$

$$=\int\frac{-1}{(x-1)^2}dx$$
$$=\int\frac{-(x-1)'}{(x-1)^2}dx=\frac{1}{x-1}+c_1\ ,\ c_1 \text{ ថេរ}$$

$$H(x)=\int h(x)dx$$
$$=\int\frac{1}{2x-3}dx$$
$$=\frac{1}{2}\ln|2x-3|+c_2\ ,\ c_2 \text{ ថេរ}$$

ដូចនេះ ព្រីមីទីវរៀងគ្នានៃ $g(x)$ និង $h(x)$ គឺ ៖

$$\boxed{G(x)=\frac{1}{x-1}+c_1\ ,\ H(x)=\frac{1}{2}\ln|2x-3|+c_2}$$ ។

**គ. ទាញរក** $I=\int_2^3 f(x)dx$

$$I=\int_2^3 f(x)dx=\int_2^3\left(\frac{-1}{(x-1)^2}+\frac{1}{(2x-3)}\right)dx$$
$$=\int_2^3\frac{-1}{(x-1)^2}dx+\int_2^3\frac{1}{(2x-3)}dx$$
$$=\left[\frac{1}{x-1}\right]_2^3+\left[\frac{1}{2}\ln|2x-3|\right]_2^3$$
$$=\left(\frac{1}{2}-1\right)+\frac{1}{2}(\ln 3-\ln 1)$$
$$=-\frac{1}{2}+\frac{\ln 3}{2}$$

ដូចនេះ ទាញរកបាន $\boxed{I=\dfrac{\ln 3}{2}-\dfrac{1}{2}}$ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ**

**សម័យប្រឡង : ០៣ វិច្ឆិកា ២០០៥**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. សរសេរចំនួនកុំផ្លិចជាទម្រង់ត្រីកោណមាត្រ $-2-2i$ ។

ខ. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច $(2+i)x^2-(5-i)x+2-2i=0$ ។ **(១ពិន្ទុកន្លះ)**

**II.** ក. គណនាអាំងតេក្រាលមិនកំណត់ $I=\int(2\sin x+3\cos x)dx$ , $J=\int\frac{dx}{x^2-5x+6}$ ។

ខ. រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f(x)=x^2-e^x$ ដែល $F(0)=1$ ។ **(១ពិន្ទុកន្លះ)**

**III.** ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''-3y'+2y=0$ ។

ខ. រកចម្លើយនៃសមីការ $(E)$ បើគេដឹងថាអនុគមន៍ចម្លើយមានអតិបរមាស្មើនឹង $1$ ត្រង់ $x=1$ ។ **(១ពិន្ទុកន្លះ)**

**IV.** សរសេរសមីការនៃប្លង់ $(P)$ ដែលកាត់តាមចំណុច $M(1,2,-3)$ និងស្របជាមួយប្លង់ $(Q): 2x-4y-z+4=0$ រួចគណនាចម្ងាយរវាងប្លង់ទាំងពីរ ។ **(១ពិន្ទុ)**

**V.** គេមានតួលេខ $0,1,2,3,4$ ។ ដោយគ្រាន់តែប្រើតួលេខទាំងនេះ តើគេអាចបង្កើតចំនួនបានប៉ុន្មាន ដែលធំជាង $2000$ ?
( បញ្ជាក់ : ក្នុងចំនួននីមួយៗគ្មានតួលេខដដែលពីរដងទេ ) **(១ពិន្ទុកន្លះ)**

**VI.** គេឱ្យអនុគមន៍ $f(x)=ae^x+b$ មានខ្សែកោង $(C)$ ។

ក. កំណត់តម្លៃនៃ $a$ និង $b$ ដើម្បីឱ្យខ្សែកោង $(C)$ កាត់តាមគល់ $O$ នៃតម្រុយអរតូណរមេ និងបន្ទាត់ប៉ះខ្សែកោង $(C)$ ត្រង់ចំណុចនេះ ជាបន្ទាត់ពុះទី១ ។

ខ. សិក្សាអថេរភាព និងគូសខ្សែកោង $(C)$ តាងអនុគមន៍ $f$ ចំពោះតម្លៃនៃ $a$ និង $b$ ដែលរកឃើញ ។

គ. គណនាផ្ទៃក្រឡានៃផ្នែកប្លង់ ដែលខណ្ឌដោយខ្សែកោង $(C)$ អ័ក្ស $x'Ox$ បន្ទាត់ $x=-1$ និង $x=1$ ។ **(៣ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ២០០៥

**I.** ក. សរសេរចំនួនកុំផ្លិចជាទម្រង់ត្រីកោណមាត្រ $-2-2i$

គេមាន $-2-2i$ (មាន $r=\sqrt{(-2)^2+(-2)^2}=2\sqrt{2}$ )

$$=2\sqrt{2}\left(-\frac{2}{2\sqrt{2}}-\frac{2}{2\sqrt{2}}i\right)=2\sqrt{2}\left(-\frac{\sqrt{2}}{2}-\frac{\sqrt{2}}{2}i\right)$$

$$=2\sqrt{2}\left(\cos\frac{5\pi}{4}+\sin\frac{5\pi}{4}i\right)$$

ដូចនេះ $\boxed{-2-2i=2\sqrt{2}\left(\cos\frac{5\pi}{4}+\sin\frac{5\pi}{4}i\right)}$ ។

ខ. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច

គេមាន $(2+i)x^2-(5-i)x+2-2i=0$

$$\Delta=\left[-(5-i)\right]^2-4(2+i)(2-2i)$$

$$=25-10i+i^2-4\left(4-4i+2i-2i^2\right)$$

$$=25-10i-1-24+8i=-2i$$

ដោយ $2i=1-2i-1=1-2i+i^2=(1-i)^2$

នាំឱ្យ $x=\dfrac{5-i\pm(1-i)}{2(2+i)}=\left[\begin{array}{l}\dfrac{2}{2+i}\\ \dfrac{3-i}{2+i}\end{array}\right.\Rightarrow x=\left[\begin{array}{l}\dfrac{4}{5}-\dfrac{2}{5}i\\ \dfrac{7}{5}-\dfrac{2}{5}i\end{array}\right.$

ដូចនេះ សមីការមានឫស $\boxed{x=\frac{4}{5}-\frac{2}{5}i\ ,\ x=\frac{7}{5}-\frac{2}{5}i}$ ។

**II.** ក. គណនាអាំងតេក្រាលមិនកំណត់

$$\mathbf{I}=\int(2\sin x+3\cos x)dx$$

$$=2\int\sin xdx+3\int\cos xdx$$

$$=-2\cos x+3\sin x+c$$

ដូចនេះ $\boxed{\mathbf{I}=-2\cos x+3\sin x+c}$ , $c$ ជាចំនួនថេរ ។

$$\mathbf{J}=\int\frac{dx}{x^2-5x+6}=\int\frac{dx}{(x-2)(x-3)}$$

$$=\int\frac{(x-2)-(x-3)}{(x-2)(x-3)}dx$$

$$=\int\frac{1}{(x-3)}dx-\int\frac{1}{(x-2)}dx$$

$$=\ln|x-3|-\ln|x-2|+c=\ln\left|\frac{x-3}{x-2}\right|+c$$

ដូចនេះ $\boxed{\mathbf{J}=\ln\left|\frac{x-3}{x-2}\right|+c}$ , $c$ ជាចំនួនថេរ ។ (គ្រូប-០៥)

ខ. រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f(x)$

គេមាន $F(x)$ ជាព្រីមីទីវនៃអនុគមន៍ $f(x)$

គេបាន $F(x)=\int f(x)dx=\int\left(x^2-e^x\right)dx$

$$=\frac{x^3}{3}-e^x+c$$

ដោយ $F(0)=1$ សមមូល $\frac{0^3}{3}-e^0+c=1\Rightarrow c=2$

ដូចនេះ ព្រីមីទីវគណនាបាន $\boxed{F(x)=\frac{x^3}{3}-e^x+2}$ ។

**III.** ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E)$

គេមាន $(E):\ y''-3y'+2y=0$

សមីការសម្គាល់គឺ $\lambda^2-3\lambda+2=0$ មាន $a+b+c=0$

តាមករណីពិសេសសមីការមានឫស $\lambda_1=1\ ,\ \lambda_2=2$

ចម្លើយទូទៅនៃ $(E)$: $y=Ae^{\lambda_1x}+Be^{\lambda_2x}$ , $A\ ,\ B$ ថេរ

ដូចនេះ $\boxed{y=Ae^x+Be^{2x}\text{ ជាចម្លើយទូទៅនៃ }(E)}$ ។

ខ. រកចម្លើយពិសេសនៃសមីការ $(E)$

ដោយ $y=Ae^x+Be^{2x}$ នោះ $y'=Ae^x+2Be^{2x}$

គេដឹងថា អនុគមន៍ចម្លើយមានអតិបរមាស្មើនឹង 1 ត្រង់ $x=1$

គេបាន $\begin{cases}y'(1)=0\\ y(1)=1\end{cases}\Leftrightarrow\begin{cases}Ae+2Be^2=0\\ Ae+Be^2=1\end{cases}\Rightarrow\begin{cases}B=-\dfrac{1}{e^2}\\ A=\dfrac{2}{e}\end{cases}$

នាំឱ្យ $y=\frac{2}{e}e^x-\frac{1}{e^2}e^{2x}=2e^{x-1}-e^{2x-2}$

ដូចនេះ: $(E)$ មានចម្លើយពិសេស $\boxed{y=2e^{x-1}-e^{2x-2}}$ ។

**IV.** ➢សរសេរសមីការនៃប្លង់ $(P)$

សមីការប្លង់ $(P): a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយ $(P)$ កាត់តាមចំណុច $M(1\ ,2\ ,-3)$

នោះ: $x_0=1\ ,\ y_0=2\ ,\ z_0=-3$

និង $(P)\parallel(Q): 2x-4y-z+4=0$ នាំឱ្យ $(P)$

មានវ៉ិចទ័រណរម៉ាល់ $\vec{n}=(2,-4,-1)$

នោះ: $a=2\ ,\ b=-4\ ,\ c=-1$

ដូចនេះ: $\boxed{(P): 2(x-1)-4(y-2)-(z+3)=0}$ ។

➢គណនាចម្ងាយរវាងប្លង់ទាំងពីរ

**របៀបទី១** តាមរូបមន្ត $d\left((P),(Q)\right)=\dfrac{|d_1-d_2|}{\sqrt{a^2+b^2+c^2}}$

ដោយ $(P):2(x-1)-4(y-2)-(z+3)=0$

$2x-4y-z+3=0$ នោះ $d_1=3$

$(Q):2x-4y-z+4=0$ នោះ $d_2=4$

នាំឱ្យ $d\left((P),(Q)\right)=\dfrac{|d_1-d_2|}{\sqrt{a^2+b^2+c^2}}$

$=\dfrac{|3-4|}{\sqrt{2^2+(-4)^2+(-1)^2}}=\dfrac{1}{\sqrt{21}}=\dfrac{\sqrt{21}}{21}$

ដូចនេះ ចម្ងាយប្លង់ទាំងពីរគឺ $d=\dfrac{\sqrt{21}}{21}$ ឯកតាប្រវែង ។

**របៀបទី២** យកចំណុច $A(x,y,z)\in(P)$

គេយក $x=y=0$ ជំនួសក្នុង $(P)$ ដើម្បីរក $z$

$(P):2(0-1)-4(0-2)-(z+3)=0$

$-2+8-z-3=0$ នោះ $z=3$

គេបាន $A(0,0,3)\in(P)$

ដោយ $d\left((P),(Q)\right)=d\left(A,(Q)\right)$

តែ $d\left(A,(Q)\right)=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$

ដោយ $A(0,0,3)\Rightarrow x_0=y_0=0\,,\ z_0=3$

$(Q):2x-4y-z+4=0$ នោះ

$a=2\,,\ b=-4\,,\ c=-1$

$d\left(A,(Q)\right)=\dfrac{|0+0-3+4|}{\sqrt{2^2+(-4)^2+(-1)^2}}=\dfrac{\sqrt{21}}{21}$

ដូចនេះ ចម្ងាយប្លង់ទាំងពីរគឺ $d=\dfrac{\sqrt{21}}{21}$ ឯកតាប្រវែង ។

**V. តើគេអាចបង្កើតចំនួនបានប៉ុន្មានដែលធំជាង 2000 ?**(គ្រប.០៥)

ដោយលេខតាមខ្ទង់ដែលត្រូវប្រើមាន៥លេខ $0,1,2,3,4$ នោះចំនួនដែលធំជាង 2000 អាចជាលេខ 4 ខ្ទង់ ឬ 5 ខ្ទង់

• ចំពោះលេខ 4 ខ្ទង់ដែលធំជាង 2000 គឺ

ខ្ទង់ពាន់ មាន 3 ជម្រើស

ខ្ទង់រយ មាន 4 ជម្រើស

ខ្ទង់ដប់ មាន 3 ជម្រើស

ខ្ទង់រាយ មាន 2 ជម្រើស

តាមគោលការណ៍ផលគុណ $3\times4\times3\times2=72$ ចំនួន

• ចំពោះលេខ 5 ខ្ទង់ដែលធំជាង 2000 គឺ

ខ្ទង់ម៉ឺន មាន 4 ជម្រើស

ខ្ទង់ពាន់ មាន 4 ជម្រើស

ខ្ទង់រយ មាន 3 ជម្រើស

ខ្ទង់ដប់ មាន 2 ជម្រើស

ខ្ទង់រាយ មាន 1 ជម្រើស

តាមគោលការណ៍ផលគុណ $4\times4\times3\times2\times1=96$ ចំនួន

សរុបចំនួនដែលធំជាង $2000=72+96=168$ ចំនួន

ដូចនេះ ចំនួនដែលអាចបង្កើតបានមាន 168 ចំនួន ។

**VI. ក. កំណត់តម្លៃនៃ $a$ និង $b$**

គេមាន $f(x)=ae^x+b$ មានខ្សែកោង $(C)$

នាំឱ្យ $f'(x)=ae^x$

ដោយ $(C)$ កាត់តាមគល់ $O$ នាំឱ្យ $f(0)=0$

$ae^0+b=0$ ឬ $b=-a\ (1)$

ហើយ បន្ទាត់ប៉ះខ្សែកោង $(C)$ ត្រង់ចំណុច $O(0,0)$ នេះ

ជាបន្ទាត់ពុះទី១ $y=x$ នាំឱ្យ $f'(0)=1$

$ae^0=1\Rightarrow a=1$ ជំនួសក្នុង $(1)$ $b=-1$

ដូចនេះ តម្លៃកំណត់បាន $a=1\,,\ b=-1$ ។

**ខ. សិក្សាអថេរភាព និងគូសខ្សែកោង $(C)$**

ចំពោះ $a=1\,,\ b=-1$ គេបាន $f(x)=e^x-1$

ដែនកំណត់ $D=\mathbb{R}=(-\infty\,,+\infty)$

លីមីត $\lim\limits_{x\to-\infty}f(x)=\lim\limits_{x\to-\infty}\left(e^x-1\right)=0-1=-1$

$\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to+\infty}\left(e^x-1\right)=+\infty-1=+\infty$

អាស៊ីមតូត ដោយ $\lim\limits_{x\to-\infty}f(x)=-1$ នោះបន្ទាត់ $y=-1$

ជាអាស៊ីមតូតដេកនៃខ្សែកោង $(C)$ ខាង $-\infty$

ដេរីវេ $f'(x)=e^x$ នោះ $f'(x)=e^x>0\,,\ \forall x\in D$

នាំឱ្យ $f$ ជាអនុគមន៍កើនជានិច្ច និងគ្មានបរមាទេ

តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-\infty$ $\qquad$ $+\infty$ |
|---|---|
| $f'(x)$ | $+$ |
| $f(x)$ | $-1$ ↗ $+\infty$ |

➢សង់ខ្សែកោង $(C)$




**គ. គណនាផ្ទៃក្រឡានៃផ្នែកប្លង់**

តាមក្រាប គេបានផ្ទៃក្រឡាផ្នែកប្លង់ដូចខាងក្រោម ៖

$$S=-\int_{-1}^{0} f(x)\,dx+\int_{0}^{1} f(x)\,dx$$

$$=-\int_{-1}^{0}\left(e^{x}-1\right)dx+\int_{0}^{1}\left(e^{x}-1\right)dx$$

$$=-\left[e^{x}-x\right]_{-1}^{0}+\left[e^{x}-x\right]_{0}^{1}$$

$$=-\left[(1-0)-\left(\frac{1}{e}+1\right)\right]+\left[(e-1)-(1-0)\right]$$

$$=\frac{1}{e}+e-2$$

ដូចនេះ ផ្ទៃក្រឡាផ្នែកប្លង់ $S=\frac{1}{e}+e-2$ ឯកតាផ្ទៃ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ................................
លេខបន្ទប់ : ................................
លេខតុ : ................................
ហត្ថលេខា : ................................

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ
## សម័យប្រឡង : ១៧ តុលា ២០០៤

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. រកចំនួនពិត $x$ និង $y$ ដើម្បីឱ្យបំពេញលក្ខខណ្ឌ $(x+y)+(2x-y)i=2-5i$ ។

ខ. ចូរសរសេរ $\left(1+i\sqrt{3}\right)^{10}$ ជារាង $a+bi$ ។ **(១ពិន្ទុកន្លះ)**

**II.** ក. រកក្រឡាផ្ទៃ $S$ ដែលកំណត់ដោយខ្សែកោង $y=\sin x$ ចំពោះ $0\le x\le 3\pi$ ជាមួយអ័ក្សអាប់ស៊ីស ។

ខ. គណនាអាំងតេក្រាលមិនកំណត់ $I=\int x\cos x dx$ , $J=\int \frac{5}{5x-7}dx$ ។ **(១ពិន្ទុកន្លះ)**

**III.** ក្នុងតម្រុយអរតូណរម៉ាល់គេមានបីចំណុច $A(1,4,2)$ , $B(2,1,3)$ , $C(-2,2,-1)$ ។ គណនាក្រឡាផ្ទៃនៃ $\Delta ABC$ រួចបង្ហាញថា $\Delta ABC$ ជាត្រីកោណកែង ។ **(១ពិន្ទុកន្លះ)**

**IV.** គេសរសេរលេខ 1 , 2 , 3 , 4 , 5 , 6 , 7 , 8 , 9 រៀងគ្នាលើកាត់ 9 ។ គេចាប់យកកាត់នេះម្តងមួយៗពីក្នុងថង់ ចំនួន 3 កាត់ មកតម្រៀបតាមលំដាប់ដែលចាប់បាន ។

ក. រកប្រូបាបដើម្បីឱ្យកាត់ទាំងបីដែលចាប់បាន បង្កើតបានជាចំនួន 123 ។

ខ. រកប្រូបាបដើម្បីឱ្យកាត់ទាំងបីដែលចាប់បាន បង្កើតបានជាចំនួនចែកដាច់នឹង 125 ។ **(១ពិន្ទុកន្លះ)**

**V.** គណនាតម្លៃអតិបរមា អប្បបរមា និងរកកូអរដោនេចំណុចរបត់ របស់ខ្សែកោងតាងអនុគមន៍ $y=3xe^{-x^2}$ ។ សង់ខ្សែកោង $(C)$ តាងអនុគមន៍នេះ ។ **(២ពិន្ទុ)**

**VI.** គេឱ្យសមីការឌីផេរ៉ង់ស្យែល $(E): y'+2y=x^2$ ។

ក. កំណត់អនុគមន៍ពហុធា $g$ មានសមីការដឺក្រេទី២ ជាចម្លើយនៃសមីការ $(E)$ ។

ខ. បង្ហាញថាអនុគមន៍ $f$ ជាចម្លើយនៃសមីការ $(E)$ លុះត្រាតែ $f-g$ ជាចម្លើយនៃសមីការ $(E'): y'+2y=0$ ។

គ. ដោះស្រាយសមីការ $(E')$ ។ ទាញរកចម្លើយនៃសមីការ $(E)$ ។ **(២ពិន្ទុ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ២០០៤

**I.** **ក. រកចំនួនពិត $x$ និង $y$**

គេមាន $(x+y)+(2x-y)i=2-5i$

ផ្ទឹមបាន $\begin{cases} x+y=2 \\ 2x-y=-5 \end{cases}$

បូកអង្គ $3x=-3 \Rightarrow x=-1$

ដោយ $x+y=2 \Rightarrow y=2-x=2-(-1)=3$

ដូចនេះ រកបាន $\boxed{x=-1\,,\; y=3}$ ។

**ខ. សរសេរ $\left(1+i\sqrt{3}\right)^{10}$ ជារាង $a+bi$**

តាង $Z=1+i\sqrt{3}$ មាន $r=\sqrt{1+\sqrt{3}^2}=2$

នាំឱ្យ $Z=2\left(\frac{1}{2}+i\frac{\sqrt{3}}{2}\right)=2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)$

គេបាន $Z^{10}=\left[2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)\right]^{10}$

$=2^{10}\left(\cos\frac{10\pi}{3}+i\sin\frac{10\pi}{3}\right)$

$=1024\left[\cos\left(2\pi+\frac{4\pi}{3}\right)+i\sin\left(2\pi+\frac{4\pi}{3}\right)\right]$

$=1024\left(\cos\frac{4\pi}{3}+i\sin\frac{4\pi}{3}\right)$

$=1024\left(-\frac{1}{2}-\frac{\sqrt{3}}{2}i\right)$

$=-512-512\sqrt{3}\,i$

ដូចនេះ $\boxed{\left(1+i\sqrt{3}\right)^{10}=-512-512\sqrt{3}\,i}$ ។

**II.** **ក. រកក្រឡាផ្ទៃ $S$**

ដើម្បីដឹងថា ខ្សែកោងតាងអនុគមន៍ $y=\sin x$ នៅខាងលើ ឬ ខាងក្រោមអ័ក្សអាប់ស៊ីស គេត្រូវគូសខ្សែកោងតាងអនុគមន៍ $y=\sin x$ ចំពោះ $0\le x\le 3\pi$




តាមរូប $S=S_1-S_2+S_3$

$$S=\int_0^{\pi}\sin x\,dx-\int_{\pi}^{2\pi}\sin x\,dx+\int_{2\pi}^{3\pi}\sin x\,dx$$

$$=\left[-\cos x\right]_0^{\pi}-\left[-\cos x\right]_{\pi}^{2\pi}+\left[-\cos x\right]_{2\pi}^{3\pi}$$

$$=-\cos\pi+\cos 0+\cos 2\pi-\cos\pi-\cos 3\pi+\cos 2\pi$$

$$=-(-1)+1+1+1-(-1)+1=6$$

ដូចនេះ $\boxed{\text{ផ្ទៃគណនាបាន } S=6 \text{ ឯកតាផ្ទៃ}}$ ។

**ខ. គណនាអាំងតេក្រាលមិនកំណត់**

$\mathbf{I}=\int x\cos x\,dx$ (តាមរូបមន្តអាំងតេក្រាលដោយផ្នែក)

គេតាង $u=x$ នោះ $du=dx$

$dv=\cos x\,dx$ នោះ $v=\sin x$

តាមរូបមន្ត $\int u\,dv=uv-\int v\,du$

$\mathbf{I}=\int x\cos x\,dx=x\sin x-\int\sin x\,dx$

$=x\sin x-(-\cos x)+c$

$=x\sin x+\cos x+c$

ដូចនេះ $\boxed{\mathbf{I}=x\sin x+\cos x+c}$ ។

$$\mathbf{J}=\int\frac{5}{5x-7}dx=\int\frac{(5x-7)'}{5x-7}dx=\ln|5x-7|+c$$

ដូចនេះ $\boxed{\mathbf{J}=\ln|5x-7|+c}$ ដែល $c$ ជាចំនួនថេរ ។

**III.** ➢គណនាក្រឡាផ្ទៃនៃ $\Delta ABC$

តាមរូបមន្ត $S_{ABC}=\frac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AC}\right|$

គេមាន $A(1\,,4\,,2)\,,\,B(2\,,1\,,3)\,,\,C(-2\,,2\,,-1)$

នោះ $\overrightarrow{AB}=(1\,,-3\,,1)$ , $\overrightarrow{AC}=(-3\,,-2\,,-3)$

នាំឱ្យ $$\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & -3 & 1\\ -3 & -2 & -3\end{vmatrix}=11\vec{i}-0\vec{j}-11\vec{k}$$

$$S_{ABC}=\frac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AC}\right|$$

$$=\frac{1}{2}\sqrt{11^2+0^2+(-11)^2}=\frac{11\sqrt{2}}{2}$$

ដូចនេះ $\boxed{S_{ABC}=\frac{11\sqrt{2}}{2} \text{ ឯកតាផ្ទៃ}}$ ។

➢ បង្ហាញថា $\Delta ABC$ ជាត្រីកោណកែង

ដោយ $\overrightarrow{AB}\cdot\overrightarrow{AC}=xx'+yy'+zz'$

$$=(1)(-3)+(-3)(-2)+(1)(-3)=0$$

នាំឱ្យ $\overrightarrow{AB}\perp\overrightarrow{AC}$ នោះ $ABC$ ជាត្រីកោណកែងត្រង់ $A$

ដូចនេះ $\boxed{ABC \text{ ជាត្រីកោណកែងត្រង់ } A \text{ ត្រូវបានបង្ហាញ}}$ ។

**IV. ក. រកប្រូបាបដើម្បីឱ្យកាក់បង្កើតបានជាចំនួន 123**

ដោយ គេចាប់យកកាក់នេះម្តងមួយៗពីក្នុងថង់ចំនួនបី

នាំឱ្យ ចំនួនករណីអាចថយចុះម្តងមួយ

ហើយ លេខនីមួយៗមានមួយលេខដូចគ្នាជាករណីស្រប

គេបាន $P(123)=\frac{1}{9}\times\frac{1}{8}\times\frac{1}{7}=\frac{1}{504}$

ដូចនេះ $\boxed{P(123)=\frac{1}{504}}$ ។

**ខ. រកប្រូបាបបង្កើតបានជាចំនួនចែកដាច់នឹង 125**

ចំនួនដែលអាចចែកដាច់នឹង 125 មាន

125 , 250 , 375 , 500 , 625 , 750 , 875

តែចំនួនដែលមានលេខ 0 មិនអាចយកបាន នោះនៅសល់តែ

125 , 375 , 625 , 875 គេបានប្រូបាប ៖

$P(\text{ចែកដាច់}125)$

$=P(125)+P(375)+P(625)+P(875)$

$=\frac{1}{504}+\frac{1}{504}+\frac{1}{504}+\frac{1}{504}=\frac{4}{504}=\frac{1}{126}$

ដូចនេះ $\boxed{P(\text{ចែកដាច់}125)=\frac{1}{126}}$ ។

**V. ក. គណនាតម្លៃអតិបរមា អប្បបរមា**

គេមាន $y=3xe^{-x^2}$ មានដែនកំណត់ $D=\mathbb{R}$

ដេរីវេ $y'=(3x)'\cdot e^{-x^2}+3x\left(e^{-x^2}\right)'$

$=3e^{-x^2}-6x^2e^{-x^2}$

$=3e^{-x^2}\left(1-2x^2\right)$

ឱ្យ $y'=0 \Leftrightarrow 3e^{-x^2}\left(1-2x^2\right)=0$

ដោយ $\forall x\in\mathbb{R}$ , $3e^{-x^2}>0$ នោះ $y'$ សញ្ញាដូច $1-2x^2$

នាំឱ្យ $\left(1-2x^2\right)=0$ នោះ $x=\pm\frac{\sqrt{2}}{2}$

គេបាន $y\left(\pm\frac{\sqrt{2}}{2}\right)=3\left(\pm\frac{\sqrt{2}}{2}\right)e^{-\left(\pm\frac{\sqrt{2}}{2}\right)^2}=\pm\frac{3\sqrt{2}}{2}e^{-\frac{1}{2}}$

តារាងសញ្ញា

| $x$ | $-\infty$ | | $-\frac{\sqrt{2}}{2}$ | | $\frac{\sqrt{2}}{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'=3e^{-x^2}\left(1-2x^2\right)$ | | $-$ | 0 | $+$ | 0 | $-$ | |

•ត្រង់ $x=-\frac{\sqrt{2}}{2}$ , $y'=0$ និងប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $y$ មានតម្លៃអប្បបរមាមួយស្មើ $\boxed{-\frac{3\sqrt{2}}{2}e^{-\frac{1}{2}}}$ ។

•ត្រង់ $x=\frac{\sqrt{2}}{2}$ , $y'=0$ និងប្តូរសញ្ញាពី $(+)$ ទៅ $(-)$

បញ្ជាក់ថា $y$ មានតម្លៃអតិបរមាមួយស្មើ $\boxed{\frac{3\sqrt{2}}{2}e^{-\frac{1}{2}}}$ ។

**➢រកកូអរដោនេចំណុចរបត់ របស់ខ្សែកោង**

គេដឹងថា អាប់ស៊ីសនៃចំណុចរបត់ គឺជាឫសនៃសមីការ $y''=0$

គេមាន $y'=3e^{-x^2}\left(1-2x^2\right)$

$y''=-6xe^{-x^2}\left(1-2x^2\right)+(-4x)\left(3e^{-x^2}\right)$

$=\left(-2x\left(1-2x^2\right)-4x\right)\left(3e^{-x^2}\right)$

$=3e^{-x^2}\left(4x^3-6x\right)$

$=6xe^{-x^2}\left(2x^2-3\right)$

ឱ្យ $y''=0 \Leftrightarrow 6xe^{-x^2}\left(2x^2-3\right)=0$

ដោយ $\forall x\in\mathbb{R}$ , $6e^{-x^2}>0$ នោះ $x\left(2x^2-3\right)=0$

នាំឱ្យ $x=0$ , $x=\pm\frac{\sqrt{6}}{2}$

គេបាន $y(0)=3\cdot 0\cdot e^{0}=0$

$y\left(\pm\frac{\sqrt{6}}{2}\right)=3\cdot\left(\pm\frac{\sqrt{6}}{2}\right)\cdot e^{-\frac{3}{2}}=\pm\frac{3\sqrt{6}}{2}e^{-\frac{3}{2}}$

ដូចនេះ ចំណុចរបត់មានបីតាងដោយ $I$ មាន

$$\boxed{I_1(0,0)\ ,\ I_2\left(-\frac{\sqrt{6}}{2},-\frac{3\sqrt{6}}{2}e^{-\frac{3}{2}}\right)\ ,\ I_2\left(\frac{\sqrt{6}}{2},\frac{3\sqrt{6}}{2}e^{-\frac{3}{2}}\right)}$$

**ខ. សង់ខ្សែកោង $(C)$ តាងអនុគមន៍នេះ**

ដើម្បីឱ្យងាយស្រួលក្នុងការសង់ក្រាប គេត្រូវមានតារាងអថេរភាព

$\lim\limits_{x\to-\infty}3xe^{-x^2}$ តាង $t=-x$ , បើ $x\to-\infty$ នោះ $t\to+\infty$

$\lim\limits_{t\to+\infty}-3te^{-t^2}=\lim\limits_{t\to+\infty}\frac{-3t}{e^{t^2}}=0$

$\lim\limits_{x\to+\infty}3xe^{-x^2}=\lim\limits_{x\to+\infty}\frac{3x}{e^{x^2}}=0$

តារាងអថេរភាព

| $x$ | $-\infty$ | | $-\frac{\sqrt{2}}{2}$ | | $\frac{\sqrt{2}}{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $-$ | $0$ | $+$ | $0$ | $-$ | |
| $y$ | $0$ | $\searrow$ | $-\frac{3\sqrt{2}}{2}e^{-\frac{1}{2}}$ | $\nearrow$ | $\frac{3\sqrt{2}}{2}e^{-\frac{1}{2}}$ | $\searrow$ | $0$ |

គេសង់ក្រាបបានដូចខាងក្រោម




**VI. ក. កំណត់អនុគមន៍ពហុធា $g$ មានសមីការដឺក្រេទី២**

ពហុធាដឺក្រេទី២ នៃ $g$ មានរាង $g(x)=ax^2+bx+c$

គេបាន $g'(x)=2ax+b$

ដោយ $g$ ជាចម្លើយនៃសមីការ $(E): y'+2y=x^2$

គេបាន $g'+2g=x^2$

$(2ax+b)+2(ax^2+bx+c)=x^2$

$2ax^2+(2a+2b)x+(b+2c)=x^2+0x+0$

ផ្ទឹមបាន $\begin{cases}2a=1\\2a+2b=0\\b+2c=0\end{cases} \Rightarrow \begin{cases}a=1/2\\b=-1/2\\c=1/4\end{cases}$

ដូចនេះ កំណត់បាន $\boxed{g(x)=\frac{1}{2}x^2-\frac{1}{2}x+\frac{1}{4}}$ ។

**ខ. បង្ហាញថា $f$ ជាចម្លើយនៃ $(E)$ លុះត្រាតែ $f-g$ ជាចម្លើយនៃសមីការ $(E'): y'+2y=0$**

បើ $f-g$ ជាចម្លើយនៃ $(E'): y'+2y=0$

គេបាន $(f-g)'+2(f-g)=0$

$f'-g'+2f-2g=0$

$f'+2f=g'+2g$

$f'+2f=x^2$

ដូចនេះ $\boxed{f \text{ ជាចម្លើយនៃ } (E): y'+2y=x^2}$ ។

**គ.ដោះស្រាយសមីការ $(E')$**

គេមាន $(E'): y'+2y=0$

មានចម្លើយទូទៅរាង $y_c=Ae^{-ax}$ , $A$ ជាចំនួនថេរ

ដូចនេះ $(E')$ មានចម្លើយ $\boxed{y_c=Ae^{-2x}}$ ។

**➤ទាញរកចម្លើយនៃសមីការ $(E)$**

ចម្លើយទូទៅនៃសមីការ $(E): y'+2y=x^2$

មានរាង $f=$ ចម្លើយទូទៅអូម៉ូសែន $+$ ចម្លើយពិសេស

$f=y_c+g$

$f=Ae^{-2x}+\frac{1}{2}x^2-\frac{1}{2}x+\frac{1}{4}$

ដូចនេះ $(E)$ មានចម្លើយ $\boxed{f=Ae^{-2x}+\frac{1}{2}x^2-\frac{1}{2}x+\frac{1}{4}}$ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ

**សម័យប្រឡង : ១៥ តុលា ២០០៣**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. សរសេរសចំនួនកុំផ្លិចជាទម្រង់ត្រីកោណមាត្រ $1+i\sqrt{3}$ ។

ខ. ដោះស្រាយសមីការ $|z|-z=1+2i$ , ($z$ ជាចំនួនកុំផ្លិច) ។ **(១ពិន្ទុកន្លះ)**

**II.** ក. គណនាដេរីវេទី 5 នៃអនុគមន៍ $f(x)=x^5-2x^4+3x^3-2$ ។

ខ. កំណត់ដេរីវេទី $n$ នៃអនុគមន៍ $h(x)=x^n$ , $(n\in\mathbb{N}^*)$ ។ **(១ពិន្ទុកន្លះ)**

**III.** រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f(x)=\cos x$ ដែលខ្សែកោងតាង $F(x)$ កាត់តាមចំណុច $A\left(\frac{\pi}{2},0\right)$ ។ **(១ពិន្ទុកន្លះ)**

**IV.** រកចម្លើយនៃសមីការឌីផេរ៉ង់ស្យែល ផ្ទៀងផ្ទាត់លក្ខខណ្ឌដែលឱ្យ $y''-3y'+2y=0$ , $y(1)=1$ , $y'(1)=3$ ។ **(១ពិន្ទុ)**

**V.** ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេឱ្យប្លង់ពីរ $(\alpha)$ និង $(\beta)$ មានសមីការរៀងគ្នាគឺ : $3x-2y+2z-5=0$ និង $4x+5y-z+1=0$ ។

ក. ស្រាយបញ្ជាក់ថា ប្លង់ $(\alpha)$ អរតូកូណាល់ប្លង់ $(\beta)$ ។

ខ. សរសេរសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ ដែលជាប្រសព្វនៃប្លង់ $(\alpha)$ និង $(\beta)$ ។ **(២ពិន្ទុ)**

**VI.** គេឱ្យអនុគមន៍ $f(x)=\dfrac{ax^2+bx}{x^2-4x+3}$ ។

ក. រកតម្លៃនៃ $a$ និង $b$ ដោយដឹងថាអនុគមន៍មានតម្លៃអប្បបរមាស្មើ 4 ត្រង់ $x=2$ ។

ខ. សិក្សាទិសដៅអថេរភាព និងសង់ក្រាបនៃអនុគមន៍ $f$ ចំពោះតម្លៃនៃ $a$ និង $b$ ដែលបានរកឃើញ ។ **(២ពិន្ទុកន្លះ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ២០០៣

**I.** **ក. សរសេរសចំនួនកុំផ្លិចជាទម្រង់ត្រីកោណមាត្រ**

គេមាន $1+i\sqrt{3}$ (មាន $r=\sqrt{1^2+\sqrt{3^2}}=2$)

$=2\left(\frac{1}{2}+i\frac{\sqrt{3}}{2}\right)$

$=2\left(\cos\frac{\pi}{6}+i\sin\frac{\pi}{6}\right)$

ដូចនេះ $\boxed{1+i\sqrt{3}=2\left(\cos\frac{\pi}{6}+i\sin\frac{\pi}{6}\right)}$ ។

**ខ. ដោះស្រាយសមីការ**

គេមាន $|z|-z=1+2i$ និង $z$ ជាចំនួនកុំផ្លិច

គេតាង $z=a+bi$ នោះ $|z|=\sqrt{a^2+b^2}$

គេបាន $\sqrt{a^2+b^2}-(a+bi)=1+2i$

$\left(\sqrt{a^2+b^2}-a\right)+(-b)i=1+2i$

ផ្ទឹមបាន $\begin{cases}\sqrt{a^2+b^2}-a=1\\ b=-2\end{cases}$

$\begin{cases}\sqrt{a^2+4}-a=1 \ (1)\\ b=-2\end{cases}$

តាម $(1)$ $\sqrt{a^2+4}=a+1$ (លើកជាការេ)

$a^2+4=a^2+2a+1$

$a=\frac{3}{2}$

ដូចនេះ សមីការមានឫស $\boxed{z=\frac{3}{2}-2i}$ ។

**II.** **ក. គណនាដេរីវេទី 5 នៃអនុគមន៍ $f$**

គេមាន $f(x)=x^5-2x^4+3x^3-2$

$f(x)=x^5-2x^4+3x^3-2$

$f'(x)=5x^4-8x^3+9x^2$

$f''(x)=20x^3-24x^2+18x$

$f'''(x)=60x^2-48x+18$

$f^{(4)}(x)=120x-48$

$f^{(5)}(x)=120$

ដូចនេះ ដេរីវេទី 5 គឺ $\boxed{f^{(5)}(x)=120}$ ។

**ខ. កំណត់ដេរីវេទី $n$ នៃអនុគមន៍ $h(x)=x^n$**

$h'(x)=nx^{n-1}$

$h''(x)=n(n-1)x^{n-2}$

$h'''(x)=n(n-1)(n-2)x^{n-3}$

$h^{(4)}(x)=n(n-1)(n-2)(n-3)x^{n-4}$

.....................................................................

$h^{(n)}(x)=n(n-1)(n-2)(n-3)\times\ldots\times2\times1\times x^{n-n}=n!$

ដូចនេះ ដេរីវេទី $n$ គណនាបាន $\boxed{h^{(n)}(x)=n!}$ ។

**III.** **រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f(x)$**

គេបាន $F(x)=\int f(x)dx=\int\cos xdx=\sin x+c$

ដោយ ខ្សែកោងតាង $F(x)$ កាត់តាមចំណុច $A\left(\frac{\pi}{2},0\right)$

គេបាន $\sin\frac{\pi}{2}+c=0 \Rightarrow c=-1$

ដូចនេះ ព្រីមីទីវគណនាបានគឺ $\boxed{F(x)=\sin x-1}$ ។

**IV.** **រកចម្លើយនៃសមីការឌីផេរ៉ង់ស្យែល**

គេមាន $y''-3y'+2y=0$

មានសមីការសម្គាល់ $\lambda^2-3\lambda+2=0$

តាមករណីពិសេស $a+b+c=0$ នោះ $\lambda_1=1,\ \lambda_2=2$

ចម្លើយទូទៅរាង $y=Ae^{\lambda_1x}+Be^{\lambda_2x}$ , $A, B$ ថេរ

គេបាន $y=Ae^x+Be^{2x}$

នាំឱ្យ $y'=Ae^x+2Be^{2x}$

ដោយ $\begin{cases}y(1)=1\\ y'(1)=3\end{cases}\Leftrightarrow\begin{cases}Ae+Be^2=1 & (1)\\ Ae+2Be^2=3 & (2)\end{cases}$

យក $(2)-(1)$ គេបាន $Be^2=2 \Rightarrow B=2e^{-2}$

តាម $(1)$ $Ae+2e^{-2}\cdot e^2=1 \Rightarrow A=-e^{-1}$

គេបាន $y=Ae^x+Be^{2x}$

$=-e^{-1}\cdot e^x+2e^{-2}\cdot e^{2x}$

$=-e^{x-1}+2e^{2x-2}$

ដូចនេះ ចម្លើយពិសេសនៃសមីការឌីផេរ៉ង់ស្យែលគឺ

$\boxed{y=-e^{x-1}+2e^{2x-2}}$ ។

**V.** **ក. ស្រាយបញ្ជាក់ថា ប្លង់ $(\alpha)$ អរតូកូណាល់ប្លង់ $(\beta)$**

គេមាន $(\alpha): 3x-2y+2z-5=0$

មានវិចទ័រណរម៉ាល់ $\vec{n}_1=(3\,,-2\,,2)$

$(\beta): 4x+5y-z+1=0$

មានវិចទ័រណរម៉ាល់ $\vec{n}_2=(4\,,5\,,-1)$

បើ $(\alpha)\perp(\beta)$ លុះត្រាតែ $\vec{n}_1\perp\vec{n}_2$ នោះ $\vec{n}_1\cdot\vec{n}_2=0$

ដោយ $\vec{n}_1\cdot\vec{n}_2=xx'+yy'+zz'$

$=(3)(4)+(-2)(5)+(2)(-1)$

$=12-10-2=0$ ពិត

ដូចនេះ ប្លង់ $(\alpha)$ អរតូកូណាល់ប្លង់ $(\beta)$ ។

**ខ. សរសេរសមីការប៉ារ៉ាម៉ែតនៃបន្ទាត់**

តាង $\ell:\begin{cases}x=x_0+at\\y=y_0+bt\,,\,t\in\mathbb{R}\\z=z_0+ct\end{cases}$ ជាសមីការប៉ារ៉ាម៉ែតនៃបន្ទាត់

ប្រសព្វនៃប្លង់ $(\alpha)$ និង $(\beta)$

គេមាន $\begin{cases}(\alpha): 3x-2y+2z-5=0\\(\beta): 4x+5y-z+1=0\end{cases}$ (គេយក $z=t$)

$\begin{cases}3x-2y=5-2t & \times5\\4x+5y=t-1 & \times2\end{cases}$

$\begin{cases}15x-10y=25-10t\\8x+10y=2t-2\end{cases}$

$23x=23-8t \quad\Rightarrow\quad x=1-\dfrac{8}{23}t$

ដោយ $3x-2y=5-2t$

$3\left(1-\dfrac{8}{23}t\right)-2y=5-2t$

$3-\dfrac{24}{23}t-2y=5-2t$

$69-24t-46y=115-46t$

$46y=-46+22t$

$y=-1-\dfrac{11}{23}t$

ដូចនេះ សមីការប៉ារ៉ាម៉ែតគឺ $\begin{cases}x=1-\dfrac{8}{23}t\\y=-1-\dfrac{11}{23}t\quad,\ t\in\mathbb{R}\\z=t\end{cases}$ ។

**VI.** **ក. រកតម្លៃនៃ $a$ និង $b$**

ដោយ អនុគមន៍មានតម្លៃអប្បបរមាស្មើ 4 ត្រង់ $x=2$

គេបាន $\begin{cases}f'(2)=0\\f(2)=4\end{cases}$

គេមាន $f(x)=\dfrac{ax^2+bx}{x^2-4x+3}$ នោះគេបាន ៖

$$f'(x)=\frac{(2ax+b)(x^2-4x+3)-(2x-4)(ax^2+bx)}{(x^2-4x+3)^2}$$

$$f'(2)=\frac{(4a+b)(2^2-4\cdot2+3)-(4-4)(ax^2+bx)}{(2^2-4\cdot2+3)^2}$$

$$=\frac{(4a+b)(-1)}{(-1)^2}=-4a-b$$

នាំឱ្យ $\begin{cases}f'(2)=-4a-b=0\\f(2)=\dfrac{a\cdot2^2+b\cdot2}{2^2-4\cdot2+3}=4\end{cases}$

$\begin{cases}-4a-b=0\\-4a-2b=4\end{cases}\Rightarrow\begin{cases}b=-4\\a=1\end{cases}$

ដូចនេះ តម្លៃកំណត់បាន $a=1\,,\,b=-4$ ។

**ខ. សិក្សាទិសដៅអថេរភាព និងសង់ក្រាបនៃអនុគមន៍ $f$**

ចំពោះ $a=1\,,\,b=-4$

គេបាន $f(x)=\dfrac{x^2-4x}{x^2-4x+3}=\dfrac{x(x-4)}{(x-1)(x-3)}$

ដែនកំណត់ $x^2-4x+3\neq0$ នោះ $x\neq1\,,\,x\neq3$

ដូចនេះ $D=(-\infty\,,1)\cup(1\,,3)\cup(3\,,+\infty)$

លីមីតត្រង់ចុងដែនកំណត់

$$\lim_{x\to-\infty}f(x)=\lim_{x\to-\infty}\frac{x^2-4x}{x^2-4x+3}=1$$

$$\lim_{x\to+\infty}f(x)=\lim_{x\to+\infty}\frac{x^2-4x}{x^2-4x+3}=1$$

$$\lim_{x\to1^-}f(x)=\lim_{x\to1^-}\frac{x(x-4)}{(x-1)(x-3)}=\frac{1(-3)}{0^-(-2)}=-\infty$$

$$\lim_{x\to1^+}f(x)=\lim_{x\to1^+}\frac{x(x-4)}{(x-1)(x-3)}=\frac{1(-3)}{0^+(-2)}=+\infty$$

$$\lim_{x\to3^-}f(x)=\lim_{x\to3^-}\frac{x(x-4)}{(x-1)(x-3)}=\frac{3(-1)}{2(0^-)}=+\infty$$

$$\lim_{x\to3^+}f(x)=\lim_{x\to3^+}\frac{x(x-4)}{(x-1)(x-3)}=\frac{3(-1)}{2(0^+)}=-\infty$$

អាស៊ីមតូត

$\lim\limits_{x\to\pm\infty} f(x)=1$ នោះបន្ទាត់ $y=1$ ជាអាស៊ីមតូតដេក

$\lim\limits_{x\to 1} f(x)=\pm\infty$ នោះបន្ទាត់ $x=1$ ជាអាស៊ីមតូតឈរ

$\lim\limits_{x\to 3} f(x)=\pm\infty$ នោះបន្ទាត់ $x=3$ ជាអាស៊ីមតូតឈរ

ដេរីវេ

$$f'(x)=\frac{(2ax+b)(x^2-4x+3)-(2x-4)(ax^2+bx)}{(x^2-4x+3)^2}$$

$$=\frac{(2x-4)(x^2-4x+3)-(2x-4)(x^2-4x)}{(x^2-4x+3)^2}$$

$$=\frac{(2x-4)(x^2-4x+3-x^2+4x)}{(x^2-4x+3)^2}$$

$$=\frac{6(x-2)}{(x^2-4x+3)^2}$$

ឱ្យ $f'(x)=0 \Leftrightarrow \dfrac{6(x-2)}{(x^2-4x+3)^2}=0$

$\forall x\in D\,,\,(x^2-4x+3)^2>0$ ជានិច្ច

នោះ $f'(x)$ មានសញ្ញាដូច $x-2$ ដែលមានឫស $x=2$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | 1 | | 2 | | 3 | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | $-$ | ‖ | $-$ | 0 | $+$ | ‖ | $+$ |

ត្រង់ $x=2$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានអប្បបរមាមួយស្មើ $f(2)=-4$

តារាងអថេរភាព

| $x$ | $-\infty$ | 1 | | 2 | | 3 | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | $-$ | ‖ | $-$ | 0 | $+$ | ‖ | $+$ |
| $f(x)$ | 1 ↘ $-\infty$ | ‖ | $+\infty$ ↘ | $-4$ | ↗ $+\infty$ | ‖ | $-\infty$ ↗ 1 |

សង់ក្រាប និងអាស៊ីមតូត

តារាងតម្លៃលេខនៃក្រាប $C$

| $x$ | 0 | 2 | 4 |
|---|---|---|---|
| $y$ | 0 | -4 | 0 |



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឈ្មោះ : ..................................

លេខបន្ទប់ : ..................................

លេខតុ : ..................................

ហត្ថលេខា : ..................................

**ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ**

**សម័យប្រឡង : ១១ តុលា ២០០២**

**វិញ្ញាសា : គណិតវិទ្យា រយៈពេល : ១២០ នាទី ពិន្ទុ : ១០**

**I.** ក. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច $x^2-2x+5=0$ ។

ខ. គណនាឫសការេនៃចំនួនកុំផ្លិច $8-6i$ ។ **(១ពិន្ទុកន្លះ)**

**II.** ក. គណនាអាំងតេក្រាលមិនកំណត់ : $I=\int \cos^2 x dx$ , $J=\int x\sin x dx$ ។

ខ. រកព្រីមីទីវនៃអនុគមន៍ $f(x)=2x(x^3+1)$ ដោយដឹងថាព្រីមីទីវនៃអនុគមន៍នេះស្មើ $3$ កាលណា $x=-1$ ។ **(២ពិន្ទុ)**

**III.** គេឱ្យអនុគមន៍ $f(x)=\dfrac{x-1}{|x|+1}$ ។

ក. សិក្សាភាពជាប់នៃអនុគមន៍ $f$ ត្រង់ចំណុច $x=0$ ។

ខ. តើអនុគមន៍ $f$ មានដេរីវេត្រង់ចំណុច $x=0$ ឬទេ ? **(១ពិន្ទុ)**

**IV.** ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''+4y'+4y=0$ ។

ខ. គេឱ្យសមីការឌីផេរ៉ង់ស្យែល $(F): y''+4y'+4y=-4x$ កំណត់ចំនួនពិត $a$ និង $b$ ដែលអនុគមន៍ $\varphi: x\mapsto ax+b$ ជាចម្លើយនៃ $(F)$ ។ **(១ពិន្ទុកន្លះ)**

**V.** ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(2,2,2)$, $B(2,0,1)$ និង $C(4,1,-1)$ ។

ក. បង្ហាញថាត្រីកោណ $ABC$ ជាត្រីកោណកែងត្រង់ $B$ ។

ខ. រកសមីការប្លង់កាត់តាមចំណុចទាំងបីនេះ ។ **(១ពិន្ទុកន្លះ)**

**VI.** គេឱ្យអនុគមន៍ $f(x)=\dfrac{1}{(x-1)^2}+\dfrac{1}{(x+1)^2}$ ។

ក. សិក្សាទិសដៅអថេរភាព និងសង់ខ្សែកោង $(C)$ តាងក្រាបអនុគមន៍ $f$ ។

ខ. គណនាផ្ទៃក្រឡាផ្នែកប្លង់ខណ្ឌដោយខ្សែកោង $(C)$ បន្ទាត់ $x=2$ និង $x=5$ ។ **(២ពិន្ទុកន្លះ)**

# ចម្លើយ វិញ្ញាសាគណិតវិទ្យា
## ប្រឡងជ្រើសរើសគ្រូមធ្យម ឆ្នាំ២០០២

**I. ក. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច**

គេមាន $x^2-2x+5=0$

$$x^2-2x+1=-4$$
$$(x+1)^2=-4$$
$$x+1=\pm\sqrt{-4}$$
$$x=-1\pm 2i$$

ដូចនេះ សមីការមានឫស $\boxed{x=-1\pm 2i}$ ។

**ខ. គណនាឫសការេនៃចំនួនកុំផ្លិច $8-6i$**

គេតាង $z$ ជាឫសការេនៃចំនួន $8-6i$

គេបាន $z^2=8-6i$

នាំឱ្យ $z=\pm\sqrt{8-6i}$

$$=\pm\sqrt{9-6i-1}$$
$$=\pm\sqrt{9-6i+i^2}$$
$$=\pm\sqrt{(3-i)^2}=\pm(3-i)$$

ដូចនេះ $\boxed{\text{ឫសការេនៃ } 8-6i \text{ ស្មើនឹង } 3-i\ ,\ -3+i}$ ។

**II. ក. គណនាអាំងតេក្រាលមិនកំណត់**

$\mathbf{I}=\int\cos^2 x\,dx$ (តាម $2\cos^2 x=1+\cos 2x$)

$$=\int\frac{1+\cos 2x}{2}dx$$
$$=\frac{1}{2}\left(x+\frac{1}{2}\sin 2x\right)+c \quad , c \text{ ជាចំនួនថេរ}$$
$$=\frac{1}{2}x+\frac{1}{4}\sin 2x+c$$

ដូចនេះ $\boxed{I=\frac{1}{2}x+\frac{1}{4}\sin 2x+c}$ ។

$\mathbf{J}=\int x\sin x\,dx$ (ប្រើអាំងតេក្រាលដោយផ្នែក)

គេតាង $u=x$ នោះ $du=dx$

$dv=\sin x\,dx$ នោះ $v=-\cos x$

រូបមន្ត $\int u\,dv=uv-\int v\,du$

គេបាន $\int x\sin x\,dx=-x\cos x-\int -\cos x\,dx$

$$=-x\cos x+\sin x+c \quad , c \text{ ថេរ}$$

ដូចនេះ $\boxed{J=-x\cos x+\sin x+c}$ ។

**ខ. រកព្រីមីទីវនៃអនុគមន៍ $f(x)$**

គេមាន $f(x)=2x(x^3+1)$

គេតាង $F(x)$ ជាព្រីមីទីវនៃ $f(x)$

នាំឱ្យ $F(x)=\int f(x)dx=\int 2x(x^3+1)dx$

$$=2\int(x^4+x)dx$$
$$=2\left(\frac{x^5}{5}+\frac{x^2}{2}\right)+c$$

ដោយ $F(-1)=3$ នោះ $2\left(\frac{(-1)^5}{5}+\frac{(-1)^2}{2}\right)+c=3$

គេបាន $-\frac{2}{5}+1+c=3 \quad \Rightarrow c=\frac{12}{5}$

ដូចនេះ $\boxed{F(x)=\frac{2x^5}{5}+x^2+\frac{12}{5}}$ ជាព្រីមីទីវនៃ $f(x)$ ។

**III. ក. សិក្សាភាពជាប់នៃអនុគមន៍ $f$ ត្រង់ចំណុច $x=0$**

គេមាន $f(x)=\frac{x-1}{|x|+1}=\begin{cases}\frac{x-1}{x+1} & \text{បើ } x\ge 0\\ -1 & \text{បើ } x<0\end{cases}$

អនុគមន៍ $f$ ជាប់ត្រង់ $x=0$ លុះត្រាតែ វាផ្ទៀងផ្ទាត់

$$\lim_{x\to 0^-}f(x)=\lim_{x\to 0^+}f(x)=f(0)$$

ដោយ $\lim_{x\to 0^-}f(x)=\lim_{x\to 0^-}(-1)=-1$

$$\lim_{x\to 0^+}\frac{x-1}{x+1}=\frac{0-1}{0+1}=-1$$
$$f(0)=\frac{0-1}{0+1}=-1$$

នាំឱ្យ $\lim_{x\to 0^-}f(x)=\lim_{x\to 0^+}f(x)=f(0)=-1$

ដូចនេះ $\boxed{f \text{ ជាអនុគមន៍ជាប់ត្រង់ } x=0}$ ។

**ខ. តើអនុគមន៍ $f$ មានដេរីវេត្រង់ចំណុច $x=0$ ឬទេ ?**

បើ $f$ មានដេរីវេត្រង់ $x=0$ លុះត្រាតែ $f'_-(0)=f'_+(0)$

តាមនិយមន័យដេរីវេ $f'(x_0)=\lim_{x\to x_0}\frac{f(x)-f(x_0)}{x-x_0}$

គេបាន $f'_-(0)=\lim_{x\to 0^-}\frac{-1-(-1)}{x}=\frac{0}{0^-}=0$

និង $f'_+(0)=\lim_{x\to0^+}\dfrac{\frac{x-1}{x+1}-(-1)}{x}=\lim_{x\to0^+}\dfrac{\frac{x-1+x+1}{x+1}}{x}$

$=\lim_{x\to0^+}\dfrac{\frac{2x}{x+1}}{x}=\lim_{x\to0^+}\dfrac{2}{x+1}=\dfrac{2}{0+1}=2$

ដោយ $f'_-(0)\neq f'_+(0)$ នោះ $f$ គ្មានដេរីវេត្រង់ $x=0$ ទេ

ដូចនេះ $\boxed{f \text{ គ្មានដេរីវេត្រង់ } x=0 \text{ ទេ}}$ ។

**IV. ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E)$**

គេមាន $(E): y''+4y'+4y=0$

គេបាន សមីការសម្គាល់ $\lambda^2+4\lambda+4=0$ ឬ $(\lambda+2)^2=0$

នោះ សមីការសម្គាល់មានឫសឌុប $\lambda_0=-2$

សមីការ $(E)$ មានចម្លើយទូទៅរាង

$y_c=Ae^{\lambda_0 x}+Bxe^{\lambda_0 x}$ , $A,B$ ជាចំនួនថេរ

ដូចនេះ $\boxed{y_c=Ae^{-2x}+Bxe^{-2x}}$ ជាចម្លើយទូទៅនៃ $(E)$ ។

**ខ. កំណត់ចំនួនពិត $a$ និង $b$**

គេមាន $\varphi: x\mapsto ax+b$ អាចសរសេរ $\varphi(x)=ax+b$

នាំឱ្យ $\varphi'(x)=a$ និង $\varphi''(x)=0$

ដោយ $\varphi$ ជាចម្លើយនៃ $(F)$ នោះគេបាន ៖

$\varphi''+4\varphi'+4\varphi=-4x$

$0+4a+4(ax+b)=-4x$

$4ax+(4a+4b)=-4x$

$\varphi''+4\varphi'+4\varphi=-4x$

ផ្ទឹមបាន $\begin{cases}4a=-4\\4a+4b=0\end{cases}\Rightarrow\begin{cases}a=-1\\b=1\end{cases}$

ដូចនេះ កំណត់បាន $\boxed{a=-1\,,\,b=1}$ ។

**V. ក. បង្ហាញថាត្រីកោណ $ABC$ ជាត្រីកោណកែងត្រង់ $B$**

បើ $\Delta ABC$ កែងត្រង់ $B$ លុះត្រាតែ $\overrightarrow{BA}\perp\overrightarrow{BC}$

មានន័យថា គេបានផលគុណស្កាលែ $\overrightarrow{BA}\cdot\overrightarrow{BC}=0$

គេមាន $A(2,2,2)$ , $B(2,0,1)$ និង $C(4,1,-1)$

នោះ $\overrightarrow{BA}=(0,2,1)$ និង $\overrightarrow{BC}=(2,1,-2)$

គេបាន $\overrightarrow{BA}\cdot\overrightarrow{BC}=xx'+yy'+zz'$

$=(0)(2)+(2)(1)+(1)(-2)$

$=0+2-2=0$ ពិត

ដូចនេះ $\boxed{ABC \text{ ជាត្រីកោណកែងត្រង់ } B}$ ។

**ខ. រកសមីការប្លង់កាត់តាមចំណុចទាំងបីនេះ**

ប្លង់ $(ABC): a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយប្លង់ $(ABC)$ កាត់ $B(2,0,1)$

នាំឱ្យ $x_0=2$ , $y_0=0$ , $z_0=1$

ហើយ ប្លង់ $(ABC)$ មានវ៉ិចទ័រណរម៉ាល់ $\vec n=\overrightarrow{BA}\times\overrightarrow{BC}$

តែ $\overrightarrow{BA}\times\overrightarrow{BC}=\begin{vmatrix}\vec i&\vec j&\vec k\\0&2&1\\2&1&-2\end{vmatrix}=-5\vec i+2\vec j-4\vec k$

នាំឱ្យ $a=-5$ , $b=2$ , $c=-4$

គេបាន $(ABC): -5(x-2)+2(y-0)-4(z-1)=0$

$-5x+2y-4z+14=0$

ដូចនេះ $\boxed{(ABC): -5x+2y-4z+14=0}$ ។

**VI. ក. សិក្សាទិសដៅអថេរភាពនៃអនុគមន៍ $f$**

គេមាន $f(x)=\dfrac{1}{(x-1)^2}+\dfrac{1}{(x+1)^2}$

ដែនកំណត់ $\begin{cases}x-1\neq0\\x+1\neq0\end{cases}\Rightarrow\begin{cases}x\neq1\\x\neq-1\end{cases}$

នាំឱ្យ $D=(-\infty,-1)\cup(-1,1)\cup(1,+\infty)$

លីមីត $\lim_{x\to-\infty}f(x)=\lim_{x\to-\infty}\left[\dfrac{1}{(x-1)^2}+\dfrac{1}{(x+1)^2}\right]=0$

$\lim_{x\to-1^-}f(x)=\lim_{x\to-1^-}\left[\dfrac{1}{(x-1)^2}+\dfrac{1}{(x+1)^2}\right]=+\infty$

$\lim_{x\to-1^+}f(x)=\lim_{x\to-1^+}\left[\dfrac{1}{(x-1)^2}+\dfrac{1}{(x+1)^2}\right]=+\infty$

$\lim_{x\to1^-}f(x)=\lim_{x\to1^-}\left[\dfrac{1}{(x-1)^2}+\dfrac{1}{(x+1)^2}\right]=+\infty$

$\lim_{x\to1^+}f(x)=\lim_{x\to1^+}\left[\dfrac{1}{(x-1)^2}+\dfrac{1}{(x+1)^2}\right]=+\infty$

$\lim_{x\to+\infty}f(x)=\lim_{x\to+\infty}\left[\dfrac{1}{(x-1)^2}+\dfrac{1}{(x+1)^2}\right]=0$

អាស៊ីមតូត

ដោយ $\lim_{x\to\pm\infty}f(x)=0$ នោះ $y=0$ ជាអាស៊ីមតូតដេក

$\lim_{x\to\pm1}f(x)=+\infty$ នោះ $x=\pm$ ជាអាស៊ីមតូតឈរ

ដេរីវេ

$$f'(x)=-2\cdot\frac{(x-1)'}{(x-1)^3}-2\frac{(x+1)'}{(x+1)^3}$$
$$=-2\left[\frac{1}{(x-1)^3}+\frac{1}{(x+1)^3}\right]$$
$$=-2\left[\frac{(x+1)^3+(x-1)^3}{(x-1)^3(x+1)^3}\right]$$
$$=-2\left[\frac{x^3+3x^2+3x+1+x^3-3x^2+3x-1}{(x-1)^3(x+1)^3}\right]$$
$$=-2\left[\frac{2x^3+6x}{(x-1)^3(x+1)^3}\right]=\frac{-4x(x^2+3)}{(x-1)^3(x+1)^3}$$

ឱ្យ $f'(x)=0$ សមមូល $\frac{-4x(x^2+3)}{(x-1)^3(x+1)^3}=0$

ដោយ $\forall x\in D_f$ , $x^2+3>0$ , $x-1\neq 0$ , $x+1\neq 0$

នាំឱ្យ $-4x=0$ នោះ $x=0$

តារាងសញ្ញា $f(x)$

| $x$ | $-\infty$ | | $-1$ | | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $-4x$ | | $+$ | | $+$ | $0$ | $-$ | | $-$ | |
| $x^2+3$ | | $+$ | | $+$ | | $+$ | | $+$ | |
| $(x-1)^3$ | | $-$ | | $-$ | | $-$ | $0$ | $+$ | |
| $(x+1)^3$ | | $-$ | $0$ | $+$ | | $+$ | | $+$ | |
| $f'(x)=\frac{-4x(x^2+3)}{(x-1)^3(x+1)^3}$ | | $+$ | ‖ | $-$ | $0$ | $+$ | ‖ | $-$ | |

ត្រង់ $x=0$ , $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

បញ្ជាក់ថា $f$ មានអប្បបរមាស្មើ $f(0)=2$ ។

តារាងអថេរភាព

| $x$ | $-\infty$ | | $-1$ | | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $-$ | $0$ | $+$ | ‖ | $-$ | |
| $f(x)$ | $0$ | ↗ | $+\infty$ ‖ $+\infty$ | ↘ | $2$ | ↗ | $+\infty$ ‖ $+\infty$ | ↘ | $0$ |

សង់ខ្សែកោង $(C)$ តាងក្រាបអនុគមន៍ $f$

ម្យ៉ាងទៀត ដោយ $f(-x)=\frac{1}{(-x-1)^2}+\frac{1}{(-x+1)^2}$

$$=\frac{1}{(x+1)^2}+\frac{1}{(x-1)^2}=f(x)$$

នោះ $f$ ជាអនុគមន៍គូ ដែលមានអ័ក្ស $y'y$ ជាអ័ក្សឆ្លុះ




ខ. គណនាផ្ទៃក្រឡាផ្ទៃកប្លង់ខណ្ឌដោយខ្សែកោង $(C)$ បន្ទាត់ $x=2$ និង $x=5$

តាមក្រាប ផ្ទៃកប្លង់ដែលត្រូវគណនាផ្ទៃស្ថិតនៅលើអ័ក្ស $x'ox$

$$S=\int_2^5 f(x)\,dx=\int_2^5\left(\frac{1}{(x-1)^2}+\frac{1}{(x+1)^2}\right)dx$$
$$=\int_2^5\left(\frac{(x-1)'}{(x-1)^2}+\frac{(x+1)'}{(x+1)^2}\right)dx$$
$$=\left[-\frac{1}{x-1}-\frac{1}{x+1}\right]_2^5$$
$$=\left(-\frac{1}{5-1}-\frac{1}{5+1}\right)-\left(-\frac{1}{2-1}-\frac{1}{2+1}\right)$$
$$=-\frac{1}{4}-\frac{1}{6}+1+\frac{1}{3}=\frac{-3-2+12+4}{12}=\frac{11}{12}$$

ដូចនេះ ផ្ទៃក្រឡាផ្ទៃកប្លង់គឺ $S=\frac{11}{12}$ ឯកតាផ្ទៃ ។